# ចរិតខ្មែរ

## កើត រស់ ស្លាប់ ដើម្បីខ្មែរ

### ប៊ុណ្ណចន្ទម៉ុល

# ចរិតខ្មែរ

របស់

## ប៊ុណ្ណចន្ទ-ម៉ុល

ប្រធានពុទ្ធិកសមាគមមជ្ឈមណ្ឌលសាធារណរដ្ឋខ្មែរ
តំណាងរាស្ត្រ មណ្ឌលដូនពេញ
ប្រធានគណៈកម្មការវប្បធម៌ និងធម្មការ នៃសភាជាតិ

ផ្សាយចេញពី

គេហដ្ឋានលេខ ៧៥ វិថី ហែម ចៀវ

-ភ្នំពេញ-

បោះពុម្ពលើកទី ១

ព.ស. ២៥១៧ គ.ស. ១៩៧៣

-

រក្សាសិទ្ធិ

# អារម្ភកថា

នេះជាស្នាដៃទី ២ របស់ខ្ញុំបន្ទាប់ពីរឿង **គុកនយោបាយ**(*) ។ គំនិតនៃការនិពន្ធរឿងគុកនយោ-បាយ យ៉ាងណានោះ អស់លោកអ្នកសឹងបានជ្រាបសព្វគ្រប់ហើយ នៅក្នុងសៀវភៅនោះ។

«ចរិតខ្មែរ» ស្នាដៃថ្មីនេះ ក៏មានគំនិតពុំខុសឆ្ងាយប៉ុន្មាន អំពីគុកនយោបាយដែរ។ ខ្ញុំមានបំណងជំរុញ ចង់ឲ្យខេមរជន មានស្មារតីភ្ញាក់រលឹកភ្លឺថ្លាឲ្យកាន់តែច្បាស់ឡើង យល់បញ្ហាសង្គមជាតិ, យល់ផលប្រយោជន៍រួម, យល់ចំណោទកសាងជាតិ ទាន់ពេលវេលា។

«ចរិតខ្មែរ» ស្ដាប់ទៅដូចជាអ្នកនិពន្ធមានគំនិតរិះគន់ បន្ទុះបង្អាប់តែខ្មែរគ្នាឯង ប៉ុន្តែតាមការពិត គឺនិយាយឲ្យឃើញនូវទិដ្ឋិមានះ រើសអើងរបស់ខ្មែរមួយផ្នែក ដែលបណ្ដាលឲ្យកើតផលអាក្រក់ដល់សង្គមនិងបក្ស។ យើងត្រូវតែប្រយ័ត្ននិងអប់រំកុំឲ្យមានទិដ្ឋិរបៀបនោះទៀត។ ពោលមួយបែបទៀត គឺថា ផ្ដើះយកគន្លងអាក្រក់មកលាតត្រដាងដើម្បីឲ្យយើងស្អប់ខ្ពើម ហើយចៀសវាងពីគន្លងនោះ រួចប្រកាន់យកនូវគន្លងណាដែលល្អប្រសើរមកវិញ។ និយាយឲ្យខ្លីទៅគឺថា «ចរិតខ្មែរ» ជារូបមន្ត សម្រាប់បង្ហាញគុណវិបត្តិដែលបណ្ដាលឡើងដោយមនុស្សមួយជំពូក ដែលគ្មានលក្ខណៈចិត្តជាមនុស្សសោះ។ គឺពួកទាំងនោះឯងហើយ ដែលនាំឲ្យបក្សពួកនិងសង្គមជាតិអស់ថាមពល ហើយដល់នូវភាពហិនហោចខ្ទេចខ្ទាំនោះ។

ខ្ញុំគ្មានបំណងសោះ ក្នុងការរិះគន់ អស់លោកវីរជនបុព្វបុរសជាតិខ្មែរ ដែលលោកបានបំពេញហើយនូវពលិកម្មដើម្បីជាតិ ខ្លះដល់ទៅហ៊ានលះបង់ជីវិតនោះ។ ចំពោះអស់លោកទាំងនោះ ខ្ញុំបានគោរពនាមនិងសកម្មភាពរបស់លោកជាប្រក្រតី ហើយតែងយកជាបទរៀនសម្រាប់ជីវិតទៀតផង។

ខ្ញុំស៊ីរិះគន់ ចំពោះតែពួកមនុស្សណាដែលមានខ្លួនដូចជាសត្វ គ្មានឧត្ដមគតិ គ្មានវិចារណ-ញ្ញាណសោះនោះតែប៉ុណ្ណោះ, ហើយដោយគិត ការរិះគន់នោះឯងត្រូវតែសរសេរទុក ត្រូវតែនិយាយឲ្យដឹង ព្រោះខ្លួនខ្ញុំបានសង្កេតផ្ទាល់ ព្រមទាំងបានធ្វើសកម្មភាពជាមួយផង ដូចជាអំពើរបស់ពួកឥស្សរៈជាដើម ដែលធ្វើឲ្យខ្ញុំខូចចិត្តអស់មួយជីវិត បន្ទាប់ពីបានមើលឃើញសកម្មភាពព្រៃផ្សៃនៃពួកនោះក្នុងគ្រាដែលខ្ញុំរស់នៅជាមួយ។

ដូច្នេះហើយ ខ្ញុំបាទសូមអភ័យទោសជាមុនអំពីសំណាក់អស់មិត្តអ្នកអាន ក្រែងលោមានពាក្យត្រង់ណាពុំសមរម្យ ប៉ះពាល់ដល់រូបនាមអស់លោក សូមអស់លោកមេត្តាខន្តីអភ័យទោស ពីព្រោះការពិពណ៌នានៅក្នុងនេះ មានភាពទូទៅពេក។

បំណងរបស់ខ្ញុំ គឺចង់តែឲ្យមានគំនិតរិះគន់ស្ថាបនាកើតឡើង ផ្សាយជាសៀវភៅជាលាយលក្ខណ៍អក្សរដើម្បីជួយរំលឹកគ្នាឲ្យយល់ នូវមាគ៌ាល្អអាក្រក់គ្រប់យ៉ាង មិនចូលចិត្តនិយាយចែប៉ប្រែលបលាក់បួញមាត់បត់ជុំដៃ អ្នកនេះអ៊ីចេះ អ្នកនោះអ៊ីចុះសោះឡើយ។ ខ្ញុំបានគិតឃើញដល់ចាស់ៗបរម

---

(*) លោកអ្នកចង់អានរឿង **គុកនយោបាយ** នេះ សូមមេត្តាចូលទៅ amekhmer.free.fr រួចចុចត្រង់ Khmerbooks

*បុរាណរបស់យើង ដែលលោកមានគំនិតប្រដៅប្រដៅកូនចៅឲ្យបានស្គាល់សេចក្តីសុខចំរើនក្នុងជីវិតម្នាក់ៗ រហូតដល់សង្គមជាតិ ដោយលោកព្យាយាមចងក្រងពាក្យទូន្មានជាច្រើន កើតទៅជាបទសិក្សាអក្សរសាស្រ្តខ្មែរសព្វថ្ងៃនេះ ដូចជាច្បាប់កេរកាល, ពាក្យចាស់, ជាដើមៗ យើងចាស់សម័យនេះ យល់ហេតុផលយ៉ាងណាក្នុងដំណើរជីវិត ដែលយើងបានលុយឆ្លងកាត់មកហើយ គួរតែនាំដំណើរនោះមកដំ-ណាលផង ឲ្យក្មេងស្រករក្រោយគ្នាដឹង គ្នាប្រុងស្មារតីចៀសវាងអំពើអាក្រក់ជាមុន កុំឲ្យតាមគន្លងចាស់ៗ នៅទីបញ្ចប់ ខ្ញុំសូមប្រកាសប្តេជ្ញាជាឧឡារិកថាៈ គំនិតខ្ញុំ សុំកើតជាខ្មែរ រស់ជាខ្មែរ ស្លាប់ជាខ្មែរ ខ្ញុំសូមបូជាជីវិតចំពោះតែបុគ្គលណាដែលស្មោះនឹងជាតិខ្មែរ, ខ្ញុំសុំប្តេជ្ញាចិត្តថាពុំព្រមបំរើបុគ្គលណាដែលគ្មានចិត្តស្មោះត្រង់នឹងជាតិ, ប្រកាន់អាត្មានិយម បក្សពួកនិយម ផ្តាច់ការនិយម និងមានគំនិតញុះញង់បំបែកបំបាក់សាមគ្គីជាតិ ដើម្បីពួកក្រុមត្រួតត្រានោះសោះឡើយៗ*

*ប្រការមួយទៀត តាមជំនឿព្រះពុទ្ធសាសនា ឋានសួគ៌ ឋានព្រះនិព្វាន មានមែនសំរាប់បុគ្គលអ្នកសាងកុសលបារមីអស់អន្លែងកប្បកល្ប មានព្រះពុទ្ធជាដើម ជាទីដែលគួរជ្រះថ្លា ប្រាថ្នាទៅកើតណាស់ ប៉ុន្តែខ្ញុំពុំមានសំណូមសមប្រាថ្នាថានឹងទៅកើតទីនោះសោះ ទោះបីឧបមាថា ខ្ញុំមានកុសលថានឹងបានទៅកើតទីនោះដូចប្រាថ្នាក្តីៗ ដរាបណា ប្រទេសខ្មែរនៅតែមានលំបាកវេទនាហែលក្នុងថ្លុកឈាមដែលកើតមកអំពីការកាប់ចាក់គ្នាដូចសព្វថ្ងៃ ខ្ញុំស្លាប់ទៅ សូមកុសលផលបុណ្យបញ្ជូនខ្ញុំឲ្យមកកើតជាខ្មែរនេះទៀតលើទឹកដីនេះ អស់កប្បកល្បអន្លែងជាតិ កុំឲ្យខ្ញុំឃ្លាតខ្ចាត់ព្រាត់វង្វេងទៅកើតទីណាផ្សេងឡើយ ដើម្បីជួយជាតិខ្មែរ ជួយប្រទេសខ្មែរ ជាលំដាប់ជាតិរៀងរាបដរាបទៅ! នេះជាសច្ចវាទរបស់ខ្ញុំ!*

- *សូមឲ្យប្រទេសខ្មែរ ស្ថិតនៅតែជារបស់ខ្មែរជានិច្ច!*
- *សូមពិភពលោក មានយុត្តិធម៌ចំពោះមនុស្សជាតិទូទៅ!*
- *សូមប្រជាពលលោក បានចំរើនក្នុងផ្លូវសន្តិភាព!*

*ធ្វើនៅភ្នំពេញថ្ងៃទី ២៨ មេសា ២៥១៧/១៩៧៣*

**ប៊ុណ្ណចន្ទ-ម៉ុល**

# សេចក្ដីផ្ដើម

*យើងទាំងអស់គ្នា ដែលមានឈ្មោះថាជាអ្នកតស៊ូ ហើយដែលទើបតែរួចចេញមកអំពីគុកប្រវាក់ ក៏បានមកនៅជួបជុំគ្នានៅទីរួមភ្នំពេញនេះៗ ជប៉ុនដែលជាអ្នកឧបត្ថម្ភនូវនយោបាយ យើងក៏នៅតែជួយផ្ដល់នូវគំនិតដល់ក្រុមបដិវត្តន៍យើងដដែលៗ ជប៉ុនពុំទាន់ចាញ់កម្លាំងក្រុមសម្ពន្ធមិត្តនៅឡើយទេ ថ្វីត្បិតតែក្រុងភ្នំពេញត្រូវរងគ្រាប់បែករបស់កងទ័ពសម្ពន្ធមិត្ត (កាលពីថ្ងៃទី ៥ កុម្ភៈ ១៩៤៥) ក៏ដោយៗ មិនតែប៉ុណ្ណោះ នៅថ្ងៃទី ៩ មីនា ១៩៤៥ ជប៉ុន ថែមទាំងបានឡោមព័ទ្ធចាប់បារាំងនៅភ្នំពេញទាំងអស់ទៀតផងៗ*

*លោក សឺង ង៉ុកថាញ់ ដែលរត់ទៅកាន់ប្រទេសជប៉ុន តាំងពីបារាំងចាប់លោកអាចារ្យ ហែម ចៀវ នោះ ក៏បានត្រូវជប៉ុនជួយឲ្យមកវិញ នៅខែឧសភា១៩៤៥ៗ ពីរាត្រីទី ៨ ទៅទី ៩ ខែសីហា ១៩៤៥ យុវជនខ្មែរ និងទាហាន ក៏ធ្វើបដិវត្តន៍រំលំរដ្ឋាភិបាលលោក អ៊ឹង អ៊ី ដែលនៅក្រោមអាណាព្យាបាលបារាំង រួចនៅថ្ងៃទី ១៤ ខែសីហា ឆ្នាំដដែល លោក សឺង ង៉ុកថាញ់ ក៏ត្រូវបានចាត់តាំងជានាយករដ្ឋាភិបាលឡើងៗ*

*ក្នុងស្ថានភាពនេះ យើងរាល់គ្នាជាអ្នកនយោបាយ ហើយដែលមានជប៉ុនជួយឧបត្ថម្ភនោះ គួរណាស់តែបានសប្បាយភ្លឺតភ្លើនក្នុងចិត្ត ប៉ុន្តែផ្ទុយទៅវិញ យើងពុំបានទឹកគិតដូច្នោះឡើយ យើងរាល់គ្នានឹកឃើញថា កម្លាំងពួកសម្ពន្ធមិត្តប្រហែលជានឹងបន្ថែមឡើង ដើម្បីផ្ដួលរំលំនឹងយើងនេះទៅវិញបាននៅថ្ងៃណាមួយ ព្រោះគេកំពុងរៀបចំសំបើមណាស់ ដើម្បីបន្ទប់អានុភាពជប៉ុន ឬថាគេត្រូវការត្រួតត្រាឥណ្ឌូចិនដាច់មុខៗ*

*កាលបើគិតឃើញដូច្នោះ យើងរាល់គ្នាក៏គិតរកផ្លូវជាស្រេចថា នឹងគេចឲ្យផុតពីកណ្ដាប់ដៃបារាំង បើបារាំងឈ្នះជប៉ុនវិញនោះ យើងត្រូវចេញឲ្យផុតទៅក្រៅ ដើម្បីរិះរកមធ្យោបាយរំដោះស្រុកតទៅទៀតៗ*

*ថ្ងៃមួយជួបជុំគ្នា ក៏ពិគ្រោះព្រមព្រៀងគ្នាថា បើបារាំងឈ្នះជប៉ុន យើងត្រូវចេញទៅស្រុកសៀម និងស្រុកយួនៗ*

*ដូចដែលយើងបានផ្គងព្រួយនោះមែន ថ្ងៃទី ១៦ តុលា ១៩៤៥ ពួកបារាំងក៏លួងចាប់លោកនាយក សឺង ង៉ុកថាញ់ ទៅ ហើយព្រមទាំងរកចាប់ជនជាដៃជើងទៀត (មានពួកយើងអ្នកតស៊ូនេះឯង)ៗ*

*ដូចដែលបានព្រាងទុក ពួកអ្នកតស៊ូបែកបំបែកគ្នាចេញជាពីរក្រុមៗ មួយក្រុមមានលោក ប៉ាច ឈឺន, លោក ចៅ សែនកុសលឈុំ (កាលណោះជាចៅហ្វាយខេត្តកំពង់ចាម), លោកស្រី សឺង ង៉ុកថាញ់ នាមដើម ឡាំ ធីអ៊ុក និងជនជាច្រើនទៀត បានទៅនៅបាសាក់ (កម្ពុជាក្រោម)ៗ ឯចំណែកខ្ញុំ*

*ប៊ុណ្ណចន្ទ-ម៉ុល ខ្ញុំមានមាម្នាក់ឈ្មោះ ប៉ុក គុណ ហៅ ត្រឡាច នៅខេត្តបាត់ដំបង ដែលកាលណោះសៀមត្រួតត្រាជារបស់សៀមៗ ព្រំប្រទល់ខ្មែរ-សៀមកាលណោះនៅត្រង់ស្វាយដូនកែវៗ*

*តទៅមុខ អស់លោកអ្នកនឹងបានជ្រាបអំពីដំណើររបស់ខ្ញុំផ្ទាល់ទៅកាន់ខេត្តបាត់ដំបង និងអំពីកំណើតខ្មែរឥស្សរៈព្រមទាំងសកម្មភាពអ្វីខ្លះនៃក្រុមនោះៗ សកម្មភាពពួកនោះ ឃើញថាផ្ទុយពីគោលបំណងរបស់យើងអ្នកនយោបាយរំដោះជាតិ, ផ្ទុយពីគំនិតរបស់យើងដែលជាអ្នកបង្កើតពួកនោះៗ សកម្មភាពពួកនោះ គឺជាគុណវិបត្តិម្យ៉ាងដែលផ្តល់ឲ្យខ្ញុំកំហាកចិត្តយ៉ាងធំជរាបសព្វថ្ងៃៗ*

*ហេតុនោះហើយ ទើបខ្ញុំនិយាយរិះគន់អ្វីៗ ខ្ញុំចូលចិត្តថា «នេះហើយចរិតខ្មែរ» រាល់ដងដូច្នេះឯងៗ*

*វ័យចាស់ប៉ុណ្ណេះហើយ ខ្ញុំសូមចងដៃអនុជនជំនាន់ក្រោយនូវស្នាដៃនេះ ដើម្បីជាបទពិចារណារិះរកផលប្រយោជន៍ជូនបងប្អូនរួមជាតិក្នុងសាធារណរដ្ឋខ្មែរតទៅទៀតផង ដោយចៀសវាងនូវអំពើឃោរឃៅ កាប់សម្លាប់គ្នាឯងដោយព្រៃផ្សៃនោះតទៅទៀតៗ*

សូមឲ្យមានយុត្តិធម៌ក្នុងសង្គម ដើម្បីវឌ្ឍនភាពនិងសុភមង្គលរបស់សាធារណរដ្ឋខ្មែរ។

*ភ្នំពេញថ្ងៃទី ២០ កុម្ភៈ ១៩៧៣*

**ប៊ុណ្ណចន្ទ-ម៉ុល**

# ១

# ការភៀសខ្លួនរបស់ខ្ញុំ

នៅថ្ងៃទី ១៦ តុលា ១៩៤៥ វេលាម៉ោង ១១ កន្ទះថ្ងៃ ពួកសម្ពន្ធមិត្តបានមកប្រឡោមចាប់លោកនាយក សឺង ង៉ុកថាញ់ នៅវិមានរដ្ឋាភិបាលយកទៅ។ បានដំណឹងនេះភ្លាម ខ្ញុំជាអ្នកមានខ្លួនស្រាប់ក៏ត្រូវតែភៀសចន្លៀសខ្លួនចេញទៅក្រៅដូចបានព្រាងទុក។ ខ្ញុំជំនុំនឹងគ្រួសារឃើញថាត្រូវភៀសទៅនៅនឹងមាត្រឡាចរបស់ខ្ញុំឯបាត់ដំបង ដែលកាលណោះ ខេត្តបាត់ដំបងសៀមនៅត្រួតត្រាជារបស់សៀម។ ឯការដែលធ្វើដំណើរ គឺត្រូវពង្វាងផ្លូវកុំឲ្យគេតាមចាប់បាន។ គឺថាមិនត្រូវចេញទៅតាមផ្លូវខាងជើងភ្នំពេញត្រង់ទៅតែម្តងទេ ព្រោះពួកប៉ូលីសនិងគិញបារាំងត្រៀបត្រានៅផ្លូវនេះ ចាំចាប់ពួកអ្នកភៀសខ្លួនចេញទៅសៀម។ ខ្ញុំត្រូវបង្វែងផ្លូវ ទៅខាងទន្លេធំកំពង់ចាម រួចសឹមបកមកព្រែកក្ដាមវិញ វាងពួកគិញនៅម្តុំគីឡូលេខ ៦ ភ្នំពេញផង និងបំបាត់ដានផង។ ម្យ៉ាងទៀត ការចេញដំណើរតាមដងទន្លេធំនេះ ខ្ញុំក៏នឹងអាចបានជួបនឹងមិត្តកក្តិអ្នកបដិវត្តន៍ច្រើនគ្នាទៀត នៅតាមដងទន្លេធំ ខ្ញុំនឹងបានជម្រាបមិត្តទាំងនោះឲ្យជ្រាបពីព្រឹត្តិការណ៍ថ្មីៗ រួចនឹងលាគេទៅក្រៅស្រុកផង។ គ្រួសារខ្ញុំបានព្រមព្រៀងតាមនេះ ដោយណាត់គ្នាទៀតថា ខ្ញុំទៅដល់ទន្លេបិទឲ្យសំណាក់នៅនឹងផ្ទះបងប្រុសខ្ញុំឈ្មោះ ប៉ុណ្ណចន្ទ-ថាត់ ធ្វើការនៅហាងសាំងស្ពានទន្លេបិទ ឯគេនៅឯភ្នំពេញឯណោះ នឹងយកឡានមួយចេញទៅកំពង់ចាម ចាំទទួលខ្ញុំដែលមកពីទន្លេបិទ នាំយកមកព្រែកក្ដាមវិញ រួចសឹមបន្តដំណើរទៅបាត់ដំបង។

បានណាត់គ្នាស្រេចបាច់ដូច្នោះហើយ ល្ងាចនោះខ្ញុំយកមាសពីរដុំជារបស់ផ្ទាល់ខ្លួន មូរនឹងចង្កេះខោទុកសំរាប់ដូរចាយនៅស្រុកគេពេលណាគ្មានប្រាក់ រួចយកកាំភ្លើងខ្លីតូចមួយសៀតចង្កេះ រួចឡើង

កង់ប្រណាំង (course)[១] របស់ខ្ញុំប្រញាប់ប្រញាល់ទៅកាន់ចំការច្បារអំពៅ ខ្ញុំពួននៅទីនោះទៅ។ សូមជំរាបថា ម្ដាយឪពុកខ្ញុំមានចំការជំមួយនៅច្បារអំពៅនេះ។ ខ្ញុំសំរាកនៅទីនោះមួយយប់ ព្រឹកឡើងម្ចីម្នាជាក់កង់តាមផ្លូវភ្នំពេញព្រៃនគរ កាត់វាលស្បូវព្រែកឯងទៅដល់ស្រុកគគីរ ទើបចុះពីផ្លូវជាតិ កាត់ទៅជើង រួចឆ្លងទូកទៅឡើងត្រើយល្វាឯម។ មកដល់ត្រើយនេះ ខ្ញុំឡើងកង់ធ្វើដំណើរតាមមាត់ទន្លេ ឆ្ពោះទៅកាន់ព្រែកហ្លួង។ ដល់ព្រែកហ្លួងម៉ោង ១៣ ជាង ខ្ញុំក៏ឈប់សំរាករកអាហារទទួលទាន។ បន្ទាប់មកខ្ញុំក៏ទៅរកផ្ទះមិត្តម្នាក់ឈ្មោះខាន់ មិត្តខាន់ប្រញាប់ប្រញាល់សួរខ្ញុំអំពីព្រឹត្តិការណ៍នៅភ្នំពេញ ដែលថាបារាំងចាប់លោក សឺង-ង៉ុកថាញ់។ គិតទៅមិត្តខាន់ ជាមនុស្សតាមដានរឿងស្រុកទេសខ្លាំងណាស់ដែរ គួរសរសើរ។ ខ្ញុំឆ្លើយប្រាប់ហូរហែទៅវិញថាៈ ពិតមែនហើយ, លោក សឺង-ង៉ុកថាញ់ ត្រូវបារាំងចាប់ហើយ, ហើយអ្នកឯទៀតជាបក្សពួកក៏ត្រូវបារាំងរកចាប់ដែរ, ឯខ្ញុំនេះក៏ត្រូវកៀសខ្លួន ដើម្បីរកផ្លូវតស៊ូទៅមុខទៀត ខ្ញុំត្រូវទៅកាន់បាត់ដំបង តែត្រូវបង្វែងមកតាមផ្លូវនេះ រួចទៅសំណាក់នៅនឹងទន្លេបិទ ទើបបកមកព្រែកក្ដាមវិញ។ មិត្តខាន់យល់រឿងគាត់ងក់ក្បាល រួចឃាត់ខ្ញុំថាៈ ឥឡូវប្អូនឯងទៅតាមកប៉ាល់វិញទៅស្រួលជាង ព្រោះជិះកង់តាមផ្លូវគោកពិបាកណាស់, យប់នេះសំរាកនៅផ្ទះខ្ញុំហើយ, ព្រឹកស្អែកម៉ោង ៦ កន្លះសឹមចុះកប៉ាល់! ខ្ញុំក៏យល់ព្រម។ យប់នោះខ្ញុំសំណាក់នៅនឹងផ្ទះមិត្តខាន់ដោយសុខស្រួល។ ព្រលឹមឡើងមិត្តខាន់ជូនខ្ញុំមកកាន់ផែកប៉ាល់ រង់ចាំកប៉ាល់ឡើង[២]។ កប៉ាល់មកដល់ មិត្តខាន់បានឲ្យពរខ្ញុំយ៉ាងច្រើនសុំឲ្យទៅនៅស្រុកគេបានសុខសប្បាយ ដើម្បីធ្វើការរំដោះប្រទេសជាតិតទៅទៀត។ ខ្ញុំលើកដៃទទួលពរមិត្តខាន់ដោយស្មោះ រួចក៏លើកកង់ដាក់លើស្មា លាមិត្តខាន់ចុះកប៉ាល់ទាំងអាល័យ។ កប៉ាល់ចេញពីផែ ឃ្លាតឆ្ងាយមកទើបខ្ញុំអង្គុយចុះ តែខ្ញុំនៅតែសម្លឹងមិត្តខាន់ទាល់តែឆ្ងាយមើលលែងឃើញ។

កប៉ាល់ដុតឧសម៉ែត្រ រលាក់ខ្លួនតិចៗ ដូចគេអង្រួន មើលទៅក្រោយគែមរលកខ្វាយរត់ទៅក្រោយ, យូរៗ ម្ដង វាឲ្យស៊ីផ្លេចូលផែព្រះប្រសប់ រកាកោង ព្រែកពោធិ៍, ពាមជីកង ។ល។ រួចម៉ោងប្រមាណជា ១៣ ទើបបានមកដល់ទន្លេបិទ។ ខ្ញុំលើកកង់ចុះពីកប៉ាល់ រួចរូតរះប្រញាប់ឡើងគោក ខ្ញុំជិះកង់ទៅរកផ្ទះបង ប៊ុណ្ណចន្ទ-ថាត់ របស់ខ្ញុំ។ ខ្ញុំនិយាយរាយរាប់ប្រាប់បងខ្ញុំតាមដំណើររឿង។ បង ប៊ុណ្ណចន្ទ-ថាត់ ក៏ទទួលឲ្យខ្ញុំស្នាក់នៅដោយប្រុងប្រយ័ត្ន។ ខ្ញុំស្នាក់នៅនឹងផ្ទះបងខ្ញុំបានមួយយប់ ព្រឹកឡើង ក៏ត្រូវបងនេះជូនដំណើរឆ្លងមកក្រុងកំពង់ចាម ដើម្បីជួបនឹងបងប្អូនដែលណាត់គ្នាពីភ្នំពេញ។ ពេលមកដល់ក្រុងកំពង់ចាម ខ្ញុំក៏បានជួបនឹងបងប្អូនព្រមទាំងក្មួយៗ ខ្ញុំជាច្រើននាក់ដែលមកពីភ្នំពេញ គឺប្អូន ប៉ុងណា (ស្រី), ប្អូន លូ (ប្រុស) ក្មួយ ជួន-ជឿន, ជួន-មុំម, ជួន-ប្រសិទ្ធ ដែលយករថយន្តស៊ីត្រូអេន ១៥ សេះរបស់បងស្រីខ្ញុំនៅភ្នំពេញមកទទួលខ្ញុំតាមណាត់។ ខ្ញុំយកកង់ទៅទុកនឹងក្តិតឡាន។ ខ្ញុំនិងអ្នកទាំងអស់គ្នាលាបង ប៊ុណ្ណចន្ទ-ថាត់ ឡើងឡានបត់ក្បាលមកទិសខាងលិចវិញ។ នៅក្នុងឡាន ទាំងអស់គ្នានិយាយប្រាប់ខ្ញុំថាៈ ល្ងាចមិញពួកក្រសួងសម្ងាត់ ៣-៤ នាក់ បានទៅរកខ្ញុំនៅឯផ្ទះមុខវត្ត ឧណ្ណា

---

(១)- កង់ដែលខ្ញុំប្រើប្រាស់ក្នុងពេលនោះ ខ្ញុំរក្សាទុករហូតសព្វថ្ងៃជាអនុស្សាវរីយ៍ឲ្យកូនខ្ញុំបានឃើញកេរ្តិ៍ដំណែលឪពុកតស៊ូក្នុងសម័យនោះ។

(២)- ពាក្យប្រើសំរាប់ដំណើរតាមទន្លេមេគង្គ កប៉ាល់ឡើង គឺកប៉ាល់ដែលបើកឡើងពីភ្នំពេញទៅកំពង់ចាម ក្រចេះ, កប៉ាល់ចុះ គឺកប៉ាល់ដែលបើកចុះពីនោះទៅភ្នំពេញវិញ។ និយាយតាមដំណើរទឹកហូរ ដែលហូរពីក្រចេះទៅកំពង់ចាមចុះទៅភ្នំពេញ។

លោម តែបងប្អូនខ្ញុំឆ្លើយថា មិនបានឃើញខ្ញុំមកផ្ទះទេ នោះពួកនោះក៏ត្រឡប់ទៅវិញទៅ។ ខ្ញុំនឹកឃើញថាមែន ពួកបារាំងតាមរូបខ្ញុំមែន បើមិនបានគេចមកទេ ប្រហែលជាខ្ញុំមានគ្រោះធំ ជាប់ទោសទៅកោះត្រឡាចឬយ៉ាងណា។ ទៀតពុំខាន។ ខ្ញុំនឹកឃើញទៀត ពាក្យអ្នកស្នេហ៍ស្និទ្ធបារាំងដែលថា ឲ្យតែបារាំងឈ្នះជប៉ុននឹងអាលប្រាប់បារាំងឲ្យចាប់ពួកខ្ញុំ ពួកអាចារ្យ ហែម ចៀវ ដាក់គុកជាថ្មីទៀត។ ពាក្យនេះគេបានពោលពេលដែលខ្ញុំរត់រួចពីកោះត្រឡាចមកនៅភ្នំពេញវិញនោះ។ ឱ! ខ្មែរអើយ បើរវល់តែយកគាប់គួរនឹងជាតិគេ ហើយសុខចិត្តសម្លាប់ខ្មែរគ្នាឯងយ៉ាងហ្នឹង តើនឹងឲ្យស្រុកទេសដើរទៅមុខម៉េចនឹងរួច?

នៅពេលដែលរថយន្តជិតនឹងដល់ព្រែកក្ដាម ខ្ញុំឲ្យរថយន្តឈប់ដាក់ខ្ញុំចុះ ឲ្យអ្នកទាំងអស់គ្នាឆ្លងសាឡាងទៅចុះ ហើយឲ្យបើកទៅចាំនៅភូមិមួយជិតកំពង់ហ្លួង ខ្ញុំនឹងឆ្លងទៅជួបត្រង់ទីនោះ។ យើងត្រូវវាងត្រង់កំពង់ចម្លងព្រែកក្ដាមនេះ ត្បិតខ្លាចមានគិញប៉ូលីសឆែកឆេរទៀត។ ណាត់គ្នាដូច្នោះស្រេច បងប្អូនខ្ញុំក៏បើកឡានទៅឆ្លងសាឡាង ឯខ្ញុំក៏ជិះកង់ខ្ញុំតាមផ្លូវមាត់ទន្លេត្រង់ទៅជើង។ លុះទន្ទឹមនឹងភូមិមួយដែលបានណាត់នោះ ខ្ញុំក៏ឈប់ រួចក៏រកទូកគេឆ្លង។ ជាកុសលល្អ មានទូកមួយគេទទួលចម្លងទៅ ខ្ញុំបានដល់ត្រើយដូចប្រាថ្នា ហើយឈរចាំរថយន្តបងប្អូនខ្ញុំ។ ក្រោយមករថយន្តមកដល់ខ្ញុំក៏បានឡើងជិះតទៅទៀត។ គិតទៅដំណើរភៀសខ្លួននេះ កកិចកកុចណាស់។

រថយន្តបានធ្វើដំណើរទៅមុខឥតឈប់ឈរ ទៅដល់ខេត្តពោធិសាត់។ សូមជម្រាបថា កាលណោះខេត្តបាត់ដំបង, ត្រូវសៀមត្រួតត្រាជារបស់សៀម ហើយមានព្រំប្រទល់នឹងខ្មែរ ត្រង់ស្វាយដូនកែវ។ រថយន្តបាននាំខ្ញុំដល់សាលាស្រុកត្រពាំងជង, ហួសពីសាលាស្រុកត្រពាំងជងប្រហែល ៧ គីឡូម៉ែត្រ ដល់កន្លែងស្ងាត់ក៏ឈប់។ ទាំងអស់គ្នាចុះពីរថយន្ត ខ្ញុំក៏បើកគំរបក្ដិតឡានយកទោចក្រយានខ្ញុំចេញមក។ ជាឱកាសដែលខ្ញុំត្រូវបែកពីបងប្អូនក្មួយជាទីស្រឡាញ់ហើយ។ ខ្ញុំត្រូវធ្វើដំណើរទៅតែម្នាក់ឯងក្នុងពេលនេះហើយ។ ខ្ញុំក៏និយាយលាប្អូនប្រុសប្អូនស្រីនិងក្មួយខ្ញុំថា សូមប្អូនៗ និងក្មួយៗ មើលថែទាំគ្រួសារផង ព្រោះខ្ញុំទៅនេះពុំមានកំណត់ថាថ្ងៃណានឹងបានវិលមកជួបជុំគ្រួសារវិញទេ, ការតស៊ូមានតែស្លាប់ហើយនិងរស់ជាគូគ្នា។ ជាពិសេសខ្ញុំបានផ្ដាំក្មួយខ្ញុំ ជួន-ជឿន, ជួន-ម៉ុម, ជួន-ប្រសិទ្ធ ឲ្យខំរៀនមែនទែនដើម្បីជួយខ្មែរតទៅផង។ ក្មួយៗ ទាំងនេះក៏ថា ខ្ញុំនឹងគោរពតាមពាក្យមាព្រមទាំងធ្វើតាមគន្លងមាឥតរំលង។ ហើយប្អូនៗ និងក្មួយៗ ខ្ញុំក៏ឲ្យពរខ្ញុំសូមទៅឲ្យបានសុខសប្បាយ ធ្វើការបំរើជាតិបានជោគជ័យតទៅអនាគត។ ខ្ញុំទទួលពរនេះដោយញញឹម តែក្នុងចិត្តពោរពេញដោយក្រៀមក្រំស្រណោះ។ ខ្ញុំនិងគ្រួសារនៅនិយាយគ្នាតែពាក្យដដែល ផ្ដាំផ្ញើនិងឲ្យពរគ្នាទៅវិញទៅមក។ ទំរាំតែដាច់ចិត្តបែកពីគ្នា យើងចំណាយពេលអស់ ២០ នាទី។ ខ្ញុំឡើងជិះកង់ចេញទៅ ធាក់បាន ៨-១០ ជំហាន ងាកមើលទៅបងប្អូនឃើញគេឈរមើលមកខ្ញុំ ខ្ញុំធាក់តទៅទៀត ហើយងាកមើលទៅទៀតលើកដៃឡើងលា គេលើកតបមកវិញ។ ការបែកគ្នានេះគួរកត់សំគាល់ណាស់ ព្រោះខ្ញុំទៅកាន់ស្រុកសៀមនេះ មិនងាយបានត្រឡប់មកជាន់ដីខ្មែរវិញទេ តែមកពីខំកាត់ចិត្តលះបង់គ្រួសារគ្រប់យ៉ាង ដើម្បីតស៊ូកសាងជាតិ ទើបត្រូវតែឃ្លាតទៅនេះ។ នេះជាលើកដំបូងនៃជីវិតខ្ញុំដែលភៀសខ្លួនទៅកាន់បរទេស។

ខ្ញុំធាក់កង់បានប្រហែល ២ ម៉ោង ក៏ទៅដល់ផ្លូវបត់ចូលវត្តស្វាយដូនកែវ ខ្ញុំចូលទៅកាន់វត្តស្វាយដូនកែវហើយសំដៅទៅរកទូកឆ្លងទៅកាន់ត្រើយម្ខាង។ ក្នុងការឆ្លងទូកនេះ មានអនុស្សាវរីយ៍មួយដែលខ្ញុំពុំភ្លេច គឺខ្ញុំកំពុងតែជិះទូកឆ្លង បានឮសំដីពីក្នុងផ្ទះមួយនៅជិតម្ខាងដីសៀមនិយាយឡើង: យើ, រទេះកង់នោះល្អណាស់វើយ...! ខ្ញុំនឹកភ័យប៉ផ្អុក អែយ៉ា ក្រុមចោរសៀមទល់ដែនហើយតើ! ខ្ញុំស្ទាបកាំ-

ភ្លើងដែលនៅនឹងចង្កេះពង្រឹងស្មារតីឡើងវិញ! ខ្ញុំមើលកង់ខ្ញុំ និងមើលទៅមុខអ្នកអុំទូក តែអ្នកអុំទូកនិយាយថាៈ មិនអីទេ, ហើយចេះតែអុំទៅធ្វើព្រងើយ លុះត្រាតែដល់ត្រើយ។ បន្ទាប់ពីឲ្យសោហ៊ុយដល់ទូកដរួចហើយ ខ្ញុំឡើងកង់តាមថ្នល់ដែលឆ្ពោះទៅបាត់ដំបងតែម្តង។ តាមថ្នល់ខ្ញុំជិះនៅខាងឆ្វេងដៃ ព្រោះស្រុកសៀមបើកបរខាងឆ្វេង។ នៅវេលាម៉ោង ១៨ ដោយកម្លាំងខំរបស់ខ្ញុំ ខ្ញុំបានទៅដល់ស្រុកមោងឫស្សី។ ខ្ញុំទៅរកផ្សារមោងដើម្បីរកតាម្នាក់ឈ្មោះ តាទឹង ដែលស្គាល់នឹងអាលសុំស្នាក់។ លោកតាទឹងជាជាងមាសម្នាក់នៅផ្សារស៊ីញ៉ែកពីដើម តែពេលដែលមានចលាចលគាត់ក៏មកនៅស្រុកមោង។ ខ្ញុំសួរគេហូរហែទៅក៏បានស្គាល់ជួបនឹងតាទឹងដូចបំណង។ តាទឹងរាក់ទាក់ទទួលខ្ញុំ ឲ្យខ្ញុំសំណាក់នៅមួយយប់ដោយសុវត្ថិភាព។ លុះព្រឹកឡើងខ្ញុំបានលាតាទឹង បន្តដំណើរតាមទោចក្រយានខ្ញុំឆ្ពោះទៅកាន់ខេត្តបាត់ដំបង ដើម្បីសុំស្នាក់នៅនឹងមា ប៉ុក-គុណ ហៅ ត្រឡាច។ នៅម៉ោង ១១ ថ្ងៃត្រង់ ខ្ញុំក៏បានទៅដល់ផ្ទះមាខ្ញុំដូចបំណង។ ផ្ទះមាខ្ញុំស្ថិតនៅចុងស្ពានដែកផ្នែកខាងកើត ផ្ទះនេះជារបស់ម្តាយក្មេកគាត់ឈ្មោះ ម៉ម-រម៉ៃយ។ មាខ្ញុំបានទទួលខ្ញុំដោយរាក់ទាក់ជាទីបំផុត ហើយសួរខ្ញុំថាៈ តើមានជួបនឹងលោក ប៉ាន-យិន និងក្មួយ ប៊ុណ្ណចន្ទ-ជួន ទេ? ខ្ញុំឆ្លើយថា មិនបានជួបទេ។ ទើបមាខ្ញុំបែរជាប្រាប់ខ្ញុំថាៈ លោក ប៉ាន-យិន លោកទៅតែត្រឹមពោធិ៍សាត់ទេ លោកពុំហ៊ានចូលទៅភ្នំពេញទេ ខ្លាចគេចាប់ លោកត្រូវត្រឡប់ចូលទៅបាងកកវិញ ព្រោះលោកមានកូនប្រុសម្នាក់ឈ្មោះ ប៉ាន-ក្មេម៉ង់ ធ្វើការជានាយកក្នុងក្រុមហ៊ុន អុកស៊ីហ្សែន នៅក្រុងបាងកក ជាទីពឹងអាស្រ័យដែរ។ ឯក្មួយ ប៊ុណ្ណចន្ទ-ជួន អាចចូលទៅស្រុកខ្មែរវិញបានត្បិតអាងលើចំណាត់ការ ដែលប្រើឲ្យត្រឹមតែជាអ្នកបកប្រែភាសាជូនលោក ប៉ាន-យិន ប៉ុណ្ណោះ។ ហើយមាខ្ញុំសរសើរខ្ញុំថាវាងវៃមែន ចេះដោះខ្លួនរួចមកដល់កន្លែងនេះបាន។ គាត់និយាយនឹងខ្ញុំថាមិនអីទេ យើងត្រូវបង្កើតក្រុមខ្មែរអ្នកតស៊ូមួយក្រុមឡើង ធ្វើការរំដោះស្រុកពីក្រញាំបារាំង។ ខ្ញុំសប្បាយចិត្តណាស់ ដោយមាខ្ញុំមានគំនិតស្របនឹងខ្ញុំតាំងពីដំបូងដៃដូច្នេះ។

# ២

# ការបង្កើតខ្មែរឥស្សរៈ

ខ្ញុំបានមកស្នាក់នៅនឹងមាខ្ញុំ ប៉ុក-គុណ ហៅតាត្រឡាច ហើយបានផ្សាយគំនិតអំពាវនាវសុំឲ្យអ្នកស្ម័គ្រចិត្តចូលរួបរួមផងក្នុងការបង្កើតក្រុមខ្មែរតស៊ូមួយក្រុម ឲ្យឈ្មោះថា «ខ្មែរឥស្សរៈ»។ ពាក្យថា «ឥស្សរៈ» នេះជាភាសាបាលីដែលឲ្យន័យថា «ធំ, មិនកញ្ចះគេ, ជាអ្នកជា...» ដូច្នេះ «ខ្មែរឥស្សរៈ» គឺក្រុមខ្មែរដែលជាម្ចាស់លើខ្លួនឯង គ្មាននៅក្រោមអំណាចអ្នកណា, ជាខ្មែរមានឯករាជ្យ, មានសេរីភាព មានសិទ្ធិគ្រប់គ្រាន់ជាខ្មែរ។

នៅទីនោះមិនជាយូរ កំបានទួលមិត្តភក្តិនិងអស់លោកជាច្រើនរូប ដែលមានគំនិតតស៊ូដែរ ហើយដែលទើបតែភៀសចេញពីភ្នំពេញមក បានស្ម័គ្រចិត្តមករួបរួមនឹងខ្ញុំព្រមទាំងមាខ្ញុំ។ ខ្ញុំសូមរំលឹកនាមរបស់អស់លោកទាំងនោះខ្វះដែលខ្ញុំបានចាំ គឺឈ្មោះ ;

| | |
|---|---|
| ហែម សាង | ថាន សាយ |
| ហែម សាវ៉ាត | រស យឹន |
| សារូ | ហ៊ូ |
| ម៉ី ផូរ | អ៊ុក សាន |
| ទ្រង់ ចន្ទរង្សី | ខាន់ |
| ឈៀង | ពុំ |
| ចន្ទ- តោគ្រេស | ភោគ នី |

និងមានអស់លោកច្រើនទៀត ដែលខ្ញុំភ្លេចនាមពុំបានរាប់ក្នុងទីនេះ (សូមអភ័យទោស)។

មាខ្ញុំបានជួលផ្ទះគេមួយនៅម្តុំវត្តសង្កែ ជូនក្រុមទាំងអស់នៅ ព្រមទាំងបានចំណាយប្រាក់ចិញ្ចឹមបាយទឹករហូតមកៗ ហើយមាខ្ញុំបានទៅបាងកកគិតគូរនឹងរដ្ឋាភិបាលថៃ សូមឲ្យគេជួយយើងទាំងផ្លូវចិត្តនិងសម្ភារៈ។

មួយខែក្រោយមក ការទាក់ទងនោះឲ្យផលឡើង គឺរដ្ឋាភិបាលថៃបានអនុញ្ញាតឲ្យបើកកន្លែងមួយនៅឃុំអន្លង់វិលចម្ងាយប្រមាណ ៥ គ.ម. ពីក្រុងបាត់ដំបង។ យើងក៏មានលទ្ធភាពនឹងបង្កើត «ខ្មែរឥស្សរៈ» នៅឆ្នាំ ១៩៤៦។ មុនដំបូងឃើញរួបរួមគ្នាល្អណាស់ ប្រមូលអ្នកស្ម័គ្រចិត្តឯទៀតជាអ្នកស្រុកឲ្យមកហាត់រៀនបានប្រហែល ១០០ នាក់។ បានប្រហែល ២-៣ ខែក្រោយមក បានបង្កើតឲ្យមានក្រុមស៊ើបការណ៍ការពារក្រុមឥស្សរៈ ត្បិតពេលនោះរាជការបារាំង-ខ្មែរ បានប្រុងចូលកាន់កាប់ខេត្តបាត់ដំ-បងវិញហើយ។ រាជការបារាំង-ខ្មែរចាត់ឲ្យស៊ើបការណ៍រកឥស្សរៈ ដូច្នេះយើងត្រូវបង្កើតក្រុមស៊ើបតទល់ទៅវិញ។ ការបង្កើតនេះហើយ ដែលនាំឲ្យល្អក់កករគម្រោងការណ៍ខ្លះ ពីព្រោះក្រុមស៊ើបនេះ ខ្លះមានរឿងផ្ទាល់ខ្លួននឹងអ្នកដទៃ ក៏តាំងបង្កាច់បង្ខូចគេ នាំការណ៍នោះមកជំរាប ជាហេតុនាំឲ្យអ្នកធ្វើការខាងលើសម្រេចការអ្វីគ្មានប្រសិទ្ធភាពឡើយ។ ការទូលពិតបង្កាច់ត្រកូល ចង្អុលទោសគ្នានោះមានជាប្រក្រតី ដូចយ៉ាងមេក្រុមខ្លះដែលចាត់ឲ្យទៅបង្ហាត់បង្វឹកពលទាហានស្ម័គ្រចិត្តនោះជាដើម។ មេបង្ហាត់និមួយៗ បង្ហាត់មិនបានយូរទេ ចេះតែមានរឿងខុសគ្រប់យ៉ាង ខ្លះកូនទាហានមិនពេញចិត្តព្រោះត្បិតធ្វើតាមវិន័យពេក, ខ្លះដូច្នេះ ខ្លះដូច្នោះ ឮតែពាក្យរិះគន់និន្ទាខ្សឹបខ្សៀវគ្នាជារឿយៗ។ ម្យ៉ាងទៀត ទាហានខ្មែរដែលរត់មកពីភ្នំពេញទាំងប៉ុន្មាន សុទ្ធសឹងតែពួកក្រុមហៃហូទាហានជប៉ុន។ របៀបហាត់នៃទាហានជប៉ុនជំនាន់នោះគឺព្រឹកម៉ោង ៥ ហាត់រត់ ៣-៤ គ.ម. យ៉ាងតិច រួចហើយហាត់លុតក្រាបរបៀបយុទ្ធសាស្ត្រជាងមួយម៉ោងទើបឈប់ នាំគ្នាទៅទទួលទានបបរពេលព្រឹក។ ធ្វើយ៉ាងនេះបានប្រមាណ ១៥ថ្ងៃ ២០ថ្ងៃ ក៏ទៅជារឿងដែរ ដោយសារនាយទាហានរងចេះតែរអ៊ូរទាំថា ហាត់របៀបនេះមិនបានយូរទេ រត់លូនរាល់ព្រឹកគ្មានបានប្រយោជន៍ទេ នាំតែខាតពេល ហើយគ្មានកាំភ្លើងមួយដើមផង មានតែកាំភ្លើងឈើមិនដឹងជានឹងច្បាំងនឹងនរណាកើតទេ! ពាក្យទាំងនេះ មេក្រុមមិនត្រឹមតែនិយាយជាមួយមេក្រុមគ្នាឯងទេ គឺថែមទាំងពោលនៅពេលដែលកូនទាហានកំពុងហាត់អស់កម្លាំងថែមទៀត ជាហេតុនាំឲ្យកូនទាហានជឿតាមអស់ទឹកចិត្តតស៊ូទៅវិញ។

នេះឯងជា «ចរិត» របស់ខ្មែរដែលគ្មានគិតមុខក្រោយអ្វីសោះ ចេះតែពោលផ្ដួចៗ ឲ្យតែរួចពីមាត់ដោយសារតែហាត់នឿយបន្តិចបន្តួចនោះ មិនដឹងថាពាំនោលនោះនាំឲ្យខូចកម្លាំងសាមគ្គីអ្វីទេ។

ម្យ៉ាងទៀតសម័យនោះ រាជការថៃគេបើកអំណាចឲ្យប្រមូលកូនទាហានដោយសម្ងាត់ មិនចង់ឲ្យខ្ចរខ្ចាយ, យើងមិនបានរក្សាការសម្ងាត់នោះសោះ ចេះតែបញ្ចេញឲ្យគេឯងដឹងឮ។ «ចរិត» យើងគឺដូច្នេះឯង ជំនុំគ្នាសុទ្ធតែថាការសម្ងាត់ គ្មាននរណាដឹងឮទេ លុះដល់ពេលចេញពីជំនុំមកវិញ ក៏ស្រាប់តែការសម្ងាត់នោះដឹងឮឡើងនៅក្រៅការប្រជុំតែម្ដង។

ចំណែករាជការថៃវិញ លុះដឹងថារាជការបារាំង-ខ្មែរមុខជាទាញយកខេត្តបាត់ដំបងទៅវិញនោះ ក៏តាំងចាប់ផ្ដើមផ្ដល់អាវុធឲ្យខ្មែរឥស្សរៈនេះ។ ជាដំបូងរាជការសៀមឲ្យមកក្រុមខ្មែរឥស្សរៈ មានកាំភ្លើងយន្ត<មីទ្រីយើ>បួនដើម និងកាំភ្លើង<មូស្កីតុង>ប្រហែល ២៥ ដើម ហើយមានកាំភ្លើងខ្លី ២-៤ ដើមថែមទៀត។

ហេតុអ្វីបានជាសៀមសុខចិត្តផ្តល់អាវុធឲ្យខ្មែរឥស្សរៈ នៅពេលដែលខែត្របាត់ដំបងនឹងត្រូវបានមកខ្មែរវិញនោះ? ត្រង់នេះជារឿងមួយដែលយើងត្រូវគិត! គឺមកពីគេចង់ប្រើខ្មែរឲ្យបែរមុខ មិនតទល់ចំពោះតែបារាំងទេ គឺឲ្យតទល់នឹងខ្មែរគ្នាឯងនោះថែមទៀតៗ ប៉ុន្តែយើងពុំបានធោតល្ងង់ ដល់ទៅយកអាវុធមកសម្លាប់ខ្មែរគ្នាឯងទេ ប៉ុន្តែយើងត្រូវតែទទួលយក, យកមកបម្រើគោលបំណងរបស់យើង គឺឈមមុខទល់នឹងពួកបារាំងតែមួយបក្សប៉ុណ្ណោះៗ

ចំណែកកូនទាហានខ្មែរឥស្សរៈ កាលបើបានអាវុធខ្លះ ក៏កើតបម្រើនចិត្តគិតចង់ច្បាំងនឹងទ័ពបារាំងភ្លាមៗ ទោះបីហាត់រៀនវិជ្ជាយុទ្ធសាស្ត្រមិនសូវស្ទាត់ស្ទាញក៏ដោយៗ មួយថ្ងៃៗ ខ្ញុំទទួលពួកអ្នកមកសុំចេញច្បាំងនោះយ៉ាងធុញ ខ្ញុំតែងឃាត់គេថា កុំអាលសិន ចាំឲ្យយើងមានអាវុធច្រើនបន្តួរសិន ហើយចាំហាត់ឲ្យស្ទាត់ជាងនេះបន្តិចទៀតសិនៗ

ឯចំណែកមាខ្ញុំ ប៉ុក-គុណ ហៅ តាត្រឡាច នោះវិញ ក៏ឡើងចុះក្រុងបាងកកញ្ញឹកញាប់ រាជការខាងសៀមឃើញឯងទៅរ៉ោចៗ ពេក ក៏ឲ្យការក្លើងហាសិបដើមមកទៀតៗ

សុំឲ្យអ្នកអានយល់ថា សៀមប្រុងតែឲ្យទេ ពីព្រោះគេត្រូវការឲ្យខ្មែរច្បាំងនឹងខ្មែរ ប៉ុន្តែដោយគេត្រូវលាក់គំនិតគេនោះផង គេត្រូវការឲ្យក្រុមឥស្សរៈយើងដឹងគុណគេផង ដូច្នេះគេត្រូវតែតីងតែងដូច្នេះឯងៗ ឲ្យមកធូរពេក ដូចជាចង់ឲ្យពេកៗ នេះជាគំនិតសៀម! ហើយសម័យនោះ (១៩៤៦) មកដល់សម័យនេះ (ដែលខ្មែរយើងកំពុងទឹកចូលច្រមុះ) តើឃើញសៀមមានផ្តល់អ្វីឲ្យយើងសំរាប់រស់ទេ?

## អំពីឈ្មោះ ដាប-ឈួន

កាលពីដើម ដាប-ឈួន នេះ ជានាយក្រុមនៃទាហានរបស់រាជការខ្មែរ-បារាំង ដែលច្បាំងនឹងសៀមៗ កាលណោះរាជការសៀមចេះប្រើនយោបាយលួងលោមឃោសនាថា ឲ្យតែមេទាហានវង់ និងនាយក្រុមណាខាងខ្មែររត់ទៅចូលនឹងសៀម សៀមនឹងតម្លើងសក្តិឲ្យធំលើសពីនៅខ្មែរទៅទៀតៗឈ្មោះ ដាប-ឈួន កាលបើបានស្តាប់ឃោសនានេះ ដោយចង់បានសក្តិយសខ្ពស់ជាងនេះ ក៏តាំងដាក្បាលរត់ទៅចូលនឹងទាហានសៀមតែម្តងៗ ខាងទាហានសៀមទទួលរាក់ទាក់ ហើយសន្យានឹង ដាប-ឈួន ថា មិនអីទេ នឹងបំពាក់សក្តិឲ្យធំជាងនៅជាមួយទាហានខ្មែរ គឺឲ្យបានពាក់សក្តិ ១ ៗ ដាប-ឈួន មានអំណរណាស់ នឹកសង្ឃឹមហើយរង់ចាំទទួលឋានៈនោះ រហូតចប់សង្គ្រាមខ្មែរ-ថៃទៅៗ ថ្ងៃក្រោយមក រាជការសៀមប្រើ ដាប-ឈួន ឲ្យមករក្សាភូមិមួយត្រង់ម្តុំស្វាយចេកដែលកាលណោះជាទល់ដែនខ្មែរ-សៀមៗ ដាប-ឈួន រង់ចាំសក្តិដែលសៀមបំពាក់នោះអស់កាលដ៏យូរ គ្មានឃើញនាយទាហានសៀមណាមកជួបនិយាយពីរឿងសក្តិយសអ្វីសោះ ទើបក្រាក់ខ្លួនថាៈ ឱ អញចាញ់បោកសៀមទេតើ! ប៉ុន្តែ ដាប-ឈួន គ្មានផ្លូវនឹងគេចចេញទៅណារួចទេ រត់ចូលមកខាងរាជការខ្មែរវិញ ត្រូវគេបាញ់ចោល, ម៉្លោះហើយសុខចិត្តខំទ្រាំបម្រើសៀមតទៅ, តែព្យាយាមថាត្រូវតែរត់ថ្ងៃណាមួយៗ

និយាយពីខាងទ័ពខ្មែរឥស្សរៈយើងឯណោះវិញ កំពុងតែកៀរគររកគ្នាឲ្យបានច្រើន លុះស៊ើបដឹងថា ដាប-ឈួន ឯណោះមានសេចក្តីតូចចិត្តនឹងសៀមកំពុងតែរកច្រកចេញពីទ័ពសៀម ក៏ចាត់គ្នាឲ្យទៅទាក់ទងនឹង ដាប-ឈួន ឲ្យ ដាប-ឈួន ចូលមកប្រួបរួមនឹងខ្មែរឥស្សរៈវិញម្តងៗ ដាប-ឈួន មាន

*អំណរណាស់ ព្រោះនៅជាមួយសៀមនោះ ដាប-ឈួន មានសេចក្ដីអត់ឃ្លានលំបាកវេទនាជាទីបំផុត ហើយក្នុងចិត្តក៏ឈឺចាប់រាល់ថ្ងៃផង លុះដល់មកត្រូវយើងហៅឲ្យមករួបរួមដូច្នេះ ដាប-ឈួន ក៏ដូចជាបានរបូតពីខ្នោះឃ្នាងៗ គាត់ក៏នាំប្រពន្ធគាត់និងកូនប្រុសមួយ[១] ភៀសចេញពីស្វាយចេក គាត់មករកក្រុមយើងនៅអន្លង់វិលតែម្ដងៗ*

*ខ្ញុំមិនពន្ល័សទេ ដោយគាត់ត្រូវការឲ្យខ្ញុំសង្គ្រោះខ្លាំងពេក គាត់លូនសំពះខ្ញុំអំពីចម្ងាយ ព្រោះគាត់ដឹងថា គឺខ្ញុំនេះហើយជាមេកោយម្នាក់របស់ក្រុមឥស្សរៈ គាត់មកជិតក៏និយាយអង្វរដោយលើកដៃប្រណម្យជាប់ថា: សូមលោកម្ចាស់មេត្តាអនុញ្ញាតឲ្យខ្ញុំបាទបានមកនៅជ្រកកោន បំរើបក្សពួកលោកម្ចាស់ផង! ខ្ញុំបាទសូមសន្យាថា នឹងបំរើបក្សលោកម្ចាស់ដោយសេចក្ដីស្មោះត្រង់ជាទីបំផុត, ឲ្យខ្ញុំបាទស្បថជូនលោកម្ចាស់ក៏ស្បថដែរ ខ្ញុំបាទមិនក្បត់លោកម្ចាស់ទេ!*

*ពាក្យនេះ ដាប-ឈួន ដាក់ខ្លួនទាបពេកណាស់ ដែលខ្ញុំមិនចង់ឮពាក្យនេះផងទេៗ ខ្ញុំប្រញាប់ឲ្យគាត់ងើបឡើងឈរឲ្យត្រង់ខ្លួនធម្មតា ខ្ញុំនិយាយថា: សូមលោក កុំទុកខ្ញុំជាមនុស្សធំខ្ពស់អី សូមលោកទុកជាមិត្តម្នាក់ទៅចុះ, លោកមកនេះ ខ្ញុំអរពេកហើយ ព្រោះយើងនឹងបានរួមគ្នាធ្វើការតស៊ូតទៅទៀត! ឯថាការស្មោះត្រង់នោះ ខ្ញុំរឹតតែអរណាស់ ព្រោះក្រុមយើងត្រូវការនូវចិត្តបែបនេះ! យើងអត់ឃ្លានមានក្រយ៉ាងណាដូចម្ដេច ដូចៗ គ្នា! លោកថយទៅនៅនឹងគ្នីគ្នាខ្ញុំចុះ!*

*ដាប-ឈួន បន្ទន់ខ្លួនសំពះខ្ញុំសឹងបាក់ខ្នងថយទៅវិញៗ*

*ប៉ុន្តែអនាគត ដាប-ឈួន បានធ្វើយ៉ាងណាចំពោះខ្ញុំវិញនោះ អស់លោកនឹងបានឃើញ បានជ្រាបនៅពេលក្រោយៗ គឺអំពើរបស់គាត់នោះហើយ ដែលខ្ញុំចងចាំអស់មួយជីវិត ហើយដែលតែងថ្ងូរហ៊ឺះថា : នេះហើយចរិតខ្មែរ...ៗ*

---

*(១)- កូនប្រុសនោះ សព្វថ្ងៃនៅប្រទេសឥណ្ឌា ៗ*

# ៣

# អំពើព្រៃផ្សៃនៃពួកឥស្សរៈ

ខ្ញុំត្រូវតែនិយាយដោយពិតនូវការដែលខ្លួនខ្ញុំបានឃើញបានដឹង ក្នុងគ្រាដែលខ្ញុំស្ថិតនៅជាមួយពួកឥស្សរៈ ដែលខ្ញុំផ្ទុងផ្ដើមបង្កើត ហើយបែរជាឥតសណ្ដាប់ធ្នាប់ គ្មានរបៀបរៀបរយ ព្រោះតែពួកនោះចង់ធំ ពង្រីកអានុភាពវាយកំពស់ស្មើស្ដេចត្រាញ់ម្នាក់ៗ។ ដោយពិតទៅ ពួកនេះ ដោយចង់តម្កើងខ្លួនខ្លាំងពេក គឺត្រូវតែភ្លេចសីលធម៌មនុស្សធម៌អស់ពីខ្លួន បែរជាស្រឡាញ់ការកាប់សម្លាប់ស៊ីសាច់ហុតឈាមគ្នាដោយព្រៃផ្សៃទៅវិញ។

ពីរបីរឿងតទៅនេះគឺជាឧទាហរណ៍ច្បាស់ បង្ហាញនូវភាពព្រៃផ្សៃនិងអមនុស្សធម៌នៃពួកនេះ ៖

## ការសម្លាប់គិញបារាំងម្នាក់ឈ្មោះ ប៊ុន ចាន់

ការស៊ើបរកគិញបារាំង បានចាត់ឡើងៗ ចំណាត់នេះបានហុចលទ្ធផលខ្លះដែរ នាំឲ្យគិញបារាំងខ្លាចរអាជាខ្លាំងៗ គិញបារាំងដែលត្រូវចាប់បាន បន្ទាប់ពីបានវាយធ្វើទារុណកម្មហើយ តែងយកទៅបាញ់ចោលឬសម្លាប់ដោយដំបងៗ

ក្នុងបណ្ដាគិញបារាំងដែលពួកឥស្សរៈចាប់បានហើយយកមកសម្លាប់នោះ ខ្ញុំបានសង្កេតឃើញគិញបារាំងម្នាក់ជាតិខ្មែរឈ្មោះ ប៊ុន ចាន់ មានស្មារតីរឹងឥតតក់ស្លុតនឹងសេចក្ដីស្លាប់សោះ។ គេចាប់កស្ដុតាងបាន ស្គាល់ខ្លួនវាថាជាគិញច្បាស់ហើយគេយកមកវាយសួរចម្លើយ វានៅតែឆ្លើយថាពុំដឹង ថាពុំមែនជាគិញនរណាទាំងអស់ វាឆ្លើយនោះបែបព្រងើយៗ គេគំរាមសួរថា: ឯងឆ្លើយឲ្យត្រង់មក បើនៅ

រឹងប្រកែកទៀតយើងនឹងបាញ់សម្លាប់! វានៅឆ្លើយបែបព្រងើយថា: សម្លាប់ ៗ ទៅ! ខ្ញុំមិនដឹងអ្វីទាំងអស់, ខ្ញុំមិនមែនជាគិញ្ញនរណាទាំងអស់! ប៉ុន្តែបើអស់លោកស្គាល់ច្បាស់ថាគិញ្ញបារាំង នៅក្នុងកណ្តាប់ដៃលោកហើយ លោកសម្លាប់ទៅ! តែលុះគេយកទៅឲ្យឈរនៅជិតរណ្តៅ ហើយឲ្យវាការនាធម៌ ទើបវាដូចជាភ្ញាក់ខ្លួន នឹកភ័យបន្តិចនិយាយថា: ខ្ញុំគ្មានដឹងអ្វីទាំងអស់! យើម៉េចយកខ្ញុំមកសម្លាប់? គឺថាវាមានចិត្តក្លាហានមានស្មារតីរឹងណាស់ ទាល់តែឃើញរណ្តៅសំរាប់កប់វាតែម្តងទើបវាភ័យ។ ពេលនោះពួកឥស្សរៈជាពេជ្ឈឃាតដំបង[1] សំពងកួសៗ កញ្ចឹងក អ្នកទោសវាដួលចុះប្រកាច់ដាច់ខ្យល់ ទើបច្រានទម្លាក់ទៅក្នុងរណ្តៅ។

ការសម្លាប់ឈ្មោះ ប៊ុន ចាន់ នេះ ជាអំពើកាចសាហាវមធ្យមទេ ពីព្រោះពេជ្ឈឃាតប្រញាប់បំបាត់ជីវិតអ្នកទោសឲ្យផុតទៅភ្លាមៗ មិនវេទនាភ្នែកពេក។ នៅមានការសម្លាប់អ្នកទោសបែបផ្សេងពីនេះ ដែលមើលទៅគួរឲ្យវេទនារកពាក្យនិយាយមិនបាន ហើយដែលនាំឲ្យខ្ញុំមិនសប្បាយតែងតែដើរចេញ ពេលណាពួកមេៗ ឯទៀតចាត់ឲ្យធ្វើបែបនោះដែលគេឲ្យឈ្មោះថា ការសម្លាប់បែបស្រងែពេន។

សូមជ្រាបថា ខ្ញុំគឺមេឥស្សរៈមែន តែបានបំបែកនាទីខាងគិញ្ញ ខាងចាប់ចង ខាងសួរចម្លើយ និងសម្លាប់នេះទៅឲ្យគេផ្សេង គេមាននាទីគ្រប់គ្រាន់ ឯខ្ញុំ ចំពោះរឿងនេះគឺគ្រាន់ជាទីប្រឹក្សាគេប៉ុណ្ណោះ។ ដូច្នោះ ទើបខ្ញុំពុំអាចអារកាត់រឿងណាមួយឲ្យគេយល់ព្រមតាមបានឡើយ។

## ការសម្លាប់បែបស្រងែពេន

ខ្ញុំសូមជម្រាបថា: ការសម្លាប់បែបស្រងែពេន ជាការសម្លាប់មួយវេទនាភ្នែកណាស់ អ្នកដែលត្រូវគេសម្លាប់នោះ ប៉ផ្តឹតប៉ផ្តក់ជាទីបំផុតមុននឹងស្លាប់។ គឺមុនដំបូង ពួកឥស្សរៈយកមនុស្សដែលជាគិញ្ញចារបុរសនោះមកវាយដំច្រំផាក់អស់ចិត្ត រួចចងស្លាបសេកនាំយកទៅឲ្យអង្គុយលុតជង្គង់ទល់មុខរណ្តៅដែលសម្រាប់កប់ខ្មោចអ្នកទោសនោះ។ ឯពួកឥស្សរៈនាំគ្នាវាតរង្វង់ឲ្យជុំជុំវិញអ្នកទោសនោះ។ ភ្លាមនោះពេជ្ឈឃាតម្នាក់កាន់ដាវសស្លាច ស្ទុះចូលមកកណ្តាលវង់ តាំងរាំរែកពត់ពែន បញ្ចេញទឹកមុខក្រឡេបក្រឡាប់ជាអាការកាចសាហាវ, រាំបានបន្តិចក៏ស្ទុះទៅជិតអ្នកទោសដែលអង្គុយលុតជង្គង់នោះ រួចក៏យកដាវទៅអារក អ្នកទោសនោះបន្តិច, អារមិនខ្លាំងទេល្មមតែចេញឈាម រួចកន្ទុនយកមាត់ទៅជញ្ជក់បឺតឈាមនៅកនោះ យកមកព្រួសមុខដាវលាន់ ផែតៗ! ដូចគេព្រួសទឹកមាត់ស្លា ... មើលទៅសម្បើមណាស់។ ឯអ្នកទោសនោះមុខខ្មៅប៉ែ ធ្វើភ្នែកភ្លឹះៗ រាងកាយញ័ររន្ធត់ដោយឈឺចាប់និងដោយភិតភ័យស្តាយជីវិត។ ពេជ្ឈឃាតបានអារកបឺតឈាមយកមកស្ពោះព្រោះ រាំរែកអស់ក្បាច់ទើបចាក់កអ្នកទោសជាបង្ហើយ, គ្នាដួលទៅ ក៏ច្រានទម្លាក់ទៅក្នុងរណ្តៅ...

ពេលធ្វើពិធីនេះម្តងៗ ខ្ញុំមិនចង់ចេញទៅមើលទេ ពីព្រោះលំបាកមើលណាស់ ហើយខ្ញុំជំទាស់មិនឲ្យធ្វើពិធីព្រៃផ្សៃនេះជាច្រើនលើក តែពួកមេៗ ឯទៀតគេមិនព្រម គេថាត្រូវតែធ្វើដូច្នេះ ដើម្បីផ្ចាញ់ផ្ចាលសត្រូវ។ ខ្ញុំមិនយល់សោះ ព្រោះថាគ្នាត្រូវស្លាប់ទៅហើយ, ស្លាប់គង់តែស្លាប់ទេ, ម៉េចមិនសម្លាប់

---

(១)- ដំបងធ្វើពីឈើគ្រញូងប្រវែងជាង ១ ម៉ែត្រប៉ុនកដៃមនុស្សចាស់ កាលណោះគេសំចៃគ្រាប់កាំភ្លើង។

*តែម្ដងទៅ?*

*ត្រង់នោះហើយខ្ញុំបានកត់សំគាល់ថា ចរិតពួកខ្មែរឥស្សរៈនោះព្រៃផ្សៃណាស់ សត្វជាតុមិនស្មើទេ!! ហើយព្រោះតែចរិតពួកគេបែបនេះហើយ ទើបខ្ញុំដូចជាសោយដៃជើងម្ដងៗ សឹងតែចយខ្លួនចេញពីក្រុមនេះទៅវិញផង។*

□ □

□

*ក្រៅអំពីអំពើព្រៃផ្សៃនេះ គំនិតពួកឥស្សរៈមេៗ ខ្លះ ប្រកបដោយអគតិ, អយុត្តិធម៌ គ្មានការពិចារណាវែងឆ្ងាយសោះ សម្លាប់មនុស្សស្លូតត្រង់គ្មានប្រណី។ ខ្ញុំសូមលើកយករឿងមួយមកជម្រាបៈ*

## អំពីការសម្លាប់ជាងកាត់សក់ម្នាក់

*ថ្ងៃមួយក្រុមឥស្សរៈបានទទួលពីអ្នកស៊ើបការណ៍មក នូវបុរសម្នាក់អាយុប្រមាណជាសាមសិបឆ្នាំ មុខមាត់ស្អាតបាត រកស៊ីធ្វើជាងកាត់សក់នៅជាប់នឹងរបងផ្ទះបាំងបារាំង នៅកណ្ដាលក្រុងបាត់ដំបង។ តាមកំណត់ហេតុរបស់អ្នកស៊ើបការណ៍ឲ្យដឹងថា ជាងនេះឯងជាគិញរបស់បារាំងតែងតែលបចូលទៅឲ្យការណ៍បារាំងនៅផ្ទះឃ្លាំងធនាគារ (Banque) របស់បារាំងដែលមានបារាំងនៅនោះ។ ក្រុមខ្ញុំដែលជាអ្នកកាន់ការខាងលើ ក៏ចាត់ឲ្យគេសាកសួរបុរសនោះតាមដំណើរ។ នៅក្នុងព្រៃស្ងាត់មួយ ពួកអ្នកដៃដល់ប្រហែលជាប្រាំនាក់ ដែលមានកាំភ្លើងនិងដំបងក៏ចាប់ផ្ដើមវាយអ្នកនោះឯង នឹងស្វាយកាំភ្លើងនិងដំបងមួយកូសម្នាក់ ហើយសួរថាៈ*

- *ឯងជាគិញបារាំងមែនទេ?*

*បុរសនោះឈឺចាប់ញ័រទទ្រើកឆ្លើយរហ័សថាៈ*

- *បាទទេ ខ្ញុំបាទពុំមែនជាគិញទេទាន!*

*គេចាប់វាយអ្នកនោះហើយសួរទៀតៈ*

- *ឯងចូលទៅឡើងផ្ទះបារាំងនោះច្រើនដងហើយមែនទេ?*
- *បាទទាន ខ្ញុំបាទសូមជម្រាបតាមត្រង់ ខ្ញុំបាទធ្លាប់ទៅផ្ទះនោះច្រើនដងមែន ប៉ុន្តែខ្ញុំបាទគ្មានដឹងអីទេ!*
- *និយាយឲ្យត្រង់មក ឯងទៅជួបបារាំងប៉ុន្មាននាក់? ប្រាប់វាថាម៉េចខ្លះ? បើឯងនិយាយសារភាព អញនឹងទុកជីវិតឲ្យ បើមិនដូច្នោះទេ អញនឹងបាញ់ឯងសម្លាប់ឥឡូវ!*

*ពោលដូច្នោះ អ្នកពេជ្ឈឃាដយើងតាំងទាញកាំភ្លើងបញ្ចូលគ្រាប់លាន់ក្រាកៗ ចង្អុលចុងមាត់ត្រៃទៅរកបុរសនោះដែលមានទឹកមុខឡើងស្វាយ មានអាការៈញាប់ញ័រដូចកូនសត្វ។ បុរសនោះលើកដៃសំពះៗ*

- *បាទលោកម្ចាស់, សូមលោកម្ចាស់ទុកជីវិតខ្ញុំ! ខ្ញុំបាទសុំជម្រាបតាមត្រង់, ខ្ញុំបាទចូលរបងទៅផ្ទះនោះរាល់យប់នោះ គឺខ្ញុំបាទទៅលេងបៀជាមួយនឹងមិត្តភក្ដិ ដែលយកកន្លែងនោះជាកន្លែងលេង, ខ្ញុំបាទគ្មានបានយកការណ៍ទៅឲ្យបារាំងទេ ខ្ញុំបាទសូមស្បថជូន!*

*ពេលមិនទាន់ចប់ផង ពេជ្ឈឃាតយើងក៏វាយអ្នកនោះមួយស្វាយកាំភ្លើងម៉ាំង! ស្រែកអូយ! យកដៃក្តោបថ្ពាសដួលដេកនឹងដីថ្ងូរហ៊ឺស... ពេជ្ឈឃាតនេះក៏ស៊ុះទៅធាក់ប្រមៀលទៅទៀតបីបួនត្រឡប់ រួចគំហកសួរទៀតៈ*

- *អាឯងនៅរឹងដល់ណាទៀត? ម៉េចមិននិយាយឲ្យត្រង់? អាឯងនាំការណ៍ទៅប្រាប់បារាំងថាម៉េចខ្លះ?*

*បុរសនោះមានឈាមរីមៗ ចេញពីមាត់និងថ្ពាស ទំត្រដរក្រោកអង្គុយលើកដៃសំពះទៅពេជ្ឈ-ឃាតព្រមទាំងត្រដរនិយាយៈ*

- *ខ្ញុំបាទស្បថជូន... ខ្ញុំបាទពិតជាគ្មានដឹងអ្វីសោះ ខ្ញុំបាទជាជាងកាត់សក់រកស៊ីកាត់សក់រាល់ថ្ងៃ ខ្ញុំបាទគ្មានទាក់ទងអីនឹងបារាំងសោះឡើយទានប្រោស សូមមេត្តាកុំធ្វើបាបខ្ញុំបាទអី!*

*កាយវិការនិងទឹកមុខអ្នកទោសនេះ ធ្វើឲ្យខ្ញុំដែលជាអ្នកចាំកាត់សេចក្តីជាមួយនឹងមេៗ ៦ នាក់ទៀតនោះ ស្មានយល់ថាគ្នានោះជាមនុស្សស្លុតបរិតទេ ពុំមែនជាគិញបារាំងទេៗ តាមខ្ញុំ ខ្ញុំចង់តែឃាត់ពួកអាពេជ្ឈឃាតថាឲ្យឈប់សួរទៀតទៅ ប៉ុន្តែខ្ញុំពុំទាន់ហ៊ានឃាត់ទេ ខ្លាចមេៗ ឯទៀតគេពុំស្របនឹងខ្ញុំៗ*

*ចម្លើយអង្វររបស់អ្នកទោសនោះ ពុំបានធ្វើឲ្យពេជ្ឈឃាតទទួលទន់តាមឡើយៗ គេក៏តាំងទាត់ពោះអ្នកទោសនោះមួយក្ដិបយ៉ាងធ្ងន់ គ្នាចុករមួលយកដៃក្តោបពោះ ដួលទន្ទៀលទៅទៀតៗ ការនេះគួរតែឈប់មួយនាទី ប៉ុន្តែពេជ្ឈឃាតយើងរឹតតែបញ្ចេញកាពសាហាវខ្លាំងឡើង គេស៊ុះមកទាត់ទៀត អ្នកទោសរមៀលត្រឡប់ផ្កាប់ផ្ងារ ទៅម្ខាងម្នាក់ ម្នាក់ទាត់បញ្ជូនទៅម្នាក់ទៀត បុរសនេះរមៀលចុះឡើង រួចពេជ្ឈឃាតម្នាក់នោះទាត់ប្រមៀលមកឲ្យខ្ញុំ អ្នកទោសរមៀលមកជិតជើងខ្ញុំ រាល់គ្នាដូចជាចង់ឲ្យខ្ញុំធ្វើដូចគេដែរ ប៉ុន្តែតើឲ្យខ្ញុំយារជើងទាត់ធាក់មនុស្សដែលដូចជាពិរពិការនេះកើតដែរឬ? ហើយខ្ញុំកំពុងតែយល់ថា គេនេះជាមនុស្សល្អផង តើឲ្យខ្ញុំផ្តល់ទារុណកម្មឃោរឃៅដូច្នេះកើតដែរឬ? មិនកើតសោះ ហើយខ្ញុំឈរនៅស្ងៀម សម្លឹងទៅមនុស្សដែលនៅក្បែរជើងនោះឥតចេញស្តីៗ មនុស្សនោះឯងដែលដូចជាសន្ទប់មួយរំពេចហើយដឹងខ្លួនឡើងវិញនោះ ក៏ដូចជាវង្វេងទិសអស់ បានឱកាសដែលគេមិនធ្វើអ្វីនៅនឹងមុខខ្ញុំនេះ គ្នាត្រដរងើបក្បាលឡើងយកដៃប្រត់ដីបង្អើបខ្លួនបន្តិច ហើយសំពះខ្ញុំ និយាយខ្សាវៗដោយកម្លាំងខ្សោយថាៈ*

- *ព្រះតេជគុណ... អាណិតជួយខ្ញុំបាទផង, ខ្ញុំបាទគ្មានដឹងរឿងអ្វីទាំងអស់ ខ្ញុំបាទគ្មានធ្វើគិញបារាំងសោះ សុំកុំសម្លាប់ខ្ញុំអី!*

*ខ្ញុំនៅតែស្ងៀម គ្មានប្រតិកម្ម អ្នកទោសក៏និយាយទៀតថាៈ*

- *ព្រះតេជគុណ... បើព្រះតេជគុណសម្លាប់ខ្ញុំបាទ ក៏ដូចជាសម្លាប់មនុស្សពីរនាក់ទៀតដែរ គឺខ្ញុំបាទមានម្តាយចាស់ម្នាក់ និងប្អូនស្រីមួយដែលត្រូវខ្ញុំរកស៊ីចិញ្ចឹមរាល់ថ្ងៃៗ បើអត់ពីខ្ញុំនោះអ្នកទាំងពីរក៏នឹងវេទនាហើយ សូមលោកម្ចាស់អាណិតជីវិតសត្វផងទាន!*

*ខ្ញុំស្តាប់សំដីនេះ ក៏កើតពិចារណាអាណិត តែខ្ញុំពុំតបថាអ្វីទេ ខ្ញុំដើរចេញពីវង់នោះមកអង្គុយនៅមួយកន្លែង នរណាធ្វើអីអ្នកទោសនោះធ្វើចុះៗ តែពួកមេៗ និងពួកឃាតករក៏អត់មានធ្វើអ្វីដែរ គេដើរមករកខ្ញុំទាំងអស់គ្នា ក្នុងទំនងចង់ពិគ្រោះៗ មេម្នាក់សួរខ្ញុំថាៈ*

- *អាគិញនេះវាធ្លាប់ស្គាល់បងម៉ុលឯងឬ? វាជាគ្រួសារបងឯងឬ? បានជាបងឯងមិនព្រមធ្វើបាបវា?*

- វាមិនធ្លាប់ស្គាល់ខ្ញុំទេ វាមិនមែនជាសាច់ញាតិខ្ញុំទេ ប៉ុន្តែវាជាខ្មែរម្នាក់ ដែលពួកយើងរាប់ថាជាសាច់ឈាមយើងដែរ!

អាពេជ្ឈឃាតនិយាយកាត់ខ្ញុំឡើង:

- វាជាខ្មែរមែន តែខ្មែរក្តៅបារាំង វាធ្វើគិញបារាំង វាជាមនុស្សក្បត់!

ខ្ញុំតបទៅវិញ ដោយសម្លេងស្រាល:

- គ្មានភស្តុតាងឯណាគ្រប់គ្រាន់ថាគ្នានោះជាគិញទេ! បើរកភស្តុតាងឃើញគ្រប់គ្រាន់នោះ កុំថាឡើយតែបុរសនោះ ទាំងគ្នាយើងនេះក៏ដោយ ឲ្យតែហ៊ានក្បត់ ខ្ញុំហ៊ានធ្វើទារុណកម្មយ៉ាងខ្លាំងលើសនេះទៅទៀត។

មេម្នាក់សួរកាត់ឡើង:

- អ៊ីចុះកំណត់ហេតុអ្នកស៊ើបការណ៍ ដែលគេឲ្យមកនោះ ទុកជាអ្វីទៅវិញ?
- នោះមិនមែនជាភស្តុតាងគ្រប់គ្រាន់ទេ ខ្ញុំមិនយកជាបានការទាំងអស់ទេ ត្រូវស៊ើបសួរឲ្យដល់កន្លែងទៅទៀត!
- ធ្វើដូចបងម៉ុលឯង យឺតការណ៍ណាស់។
- អ៊ីចឹងហើយ ព្រោះយើងត្រូវរក្សាយុត្តិធម៌ផង!

ខ្ញុំតបដូច្នេះ ហើយងើបដើរចេញ។ មេម្នាក់សួរខ្ញុំបញ្ឆោកដោយមិនសប្បាយចិត្ត:

- អ៊ីចឹងបងម៉ុលឯងយល់ថាអានោះជាមនុស្សល្អឬ?
- ខ្ញុំមិនថាទេ តែខ្ញុំថាត្រូវអង្កេតតទៅទៀត!
- បើអ៊ីចឹង តាមបងម៉ុលឯង បងម៉ុលឯងមិនសម្លាប់អានេះទេឬ?
- ហ្នឹងហើយតាមខ្ញុំ ខ្ញុំមិនឲ្យសម្លាប់មនុស្សនេះទេ!
- ចំណែកពួកយើង ពួកយើងសម្រេចថាត្រូវតែសម្លាប់!
- ធ្វើអីធ្វើទៅ ខ្ញុំមិនដឹងទេ!
- ល្អប្រើន, បានសេចក្តីថាបងឯងមិនសប្បាយចិត្តនឹងពួកយើងធ្វើអំពើនេះទេ!

មេនោះបង្អង់បន្តិច ងាកទៅរកគ្នីគ្នា រួចនិយាយច្បាស់ៗ ថា:

- អើឥឡូវនេះ កនយើងឈប់ធ្វើបាបអ្នកទោសនោះទៀតទៅ លើកវាឲ្យទៅស្រុកវិញទៅ! ព្រោះរកភស្តុតាងគ្មាន!

រួចគេញាក់ភ្នែកដាក់ពេជ្ឈឃាត ដែលមានកាំភ្លើង Remington គ្រានោះ បុរសនោះឮគេថាឲ្យរួចទោស ក៏ខំងើបដើរទ្រេតទ្រោតចូលមកក្នុង ទំនងសុំអរគុណ តែអ្នកមានកាំភ្លើងនិយាយថា:

- ទៅ, ចេញទៅ គេឲ្យរួចខ្លួនហើយ ដើរឲ្យត្រង់ទៅ កុំងាកក្រោយ!

គ្នាខំដើរទាំងជំហានទ្រមៗ ចេញពីនោះបានប្រហែលជា ១០ ម៉ែត្រ ស្រាប់តែ ផាំង!! អូយ! អ្នកនោះដួលស្រ៊ុប ដោយគ្រាប់<រីមីងតុង>ទៅទម្លុះស្មាបែកឈាមហែង។ ទំនងជាយល់ថា គេបាញ់ឲ្យខ្លួនចេញឲ្យឆាប់ៗ ក៏មិនដឹង អ្នកនោះខំត្រដរស្រែកគ្រលួចថា: បានហើយទាន, បានហើយកុំថែមទៀត! ហើយត្រដរងើបឡើងទៀត ប៉ុន្តែ ផាំង!! មួយគ្រាប់ទៀតគ្រឹបទៅទៀតងើបលែងរួច ដោយត្រូវត្រង់ក្បាលដំណំណាស់។ បុរសនោះស្ងាត់មាត់ត្រឹមណោះ ដែលខ្ញុំនឹកថាគ្នាដាច់ខ្យល់ទៅហើយ។ ប៉ុន្តែពួកពេជ្ឈឃាតបានទៅមើលហើយស្រែកថា:

- *យី! អានេះធ្លាយក្បាលប៉ុណ្ណឹងហើយ នៅរស់ទៀតហ្ន៎!*

*គេនាំគ្នាអូសអ្នកទោសនោះមកវិញ! អស្ចារ្យណាស់ អ្នកទោសនោះធ្លាយស្មាធ្លាយក្បាល តែនៅមិនទាន់ស្លាប់ នៅតែខំបើកភ្នែក ហើយដៃញញីញញ័រសំពះមកអ្នករាល់គ្នាៗ គេរាល់គ្នាដូចជាធម្មតា ប៉ុន្តែខ្ញុំម្នាក់គឺប៉ះទង្គិចក្នុងចិត្តយ៉ាងខ្លាំងៗ ខ្ញុំមើលមុខខ្លួនប្រាណបុរសនោះ ដែលក្រាលដណ្តប់លាបលនដោយឈាមក្រហមពពុះៗ ដង្ហើមផ្អឹកៗ ខ្ញុំដូចជាភាន់ភាំងតាំងស្មារតីបន្តិច ព្រោះនឹកថាមិនគួរពួកខ្ញុំនេះសម្លាប់មនុស្សនេះដោយព្រៃផ្សៃដូច្នេះសោះៗ ហើយហេតុការណ៍ដែលធ្វើឲ្យខ្ញុំខ្លោចចិត្តរកពាក្យនិយាយពុំបាននោះ គឺពាក្យសម្តីចុងក្រោយរបស់មនុស្សនោះ ដែលនិយាយទាំងដកចង្កាមាន់មកកាន់ពួកខ្ញុំថាៈ*

- *លោកម្ចាស់... បើលោកម្ចាស់អស់អាណិត អស់យកអង្វរខ្ញុំបាទហើយ ក៏សន្មត់ជាកម្មផលរបស់ខ្ញុំបាទចុះ, ប៉ុន្តែខ្ញុំបាទសុំផ្តាំលោកម្ចាស់បន្តិចថា សុំលោកម្ចាស់មេត្តាយកដំណឹងខ្ញុំស្លាប់នេះទៅឲ្យម្តាយខ្ញុំបាទដឹងផង ហើយសុំលោកម្ចាស់ជួយលក់គ្រឿងកាត់សក់ និងអីវ៉ាន់តិចតួចនៅផ្ទះខ្ញុំបាទនោះយកប្រាក់ទៅឲ្យម្តាយខ្ញុំបាទផង រួចថាសុំឲ្យគាត់ទៅសុំសីលនៅវត្ត, ទាំងប្អូនស្រីខ្ញុំនោះក៏សុំឲ្យនាងទៅស៊ីឈ្នួលជួលព័ទ្ធគេចិញ្ចឹមម្តាយផង! សុំលោកមេត្តាជួយខ្ញុំបាទប៉ុណ្ណោះចុះ! ផ្តាំរួចក៏ដាច់ខ្យល់ល្មម ទើបគេអូសខ្មោចយកទៅកប់ដោយជាន់ដីពីលើដូចជាខ្មោចឆ្កែៗ ខ្ញុំគ្រវីក្បាលហួសចិត្តៗ ខ្ញុំនៅតែស្រមៃសម្លេងថ្លូអង្វរកររបស់បុរសនោះជាប់នឹងត្រចៀកៗ*

*ក្រោយមកពុំអស់ចិត្ត ខ្ញុំក៏បានស្នើមេៗ ខ្វះឲ្យចាត់ស៊ើបរឿងបុរសកាត់សក់នេះជាថ្មី ហើយឲ្យអ្នកស៊ើបនេះជាមនុស្សប្រាកដប្រជាផងៗ មួយសប្តាហ៍ក្រោយមក ស្រាប់តែបានរបាយការណ៍ពីអ្នកស៊ើបថ្មីនេះថា បុរសកាត់សក់ដែលពួកឥស្សរៈសម្លាប់នោះ គឺជាមនុស្សសុចរិតស្លូតត្រង់ទេ គ្នាពុំមែនជាគិញ្ចរបស់បារាំងទេៗ ដើមហេតុមកពីមានខ្មែរឥស្សរៈគ្នាឯងទៅស្រឡាញ់ប្អូនស្រីក្រមុំរបស់គ្នា គ្នាក៏ការពារប្អូនស្រីគ្នាឡើងៗ ឯងធ្វើអ្វីពុំបាន ក៏រករឿងចោទប្រកាន់គ្នាថាជាគិញ្ចបារាំងទៅៗ គិតទៅរឿងនេះមូលហេតុមកពីរឿងផ្ទាល់ខ្លួនទាំងស្រុង យកមនុស្សម្នាក់គ្មានទោសសោះ មកធ្វើទារុណកម្មយ៉ាងយង់ឃ្នង ហើយសម្លាប់គ្នាយ៉ាងព្រៃផ្សៃៗ*

*អំពើនេះនាំឲ្យខ្ញុំស្អប់បំផុត ហើយតែងតែរំឭកពួកមេៗ ជាសហការីនោះថា សូមឲ្យគ្នាយើងចៀសវាងរបបអយុត្តិធម៌បែបនេះខ្វះទៅ, ពួកគេតែងតបថា ណេហ្គីយ! គ្មាននរណាទៅពិចារណាទាន់ទេ ត្រូវតែឲ្យវាស្លាប់ខ្វះអ៊ីចឹងទៅចុះ! ខ្ញុំនិយាយថា បើអ៊ីចឹងវាមិនខុសនឹងគំនិតយើងដែលជាអ្នកស្រឡាញ់យុត្តិធម៌ទៅហើយ? បើអ៊ីចឹងយើងចង់រំដោះស្រុកទេសធ្វើអី បើយើងចេះកាន់អយុត្តិធម៌តាំងពីឥឡូវនេះទៅហើយនោះ? ពួកទាំងនោះខឹងខ្ញុំយ៉ាងខ្លាំងឥតនិយាយស្តីៗ នេះឯងជាចរិតខ្មែរឥស្សរៈជំនាន់នោះ ចូលចិត្តកាន់ផ្តាច់ការកាប់សម្លាប់គ្មានពិចារណាៗ ខ្ញុំម្តងៗ សឹងតែទ្រាំពុំបានចង់តែប្រកាសរំលាយបក្សនេះចេញៗ ប៉ុន្តែ ចេះតែខំទ្រាំបង្រួបបង្រួមតទៅទៀត ក្នុងគោលបំណងដែល ចង់កសាងស្រុកទេសឲ្យបានឯករាជ្យៗ ម្យ៉ាងទៀតរឿងអស់នោះខ្ញុំក៏សែនខ្មាសជាតិសៀមណាស់ មិនហ៊ានឲ្យសៀមដឹងរឿងបែបហ្នឹងទេៗ*

*ក្នុងរឿងបែបដូចគ្នានេះ មានមួយទៀត គឺរឿងលោក ចន្ទរង្សី ដែលសព្វថ្ងៃនេះជាអភិបាលខេត្តគិរីរម្យ និងជាមេបញ្ជាការកងពលតូចថ្មើរជើងលេខ ១៣ៗ លោក ចន្ទរង្សី កាលដែលនៅធ្វើជាឥស្សរៈ ប៊ិះតែនឹងរបេះជីវិតបាត់ហើយ ដោយសារតែការចោទប្រកាន់របស់មេៗៗ រឿងនោះគឺថា លោកចន្ទរង្សី*

ត្រូវពួកឥស្សរៈជាមេផ្ទាល់ចោទប្រកាន់ថា ជាគិញយកការណ៍ពីឥស្សរៈទៅឲ្យបារាំង រួចក៏ចាត់ឲ្យគ្នីគ្នាចងឃ្នុំមុខប្រុងនាំយកទៅសម្លាប់ជាសម្ងាត់ៗ ខ្ញុំបានដឹងដូច្នេះ ក៏ប្រញាប់ឃាត់ហើយឲ្យនាំលោកចន្ទរង្សីមកសាកសួរជាថ្មីៗ ពួកអស់នេះរិះគន់ខ្ញុំថាកាន់ជើងគ្រួសារឯង ព្រោះថាលោកចន្ទរង្សីត្រូវជាក្មួយជីដូនមួយខ្ញុំ ព្រោះខ្ញុំនិងព្រះអង្គម្ចាស់តូចជាឪពុកចន្ទរង្សីនោះ ត្រូវជាបងប្អូនជីដូនមួយខ្ញុំៗ ម្ដាយម្ចាស់តូច ឈ្មោះម៉ម-តាតជាប្រពន្ធហ្លួង នរោត្ដម ត្រូវជាម្ដាយធំខ្ញុំៗ តែខ្ញុំថា ខ្ញុំពុំមែនយល់ញាតិឲ្យឃ្លាតច្បាប់នោះទេ ខ្ញុំគ្រាន់តែសាកសួរឲ្យច្បាស់សិនទេតើ បើចន្ទរង្សីជាគិញបារាំងមែនមិនបាច់ឲ្យពួកនោះយកទៅសម្លាប់ឯណាឆ្ងាយទេ ឲ្យសម្លាប់ជាក់ស្ដែងនៅនឹងមុខខ្ញុំ នៅនឹងមុខអ្នកស្រុកតែម្ដងៗ ពួកនោះនៅស្ងៀមៗ ទើបខ្ញុំចាត់ឲ្យស៊ើបជាថ្មី ក៏ស្រាប់តែបានពត៌មានច្បាស់លាស់ថា ពុំមែនជារឿងផលប្រយោជន៍បក្សឥស្សរៈទេ គឺជារឿងផ្ទាល់ខ្លួនសុទ្ធសាធតែម្ដងៗ ហេតុនោះហើយ ដោយក្ដីក្ដៅក្រហាយរកធ្វើអ្វីចន្ទរង្សីពុំកើត មានតែផ្លូវចោទចន្ទរង្សីថាជាគិញបារាំង ទើបចោទដូច្នោះទៅចន្ទរង្សីស្លាប់ៗ

យើញទេ? មានរឿងប្រយោជន៍រួម ប្រយោជន៍បក្សឯណា សុទ្ធតែជារឿងផ្ទាល់ខ្លួន រឿងស្រីញីចេះតែមួលបង្កាច់ចោទប្រកាន់គ្នាយកគ្នាទៅសម្លាប់ធូរល្ហយទៅរួចៗ លោកចន្ទរង្សីកុំតែបានខ្ញុំឃាត់យកមកទុក ហើយចាត់ឲ្យស៊ើបរឿងទាន់ កុំអីត្រូវពួកត្មាតអស់នោះក្របែលបាត់ស្ងាត់តាំងពីនោះស្រេចៗ

ត្រង់ណេះហើយដែលខ្ញុំកត់សំគាល់ឃើញថា ពួកខ្មែរឥស្សរៈអត់មានច្បាប់ទាំងអស់ ឥតមានស៊ើបសួររកយុត្តិធម៌ទាំងអស់ ចោទប្រកាន់គ្នាពានគ្រោកពានត្រាំង អ្នកមានកម្លាំងសម្លាប់គ្នាអ្នកខ្សោយយ៉ាងស្រួលៗ

ក្រៅពីអំពើនេះ ខ្ញុំនៅមានរឿងមួយទៀតគួរឲ្យចំអក ដែលពួកឥស្សរៈគេចូលចិត្តនិយម ហើយដែលខ្ញុំបានឲ្យឈ្មោះថា ជំនឿហួសសម័យៗ

សូមជ្រាបថា សម័យនោះពួកឥស្សរៈមានជំនឿលើមន្តអាគម អូមអាម ខ្សែគាថា ខ្សែចង្កេះ កន្សែងយ័ន្ត, កុយ គជ, បៃកាច់... ជាដើមៗ

គ្រូមន្តអាគមសម័យនោះជាអាចារ្យ, ជាព្រះសង្ឃៗ អ្នកទាំងនោះតែងអះអាងថា គ្រឿងគ្រៅរបស់ខ្លួនស័ក្តិសិទ្ធិណាស់ សុទ្ធតែកាប់មិនមុត ដុតមិនឆេះ បាញ់មិនចេញៗ តើវាសុទ្ធតែខ្លាំងពូកែស័ក្តិសិទ្ធិពិតប្រាកដដូចពាក្យអះអាងទាំងនោះឬ? ខ្ញុំមានរឿងមួយមកជំរាបៈ ថ្ងៃមួយជាថ្ងៃបង្ហក់ប្រសិទ្ធីកងទ័ពៗ ពួកឥស្សរៈមួយក្រុមបាននិមន្តលោកសង្ឃមួយអង្គ ដែលជាគ្រូរបស់គេឲ្យមកប្រកបពិធីៗ ក្នុងពិធីនោះមានរៀបចំគ្រែអាសនៈ និងរៀបគ្រឿងសក្ការបូជា មើលទៅដូចជាគេរៀបធ្វើបុណ្យអភិសេកព្រះដូច្នោះ ពិធីនេះប្រព្រឹត្តទៅអស់ប្រាំពីរយប់ប្រាំពីរថ្ងៃទើបបានចប់ៗ កាលបើសូត្រមន្តអាគមប្រក់ព្រំរួចហើយ លោកសង្ឃនោះងាកមកមានពុទ្ធដីកានឹងឥស្សរៈថាៈ “អស់លោកទាំងអស់គ្នាមានគ្រឿងស័ក្តិសិទ្ធិពេញខ្លួនហើយ គ្រឿងគ្រៅទាំងនេះការពារអស់លោកបានហើយ ខ្មាំងបាញ់អស់លោកមិនចេញទេ ឬចេញដែរតែមិនត្រូវទេ បើមិនជឿ លមើលចុះ! ហើយបើអស់លោកមិនហ៊ានលគ្នាឯង លបាញ់អាត្មាវិញចុះ!

ហើយលោកនោះនិមន្តទៅឈរនៅចំកណ្ដាលទីប្រកបពិធីៗ

ខ្ញុំដែលមិនជឿរឿងនេះ ក៏បានឃាត់គ្នាឯងថាៈ «កុំអាលសិន, កុំអាលលផ្ដេសផ្ដាសទៅរកលោក លតែកន្ទែងអាសនៈសិនបានហើយ ព្រោះកន្ទែងនោះមានគ្រឿងគ្រៅយ័ន្តគាថាដែរ»ៗ ទើបខ្ញុំទាញកាំភ្លើង<ការបឹន>មួយដើមតម្រង់ទៅរកអាសនៈៗ ចុចកៃក្ទឹក! ឈឹង! មិនចេញគ្រាប់; ខ្ញុំនឹកថា

*អែយ៉ា! ខ្លាំងពូកែមែនទេដឹង? ប៉ុន្តែ ខ្ញុំលោក់គ្រាប់នោះចេញ ដាក់គ្រាប់ថ្មីចុចកែក្លឹក! ផាំង! ហុយផ្សែងទូលោម! ខ្ញុំលាន់មាត់ថាៈ នែ៎ ឃើញទេ? មិនស្រួលទេ កុំលេងផ្តាសឲ្យសោះ, គ្រាប់មុនស្អុយ គ្រាប់ក្រោយល្អបាញ់ចេញ, សុំកុំអាលថាបាញ់មិនចេញនោះ!*

*ប៉ុន្តែលោកគ្រូនោះ ប្រហែលជាខ្មាស់ខ្ញុំម៉េចមិនដឹង ឬក៏ជឿមន្តអាគមលោកស្មោះទៅហើយក៏មិនដឹង លោកស្រែកប្រាប់ទៅទាហានឥស្សរៈថាៈ «នែ៎អស់លោកកុំទៅលអីនឹងទីអាសនៈរបស់ឥតវិញ្ញាណនោះ, ឲ្យលមនុស្សវិញទើបដឹងប្រាកដ អស់លោកបាញ់មកអាត្មាចុះ! បើគ្រាប់ចេញមកត្រូវស្លាប់អាត្មា ក៏ស្លាប់ទៅចុះ!*

*ខ្ញុំក៏បានឃាត់លោកវិញថាៈ «សូមព្រះតេជគុណកុំឲ្យគេលលេងៗ នោះ របស់ស័ក្តិសិទ្ធិគេតែងតែមិនលទេ, ខ្ញុំករុណាយល់ថាគួរកុំសាកល្បងធ្វើអី! តាមពិតត្រូវតែពន្យល់កូនទាហានឲ្យចេះលុតក្រាបតាមរបៀបយុទ្ធសាស្រ្តបច្ចុប្បន្នទើបត្រូវ ពីព្រោះសម័យឥឡូវនេះ គ្រាប់កាំភ្លើងខុសពីសម័យដូនតាយើងឆ្ងាយណាស់ គ្រាប់កាំភ្លើងពីដើមប្រកពីមាត់ត្រែ យើងយកភ្លើងដុត ឬក៏ដុតពីគល់ទៅទើបផ្ទុះស្ទុះទៅមុខ, ឯឥឡូវ គ្រាប់ចេញមួយវិនាទីរាប់មិនអស់, ជានាម្តេចនឹងកើត? ឲ្យកូនទាហានរងម្តេចបាន?*

*លោកសង្ឃនោះធ្វើមិនឮ ហើយបែរជានិយាយនឹងទាហានឥស្សរៈថា, «អស់លោក វាស់ពីកន្ទែងអាត្មាឈរនេះទៅចំនួន ៧ កាំភ្លើងរួចបាញ់មកចុះ!»*

*ពីមុខកន្ទែងបួងសួងនោះមានគ្រែតូចមួយ លោកសង្ឃនោះគង់លើគ្រែនៅក្បែរនោះ សូត្រការ-នា រួចស្រែកថា ឲ្យបាញ់មកចុះ!*

*ទាហានម្នាក់ដែលកំពុងចង់ល្បង ក៏តាំងយកកាំភ្លើងទៅវាស់ពីកន្ទែងលោកឈរ ថយមកគ្រប់ចំនួន ៧ កាំភ្លើង ក៏តាំងតម្រង់កាំភ្លើងទៅលោកសង្ឃនោះ លោកសង្ឃនោះនៅធ្វើព្រងើយ ស្រាប់តែផាំង! ដួលគ្រឹប! លោកមានទៅស័ក្តិសិទ្ធឯណា លោកដកចង្កាមាន់ពីរបីដង្ហឹក ក៏ផុតខ្យល់ល្មម... ទាំងអស់គ្នាភ័យបះសក់ លែងប្រកបពិធីត្រឹមនោះ នាំគ្នាសែងខ្មោចលោកនោះ យកទៅកប់ចោលបំបាត់ដានខ្លាចសៀមដឹង វាចោទឯងថាយកលោកសង្ឃមកបាញ់លេង ឬដូច្នេះ ដូច្នោះៗ ខ្ញុំនិយាយថាៈ «ម៉េច, ឃើញទេ? ជំនឿចោលម្សៀត! រៀនលុតក្រាបលូនតាមពិធីច្បាំងមិនគិតទេ មកវល់នឹងរឿងអូមអាមឈរបាញ់ ឥឡូវម៉េចទៅ? រាល់គ្នាស្ងៀមៗ*

*ប៉ុន្តែនៅតែជដែល រឿងមន្តអាគមអូមអាមនោះៗ ដូចជាលោកមេឥស្សរៈម្នាក់ គាត់រើសបានអំ-បែងដៃកែវបុរាណមួយ ដែលបែកចេញពីតួកែវ គាត់ប្រកាន់ថាជាគជពិសេសណាស់ ខំយកមកស្រោបមាស ពាក់នៅកៗ ខ្ញុំប្រាប់គាត់ថាៈ ពុំមែនគជទេ, គឺជាបំណែកដៃកែវបុរាណទេ, គាត់នៅតែថាៈ ទេ, គជប្រាកដណាស់, គាត់រើសបានមក ដោយសារទេវតាបង្ហាញគាត់ឲ្យឃើញ! តាមពិតគឺជាបំណែកដៃកែវសោះ គួរឲ្យសើច!*

*សូមជម្រាបថា បានជាខ្ញុំស្គាល់ថាជាដៃកែវបុរាណ ត្បិតផ្ទះខ្ញុំធ្លាប់មានកែវធុននោះដែរៗ*

*ឃើញទេ, ជំនឿអកុសល, គ្មានពិចារណា មិនស្គាល់គជនោះយ៉ាងម៉េច, កែវយ៉ាងម៉េច ឮតែគេប្រាប់រាងវៅ តាំងជឿភ្លាម យកមកតំកើងភ្លាមៗ អ្នកដែលគេដឹង គេលបសើចមានទៅតិចអីៗ*

*ត្រង់ណោះ ខ្ញុំយល់ថា គំនិតពួកយើងនេះនៅទាបណាស់, នៅល្ងង់ណាស់ ស៊ើរតែថារកលេខដាក់ពុំបានៗ ខ្ញុំ, ខ្ញុំជឿដែរ គឺជឿព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ និងកម្មផល កុសល អកុសល ធ្វើល្អបានល្អធ្វើអាក្រក់បានអាក្រក់ៗ ឯថាទៅជឿលើមន្តអាគម ខ្សែចង្កេះខ្នាយតាន់ គជ កុយ បែកាច់ នាងពួនស្អីៗ*

នោះ មិនជឿទេ។ អំពើល្អ កុសលផលបុណ្យទេ ដែលនាំឲ្យខ្ញុំបានរួចពីស្លាប់រួចពីគ្រោះថ្នាក់ ពុំមែនមកពីគ្រឿងគ្រាមន្តអាគមអូមអាមនោះទេ។

ខ្ញុំ នេះ សូមអស់លោកអ្នកធំ អ្នកតូចដែលមានជំនឿយ៉ាងណា។ នោះ មេត្តាអភ័យទោសឲ្យផង បើយល់ថាយោបល់ខ្ញុំនេះមិនស្របនឹងអស់លោក។

*

*     *

# ៤

# ការវាយប្រហារក្រុងសៀមរាប

នៅពេលដែលក្រុមខ្មែរឥស្សរៈចេះតែទទួចច្រើនដងពេក ហើយដែលយើងមានអាវុធល្មម ហើយ ខ្ញុំ ប៊ុណ្ណចន្ទ-ម៉ុល ក៏បើកសម័យប្រជុំពិគ្រោះនឹងអស់លោកមេៗ ឯទៀតថា តើយើងចូរអនុញ្ញាតឲ្យគ្នាយើងទៅវាយបារាំងឬទេ? ហើយបើថាអនុញ្ញាត តើយើងទៅវាយកន្លែងណាជាមុន?

ក្រោយដែលបានពិភាក្សាគ្នាដ៏យូរមក អង្គប្រជុំក៏សម្រេចថាត្រូវអនុញ្ញាតឲ្យទៅវាយខេត្តសៀមរាប ហើយមុននឹងចូលវាយក្រុងសៀមរាប ត្រូវវាយសាលាស្រុកពួកឲ្យបានជាមុនសិន យកផ្លូវទៅក្រុងសៀមរាប។

ក្រោយសេចក្ដីសំរេចនេះ អ្នកមេចាត់ក៏បណ្ដោះកូនទ័ពឲ្យធ្វើដំណើរតាមផ្លូវព្រៃខ្ទះ តាមផ្លូវរថ-យន្តខ្ទះ ទៅកាន់ស្រុកសិរីសោភ័ណ ដែលកាលនោះថៃត្រួតត្រាជារបស់ថៃ ហៅស្រុកនោះថា ស៊ីសុផុន ហើយដែលរាជការថៃបានលើកស្រុកនោះជាខេត្ត ឲ្យឈ្មោះថា ខេត្តពិប៊ូនសុងក្រាម (ពិបុលសង្គ្រាម) ផង។

ការចេញដំណើរនោះ មិនតិចមិនតួច ដើរជិត ៥ ថ្ងៃទើបបានដល់ទីដៅជួបជុំគ្នា។ ជួបជុំគ្នាហើយ លោក ហែម-សាវាង និងលោក សារូ តាំងបញ្ជាឲ្យឈប់នៅក្នុងមណ្ឌលនៃសិរីសោភ័ណ ឆ្ងាយពីស្រុកក្រឡាញ់ប្រហែលជា ៥ គ.ម ស្ថាននោះជាព្រំប្រទល់ខ្មែរនឹងសៀមសម័យនោះ។

បានឈប់នៅត្រង់ភូមិវ៉ារិន លោក ហែម-សាវាង និងលោក សារូ តាំងយកផែនទីមកពិនិត្យឲ្យវាយសាលាស្រុកពួក និងទីក្រុងសៀមរាប។ មួយក្រុមឲ្យចាំវាយសាលាពួក មួយក្រុមទៀតមានគ្នាប្រហែល ២០០ នាក់ ឲ្យទៅកាន់ក្រុងសៀមរាប។

ក្រុមខ្មែរឥស្សរៈ មិនបានអត់គំនិតទេ គេចាត់គ្នីគ្នាឲ្យទៅស៊ើបចំនួនទាហានបារាំងនៅក្រុងសៀមរាប ដឹងទៀតថាមានបារាំងនៅក្រុងសៀមរាបប្រហែល ២៥ នាក់ជានាយទាហាន ដេកនៅនឹងសណ្ឋាគារខេត្ត។

លោក ហែម-សាវាង និងលោក សារូ បានឲ្យបញ្ជាទៅអ្នកដែលត្រូវទៅកាន់ក្រុងសៀមរាប ឲ្យធ្វើដំណើរទៅតាមផ្លូវបារាយណ៍ ហើយឲ្យចែកគ្នាជា ៥ ក្រុមសំរាប់វាយដូចទៅនេះ ៖

- ក្រុមទី ១ ឲ្យវាយសណ្ឋាគារខេត្ត (ដែលមានបារាំង)
- ក្រុមទី ២ ឲ្យវាយបន្ទាយទាហានជើងខ្មៅ
- ក្រុមទី ៣ ឲ្យវាយប៉ុស្តិ៍ខ្សែលួសផ្តាច់ការទាក់ទង
- ក្រុមទី ៤ ឲ្យវាយពន្ធនាគាររំដោះអ្នកទោស
- ក្រុមទី ៥ ឲ្យវាយផ្ទះគិញតម្រួតខេត្តនិងផ្ទះគយ

ក្រុមទាំងនេះ ត្រូវចាប់វាយមួយព្រឹបក្នុងពេលយប់ឲ្យព្រមគ្នាតែម្តង កុំឲ្យមួយមុនមួយក្រោយ នាំខ្សោយកម្លាំង។ ដើម្បីចៀសវាងកុំឲ្យគ្រោះថ្នាក់ តម្រូវឲ្យកូនពលទាំងអស់កុំបាញ់លេងផ្តេសផ្តាស ឥតសណ្តាប់ធ្នាប់។ ហៀបនឹងចូលវាយនោះទៀត ក៏កុំឲ្យបាញ់ប៉ាតណាប៉ាតណី ឲ្យស្តាប់បញ្ជាមេក្រុមទី ១ បើមេក្រុមទី១ បាញ់ សឹមបាញ់ព្រមគ្នាចូលលុកតែម្តងទៅ។

បានចាត់ទាំង ៥ ក្រុមស្រេចហើយ បញ្ជាក់ហើយបញ្ជាក់ទៀតថាលើកនេះជាដំបូងហើយ យើងឲ្យមានរបៀបរៀបរយហើយនឹងមានសេចក្តីក្លាហាន ទើបអាចនឹងមានជ័យជំនះ។ ទាំងអស់គ្នាសុទ្ធតែទទួលបាទៗ គោរពទាំងអស់ ព្រោះសុទ្ធតែចង់យកជោគជ័យ យកឈ្មោះល្បីរៀងខ្លួន។ បន្ទាប់ពីបានទទួលបញ្ជាច្បាស់លាស់ ពួកដែលមានបេសកម្មវាយសៀមរាបនោះ ក៏ធ្វើដំណើរមកតាមផ្លូវបារាយណ៍។ នៅពេលយប់ ទាំងអស់គ្នាលបចូលមកកាន់ក្រុងសៀមរាប ហើយបំបែកគ្នាជាក្រុមចាំប្រតិបត្តិការតាមចំណាត់របស់នាយចៅហ្វាយដែលបានឲ្យមកហើយនោះ។ បន្ទាប់ពីបញ្ជាបំបែកហើយ ក្រុមទីមួយបានចូលតាមផ្លូវអង្គរវត្តសន្សឹមៗ ទៅរកសណ្ឋាគារខេត្ត។

ពេលនោះម៉ោងពីរអាធ្រាត្រនៃថ្ងៃទី ៧ ខែសីហា ១៩៤៦ ទាំងអស់គ្នាលបបន្តិចម្តងៗ ចូលទៅកាន់សណ្ឋាគារខេត្ត នៅប្រមាណជាពីរគីឡូម៉ែត្រនឹងដល់ ក៏ឮសូរសន្ធឹករទេះអណ្តើក (Auto-blindé) កក្រើកដីចេញមកពីក្រុង គឺពួកទាហានយាមល្បាតរក្សាក្រុង។ រទេះអណ្តើកចេញមកដល់ថ្លោ ពេលនោះលោកមេក្រុមទីមួយបានបញ្ជាឲ្យកនយើងក្រាបចុះ ហាមមិនឲ្យបាញ់ដាច់ខាត។ ប៉ុន្តែមានឥស្សរៈម្នាក់ឈ្មោះ ម៉ែន ប្រហែលជាភ្លាក់ផ្អើលសម្ងាត់របស់បារាំងក៏មិនដឹង ព្រោះយើងធ្វេសប្រហែសមិនសង្កេតឲ្យជាក់លាក់ គាត់មានស្តាប់ឯណា រទេះអណ្តើកមកជិតក៏បាញ់ប្រាវទៅតែម្តង ដូចជាឲ្យសញ្ញាទៅរទេះអណ្តើកនោះ។ រទេះអណ្តើកនោះបាញ់ស្រោចមកវិញភ្លាម រួចត្រឡប់ចូលបន្ទាយវិញ ប្រកាសភាពអាសន្នមួយរំពេច។

ឯចំណែកទាំងបួនក្រុមទៀតដោយបានសញ្ញាប្រយុទ្ធហើយ ក៏បានវាយលុកទៅគ្រប់ទីដៅគគ្រឹកគគ្រេង។ ពួកទាហាននៅរក្សាក្រុងទាំងប៉ុន្មាន វង្វេងច្រលូលច្របល់របល់ជាខ្លាំង។ រីឯក្រុមទីមួយដែលជ្រុលដៃបាញ់នាំឲ្យរទេះអណ្តើកដឹងខ្លួនហើយបើកចូលទៅក្រុងវិញនោះ ក៏តាំងរត់តាមឡានទោះទៅទៀតរហូតដល់សណ្ឋាគារខេត្ត។ នេះកុំតែមានសេចក្តីក្លាហាន កុំអីពុំអាចចូលមកដល់បានទេ ព្រោះបារាំងបានបាញ់ទប់ខ្លាំងណាស់ មកពីវាដឹងខ្លួនមុនៗ ហើយនេះបើកុំតែមានមេកោយគ្រាន់បើ កុំអីក៏

វគាត់រគាយស្រេចទៅហើយ។ ពួកក្រុមទីមួយនេះបានចូលជិតដល់សណ្ឋាគារ ក៏តាំងបាញ់សំដៅទៅរកបន្ទប់បារាំង។ ចំណែកបារាំងនាយទាហានបារាំងមានតាំងពីសក្តិពីរទៅដល់សក្តិប្រាំ បានបាញ់មកវិញយ៉ាងខ្លាំងក្លា។ នៅមាត់ជណ្តើរ បារាំងបានទាញតុទូឃាំងផ្លូវមិនឲ្យយើងចូលបាន។ នាយក្រុមយើងស្រែកបញ្ជាឲ្យចូល តែចូលមិនចុះ គ្រាន់តែបានគប់គ្រាប់បែកទៅព្រោងព្រាត ធ្វើឲ្យបារាំងទីនោះដួលចុះខ្លះប៉ុណ្ណោះ ក្រៅពីនោះវាបាញ់ទប់យើងជាប់។

សូមអស់លោកអ្នកពិចារណាចុះថា ខ្មែរឥស្សរៈពេលនោះចេញដើរពីក្រឡាញ់តាំងពីព្រលប់មកដល់ក្រុងសៀមរាបម៉ោង ២ ទៅហើយ តើអស់កម្លាំងប៉ុណ្ណា។ ដែលមកដល់ហើយចាប់ធ្វើការវាយលុកភ្លាមនេះ គឺធ្វើដោយចិត្តចង់ធាប់តែម្តងគ្មានគិតមុខក្រោយអ្វីទេ។ នេះហើយជាចរិតរបស់យើងមួយបែបដែរ ដែលធ្វើការអ្វីមិនសូវសួងកម្លាំងអាត្មាឯងសោះ។

ឯចំណែកកន្ទែងទាំងបួនទៀត ដែលមានក្រុមទាំង ៤ ជាអ្នកប្រតិបត្តិការនោះ សឹងមានជោគជ័យដូចប្រាថ្នា គឺយើងវាយបន្ទាយជើងខ្មៅបាន បានកាំភ្លើង ៤០ ដើម នៅគុកក៏វាយធ្លាយ នៅកន្ទែងពីរទៀតក៏ធ្លាយ សរុបទៅបានអាវុធជិត ១០០ ដើម។ អាវុធទាំងនោះ នាំគ្នាម្នីម្នាលើកដាក់លើឡាន ប្រុងនាំចេញទៅតាមផ្លូវអង្គរវត្ត។ តែគួរឲ្យសើចទៅចុះ ពេលដែលដាក់អាវុធលើឡានហើយ តាំងប្រើគ្នាឯងឲ្យបើកឡាន, គ្មាននរណាម្នាក់ចេះសោះ តាំងនាំគ្នារើយកអាវុធនោះពីឡានមកវិញកាន់ម្នាក់មួយៗ ទៅវិញ សល់ប៉ុន្មានទុកលើឡានដដែល។ គិតទៅចំណាយពេលអត់ប្រយោជន៍ ព្រោះតែមិនបានសាកសួរគ្នាឲ្យដឹងមុន។ ណាមួយខ្លាចបារាំងមកសង្គ្រប់វិញផង មានទៅស្រួលអី មកចំណាយពេលលើកដាក់ដូច្នេះ។

ឯចំណែកក្រុមទី១ ដែលមិនអាចទម្លាយសណ្ឋាគារបាន មកពីម្យ៉ាងបារាំងនៅពីលើ ម្យ៉ាងទៀតយើងភ្លេចចាប់ក្អឹកពីរឿងសូរសព្ទ ដែលចេញពីខ្លួនយើងនាំឲ្យបារាំងដឹងបាន ហើយបាញ់តម្រង់មក។ ពេលនោះយប់ងងឹតមែនហើយ តែដល់បារាំងឮសូររ៉ែករ៉ាករបស់ដែលយើងស្ពាយ វាដឹងវាបាញ់ប្រាវមកតែម្តង ធ្វើឲ្យយើងរុលទៅមុខពុំរួចសោះ។ សូររ៉ែករ៉ាកនោះ គឺសូរស្ពាបព្រានិងថ្នាំងដែលយើងស្ពាយនោះទង្គិចគ្នា។ ដើរធម្មតា ឥតទង្គិចគ្នាឮសូរអ្វីទេ លុះមកដល់រត់ ក៏ទង្គិចគ្នារ៉ាករ៉ាកៗ តែម្តង។

យើងរត់ទៅណាក៏ឮសូរ ដូចជាសញ្ញាឲ្យបារាំងដឹងតែម្តង ដូច្នេះទោះបីបាញ់យើងមិនត្រូវក្តី ក៏បាញ់ស្រោចមកដែរ ប៉ិះខ្លួន។ ហេតុនេះទើបយើងចូលពុំបាន។

ការនេះជាបទរៀនមួយដែរ ថាមុននឹងធ្វើអ្វីៗ ត្រូវតែគិតឲ្យបានល្អិតល្អន់សឹមធ្វើ។ ចំណែកក្រុមទី ៥ ដែលបានទៅវាយផ្ទះគិញនិងផ្ទះគយនោះ បានចូលទៅបាញ់មេគយជាតិបារាំងម្នាក់ស្លាប់នៅទីនោះតែម្តង មេគយជាតិបារាំងមានប្រពន្ធជាតិលាវ។

ពេលនោះម៉ោង ៦ ព្រឹកល្មម ពួកឥស្សរៈយើងខ្លះកំពុងត្រេងត្រាងដើររើសកាំភ្លើងដែលទាហានបារាំងទុកចោល ស្រាប់តែក្រឡេកទៅភូមិជាយក្រុង ក៏ឃើញទ័ពបារាំងកំពុងសន្ធុញចូលមកវិញ។ ទើបដឹងថា អែយ៉ា ពួកអានេះគៀសខ្លួនពីយប់ ទៅក្រៅបណ្តោយឲ្យឯងអុកឡុកបន្ទាយវាចុះ វាចាំក្រសោបឯងពីក្រៅមកវិញទេតើ! មិនកើតទេ! កុំនៅត្រេងត្រាងដល់ណាទៀត។ មេក្រុមទាំងអស់ ស្រែកបញ្ជាឲ្យថយតាមក្បួនយុទ្ធសាស្ត្រឆ្ពោះទៅទិសខាងជើង តាមផ្លូវអង្គរវត្ត។ ទាំងអស់គ្នាថយទៅគ្មានបង្អង់ ពួកទាហានបារាំង គឺបាញ់ព្រោងព្រាតមក រួចដេញតាមយើងរហូតនគរវត្ត។ ទាំងអស់គ្នាបំបែកគ្នាបំបាត់ដានរួចក៏តាំងធ្វើដំណើរឆ្ពោះទៅកំពង់ថ្កូវតែម្តង។

*ការវាយក្រុងសៀមរាបនេះ មិនសន្មតថាជោគជ័យឬបរាជ័យអ្វីទេ ប៉ុន្តែជាស្រមោលតស៊ូមួយដែលធ្វើឲ្យពួកអាណានិគមបារាំង ភ័យផ្អើមមាត់មួយគ្រាដ៏ធំទៅដែរ ហើយវាអាចបណ្តុះទឹកចិត្តខ្មែរឯទៀតឲ្យក្រោកលើកឡើងផង។*

## ពត៌មានក្រោយការវាយប្រហារ

*មានអំពើគួរឲ្យឈឺចាប់មួយដែលគួរនាំយកមកជម្រាប។*

*ពួកឥស្សរៈមុននឹងដកថយចេញពីលានប្រយុទ្ធបាននាំគ្នានាំអ្នករបួសស្រាលៗ មកតាម ឯអ្នករបួសធ្ងន់យកមកពុំរួច ក៏នាំគ្នាគ្រាហ៍យកទៅដាក់នៅនឹងមុខគិលានដ្ឋានក្រុង។*

*ដោយគិតឃើញថា: ពួកបុគ្គលិកពេទ្យគង់មានចិត្តធម៌ជួយព្យាបាលដែរ។ ប៉ុន្តែមានដូចយើងគិតឯណា? ក្រោយដែលបានចូលមកកាន់កាប់ក្រុងវិញ ភ្លាមនោះពួកបារាំងបានបញ្ជាឲ្យលើកឥស្សរៈអ្នករបួសទាំងប៉ុន្មានដាក់លើឡានទាហានដឹកចេញពីទីក្រុង ដល់ព្រៃហើយក៏ឲ្យឈប់ រួចលើកអ្នករបួសទាំងនោះបោះមកដីបាញ់ចោលមួយម្តងៗ សម្លាប់ទាំងអស់[១]។ គិតទៅជាអំពើព្រៃផ្សៃមែនទែន។ តាមធម្មតាច្បាប់សកល រឿងសង្គ្រាមគេមិនដែលសម្លាប់ឈ្លើយសង្គ្រាមទេ ហើយឯណេះបារាំងសម្លាប់ខ្មែរឥស្សរៈជាឈ្លើយ ដែលគ្មានអាវុធនៅដៃថែមទាំងមានរបួសទៀតផង។*

*ចំណែកនៅសាលាស្រុកពួកឯណោះ ក្រោយការវាយប្រហាររបស់ពួកឥស្សរៈ ពួកបារាំងក៏ចាប់ពួកបុគ្គលិកសិក្សាមានលោក សំអឿ ជាអ្នកកីឡាបាល់ទាត់ជើងឯកខាងចាំទីជំនាន់នោះវាយស្លាប់និងភ្នាក់ងារសាលាស្រុកយកទៅចងវាយសម្លាប់អស់ជាច្រើនគ្នា ដោយវាចោទថាពួកទាំងនេះចូលដៃនឹងពួកឥស្សរៈ ក្នុងការវាយប្រហារនេះ។ ពីព្រោះកាលពីក្បាលល្ងាច ពួកបុគ្គលិកសិក្សានិងបុគ្គលិកសាលាស្រុកច្រើនគ្នា ជួបជុំគ្នាស៊ីលៀង។ ដល់កណ្តាលអាធ្រាត្រ ពួកឥស្សរៈក៏វាយប្រាវមកតែម្តង បារាំងវាចោទថាពួកនេះឲ្យដៃទៅពួកឥស្សរៈ[២] តាមពិតពុំមានសោះ ប៉ុន្តែបារាំងដែលវារកតែឱកាសធ្វើបាបខ្មែរ ក៏ចេះតែចោទយ៉ាងហ្នឹងទៅ។*

---

(១) *រឿងនេះដឹងដោយសារលោក ស-សុង រដ្ឋមន្ត្រីក្រសួងកសិកម្ម, កាលណោះលោកជាកូនសិស្សសាលាខេត្តសៀមរាប ។*

(២) *ដឹងរឿងនេះដោយសារលោក ណុប- ធុំ តំណាងរាស្ត្រសព្វថ្ងៃ, កាលណោះលោកជាគ្រូបង្រៀននៅខេត្តសៀមរាប។*

# ៥

# ការបំបែកគ្នានៃពួកឥស្សរៈ

*បន្ទាប់ពីការដកថយអំពីក្រុងសៀមរាប, ពួកឥស្សរៈបានធ្វើដំណើរមកតាមផ្លូវកំពង់ថ្កូវ ហើយមកឈប់នៅជួរភ្នំដងរែក។*

*ដើម្បីឲ្យបានរស់ស្រួល ពួកឥស្សរៈបានបំបែកគ្នាជាបីក្រុម។ ក្រុមទី ១ មាន ដាប-ឈួន ជាមេ, ក្រុមទី ២ មានលោក ហែម-សាវាង និងលោក សារូ ជាមេ, ក្រុមទី ៣ មានឈ្មោះដែលខ្ញុំភ្លេចឈ្មោះ ក្រុមនេះបានមកនៅនឹងស្វាយចេក។*

*ចំនួនទ័ពកាលណោះ មួយក្រុមៗ មាន ៣៥ ឬ ៤០ ឬ ៥០ នាក់។ មធ្យោបាយចិញ្ចឹមកងទ័ព ជាភារៈនៅលើមេក្រុមដែលកាលណោះគេប្រើកូនចៅរបស់គេ ឲ្យដើររៃអង្គាសអង្ករត្រីសាច់ជាស្បៀងអំពីប្រជារាស្ត្រ។ ដោយតំបន់នោះជាតំបន់ពុំសូវមានប្រជាជនច្រើន ការរៃអង្គាសប្រមែប្រមូលស្បៀងសម្រាប់ចិញ្ចឹមជីវិតនោះ បានដោយតិចតួចស្ដួចស្ដើងណាស់។*

*ចំណែកខ្ញុំ ប៊ុណ្ណចន្ទ-ម៉ុល មានមួយក្រុមផ្សេង មានចំនួនតិចគ្នាទេ បានហួសទៅនៅបាងកកតែម្ដង ជាមួយមាខ្ញុំ ប៉ុក-គុណ ហៅ ត្រឡាច ដែលគាត់មានផ្ទះមួយទៀតនៅក្រុងបាងកក នាផ្លូវប្រែកសែងចន្ទ តំបន់ព្រះខ្នង។ បានជាមាខ្ញុំនិងខ្ញុំនាំគ្នាបោលបាត់ដំបងនិងអន្លង់វិល ពីព្រោះកាលណោះគឺជាពេលដែលរាជការបារាំង-ខ្មែរ បានទារយកខេត្របាត់ដំបងពីសៀមបានមកវិញហើយ ហើយកាន់កាប់ខេត្រនេះ ដែលធ្វើឲ្យពួកខ្ញុំពុំអាចស្ថិតនៅកើត។*

*ត្រង់ណោះ ខ្ញុំសូមបើកវង់ក្រចក ជម្រាបអស់លោកអ្នកបំបាត់ការសង្ស័យបន្តិចថា ហេតុអ្វីបានជាខ្ញុំពុំព្រមចូលមករួបរួមនិងរដ្ឋាភិបាលបារាំង-ខ្មែរវិញ បើខេត្របាត់ដំបងត្រូវបានមកខ្មែរវិញហើយនោះ? បើខ្ញុំស្រឡាញ់ជាតិ កាលឃើញស្រុកទេសបានទាមទារខេត្រពីអ្នកក្បែរខាងបានហើយ គួរតែសប្បាយចិត្ត ហើយចូលមករួបរួមនឹងរដ្ឋាភិបាលវិញ។ នេះមិនដូច្នោះ បែរជាបោលចូលទៅស្រុកដែល*

ជាសត្រូវរបស់ជាតិទៅវិញគ្មុយ! តើខ្ញុំមិនសប្បាយចិត្តនឹងខេត្តបាត់ដំបងត្រូវបានមកខ្មែរឬ? បើមិនមែនទេ តើខ្ញុំនៅតែស្អប់បារាំងដែលគ្នាទំទាមទារបាត់ដំបងឲ្យខ្មែរវិញឬ?

ត្រង់ណេះ ខ្ញុំសូមជម្រាបឲ្យច្បាស់លាស់ដូចតទៅៈ

ទី ១- ខ្មែរឥស្សរៈ បានចិញ្ចឹមចិត្តគិតឃើញថា ប្រទេសខ្មែរទាំងមូលពុំទាន់បានឯករាជ្យនៅឡើយទេ ត្រូវតែតស៊ូរំដោះស្រុកទាំងមូលឲ្យផុតពីនឹមបារាំងសែស, ឯរឿងខេត្តបាត់ដំបងនោះ ក៏ជាកម្មវត្ថុនៃការទាមទាររបស់ខ្មែរឥស្សរៈដែរ គឺថា ខ្មែរឥស្សរៈតាំងចិត្តថា នឹងទាមទារខែត្រនេះពីសៀមដែរនៅថ្ងៃណាមួយ។ ឥឡូវបើរាជការបារាំង-ខ្មែរទាមទារខែត្រនេះបានមកមុន ក៏ពួកឥស្សរៈជួយអរដែរ ប៉ុន្តែមិនសូវសប្បាយចិត្តត្រង់ដែលថាខែត្រនេះ វាទៅនៅក្នុងដៃបារាំងដដែល វាពុំនៅលើដៃខ្មែរសោះ។

ទី ២- រឿងផ្ទាល់ខ្លួន, រូបខ្ញុំពុំអាចចូលស្រុកខ្មែរកើតទេ ត្បិតខ្ញុំចេញពីគុកកោះត្រឡាចនោះ មិនទាន់ដល់ឆ្នាំចេញឯណា? ខ្ញុំចេញពីគុកនោះ មួយឆ្នាំមុនសាលក្រមសម្រេចឲ្យចេញ។ ដូច្នេះខ្ញុំនៅជំពាក់គុកកោះត្រឡាច ១ ឆ្នាំទៀតឯណោះ។ អ្នកដាក់គុកខ្ញុំគឺបារាំង អ្នកដោះខ្ញុំគឺជប៉ុន[១]។ ឥឡូវពួកបារាំងចាប់ទាំងលោក ស៊ឺង-ង៉ុកថាញ់ ជាមេបក្សរបស់ខ្ញុំទៅហើយ បើខ្ញុំចូលទៅស្រុកវិញ តើបារាំងវាប្រណីខ្ញុំឬ? ប្រាកដណាស់ វាមុខជាបញ្ជូនខ្ញុំឲ្យទៅកោះត្រឡាចជាថ្មី ឬក៏យ៉ាងណាយ៉ាងណីទៀតមិនខាន។

ទី ៣- ខ្មែរឥស្សរៈ កំពុងមានលទ្ធភាព នឹងពង្រីកឥទ្ធិពល ពីព្រោះពេលនោះចលនាតស៊ូរំដោះស្រុករបស់យួន ក៏បានផុសផុលឡើងដែរ ដែលយើងហៅថា ក្រុមវៀតមិញនៅកាលនេះ។ ខ្មែរតស៊ូហៅខ្មែរឥស្សរៈ ក៏បានមានទំនាក់ទំនងជាមួយពួកនោះបន្តិចៗ ដែរ ហើយជាហេតុនាំឲ្យមានកម្លាំងនិងសេចក្តីសង្ឃឹមថាឈ្នះបារាំងទៅអនាគត។

នេះជាចម្លើយរបស់ខ្ញុំ ដោះចំពោះអាថិប្រស្នាដូចដែលបានចោទមកហើយ។

ពួកខ្ញុំ ប៊ុណ្ណចន្ទ-ម៉ុល ដែលនៅក្រុងបាងកក មានភារៈទិញអាវុធយុទ្ធភ័ណ្ឌមកចែកក្រុមឥស្សរៈនៅដងរែក និងនៅស្វាយចេក។ ប្រាក់កាសទិញនេះ គឺបានមកពីពួកក្រុមទាំងបីនោះ ដែលគេបានរៃអង្គាសពីអ្នកស្រុកដែលស្ម័គ្រចិត្ត។ ក្រុមទាំងបីនេះ ជួនកាលគេរកផ្លូវទិញអាវុធនេះដោយខ្លួនគេដែរ តាមខេត្តបាត់ដំបង និងសុរិន្ទ។ កាំភ្លើងកាលណោះមានការ៉ាប៊ីន មីត្រៃយើ និងគ្រាប់បែក។ ប៉ុន្តែការទិញអាវុធពេលនោះ បានដោយស្តួចស្តើងណាស់ ដោយរៃអង្គាសប្រាក់កាសពុំសូវបាន។

ចំពោះអាវុធដែលទិញបាន នាំយកមកចែកត្រង់អារញ្ញនិងសុរិន្ទ ដោយរថយន្តជំរត់ឈ្នួល (ដែលស្ម័គ្រជួយដឹកទទេឥតយកឈ្នួល)។ ឯចំណែកខាងសុរិន្ទ ដឹកនាំដោយរថភ្លើងដោយលួចលាក់។ មានពេលខ្លះដាក់ក្នុងការុងអង្ករ, មូរកប់ក្នុងរមូរកន្ទេល ។ល។ តាមរទេះភ្លើងនេះមិនសូវគ្រោះថ្នាក់ទេ ប៉ុន្តែចំពោះផ្លូវអារញ្ញវិញពិបាកណាស់ ដោយសៀមប្រយ័ត្ន មិនឲ្យនាំកាំភ្លើងចេញ។

សូមជម្រាបថា គំនិតគេ គឺនៅតែគំនិតមិនត្រង់នឹងយើងដដែល ពីមុនថាជួយ ក្រោយមកឃើញយើងបែបលូតលាស់ខាងបដិវត្តន៍ ក៏តាំងប្រយ័ត្នប្រយែងចំពោះយើងទៅវិញ។ អ្នករកស៊ីលក់អាវុធឲ្យយើងនោះក៏ដូច្នោះដែរ គេស្មោះនឹងរាជការគេ ជាងស្រឡាញ់ប្រាក់កាសរបស់យើងទៅទៀត ជួនកាលគេលក់អាវុធឲ្យយើងបានច្រើនហើយ ហើយដឹងថាយើងល្មមដឹកចេញនៅថ្ងៃណានោះ គេខ្សឹបឲ្យការណ៍ទៅអ្នករាជការគេស្រេច លុះយើងដឹកអាវុធចេញ តម្រួតគេក៏មកចាប់ឃាត់ឬក៏ធាធៅរំខានយើង

---

(១) សូមមេត្តាមើលរឿងគុកនយោបាយ។

ដោយប្រការផ្សេងទៀត។ នេះជាគំនិតគេដើរលើយើង។ យើងដឹង។ ហេតុនេះទើបយើងចេះតែប្រយ័ត្ន ហើយប្រើឧបាយបង្វែងដាន ឬក៏និយាយបន្លុសពេលវេលាដែលត្រូវនាំចេញប្រាប់ទៅពួកនោះវិញ ទើបបានស្រួលក្នុងការរត់អាវុធយកមកឲ្យគ្នាឯងឯណេះ។ ម្យ៉ាងទៀតយើងសុំប្លាប់ទិញអាវុធពីអាជ្ញាធរផង ក៏គង់មានការភ័យភិតក្នុងការដឹកនាំចេញដែរ។ ខ្ញុំមានរឿងមួយជម្រាបថាៈ ថ្ងៃមួយវេលាម៉ោង ៤ ល្ងាច ក្រុមខ្ញុំមាន ៨ នាក់ បានទិញអាវុធគ្រប់ធុនទៅបាងកកដាក់លើរថយន្តប្រុងនាំចេញមកអារញ្ញ។ ពេលនោះ ស្រាប់តែឃើញកងអាវុធហត្ថសៀមប្រហែល ១០០ នាក់ ប្រកបដោយអាវុធគ្រប់ដៃស្ទុះស្រមកឡោមព័ទ្ធឡានដែលរៀបចេញនោះ។ មេបញ្ជាការគេស្រែកមកថាៈ នៅឲ្យស្ងៀម! លើកដៃឡើងលើ, កុំកម្រើក! តែកម្រើក, បាញ់! ពេលនោះមាខ្ញុំពុំនៅផង ខ្ញុំភ័យយ៉ាងខ្លាំង យើយ៉ាងណាទៅអ៊ីចេះ? ខ្ញុំក៏ឲ្យគ្នាខ្ញុំនៅស្ងៀម! ក្រោយមក គេបញ្ជាឲ្យយើងរើអាវុធយុទ្ធភ័ណ្ឌចុះមកដីវិញ ឲ្យគេកត់ចំនួន។ ឆ្លៀតពេលនោះ ខ្ញុំប្រើក្មួយខ្ញុំម្នាក់ឲ្យរត់ទៅតាមមា ប៉ុក-គុណ ដើម្បីមកសម្រួលការណ៍នេះ។ នៅចន្លោះពេលនោះមានខ្មែរម្នាក់ឈ្មោះ អាចារ្យហេង ចេះសៀមជ្រៅជ្រះ ទៅនិយាយការណ៍និងនាយអាវុធហត្ថសៀមបញ្ជាក់ថា អាវុធទាំងនេះ គឺរាជការថៃអនុញ្ញាតឲ្យទិញដែរហើយ។ នាយអាវុធហត្ថនោះ ដឹងដូច្នោះរកធាតុមិនកើត ក៏ឲ្យគ្នីគ្នាគេថយទៅវិញ ប៉ុន្តែគេទុកឲ្យទាហានពីរនាក់នៅយាមអាវុធនោះសិន។

លុះស្អែកឡើងម៉ោង ១១ ទើបមាខ្ញុំ ប៉ុក-គុណ មកប្រាប់ថាៈ ឲ្យយកចេញទៅចុះគេអនុញ្ញាតហើយ! ទើបយើងនាំគ្នានាំអាវុធនោះចេញមក។ មកដល់អារញ្ញម៉ោង ៤ ភ្លឺ។ សម្រាកចាំព្រឹក លុះម៉ោង ៨ ចេញពីអារញ្ញមកទៀត តាមផ្លូវសិរីសោភ័ណ។ ម៉ោង ១២ ថ្ងៃត្រង់ទើបដល់កំពង់ថ្កូវ។ ទាំងអស់គ្នាឈប់សម្រាកនៅវត្តមួយឈ្មោះវត្តបាត្រ។ គឺវត្តនោះហើយ ជាទីប្រជុំហាត់នៃក្រុមខ្មែរឥស្សរៈនិងជាទីបញ្ជាការ ចាត់បញ្ជូនស្បៀងនិងអាវុធយុទ្ធភ័ណ្ឌទៅឲ្យពួកឯទៀតទាំងបីក្រុម។

*    *

*

# ៦

# ការបាក់បែកគ្នានៃពួកឥស្សរៈ

ពួកឥស្សរៈក្រុមនិមួយៗ សុទ្ធតែមានគំនិតចង់ល្បីឈ្មោះតែម្នាក់ឯង។ ពួកមេៗ សុទ្ធតែចង់បានធំ គ្មាននិយមគ្នាទៅវិញទៅមកទេ។ ក្រុមនិមួយៗ ហាក់ដូចជានៅដាច់ដោយឡែកពីគ្នា គ្មានទាក់ទងគ្នាសោះ។ មិនតែប៉ុណ្ណោះ ដោយចង់មានឈ្មោះតែឯងពេក ក្រុមខ្លះបានព្យាយាមបំបាត់ក្រុមឯទៀតឲ្យសាបសូន្យទៅផង។ ឈ្មោះដាប-ឈួនមានជ័យជំនះលើគេក្នុងរឿងនេះ។ ដាប-ឈួនបានល្បួងហៅមេក្រុមឯទៀត ឲ្យទៅកាន់កន្លែងមួយនៅខ្នងភ្នំដងរែកដែលគាត់បានណាត់ទុក ហើយដែលគេឯទៀតពុំធ្លាប់ដឹងកន្ទុកកន្ទៀត គាត់បានចាត់ការសម្លាប់មេក្រុមឯទៀតយ៉ាងស្ងាត់ៗ។ ឈ្មោះលោក ហែម-សាវ៉ាង និងលោក សារូ ដែលធ្លាប់ល្បីឈ្មោះបោះសម្លេងក្នុងវេលានោះ ក៏ត្រូវចាញ់កលដោយដាប-ឈួនបញ្ឆោតនាំយកមកសម្លាប់ដែរ។ កលនោះដូចម្ដេច? គឺដាប-ឈួនធ្វើជាសេចក្ដីអញ្ជើញហៅ ហែម-សាវ៉ាង និង សារូ ឲ្យមកប្រជុំជំនុំការ។ ហែម-សាវ៉ាង និង សារូ ទុកចិត្ត ក៏ធ្វើដំណើរមកដោយមិនដឹងខ្លួន។ ដាប-ឈួនឲ្យគ្នាគាត់ស្ទាក់នៅកណ្ដាលផ្លូវព្រៃជាស្រេច។ អ្នកទាំងពីរមកដល់ ក៏ត្រូវគេលបបាញ់ចោលទៅ។ បក្សពួកកូនចៅឈ្មោះ ហែម-សាវ៉ាង និង សារូ គ្មានមេកោយក៏រលាយទៅ ហើយខ្លះបែរជាចូលនឹងដាប-ឈួន ខ្លះទៀតបែរជាចូលនឹងក្រុមដទៃដែលមិនទាន់រលាយ។

មកដល់ត្រឹមណោះ ខ្ញុំដែលជាអ្នកបង្កើតនិងជាអ្នកមានគំនិតបង្រួបបង្រួមនោះ ក៏អស់កម្លាំងអស់សមត្ថភាពត្រឹមណោះ រួចក៏តាំងបែរជាមកប្រយ័ត្នអាត្មាឯងវិញ ខ្លាចពួកទាំងនោះធ្វើឧបឃាតតាមវិធីនេះនោះ ដែលខ្ញុំពុំអាចនឹងដឹងបាន។ តាំងពីបាត់ ហែម-សាវ៉ាង និង សារូ មក, ដាប-ឈួន លែងទាក់ទងនឹងខ្ញុំ ចង់សម្លាប់ខ្ញុំទៅទៀត។ ខ្ញុំក៏ពុំមានតូចចិត្តអ្វីចំពោះគាត់ដែរ ប៉ុន្តែខ្ញុំមកនៅនឹកស្ដាយចំពោះអំពើឃោឃៅរបស់គាត់ ដែលមិនគួរជានឹងប្រព្រឹត្តទៅលើក្រុមឯទៀត នាំឲ្យរលាយអស់នោះសោះ។ ដាប-ឈួន មិននឹកឃើញថា ដល់អាត្មាអញសម្លាប់មិត្តរបស់អាត្មាអញអស់ទៅនោះ តើនឹងនាំឲ្យអាត្មាអញមានកម្លាំងខ្លាំងឡើងបានទេ? នេះហើយចរិតខ្មែរ! គិតអ្វីចង់តែធំមិនគិតឲ្យបានវែងឆ្ងាយ។ បានធំហើយ តើដំណើរការតទៅបានស្រួលទេ។ កុំតាំងចិត្តចង់តែធំ, កុំតាំងចិត្តក្រុមអញធំ ខ្លួនអញធំទើប

ធ្វើការកើតនោះ មិនប្រសើរទេ។ បើចេះណែនាំគ្នាឲ្យរួបរួមគ្នា កិច្ចការអាចដើរទៅបានស្រួលជាជាងបែកបាក់គ្នា។ នេះគឺគំនិតខ្ញុំ ប៊ុណ្ណចន្ទ-ម៉ុល។

ប៉ុន្តែ ដាប-ឈួន ជាជនស្រេកឈាម ជាជនចង់ធំប៉ុនស្តេច គាត់គ្មានគិតពីអ្វីសោះឡើយ សូម្បីមិត្តសម្លាញ់គាត់ ក៏គាត់សម្លាប់ចោលដែរ។ គិតមើលលោកកៅ-តក់ ជាមេឥស្សរៈមានឈ្មោះល្បីរបស់លោក សឺង-ង៉ុកថាញ់ ប្រមុខចលនាខ្មែរសេរី ហើយជាមិត្តចិត្តមួយនឹង ដាប-ឈួន ផង ក៏ត្រូវ ដាប-ឈួន ចាត់ការឲ្យបាញ់សម្លាប់ចោលទៅដែរ (នៅថ្ងៃ ១១ កុម្ភៈ ១៩៥៥ នៅពួកខេត្តសៀមរាប)។

ខ្ញុំសូមរំលឹករឿងឈ្មោះ កៅ-តក់ នេះបន្តិច ព្រោះឈ្មោះនេះជាអ្នកបដិវត្តន៍តស៊ូ នៅក្នុងប្រវត្តិតស៊ូគួរសរសើរម្នាក់ដែរ។

លោក កៅ-តក់ ជាមេឥស្សរៈខ្មែរសេរីដ៏សំខាន់នៅតំបន់សៀមរាប។ គាត់ជាអ្នកប្រឆាំងនឹងពួកអាណានិគមនិយមយ៉ាងល្បីល្បាញ។ នៅឆ្នាំ ១៩៥៤ ក្នុងពេលដែលសន្និសីទហ្សឺណែវតម្រូវឲ្យខ្មែរគ្រប់និន្នាការទាំងអស់នៅក្នុងព្រៃទម្លាក់អាវុធរួបរួមនឹងរដ្ឋាភិបាល, ពេលដែលលោក សឺង-ង៉ុកថាញ់ ដាក់អាវុធដែរ តាមសេចក្តីសម្រេចនោះ, លោក កៅ-តក់ ក៏បានដាក់អាវុធចុះ សុខចិត្តរួបរួមនឹងរដ្ឋាភិបាល។ ពេលជាមួយនោះ ឈ្មោះ ចន្ទ-សូវ៉ាត ជាមេឥស្សរៈខ្លាំងពូកែដូចគ្នា ក៏បានដាក់អាវុធរួបរួមដែរ ព្រមទាំងអស់លោកអ្នកតស៊ូនៅក្នុងព្រៃច្រើនគ្នាទៀត ក៏បានមករួបរួមនឹងរដ្ឋាភិបាលដែរ។

ឯលោក កៅ-តក់ ពេលដែលគាត់មករួបរួមក្នុងសង្គមជាតិវិញនេះ គ្មានអ្វីនឹងប្រកបរបរចិញ្ចឹមជីវិត ក៏ស្នើសុំខ្ចីប្រាក់របស់ ដាប-ឈួន ជាដើមទុនខ្លះ នឹងប្រកបរបរ ព្រោះអាងថាដាប-ឈួនជាមិត្តចិត្តមួយ។ ដាប-ឈួនក៏ផ្តាំថា ឲ្យចូលមកយកលុយចុះ គាត់ទុកឲ្យនៅម្តុំពួក ទើបគាត់ចាត់គ្នាជាស្រេចឲ្យចាំចាប់ កៅ-តក់។ លោក កៅ-តក់ មិនបានដឹងខ្លួនក៏មក មកដល់ប្រហែល ១០ គ.ម. នឹងដល់ស្រុកពួក ក៏ស្រាប់តែត្រូវពួកដាប-ឈួនស្ទុះទៅឱបមួយរំពេច។ យល់ថាចាញ់កលដាប-ឈួន លោក កៅ-តក់ ក៏បំរះលោតទាត់ធាក់ ខាំកកេរពួកអ្នកចងយ៉ាងពេញទំហឹង។ ប្រសិនបើមានតែកាំភ្លើងខ្លីមួយឬមានកាំបិតស្នៀត ប្រហែលជាធ្វើអ្វីគាត់ពុំបានទេ តែគាត់គ្មានយកអាវុធអ្វីមកកំដរខ្លួនសោះ ដោយអាងតែថាដាប-ឈួនជាមិត្ត មិនដឹងជាមិត្តសម្លាប់មិត្តអី ក៏ត្រូវពួកគ្នាតរបស់ដាប-ឈួនអូសទាញគាត់យកទៅបាញ់ចោលទៅ! គួរឈឺចាប់។ ពេលល្ងាចទើបគ្រួសាររបស់លោក កៅ-តក់ មកលបយកសាកសពលោក កៅ-តក់ យកទៅបញ្ចុះនៅវត្តភ្នំបាត្រ កំពង់ថ្កូវ។ សូមជំរាបថា លោក កៅ-តក់ មានកូនស្រីតែមួយគត់ ដែលសព្វថ្ងៃនេះ ត្រូវបានជាភរិយាលោក ហង្ស-ធុនហាក់។

នេះឯងហើយដែលសឲ្យឃើញថាដាប-ឈួនចង់ធំតែម្នាក់ឯង ទុកមិត្តភក្តិឲ្យនៅទើសមុខមាត់ខ្លាចមិត្តភក្តិនោះបានធំផង នាំឲ្យខ្លួនធំតែឯងមិនកើត។ រឿងនេះបានពតិមានច្បាស់លាស់ថា មកពីខ្លាច កៅ-តក់ បានយសសក្តិខ្ពង់ខ្ពស់ទៅថ្ងៃមុខ ទើបត្រូវតែសម្លាប់ កៅ-តក់ ចោល។ សម័យនោះនរណាមិនល្បីឈ្មោះថា កៅ-តក់ ជាមនុស្សសំខាន់?

ឥឡូវខ្ញុំសូមត្រឡប់មកនិយាយរឿងខ្ញុំតទៅទៀត៖

ក្រោយមកទៀតដោយយល់ថា យើងអត់អំណាចនឹងគ្រប់គ្រងឥស្សរៈហើយនោះ មាខ្ញុំនិងខ្ញុំក៏ប្រកាសសុំលាលែងពីក្រុមឥស្សរៈទៅ។ ការលាលែងនេះ ពួកមេឥស្សរៈឯទៀតនោះ គេមិនមាត់ទេ ព្រោះគេរឹងដៃរឹងជើង អាចរស់នៅដោយខ្លួនគេបានហើយ គេគ្មានការអីនឹងពឹងពាក់មាខ្ញុំ និងខ្ញុំដូចមុនៗ

ទេ។ ហើយសមបើខ្ញុំចេះតែប្រឆាំងនឹងអំពើព្រៃផ្សៃរបស់ពួកគេផង តើគេចង់ឲ្យខ្ញុំនៅជាមួយពួកគេណាស់ទៅឬ? គេមិនចង់ទេ គេចង់តែឲ្យខ្ញុំថយចេញទៅយ៉ាងហ្នឹងឯង។

ត្រង់ហ្នឹងហើយ ដែលខ្ញុំបានជម្រាបអស់លោកអ្នកក្នុងសេចក្ដីផ្ដើមថា សកម្មភាពពួកខ្មែរឥស្សរៈឃើញថាផ្ទុយពីគោលបំណងរបស់យើងអ្នកនយោបាយរំដោះជាតិ។ សកម្មភាពពួកនោះ គឺជាគុណវិបត្តិយ៉ាងធំដែលផ្ដល់ឲ្យខ្ញុំនូវការខកចិត្តយ៉ាងជូរចត់ជរាបសព្វថ្ងៃ។ ហេតុនោះហើយ ទើបខ្ញុំនិយាយរិះគន់អ្វីៗ ខ្ញុំចូលចិត្តនិយាយថា នេះហើយចរិតខ្មែរ។

ដូចជាសព្វថ្ងៃនេះទៀត យើងឮពេញត្រចៀក ខាងពួកព្រៃគេថា «គេរំដោះ» ចូលមកដល់ស្រុកណា ដុតស្ពានដុតផ្ទះអ្នកស្រុកហ្នឹងម៉្លេះ។ ខាងយើងឯណោះដែរ ដើម្បីកុំឲ្យពួកព្រៃដុត ក៏មានអ្នកដៃខូចៗ នៅពីក្រោយកងទ័ព ចាំរុះរើផ្ទះអ្នកស្រុកដឹកគ្មានសល់ដែរណែង បង្អួច ផ្ទាំងផ្តាន ធ្នើយដាក់ទាហាន។ ទាហានអ្នកច្បាំងជាប់ខ្លួន ជាប់ភ្នែកតែនឹងខ្មាំង មានពេលឯណានឹងផាកមកលួចធក់រុះរើដឹកជញ្ជូននោះ។ ចោរម្នាងចូលមកដុតបំផ្លាញ ចោរម្នាងស្រវារេច តើឲ្យផ្ទះខ្មែរនៅសល់អ្វីទៅ? សព្វថ្ងៃនេះខ្មែរកំពុងចាញ់ចម្បាំងយ៉ាងខ្លាំងពីព្រោះអ្វី ពីព្រោះបើពួកព្រៃឈ្នះក៏ផាប់ខ្មែរ មិនមែនផាប់អាមេរិកាំងទេ បើពួកស្រុកឈ្នះក៏ផាប់ខ្មែរ មិនមែនផាប់យួនហាណូយទេ។

ប៉ុន្តែពួកមេៗ ខាងលើមានគិតអ្វីរឿងនេះ។ ពួកមេៗ ខាងរំដោះក្ដី ពួកមេៗ ខាងចោរស្រុកក្ដីសុទ្ធតែសូត្រទ្រឹស្ដីស្រឡាញ់ជាតិទាំងអស់ គ្មាននរណាយល់ថាធ្វើនេះ គឺបំផ្លាញជាតិឲ្យរាស្ដ្ររងវេទនាទេ មិនគិតមើលបាក់ស្ពានជ្រោយចង្វាក្នុង ស្ដេចសីហនុស្រែកបន្ទរមកថាៈ ធ្វើហ្នឹងត្រូវហើយ! នេះបានចំ! ឯពួកឥស្សរៈកាលណោះក៏របៀបហ្នឹងដែរ! ចរិតខ្មែរមានតែមួយអ៊ីចឹង!

*        *

*

# ៧

# ខ្ញុំចូលមកក្នុងប្រទេសវិញ

*នៅពេលដែលថយខ្លួនពីឥស្សរៈ ខ្ញុំក៏បាននៅនឹងក្រុងបាងកកតទៅទៀត។ ប៉ុន្តែដោយក្រុងបាងកកគ្មានរបរអ្វីនឹងប្រកប នៅឆ្នាំ ១៩៤៨ ខ្ញុំក៏បានមកនៅអារញ្ញ។ មុននឹងនិយាយពីដំណើរចូលទៅស្រុកវិញ ខ្ញុំសុំរំលឹករឿងមួយ ដែលសឲ្យឃើញចិត្តមិនស្មោះរបស់សៀមចំពោះយើង។ កាលណោះមានមេឈ្មោះ ផៅផលិត អភ័យវង្ស ជាចៅលោក កថាថន (កទាធរ) (អ្នកបាត់ដំបងហៅថាលោកម្ចាស់ៗ) មានខ្មែរម្នាក់ឈ្មោះ ឈួន ដែរជាមេរង។ ឈ្មោះ ឈួន បានលបចាប់ពួកខ្មែរឥស្សរៈនៅក្រោមឱវាទលោក តាត្រឡាច មាខ្ញុំពីរនាក់ឈ្មោះគ្រូ រស-យឹន មួយ, ឈ្មោះ ម៉ី-កូវិទ្ធ មួយ។ គ្រូ រស-យឹន និង ម៉ី-កូវិទ្ធ[(១)] ជាមនុស្សសំខាន់ណាស់ ក្នុងចំណោមខ្មែរឥស្សរៈឯទៀត។ ពួកឈ្មោះ ឈួន នោះនាំគ្រូ រស-យឹន និង ម៉ី-កូវិទ្ធ ទៅសម្លាប់នៅនឹងឃុំតាបញ៉ាទាំងពីរនាក់។ បានបីថ្ងៃទៅបួនថ្ងៃ ទើបបានដំណឹងនេះទៅដល់មាខ្ញុំឯបាងកក ទើបមាខ្ញុំប្ដឹងតម្រួតនៅបាងកក។ មេតម្រួតបានអនុញ្ញាតឲ្យខ្ញុំនិងមិត្តភក្តិបីនាក់ទៀត ទៅរកកន្លែងកប់ខ្មោចអ្នកទាំងពីរតាមការនាំផ្លូវនៃឥស្សរៈម្នាក់។ ខ្ញុំបានយកទាំងប្រដាប់ថតរូបទៅផង ទុកថតខ្មោច។ ផ្នូរអ្នកទាំងពីរនៅឃ្លាតពីគ្នាប្រហែល ៥ ម៉ែត្រ។ ខ្ញុំសុំអនុញ្ញាតគាស់កាយផ្នូរមិត្តមើលឲ្យច្បាស់។ គ្មាននរណាជួយគាស់កាយទេ ខ្ញុំកាយគាស់ដោយខ្លួនឯងផ្នូរលោកគ្រូ រស-យឹន។ ខ្មោច ៥-៦ ថ្ងៃហើមរសាយក្លិនអសោចិ៍ពេញបន្ទុក ដង្កូវប៉ុនៗ កូនដៃ ខ្ញុំក៏តាំងថតយកភិនភាគបានសព្វគ្រប់ រួចខ្ញុំសុំគាស់ផ្នូរលោក កូវិទ្ធ ទៀត ស្រាប់តែតម្រួតថៃនោះនិយាយថា: បានហើយ! គាស់តែមួយដូចជាគាស់ទាំងអស់ដែរ មិនបាច់គាស់មួយទៀតនោះនាំតែហត់អស់កម្លាំងទេ! ខ្ញុំនិយាយថា: មនុស្សខ្មោចមានពីរ ត្រូវតែមានសំណុំរឿងពីរដែរ ថតតែមួយខ្វះមួយបានអ្វីបំពេញសំណុំរឿង! ឲ្យខ្ញុំសុំអនុ-*

---

*(១)- លោកកូវិទ្ធ ត្រូវជាបងថ្លៃរបស់លោក ណុប-ធុំ។*

ញាតគាស់មួយទៀតចុះ! តម្រួតនោះក៏និយាយដាច់ខាតថាៈ មានបញ្ជាពីមេមកថាឲ្យគ្រាន់តែនាំគ្នាមកមើលប៉ុណ្ណោះ គ្មានអនុញ្ញាតឲ្យថតឲ្យអីទេ! ប៉ុន្តែឥឡូវបើថតមួយក៏ថតទៅចុះ! រួចតម្រួតនោះនិយាយថាៈ ឥឡូវនេះឲ្យខ្ញុំសុំប្រដាប់ថតរូបនិងហ្វីលម៍ក្នុងនេះយកទៅផ្ដិតមកជូនលោក! រួចបន្ទឹដោះហ្វីលម៍នោះទៅៗ គេបំបាត់រឿងនោះរហូតទៅៗ ខ្ញុំក៏ចាប់យល់ថា ឱ! អានេះលេងល្បែងថ្លិនក្មែកទេតើ វាញុះញង់ឲ្យខ្មែរនិងខ្មែរសម្លាប់គ្នា វាធ្វើជាជួយឈឺក្បាល! ហ៊ឺ !

នៅទីផអារញ្ញខ្ញុំរករបរទទួលទានលក់កំណាត់សំពត់ នៅអូរជ្រៅព្រៃប្សៀៗ របរនេះមិនសូវជាចម្រើនប៉ុន្មានទេ នៅគ្រាន់តែរកផ្លូវចូលមកប្រទេសកម្ពុជាវិញប៉ុណ្ណោះ ព្រោះពេលនោះរដ្ឋាភិបាលខ្មែរចាប់ផ្ដើមអំពាវនាវឲ្យពួកឥស្សរៈចុះចូលហើយៗ ឯខ្ញុំបានជាពិបាកចូល ព្រោះដូចអស់លោកអ្នកជ្រាបស្រាប់ ខ្ញុំនៅជំពាក់ទាក់ទិននឹងរឿងនយោបាយធំៗ ព្រមទាំងជាអ្នកទោសកោះត្រឡាចចេញពីកោះមុនកំណត់សាលក្រមផង ចូលមកឥតបើគិត ខ្លាចមិនស្រួលៗ ទើបខ្ញុំចាត់ឲ្យគ្រួសារនៅភ្នំពេញដើរទាក់ទងនឹងរាជការសមត្ថកិច្ច រហូតជួបនឹងលោក Résident Supérieur ផង ឲ្យសម្រួលការនេះៗ លុះបានស្រួលហើយ នៅថ្ងៃទី ២៩ កក្កដា ១៩៤៩ ខ្ញុំក៏បានចូលមកប្រទេសខ្មែរវិញៗ

អកុសលខ្ញុំ! ថ្ងៃដែលខ្ញុំចូលមកដល់ស្រុក ក៏ជាថ្ងៃដែលលោកឪពុកជាទីគោរពរបស់ខ្ញុំ ដែលខ្ញុំពុំទាន់បានតបស្នងសងគុណលោកសោះ លោកបានទទួលមរណភាពក្នុងថ្ងៃនោះទៅដោយរោគាពាធិៗ ខ្ញុំនឹកខ្លោចចិត្តអាណិតខ្លួនពេកណាស់ ដែលរវល់តែដើរចោលស្រុក ចោលគ្រួសារ រហូតដល់លោកឪពុកបាត់បង់ជីវិត ដោយគ្មានបានជួយថែទាំគក់ប្រឲបាច់ បំរើទឹកក្ដៅទឹកត្រជាក់លោកសោះៗ តែនេះធ្វើម៉េចបើយើងយកជីវភាពនយោបាយយ៉ាងហ្នឹងទៅហើយៗ អ្នកនយោបាយ គឺសុទ្ធតែជាមនុស្សចោលស្រុក ចោលឪពុកម្ដាយ ប្រពន្ធកូន ជាមនុស្សគុកច្រវាក់ ជាមនុស្សលែងគិត តាមតែនរណាដឹកយកទៅធ្លាក់ឯណាក៏ដឹកទៅៗ ដូចជាខ្ញុំដែលអណ្ដែតប្ញេងបោ្ញង ចោលម៉ែចោលឪ ជាប់គុកច្រវាក់ ចោលស្រុកមួយលើកជាពីរលើក លុះចូលមកស្រុកវិញ ឪពុកក៏ស្លាប់ទៅទៀត គឺអ្នកនយោបាយវាអក័ព្វមួយចប់យ៉ាងហ្នឹងៗ ខ្ញុំបានសំគាល់ក្នុងចិត្តខ្ញុំដូច្នោះឯងៗ

## ការកសាងជីវភាពថ្មី

មកដល់ភ្នំពេញ ខ្ញុំដែលសល់ប្រាក់កាសបន្តិចបន្តួច បានចូលហ៊ុនជាមួយបងប្អូន បង្កើតឲ្យមានរថយន្តក្រុងចំនួនបីគ្រឿង រត់បណ្ដាក់គ្នាពីផ្សារថ្មីទៅតាមផ្លូវមាត់ទន្លេ រួចបត់ទៅលិចដល់ផ្លូវមុនីវង្ស ទើបបត់មកផ្សារថ្មីវិញៗ គឺជាការបង្កើតមុនដំបូងបំផុតនៅក្រុងភ្នំពេញ ដោយខ្ញុំធ្លាប់ឃើញនៅបាងកកអ្នកដំណើរជិះរថយន្តក្រុងបែបនេះច្រើនណាស់ៗ ចំពោះថ្លៃជិះ ខ្ញុំបានយកពីអ្នកជិះម្នាក់ៗ ៥ កាក់ៗ សម័យនោះគេបានស្គាល់ច្រើនគ្នា ហើយនិយមហៅរថយន្តខ្ញុំថា «ឡាន៥កាក់ៗ» គ្រប់គ្នាៗ ប៉ុន្តែរបរនេះពុំបានផលប៉ុន្មានទេ ដោយឡានមានតែ ៣ បណ្ដាក់គ្នាឆ្ងាយៗ ពេក មិនជាប់ៗ គ្នាដូចនៅបាងកក, អ្នកជិះគេខ្ជិលចាំ គេតែងជិះស៊ីក្លូ ជិះកង់អ្វីៗ ទៅ មិនសូវមានអ្នកជិះច្រើនៗ យូរៗ ទៅកាន់តែខ្សោយៗ ទៅ ជាហេតុនាំឲ្យខាតបង់សោហ៊ុយជាលំដាប់ៗ របរ «ឡាន៥កាក់» ក៏ត្រូវចប់ទៅក្រោយពេលដែលលក់ឡានទាំងបីនោះទៅវិញៗ

បន្ទាប់ពីបរាស័យស៊ាវនេះ ខ្ញុំបែកគំនិតគិតរកស៊ីជាអ្នកដើរថតរូបវិញម្តង ព្រោះកាលណោះរាជការបង្កើតឲ្យមានអត្តសញ្ញាណប័ណ្ណមានបិទរូបថតជាសំគាល់ ចំពោះប្រជាជនទូទៅ។ ខ្ញុំទិញរថយន្តហ្ស៊ីបមួយរបស់បងប៊ុណ្ណចន្ទ-ថាត់នៅទន្លេបិទ បើកបរថតរូបឲ្យគេនៅគ្រប់ច្រកល្ហក តាំងពីខេត្តកំពង់ចាម-កណ្តាល- បាត់ដំបង និងសៀមរាប។ ខេត្តទាំងពីរខាងក្រោយ (គឺបាត់ដំបងនិងសៀមរាប) នេះខ្ញុំត្រូវកើតមានរឿងធំៗ ដែលខ្ញុំគួរយកមកជំរាបដែរ។

ខេត្តបាត់ដំបង ខ្ញុំចូលទៅប្រកបរបរថតរូបនេះជាមួយប្អូនប្រុសពៅខ្ញុំឈ្មោះ ប៊ុណ្ណចន្ទ-ថាណារិត មិនបានយូរប៉ុន្មាន ស្រាប់តែមានមេឥស្សរៈដែលទើបកើតថ្មីម្នាក់ឈ្មោះ ហ៊ុលវង្សអានុភាព បានប្រាប់កូនចៅដៃជើងគេថា បើឃើញឈ្មោះខ្ញុំឬក៏ប្អូនប្រុសខ្ញុំចូលទៅក្នុងតំបន់គេ ត្រូវឲ្យកាប់សម្លាប់ចោលកុំប្រណី។ ប្អូនខ្ញុំបានដឹងដំណឹងនេះ រត់មកប្រាប់ខ្ញុំ។ ខ្ញុំនឹកឆ្ងល់ព្រោះមិនដឹងជាឈ្មោះ ហ៊ុលវង្សអានុភាព នោះស្អប់ខ្ញុំពីរឿងអ្វី។ គិតៗ ទៅយល់ថាប្រហែលជាលោកនោះស្អប់ខ្ញុំព្រោះខ្ញុំធ្លាប់ធ្វើជាមេឥស្សរៈ ហើយពួកឥស្សរៈកនខ្ញុំនោះល្បីឈ្មោះសម្បើម កាលទៅវាយក្រុងសៀមរាបនោះក៏មិនដឹង។ ពីព្រោះ សូមជ្រាបថា សម័យនោះក្រុមខ្ញុំកើតមុនគេបង្អស់ក្នុងស្រុកខ្មែរ។ កំណើតនោះហើយដែលអាចសាយភាយ នាំឲ្យកើតខ្មែរឥស្សរៈតៗ មកទៀតព្រោងព្រាត។ ទាំងពួកធ្លាប់ធ្វើចោរ ក៏មានតាំងខ្លួនជាឥស្សរៈដែរ ដែលសម័យនោះអ្នកស្រុកឲ្យឈ្មោះគន្ធាស់ថា «អ៊ិសរ៉ាចាក់, ឥស្សរៈចោរ» គឺពួកនេះហើយដែលប្លន់ឡាន ប្លន់កប៉ាល់ ចាប់មនុស្សបង្ខាំប់យកប្រាក់ ។ល។ កក្កូរស្រុកឲ្យកើតចលាចល អ្នកស្រុកកិតភ័យជ្រួលច្របល់គ្រប់កន្លែង។ អ្នកខ្លះពីដើមគេហៅអាចារ្យ លុះឡើងជោរស្អប់ធម៌សៀវភៅ ក៏ធ្មៀតចូលឥស្សរៈចោរ គិតតែពីដើរដុតបំផ្លាញគម្ពីរដីកាក្នុងវត្តអស់ មានមេឥស្សរៈឈ្មោះអាចារ្យ ឃី ជាដើម អ្នកទន្លេធំស្គាល់ហើយ។ ឥស្សរៈដុះដូចផ្សិត តែមិនដឹងជាមានឧត្តមគតិត្រង់ណាទេ ដែលបង្ហាញឲ្យឃើញថាស្នេហាជាតិនោះ បើមានសុទ្ធតែពួកប្លន់ ពួកដុតគម្ពីរដីកាចោល ដោយស្អប់ធម៌សៀវភៅចោទពួកធម៌សៀវភៅថាធម៌ថ្មីយ៉ាងនេះ។ ពួកនោះគ្មានគិតពីរំដោះស្រុកទេសអ្វីទេ។ អស់លោកក្មេងៗស្រករក្រោយដែលកើតមិនទាន់រឿងចលាចល បង្កឡើងដោយពួកអ៊ិសរ៉ាចាក់នេះទេ, មើលដល់ត្រង់ណេះសូមប្រញាប់ផាកទៅសួរបញ្ជាក់ចាស់ៗ ដែលនៅក្បែរៗ ខ្លួននេះមើលបើមិនជឿ។ អ្នកនៅភ្នំពេញនេះ ខ្លះក៏បានមកនៅដោយសារពួកនោះអុកឡុកខ្លាំងនាសម័យនោះដែរ សូមស៊ើបមើលចុះបើមិនជឿ។

ចំណែកមេឥស្សរៈឈ្មោះ ហ៊ុលវង្សអានុភាព ដែលចាំបំបាត់រូបខ្ញុំនោះ ប្រហែលជាមកពីក្រែងខ្លួនខ្ញុំចូលទៅតំបន់គាត់ ខ្លួនគាត់មានការអាប់មុខអាប់មាត់ក៏មិនដឹង ព្រោះខ្ញុំជាមេឥស្សរៈតាំងពីដំបូងទីហើយធ្លាប់ល្បីក្នុងរឿងវាយបារាំងនៅក្រុងសៀមរាបនោះ។

តែយ៉ាងណាក៏ដោយ ខ្ញុំធ្លាប់ស្គាល់ចរិតខ្មែរខ្លះដែរ ហើយខ្ជិលចង់ឈ្នះចង់ចាញ់ សុខចិត្តឈប់ចូលទៅក្នុងតំបន់នោះទៅ។

បន្ទាប់ពីនោះ ខ្ញុំចូលទៅកាន់សៀមរាប។ គឺទីនេះហើយ ដែលនាំឲ្យខ្ញុំឃើញ ដាប-ឈួន សងគុណខ្ញុំរបៀបណានោះ។ ត្រង់ណេះហើយដែលខ្ញុំសរសេរពីខាងដើមនោះថា: ឲ្យអស់លោកចាំមើល ដាប-ឈួនយ៉ាងណាជាមួយខ្ញុំនោះ។

សូមរំលឹកឡើងវិញថា ដាប-ឈួនបានចុះចូលនឹងសម្តេចសីហនុ នៅថ្ងៃទី ១ តុលា ១៩៤៩ ហើយសម្តេចសីហនុបានតម្កើង ដាប-ឈួន ជាមេទ័ពត្រួតត្រាខេត្តសៀមរាប និងកំពង់ធំ។

*ខ្ញុំចូលទៅរកស៊ីនៅខេត្តសៀមរាប បានចូលទៅជំរាបសុំលោកដាប-ឈួនតាមផ្លូវការ ត្បិតគេជាប្រធាននៅខេត្តនោះ។ ដាប-ឈួន បានទទួលដោយរីករាយ និយាយថាមិនអីទេ អញ្ជើញរកស៊ីតាមសម្រួលចុះ ខ្ញុំនឹងឲ្យគេជួយមើលផង កុំព្រួយ។*

*ខ្ញុំនឹកអរគុណដាប-ឈួនសន្ធឹក។ ប៉ុន្តែខ្ញុំកំពុងប្រកបរបរនេះមិនទាន់បានប៉ុន្មានផង ស្រាប់តែស្តេចត្រាញ់នេះ រករឿងដោយផ្លូវសម្ងាត់ ឲ្យគេចាប់ខ្ញុំយកទៅសម្លាប់តែម្តង។ ខ្ញុំដឹងពត៌មាននេះដោយសារសេក្តិបីម្នាក់នៅក្នុងកងទ័ពដាប-ឈួនដែលស្រឡាញ់ខ្ញុំស្មោះ ព្រោះគេពីដើមគេជាកូនចៅរបស់ខ្ញុំដែរ គេបានប្រាប់ខ្ញុំថា ឲ្យប្រញាប់ថយទៅ ត្បិតដាប-ឈួនកំពុងចាត់ការឲ្យគេលបចាប់ខ្ញុំហើយ។ ខ្ញុំនឹកហួសចិត្តតែម្តង រឿងនេះមិនខុសពីរឿងព្រេងខ្មែរដែលនិយាយពីរឿងឥសីជបឆ្មាឲ្យទៅជាខ្លានោះទេ។ រឿងនោះថែងថា: តាឥសីចិញ្ចឹមឆ្មាមួយ ដោយស្រឡាញ់ឆ្មានោះ ក៏ជបវាឲ្យក្លាយទៅជាខ្លា។ ខ្លានេះគិតឃើញថា អតីតកាលរបស់អញជាឆ្មា លោកតាឥសីជបអញ តទៅបើគេដឹងថាអញមានដើមកំណើតជាឆ្មា អញមិនប្រសើរទេ។ ដើម្បីកុំឲ្យគេដឹងថាអញពីដើមជាឆ្មា អញត្រូវតែសម្លាប់ឥសីនោះចោល ព្រោះបើទុកគាត់ឲ្យនៅ សមគាត់និយាយរឿងដើមកំណើតអញ នាំឲ្យអញថោកទាប។ គិតហើយក៏ប្រុងប្រហារឥសី តែឥសីដឹងទាន់ក៏ធ្វើឲ្យខ្លានោះក្លាយទៅជាឆ្មាវិញទៅ។ ដាប-ឈួនប្រហែលជាចង់បំបាត់អតីតកាលរបស់គាត់ជាមួយខ្ញុំ ទើបត្រូវតែកំចាត់ខ្ញុំនោះឯង។ ឬក៏មកពីគ្រានោះខ្ញុំពុំបានឲ្យកម្រៃអ្វីសោះដល់រូបគាត់ក៏មិនដឹង បានជាគាត់ចងអាឃាតព្យាបាទដល់ថ្នាក់នេះ ព្រោះសម័យនោះគាត់ត្រូវការស្នួយសារអាករសន្ធឹកសន្ធាប់ណាស់ ថៅកែចិនព្រិនគ្រប់ៗ គ្នាត្រូវតែសែនព្រេនគាត់គ្មានសល់ក្បាលមួយ។*

*ខ្ញុំមិនអាចនៅបានក៏នាំគ្នីគ្នាចាកចេញពីខេត្តសៀមរាបប្រញាប់ប្រញាល់។ នេះហើយរឿងខ្ញុំជាមួយលោកដាប-ឈួន ដែលក្រោយមកគេស្គាល់ឈ្មោះថា ដាប-ឈួនម្ហូលពេជ្រ នោះ។*

*ខ្ញុំមកនៅភ្នំពេញវិញ ហើយគិតថារករបរណាឲ្យបានស្រួល កុំឲ្យចម្រូងចម្រាសដូចនេះទៀត។ ហើយរឿង «នយោបាយ» ខ្ញុំពុំភ្លេចទេ ដូចគេញៀននឹងអាភៀនដូច្នោះដែរ។ ខ្ញុំបានចូលបម្រើគណបក្សនយោបាយនៅដើមឆ្នាំ ១៩៥០ រហូត ១៩៥១ ដែលខ្ញុំនឹងសរសេរជម្រាបតទៅទៀតនៅជំពូកខាងក្រោយ។ ខ្ញុំសូមបញ្ជាក់នៅទីនេះឲ្យហើយថា តាំងពីនៅព្រៃរហូតចូលស្រុកវិញ ខ្ញុំបានសំគាល់ឃើញថាពួកនៅស្រុកគំនិតមេនិយម ផ្តាច់ការនិយម កាប់សម្លាប់គ្នា មានដូចគ្នា ដូចជាពួកនៅក្នុងព្រៃដែរ ដដែលជាដដែល។ នេះហើយចរិតខ្មែរ!*

* *

*

# ៨

# ខ្ញុំចូលគណបក្សប្រជាធិបតេយ្យ

ក្នុងពេលដែលខ្ញុំបានចូលមកស្រុកវិញនេះ ខ្មែរយើងមានគណបក្សនយោបាយ តាមលក្ខណៈប្រជាធិបតេយ្យដែរហើយ តាមរដ្ឋធម្មនុញ្ញដែលទ្រង់ស៊ីសុវត្ថិ យុត្តិវង្ស និង លោក អៀវ-កើស បានកសាងឡើងៗ ឆ្នាំដែលខ្ញុំចូលមកនោះ គណបក្សដែលខ្ញុំអាចរំលឹកបាននៅពេលនោះគឺ:

- គណបក្សប្រជាធិបតេយ្យ រូបក្បាលដំរីកាន់ផ្កាឈូកបីជាសញ្ញាលក្ខណ៍, ដឹកនាំដោយលោក អៀវ-កើស
- គណបក្សសេរីភាព រូបប្រាសាទកំពូលបីជាសញ្ញាលក្ខណ៍, ដឹកនាំដោយទ្រង់ នរោត្តម នរិន្ទដេត
- គណបក្សខេមរប៉ុន្នការ រូបនាងគង្ហីងព្រះធរណីជាសញ្ញាលក្ខណ៍ ដឹកនាំដោយលោក លន់-នល់
- គណបក្សតំកើងប្រជាជាតិ រូបហនុមានទ្រផែនទីស្រុកខ្មែរជាសញ្ញាលក្ខណ៍ដឹកនាំដោយលោកយ៉ែម-សំបូរ
- គណបក្សចំរើនជាតិ រូបព្រួញទម្លុះកងបួន របស់លោក ជា ជិនកុក
- គណបក្សព្រៀសានមានជ័យ រូបទង់ជាតិពីរខ្វែងគ្នាទ្រម្កុដ ជាសញ្ញាលក្ខណ៍របស់លោក ម៉ៅ ចយ
- គណបក្សរួបរួមជាតិ
- គណបក្សប្រជាជន រូបនង្គ័លជាសញ្ញាលក្ខណ៍
- គណបក្ស រូបសំបុកឃ្មុំរបស់លោក ម៉ម សុទ្ធ (មិនមែន ម៉ម សុទ្ធ ទុតិយម្បិតឡូវនេះទេ)
- គណបក្ស រូបកណ្ឌៀវ
- គណបក្សរូបកណ្ដាប់ស្រូវ- សំ ញៀន ជាមេ ។

ធម្មតាអ្នកនយោបាយ តែងញៀននឹងរឿងនយោបាយ យ៉ាងណាមិញ រូបខ្ញុំដែលធ្លាប់ជាប់គុក ព្រោះរឿងនយោបាយក៏នៅតែចង់ប្រឡូកក្នុងល្បែងនេះដែរ។

ខាងគណបក្សប្រជាធិបតេយ្យ មានគ្នីគ្នាខ្ញុំជាច្រើនបានចូលបំរើ មានលោក ប៉ាច-ឈឺន, ជុំ-មួង ជាដើមដែលធ្លាប់តែរួមសកម្មភាពនយោបាយតាំងពីឆ្នាំ ១៩៣៦ មកនោះ។ ខ្ញុំមកដល់ភ្លាម លោក ម៉ុញ-ណាគ្រី និងលោក ជុំ-មួង បានមកជួបខ្ញុំ ហៅខ្ញុំឲ្យចូលគណបក្សប្រជាធិតេយ្យ។ មានខាងគណបក្សឯទៀតដែរ ដែលមកទាក់ទង តែខ្ញុំពុំបានចូល ខ្ញុំទទួលចូលខាងគណបក្សប្រជាធិបតេយ្យ ដែលមានគ្នាខ្ញុំច្រើនស្រាប់។ ខ្ញុំក៏បានជួបផ្ទាល់និងលោក អៀវ-កើស បំរើគណបក្សប្រជាធិបតេយ្យតមក។

សូមរំលឹកថា នីតិកាលទី ១ នៃសភាជាតិដែលបើកសម័យពីថ្ងៃ ២១ ខែ មករា ១៩៤៨ សមាជិកភាគច្រើនជាគណបក្សប្រជាធិតេយ្យ (ក្បាលដរី)។ សភាជាតិដែលមានករណីយកិច្ចការពាររដ្ឋធម្មនុញ្ញ ការពារលទ្ធិប្រជាធិតេយ្យ តែងតែត្រូវរងអំពើជិះជាន់របស់ហ្លួងសីហនុជានិច្ច។ រដ្ឋធម្មនុញ្ញដែលបានប្រកាសប្រើពីឆ្នាំ ១៩៤៧ រហូតមកតែងរអាក់រអួលជានិច្ច បណ្ដាលមកពីស្ដេចសីហនុដែលគ្មានទសពិធរាជធម៌សោះ ចេះតែកែរដ្ឋធម្មនុញ្ញត្រឡប់ត្រឡិនការពារតែប្រយោជន៍និងឋានៈក្សត្រ។

ហើយដឹងយ៉ាងណាទេ? ដោយមិនសប្បាយចិត្តនឹងគណបក្សប្រជាធិបតេយ្យ ដែលមានប្រជាប្រិយភាពជាងខ្លួន ព្រមទាំងធ្វើការមិនសូវស្របនឹងបំណងខ្លួននោះ, នៅថ្ងៃទី ១៧ កញ្ញា ១៩៤៩ ស្ដេចសីហនុបានប្រកាសរំលាយសភាជាតិនីតិកាលទី ១ នោះទៅ។

ការនោះធ្វើឲ្យប្រជាជនខ្មែរ បាត់មាត់បាត់កលែងហ៊ានក្អកគ្រហែមត្រឹមណោះ ខ្លាចស្លាប់ដោយសារព្រះករុណាជាអម្ចាស់ជីវិតលើត្បូង។ ហើយគេដឹងថា មើលទៅព្រឹត្តិការណ៍ស្រុកទេសមុខជាមិនសូវប្រែប្រួលច្របូកច្របល់អ្វីតទៅទៀតទេ។ ប៉ុន្តែមានស្ងប់ឯណា នៅថ្ងៃសៅរ៍ ១៤ មករា ១៩៥០ ស្រាប់តែព្រឹត្តិការណ៍មួយកើតឡើងដូចរន្ទះ ធ្វើឲ្យអ្នកភ្នំពេញភ្ញាក់ផ្អើល រហូតដល់ស្រុកស្រែចំការនិគមជនបទ គឺដំណឹងមរណភាពនៃលោក អៀវ-កើស អតីតប្រធានសភាជាតិ បច្ចុប្បន្នអគ្គលេខាធិការគណបក្សប្រជាធិបតេយ្យ ដែលត្រូវជនម្នាក់បោះគ្រាប់បែកធ្វើឃាតលោក នៅទីស្នាក់ការគណបក្សប្រជាធិបតេយ្យ លេខ ៦៧ ផ្លូវឧកញ៉ាផ្លុង ជិតកាច់ជ្រុងវិថី ៩ តុលាសព្វថ្ងៃនេះ។

សូមជម្រាបថា ឆ្នាំដែលលោក អៀវ-កើស ទទួលមរណភាពនោះ លោក យ៉ែម-សំបូរ ជានាយករដ្ឋមន្ត្រី, លោក ចៅ-សែនកុសល ជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌, និងមានលោក តាន់-គិមតឹក ជាមេគិញ, លោក សេង-ទិព ជាមេប៉ូលីសនៅតំបន់ផ្សារថ្មី ដែលមាននាទីមើលទៅដល់ផ្លូវឧកញ៉ាផ្លុង នោះផង។

គេអ្នកក្រុងភ្នំពេញទាំងមូល កាលណោះសឹងតែយល់ថាលោក អៀវ-កើស ស្លាប់នេះគឺដោយគម្រោងឧបឃាតរបស់ស្ដេចសីហនុតែម្ដង។ ព្រោះព្រះអង្គនិងពួកបរិវារលោក ពុំមែនចង់ឃើញជីវិតលោក អៀវ-កើស រស់នៅការពាររដ្ឋធម្មនុញ្ញ ការពារលទ្ធិប្រជាធិតេយ្យនោះកាលណា។

គ្រាដែលសម្លាប់លោក អៀវ-កើស ស្លាប់ហើយ គេបែរជាទៅចាប់សមាជិកគណបក្សសេរី-ភាពម្នាក់ ឈ្មោះ នូយ៉ា នៅបឹងប្រយាបយកមកវាយសួរចម្លើយ វាយបង្ខំឲ្យឆ្លើយថាខ្លួនពិតជាឃាតករធ្វើឃាតលោក អៀវ-កើស។ កាលណោះអ្នកភ្នំពេញខ្សឹបខ្សៀវគ្នាថា: «នយោបាយនោះឆើតណាស់ ទាត់មួយបានពីរតែម្ដង» បានសេចក្ដីថាគេសម្លាប់មេប្រជាធិតេយ្យហើយ គេដដែលហ្នឹងធ្វើឲ្យខាងគណបក្សសេរីភាពនោះ ជាប់រឿងរ៉ាវទៅដែរ។ អ្នកភ្នំពេញយល់ថា រឿងហ្នឹងប្ដឹងក្អែកសុទ្ធសាធ ព្រោះ

*ខាងគណបក្សផង ព្រោះគ្មាននឹកឃើញថាគណបក្សសេរីភាពជាគូប្រឆាំងមកសងសឹកបែបនេះផងទេ។ ខ្ញុំមកជួបហេតុការណ៍ដ៏សម្បើមនេះ ក៏ក្រាក់ខ្លួនដូចគេកន្ទ្រាក់ ទឹកថា ឱ! នយោបាយពួកក្នុងស្រុក មិនខុសពីនយោបាយពួកក្នុងព្រៃដែលខ្ញុំធ្លាប់រស់នៅជាមួយនោះប៉ុន្មានទេ។ កាប់សម្លាប់គ្នាឥតអាណិត ដូចខ្ញុំបាននិយាយទុកមកហើយ នេះហើយចរិតខ្មែរ! បើវល់តែប្រកាប់ប្រចាក់ បំបាត់ជីវិតគ្នាយ៉ាងនេះ មានពេលឯណានឹងកសាងស្រុកទេស? កសាងប្រយោជន៍រួមកើត? ហ៊ឺ អកុសល!*

*ខ្ញុំដែលទើបតែបានចូលក្នុងគណបក្សប្រជាធិបតេយ្យ ក៏ដូចជាបានមកទទួលមរណសញ្ញា និងជួយហែសពលោកអតីតប្រធាន អៀវ-កើស តែម្ដង។ សពលោក អៀវ-កើស ត្រូវបានដង្ហែយកទៅតំកល់នៅគេហដ្ឋានលោក នៅផ្លូវកាតរកាព (អតីតស៊ីសុវត្ថិ) មាត់ទន្លេ ផ្ទះលេខ ២៣៣ ខាងត្បូងវត្តកែវព្រះភ្លើង ធ្វើបុណ្យទក្ខិណានុប្បទានអស់ ៧ យប់ ៧ ថ្ងៃ។ ហើយនៅថ្ងៃទី ២២ មករា ១៩៥០ សពរបស់លោកត្រូវដង្ហែជាក្បួនយ៉ាងមហោឡារិក ឆ្ពោះទៅបូជានៅវត្តបទុមវត្តី ។ ក្បួនដង្ហែនោះគគ្រឹកគគ្រេង*

(រូបថត ១ : មឈូសសពឯកឧត្តម អៀវ-កើស បានប្រុងប្រៀបដង្ហែចេញ)

(មិនមានលទ្ធភាពដាក់ជូន)

*សម្បើមណាស់ ខ្ញុំត្រូវគណៈកម្មការបុណ្យ ចាត់ឲ្យនាំមុខក្បួនដែលដង្ហែបត់បែនតាមផ្លូវជាច្រើនទាក្រុងភ្នំពេញ គឺចេញពីគេហដ្ឋានសពផ្លូវកាតរកាព (អតីតផ្លូវស៊ីសុវត្ថិ) ត្រង់ទៅខាងត្បូង បត់ទៅលិច ដល់*

(រូបថត ២ : ក្បួនដង្ហែសព ឯកឧត្តម អៀវ-កើស ថ្ងៃទី ២២ មករា ឆ្នាំ១៩៥០)

(មិនមានលទ្ធភាពដាក់ជូន)

(រូបថត ៣ : ពិធីបង្សុកូល នៅមុខមន្ទីរសភាជាតិសម័យនោះ)

(មិនមានលទ្ធភាពដាក់ជូន)

*ផ្លូវ ៩ តុលាសព្វថ្ងៃ ក៏ដើរតាមផ្លូវនេះមកខាងជើង មកដល់ផ្លូវសីនគុយសព្វថ្ងៃ ក៏ដើរតាមនេះរហូតដល់មាត់ទន្លេ ផ្លូវកាតរកាពវិញ។ រួចក្បួនក៏តជំណើរសន្សឹមៗតាមផ្លូវនេះ រហូតដល់ផ្លូវឧកញ៉ាឈុន ទើបបត់ចូលមកលិចវិញ មកដល់មុខមន្ទីរសភាជាតិ ក្បួនបានឈប់ ហើយនិមន្តព្រះសង្ឃបង្សុកូលជូនសពនៅទីនោះដោយស្រងូតស្រងាត់។ បន្ទាប់មកទើបក្បួនតជំណើរតាមផ្លូវឧកញ៉ាឈុនមកលិចទៀត ទើបចូលទៅត្បូងតាមផ្លូវវត្តបុទមវតីទៅឈប់នៅឈាបនដ្ឋានវត្តបុទមវតីនោះ ដើម្បីបូជា។ អ្នកនៅភ្នំពេញចូលរួបរួមក្នុងក្បួននេះជាច្រើនក្រុមជាច្រើនពួក ប្រកបដោយទឹកមុខក្រៀមក្រំជាទីបំផុត។ ការមួយទៀតដែលទុកដូចជាអស្ចារ្យបន្តិចដែរ គឺពេលដង្ហែសពនោះ តំកល់លើប៉ាឆាបានបន្តិច ព្រះកិរុណាបង្អុរចុះមករួចមេឃស្រទុំស្រទន់ដូចជាចេះកាន់ទុក្ខ ចំពោះមរណភាពវង្គបុរសខ្មែរនេះដែរ។ អស់លោកនៅភ្នំពេញចាស់ៗ អាចនឹងនិយាយរឿងនេះឡើងវិញបាន សូមប្អូនៗ ស្រាវនេះសាកសួរលោកផងចុះ។*

*សម័យនោះ, លោក អៀវ-កើស បាត់បង់ជីវិតទៅ, តើស្មារតីស្រឡាញ់លទ្ធិប្រជាធិតេយ្យរបស់រាស្ត្រខ្មែរចុះថយឬ? តើគណបក្សប្រជាធិបតេយ្យ (ក្បាលជីរ) ចុះថយកម្លាំងឬ? មិនមែនទេ! ផ្ទុយពីវត្ថុបំណងរបស់ពពួករាជនិយម ផ្ដាច់ការនិយម អាណានិគមនិយម ដែលចង់បំបាត់លទ្ធិប្រជាធិប-*

(រូបថត ៤ : ពិធីបូជាសព ឯកឧត្តម អៀវ-កើស)
(មិនមានលទ្ធភាពដាក់ជូន)

*តេយ្យ និងគណបក្សប្រជាធិបតេយ្យ រាស្ត្រខ្មែររឹតតែមានស្មារតីភ្លឺថ្លាឡើងមួយកំរិតទៀត ស្រឡាញ់លទ្ធិនេះខ្លាំងឡើង ព្រោះគេយល់ថា ឱ! លទ្ធិនេះមានតម្លៃណាស់តើ សម្រាប់អញជារាស្ត្រនោះ! ដូច្នេះទើបគេសម្លាប់លោក អៀវ-កើស ចោលកុំឲ្យលោកជួយការពារអញកើត គេចង់ទុកអញជារាស្ត្រងងឹត គ ថ្លង់ទៅរាប់សតវត្សទៀត កុំឲ្យងើបភ្លឺស្វាងកើតៗ*

*កាលបើរាស្ត្រខ្មែរយល់យ៉ាងហ្នឹងហើយ គណបក្សប្រជាធិបតេយ្យ ក៏ក្លាយទៅជាគណបក្សដែលរាស្ត្រស្រឡាញ់យ៉ាងលើសលុបៗ*

*　　*

*

# ៥

# ខ្ញុំនិងគុកនយោបាយម្តងទៀត

ចូលមកក្នុងឆ្នាំ ១៩៥១ គណបក្សនយោបាយបានមានសកម្មភាពជាថ្មី ដោយប្រជាជាតិខ្មែរត្រូវការឲ្យមានអង្គការនីតិបញ្ញត្តិឡើងវិញ។

គណបក្សប្រជាធិបតេយ្យ ជាគណបក្សដែលឈរជួរមុខគណបក្សឯទៀត ដោយរាស្ត្រធ្លាប់ស្គាល់និងស្រឡាញ់។ ចំពោះរូបខ្ញុំពុំមានពន្ទើសទេ ការឃោសនាបោះឆ្នោត ដូចជាការកំសាន្តបុណ្យទាន

(រូបថត ៥ : ការឃោសនារបស់គណបក្សប្រជាធិបតេយ្យសម័យនោះ)
(មិនមានលទ្ធភាពដាក់ជូន)

សុទ្ធសាធ ត្បិតខ្ញុំនិយាយឃោសនាម្តងៗ កន្លែងណាក៏ដោយគេទះដៃអបអរសាទរពុំដែលខាន។ ម្យ៉ាងទៀត គេធ្លាប់ល្បីថា ខ្ញុំ ប៉ុណ្ណចន្ទ-ម៉ុល ធ្លាប់ជាប់គុកកោះត្រឡាច ធ្លាប់កសាងកំណើតឥស្សរៈ។ ម៉្លោះហើយគេរាប់អានខ្លាំងណាស់ចំពោះរាស្ត្រ។

សភាជាតិនីតិកាលទី ២ ក៏ត្រូវបានកៅអីមកខាងគណបក្សប្រជាធិបតេយ្យយ៉ាងច្រើន ដែលមានរូបខ្ញុំក្នុងនោះម្នាក់ដែរ។ នីតិកាលសភាជាតិទី២ នេះបានបើកសម័យប្រជុំនៅថ្ងៃទី ៤ តុលា ១៩៥១ ។

ហើយនៅថ្ងៃទី ១២ តុលា ១៩៥១ គណៈរដ្ឋមន្ត្រីថ្មី ដែលភាគច្រើនខាងប្រជាធិបតេយ្យ ហើយដែលដឹកនាំដោយលោក ហ៊ុយ គន្ធុល ជានាយកនោះ បាននាំសមាជិកមកបង្ហាញខ្លួនចំពោះសភាផង។

(រូបថត ៦ : បើកសម័យប្រជុំសភាជាតិទី ២ សម័យនោះ។ រូបពីឆ្វេងទៅស្តាំ : ជួរខាងមុខ លោក សឺន-សាន, ទ្រង់ ឥន្ទ្រាវង្ស ។ ជួរខាងក្រោយ : លោក ជុំ-មួង, ខ្ញុំ ប៉ុណ្ណចន្ទ-ម៉ុល ។)
(មិនមានលទ្ធភាពដាក់ជូន)

សភាជាតិធ្វើការបម្រើតែឧត្តមគតិជាតិដដែល ការពារតែលទ្ធិប្រជាធិបតេយ្យដដែល ក៏មិនបានសុខស្រួលសោះ ចេះតែទទួលការសង្កត់សង្កិនរបស់ស្តេចសីហនុជរាប។ ហើយបានតែជាងមួយឆ្នាំ

*ប៉ុណ្ណោះ ដោយយើងចេះតែចចេសរឹងទទឹងនឹងព្រះអង្គខ្លាំងពេក នៅថ្ងៃទី ១៣ មករា ១៩៥៣ ព្រះអង្គប្រើអំណាចផ្តាច់ការរំលាយសភាជាតិនីតិកាលទី ២ នោះទៅ។ ខ្ញុំ ប៉ុណ្ណចន្ទ-ម៉ុល និងអ្នកប្រឆាំងចេញមុខច្រើនគ្នា ត្រូវដៃជើងព្រះអង្គចាប់អូសក្បាលបញ្ចូលគុកក្នុងពេលនោះទៅ។ ជីវិតខ្ញុំ, ជាប់គុកលើកទី២ នឹងលើកនេះហើយ!។ ឱ! អនិច្ចាកម្មគុក, អីក៏អ្នកស្រឡាញ់ខ្ញុំម្ល៉េះ? បាត់មុខខ្ញុំយូរមិនបានឬ? កាលពីឆ្នាំ ១៩៤២ ខ្ញុំបានមកជួបនឹងអ្នកម្តងហើយ ហើយហួសរហូតទៅកោះត្រឡាច, ឥឡូវឆ្នាំ ១៩៥៣ ខ្ញុំមកនេះម្តងទៀត ហើយមិនដឹងជានឹងទៅណាទៀតទេ?*

*ខ្ញុំចូលគុកលើកទី ២ នេះ បានសង្កេតក្នុងគុកធំរបស់ខ្មែរគ្មានខុសពីជំនាន់ឆ្នាំ ១៩៤២ ទេ របៀបបែបបទធ្វើទារុណកម្មមនុស្សនៅដដែល។ ហើយខ្ញុំសង្កេតឃើញគេផ្ចាលមនុស្សដោយវិធីប្លែកៗ ដូចជាគេយកអ្នកទោសទៅចងផ្អោបនឹងគល់ស្វាយឲ្យអង្ក្រងចោមខាំ ស្រែករកពុទ្ធោ!*

*នេះជាចរិតអ្នកដឹកនាំរដ្ឋខ្មែរ គ្មានកែប្រែរបៀបសោះ នៅតែចាស់គម្រឹលព្រៃផ្សៃដដែល។ ខ្ញុំទ្រាំរស់នៅក្នុងគុកអកុសលអស់ពេល ៨ខែ ២០ថ្ងៃ ទើបមានវាសនារំដោះរួចមកវិញ។*

*ខ្ញុំសូមរំលឹករឿងមួយ។ មុនពេលរួចពីការឃុំឃាំង ខ្ញុំព្រមទាំងមិត្តជាច្រើន បានទទួលសេចក្តីក្តៅក្រហាយតូចចិត្ត ចំពោះមេនយោបាយគណបក្សប្រជាធិតេយ្យដូចគ្នា ដែលគេមានវាសនាល្អមិនជាប់គុក គេចូលទៅប្រាស្រ័យនឹងពួកខ្ញុំនៅក្នុងគុក គេពោលបន្ទោសពួកខ្ញុំថាៈ អស់លោកឃើញទេ? អស់លោកមិនជឿខ្ញុំ, ខ្ញុំបានរំលឹកច្រើនលើកច្រើនគ្រាហើយថា កុំប្រឆាំងនិងព្រះករុណាជាអម្ចាស់ជីវិតលើត្បូងឲ្យសោះ, ពួកលោកមិនស្តាប់ខ្ញុំទេ ឥឡូវទាល់តែអីចឹងទៅ! ប៉ុន្តែមិនអីទេ អស់លោកនឹងបានរួចខ្លួនក្នុងពេលឆាប់ៗ នេះហើយ!*

*នែ! វាទៅជាអីចឹង, គួរណាស់តែមកលួងលោមលើកទឹកចិត្តគ្នា មិនដូច្នោះបែរជាមកបន្ទោសដូចគេយកភ្លើងមកចាក់លើទ្រូង! នេះចរិតខ្មែរវាអីចឹង!*

*តាំងពីចេញពីគុកកាលណា ខ្ញុំនឹកតូចចិត្តចំពោះខ្លួនឯងយ៉ាងខ្លាំងដែលពីនោះមកនេះ គ្មានបានសុខស្រួលសោះ ជីវិតខ្ញុំជាជីវិតមានសុទ្ធតែបន្ទាប្រួងប្រាំងចម្រូងចម្រាសជានិច្ច គុកប្រវាក់ជាប់កែងគួរឲ្យស្អប់ស្អែង។ ខ្ញុំដូចជាអស់កម្លាំងនឹងបម្រើជីវិតនយោបាយត្រឹមណេះ។ ខ្ញុំហេវហត់ណាស់ហើយ។ ខ្ញុំក៏បានដកខ្លួនពីជីវិតនេះមួយគ្រា ហើយបែរជាមកខិតខំប្រកបរបរទទួលទានចិញ្ចឹមជីវិតនឹងគ្រួសារវិញម្តង ដោយប្រកបរបរពាណិជ្ជកម្មយ៉ាងស្ងិតស្ងាញប្រឡូកប៉ូកប៉ាកជាមួយចិនពេញទំហឹង ដរាបបានមានជីវភាពសមរម្យជាមនុស្សនឹងគេលុះសព្វថ្ងៃ។ ប៉ុន្តែទោះបីលាក់ខ្លួនលែងធ្វើនយោបាយ គិតតែរកស៊ីក៏ដោយ ក៏ខ្ញុំចេះតែតាមកត់សំគាល់ស្ថានការណ៍ស្រុកខ្មែរជាដដែលដែរ ព្រោះដូចបានជ្រាបហើយ អ្នកចូលវង់នយោបាយ ទោះបីឃ្លាតពីវង់ទៅហើយក៏ដោយ តែងតែលបមើលគេអ្នកថ្មី ដែលកំពុងតែកាន់ការរដ្ឋនោះជាដរាប។ ការសំខាន់ៗ ដែលខ្ញុំកត់សំគាល់ ហើយដែលខ្ញុំចេះតែស្រមៃថារបបរបស់ស្តេចសីហនុ មុខជានឹងមានហេតុអាក្រក់នៅថ្ងៃណាមួយ ដោយយើងជារាស្ត្រទ្រាំនៅលែងបាន ត្រូវតែរុះរើនោះគឺ៖*

- *ស្តេចសីហនុយកតំណែងនាយករដ្ឋមន្ត្រីមកកាន់ បន្ទាប់ពីរំលាយសភាជាតិនីតិកាលទី ២ ឆ្នាំ ១៩៥៣ ។*
- *មកពីលោភលោភអំណាច វាតយកអំណាចរដ្ឋគ្រប់យ៉ាងមកកាន់ ដើម្បីញាក់ញោចទៅណាក៏បាន។*

- *ស្តេចសីហនុដាក់តំណែងរាជ្យឲ្យស្តេចឪពុកសោយរាជ្យជួសតទៅ ១៩៥៥, លោកចូលប្រឡូកក្នុងនយោបាយឲ្យបានកប់ដៃ; គណបក្សដែលធ្វើស្របតាមរដ្ឋធម្មនុញ្ញត្រូវលាយៗអស់ ដោយអានុភាពលោកៗ*

*ត្រង់ណេះមកពីលោកខ្លាចលោយរាជបល្ល័ង្កផង ចង់ពង្រីកមុខមាត់ឲ្យមានប្រជាប្រិយភាពតែម្នាក់ឯងផងៗ*

*មួយទៀតសម្តេចសីហនុឃោរឃៅណាស់ ចិត្តមិនត្រង់បង់សច្ចៈធ្វើបាបពួកគណបក្សប្រជាធិតេយ្យសម្បើមៗ នៅថ្ងៃទី ១១ សីហា ១៩៥៧ សម្តេចសីហនុបានប្រកាសឲ្យគណៈកម្មការកណ្តាលនៃគណបក្សប្រជាធិបតេយ្យ ចូលទៅក្នុងព្រះបរមរាជវាំងជំនុំនៅព្រះទីនាំងកោជនីយ ដើម្បីចោទឆ្លើយអំពីវត្ថុបំណងរបស់គណបក្សប្រជាធិបតេយ្យៗ ពេលនោះមានមនុស្សច្រើនពាន់នាក់ បានចូលទៅស្តាប់ផ្ទាល់ ឯវិទ្យុជាតិក៏មានផ្សាយបន្តឲ្យអ្នកស្តាប់ឯទៀតឮផងៗ ខាងគណបក្សប្រជាធិបតេយ្យមានរូបលោក ស្វាយ-សូរ ជាប្រធាន, លោក តាន់-គីមហួន, ទ្រង់នរោត្តម-ភូរិស្សរា, លោក កែវ-ម៉ុងគ្រី, លោក គាំ-រ៉េត ជាសមាជិកៗ ក្នុងឱកាសបើកសម័យប្រជុំរួច សម្តេចសីហនុប្រកាសយ៉ាងម៉ឺងម៉ាត់ថាសុំឲ្យអស់លោកខាងគណបក្ស កុំបីគិតភ័យឬព្រួយបារម្ភឲ្យសោះក្នុងរឿងគេធ្វើបាបផ្សេងៗ, ខ្ញុំសុំធានាទាំងអស់ថាគ្មាននរណាប៉ះពាល់លោកទេ លោកនិយាយអ្វីនិយាយឲ្យត្រង់ៗ ទៅចុះ កុំព្រួយ!*

*ពេលប្រជុំនោះ ចាប់ពីម៉ោង ៩ រហូតដល់ម៉ោង ១៣:៤០ ទើបចប់ គណបក្សប្រជាធិបតេយ្យបានបង្ហាញនូវគោលបំណងដែលរក្សាលទ្ធិប្រជាធិតេយ្យស្របតាមរដ្ឋធម្មនុញ្ញពិតប្រាកដ ធ្វើឲ្យសម្តេចសីហនុមិនសប្បាយចិត្តសោះឡើយៗ ឯពួកឆ្កែជាបរិវារសីហនុវិញ ឆាប់យល់ព្រះទ័យសីហនុជាម្ចាស់ណាស់ទៅទៀត ពួកនោះចាំឲ្យតែចប់ពេលប្រជុំនឹងរោមខាំពួកអស់លោកគណបក្សប្រជាធិបតេយ្យឲ្យក្ស័យតែម្តងៗ មែន, សីហនុជាម្ចាស់របស់វាហាមតែមាត់ទេ ក្នុងចិត្តគឺពន្យុះវាជាឆ្កែឲ្យចាំត្របាក់ក្បាលគេជាស្រេចៗ គ្រាន់តែជំនុំចប់ភ្លាម លោក ស្វាយ-សូរ, លោក កែវ-ម៉ុងគ្រី, ទ្រង់នរោត្តម-ភូរិស្សរាចេញតាមទ្វារខាងជើងក៏ត្រូវពួកនោះ ស្រែកជេរម្តាយតាយឪពុកដូចជាពួកបាតផ្សារអាវ៉ាសែ ព្រមទាំងព័ទ្ធគប់ដុំថ្មព្រោងព្រាត ទៅលើលោក ស្វាយ-សូរ ដំណាំជាងគេ តាំងពីក្នុងវាំងរហូតក្រៅវាំងបែកមុខបែកមាត់អស់ៗ លោក តាន់-គិមហួន និងលោក គាំ-រ៉េត ចេញទៅទ្វារខាងកើតរួចខ្លួន ប៉ុន្តែបានភ័យព្រលឹងចុងសក់មិនតិចៗ នេះជាលក្ខណៈទ្រើសឃ្នងរបស់សម្តេចសីហនុ ដែលចូលចិត្តបោកបញ្ឆោតគេឲ្យស្លាប់តាមគំនិតថោកទាបៗ*

*- ស្តេចសីហនុឡើងជោរ ដោយចេះតែស្តាប់ពាក្យបញ្ចោររបស់ ចិន-យួន កុម្មុយនិស្ត ក៏ស្អប់អាមេរិកាំងចាក់ឲ្យបាតុករវាយទូតអាមេរិកាំង ១៩៦២ ហើយកាត់ទូតពីអាមេរិក, អព្យាក្រិតចាក់ថែវទៅខាងកុម្មុយនិស្ត ដោយខំយកចិត្តកុម្មុយនិស្ត កុំឲ្យកុម្មុយនិស្តបំបាត់រាជ្យ បើកាលណាកុម្មុយ-និស្តចូលមកដល់ៗ*

*រាស្ត្រយល់ថា រឿងនេះមកពីលោកខ្លាចកុម្មុយនិស្តដែលជាសត្រូវនឹងស្តេច ចូលមកកាប់សម្លាប់លោក ទើបលោកលេងផ្លូវល្បួងយកចិត្តឲ្យហើយៗ*

*ចុងចប់ អស់សមត្ថភាពនឹងស្តារស្រុកទេសដែលមានឱនភាព ថវិកាធ្លាក់ស្រុតដល់បាតដាលបណ្តាលមកពីការគ្រប់គ្រងរបស់ខ្លួនដែលចេះតែចាយពុំចេះរក, សីហនុក៏តាំងខំធ្វើកុន ធ្វើល្ខោន បង្កើតមេជាយលក់វែយកលុយ រហូតដល់បើកកាស៊ីណូឆ្នាំ ១៩៦៩ នាំឲ្យរាស្ត្រអន្តរាយហិនហោចមិនតិចៗ*

ដោយស្ថានការណ៍ស្រុកកាន់តែលិចលង់សស្រឹមនេះ ហើយដែលមានយួនយៀកកុងចោរក្រពើប្រវត្តិ-សាស្ត្រប្រចាំជាតិ កំពុងតែហាមាត់ប្រុងត្របាក់លេបយកទៅផងនេះ សីហនុចំប្រប់មែនទែន ចង់ដោះដៃពីទំនួលខុសត្រូវ ក៏តាំងហៅលោក លន់-នល់ សិរិមតៈ ឲ្យមកជួយស្តារនាវាកម្ពុជានេះ ដោយឲ្យនាមរដ្ឋាភិបាលលោក លន់-នល់ ថា រដ្ឋាភិបាលស្រោចស្រង់ជាតិ (Gouvernement de Sauvetage) ហើយឲ្យទទួលខុសត្រូវចំពោះមុខប្រវត្តិសាស្ត្រ (ខែសីហា ១៩៦៩)។

កត់សំគាល់ជាលំដាប់មកប៉ុណ្ណេះ ខ្ញុំចេះតែនឹកមមៃថា មិនយូរទេ ស្រុកខ្មែរមុខជានឹងកាន់ប្រែ មិនខានទេ។ កំពុងគិត ស្រាប់តែភ្លូង! ថ្ងៃទី ១៨ មីនា ១៩៧០ ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រផ្ទុះឡើង សភាជាតិដែលជាតំណាងប្រជាជាតិខ្មែរទាំងមូល ដែលជាសភារបស់ស្តេចសីហនុរបស់សង្គមរាស្ត្រនិយម បានបោះឆ្នោតជាឯកច្ឆន្ទទំលាក់សម្តេចសីហនុពីប្រមុខរដ្ឋខ្មែរ!

មែន! សេចក្តីស្រមៃរបស់ខ្ញុំបានដើរដល់ភាពពិតហើយ។ ខ្ញុំមានអំណររកពាក្យនិយាយពុំបាន! ព្រឺខ្លួនចំពោះស្មារតីភ្ញាក់រលឹកនៃអស់លោកវរជនយើង បញ្ញវន្តយើង ព្រះសង្ឃយើង ប្រជាពលរដ្ឋយើង ដែលរួមគ្នាកំចាត់សីហនុ មេផ្តាច់ការតំណាងរបបរាជនិយមចុងក្រោយនេះឲ្យខ្ចាត់ទៅបាន។ តែប៉ុណ្ណេះ សីហនុអស់លក្ខណ៍ហើយ ហើយបើអាចត្រឡប់ចូលមកស្រុកវិញបាន សីហនុអស់មានភាពជាខ្លា ជារាជសីហ៍ទៀតហើយ តែគឺជាឆ្មាមួយប៉ុណ្ណោះ។ ខ្ញុំយល់ជាស្រេច។

ដោយខឹងឃោរនឹងគេទម្លាក់ខ្លួន ស្តេចកន្ត្រៀនេះដែលស្ថិតនៅឯប៉េកាំងស្រាប់ផង មានលទ្ធភាពគ្រប់គ្រាន់នឹងធ្វើការសងសឹកមកលើខ្មែរ ក៏ពន្យុះយួនយៀកកុងយៀកណាមខាងជើងដែលមានស្រាប់នៅលើដីខ្មែរ ឲ្យវាយខ្មែរគគ្រឹកគគ្រេងតែម្តង នាចុងខែមីនា ១៩៧០ និងតៗ មក។

ទល់នឹងស្ថានការណ៍ប្រថុចញ៉ុចនេះ លោកសេនាប្រមុខ លន់-នល់ បានថ្លែងសារហាហៅខ្មែរឲ្យជួយប្រយុទ្ធ ហើយលោកប្រមូលអ្នកនយោបាយគ្រប់និន្នាការទាំងអស់ ឲ្យចូលជួយស្តាបនាជាតិជាមួយនឹងលោក។ គ្រានោះទឹកចិត្តខ្មែរ ឈាមខ្មែរអ្នកចម្បាំង មានការពេញចិត្តចំពោះលោកសេនាប្រមុខ លន់-នល់ យ៉ាងខ្លាំង ទាហាន ២៤ ម៉ោងកើតឡើងព្រោងព្រាតជួយស្រុក។ រឿងនេះអស់លោកភាគច្រើនណាស់បានដឹងបានចាំទុកដែរ។

ឯរូបខ្ញុំត្រូវលោកសេនាប្រមុខ លន់-នល់ នាយករដ្ឋមន្ត្រី និងជានាយអគ្គសេនាធិការកងយោធពលខេមរជាតិ ហាហៅទៅបំពាក់សក្តិឋានៈជាវរសេនិយត្រី បំរើកងទ័ពតទៅ។

គឺខ្ញុំពេញចិត្តណាស់ទៅហើយ ដោយខ្ញុំបានមានឱកាសនឹងបំរើនយោបាយថ្មីរបស់រដ្ឋាភិបាលស្រោចស្រង់ជាតិយ៉ាងពេញទំហឹង។ ខ្ញុំដែលលាក់ខ្លួនពួនអាត្មាអស់កាលជិតម្ភៃឆ្នាំក្នុងរបបរាជនិយមនោះ ពេលនេះត្រូវតែផុសឡើងវិញ។

- ខែឧសភា ១៩៧១ ខ្ញុំបានត្រូវតែងតាំងជាអនុរដ្ឋលេខាធិការក្រសួងធម្មការ
- ថ្ងៃ ២៨ មីនា ១៩៧២ ខ្ញុំបានត្រូវតែងតាំងជាឧបការីនៃលោកសេនាប្រមុខ លន់-នល់ ប្រធានាធិបតី
- ហើយខែកញ្ញា ១៩៧២ ខ្ញុំបានចូលរួមក្នុងគណបក្សសង្គមសាធារណរដ្ឋ ជាប់ឆ្នោតជាសមាជិកសភាជាតិនីតិកាលទីមួយសព្វថ្ងៃនេះ។

រឿងចូលគណបក្សនេះ មានគេដណ្តឹងសួរថាហេតុអ្វីបានជាខ្ញុំចូល បោលឯគណបក្សប្រជាធិបតេយ្យរបស់ខ្ញុំពីមុន?

ខ្ញុំសូមជំរាបក្នុងវង់ក្រចកថា ដោយខ្ញុំសង្កេតឃើញគោលបំណងនៃគណបក្សនេះសមរម្យល្មម ឲ្យរួបរួមជាមួយកើតនេះម្យ៉ាង ម្យ៉ាងទៀត ចង់ចូលទៅជួយតម្រែតម្រង់ខ្មែរគ្នាយើងឲ្យឆ្ពោះទៅទិសតែមួយផង។ ខ្ញុំមិនយល់សោះ ចំពោះអ្នកខ្លះដែលចេះតែមានះ មិនជួយគ្នាសោះ ដោយគិតតែពីជួយគណបក្សទៅវិញ ចង់ជាតិលិចលង់ដល់ណាដល់ណីក៏ដោយ។ អ្នកកាន់ការរដ្ឋនោះជាគ្នាគេ អញមិនរវល់ទៅបៀតទេ ចាំគណបក្សអញ គ្នាអញឡើងកាន់ការសឹមអញរវល់ជាមួយ។

ខ្ញុំមិនដែលគិតដូច្នេះទេ ហើយចំពោះមិត្តខ្ញុំខាងគណបក្សប្រជាធិបតេយ្យ ក៏ខ្ញុំមិនដែលចោលដែរ មិនដែលស្អប់ទេ នៅតែតាមរាប់អាន នៅតែស្រឡាញ់ ឧទាហរណ៍ច្បាស់សពលោក ប៉ាច-ឈឹន (ថ្ងៃ១៦តុលា១៩៧១) សពលោក ជុំ-មួង (ពីថ្ងៃ១១មីនា១៩៧៣) គឺមានរូបខ្ញុំជាអ្នកចាត់ចែងលើកដាក់រៀបចំដោយផ្ទាល់ៗ ដែរ។ យើងបែកពីគណបក្សគ្រាន់តែជាការផ្លាស់បរិយាកាស ខ្វែងយោបល់គ្នាប៉ុណ្ណោះ ទិដ្ឋភាពនយោបាយយើង ប្រកាន់យកដដែលដូចគ្នាក្នុងរឿងប្រទេសជាតិ នៅស្រុកអាមេរិកមានអ្នកខ្លះចេញពីគណបក្សប្រជាធិបតេយ្យ ទៅចូលគណបក្សសាធារណរដ្ឋ អីចឹងដែរ។ ខ្ញុំយល់ថាវាដូចជាទុទិដ្ឋិនិយមពេក បើយើងប្រកាន់តែគណបក្សមួយៗ។

ឥឡូវខ្ញុំសូមវិលបែរមកពោលអំពីចរិតខ្មែរ ក្រោយ ១៨ មីនា ១៩៧០ តមកទៀតនេះ តើមានខុសប្លែកប៉ុន្មានពីរបបរាជនិយមទេ? ផ្លាស់តែរបប ប៉ុន្តែមនុស្សមានផ្លាស់ទាំងអស់គ្នាឯណា? ខួរក្បាលខ្មែរ ចរិតខ្មែរ មានផ្លាស់ឯណា? គំនិតចង់ធំដាច់តែឯង, គំនិតរិះគន់ឈ្នានីសគ្នា, គំនិតកាប់សម្លាប់បំបាត់ជីវិតគ្នា, គំនិតប្រទូសរ៉ាយគ្នាគ្មានឈប់ឈរ, គំនិតបក្សពួកនិយម អញនិយម, មើលងាយគេ អានោះមិនកើត អានេះមិនផេះ អានេះអីចេះ អានោះអីចុះ... មិនដល់ពួកយើងទេ, ។ល។ និង ។ល។ នៅមានដដែលក្នុងសង្គមខ្មែរ។

*      *

*

# ១០

# តើរបបថ្មីនេះ ខ្មែរមានផ្លាស់ ចរិត ទេ?

ខ្ញុំសូមរំលឹកឡើងវិញ នូវហេតុការណ៍ទាំងឡាយដែលសឲ្យឃើញថា យើងចេះតែមានចរិតប្រឆាំងគ្នាដូចដែលនិយាយមកហើយនេះដូចតទៅ ៖

ក្នុងឆ្នាំ ១៩៧០ មុនដំបូងវរជនយើង ប្រជាពលរដ្ឋយើងរួបរួមគ្នាល្អណាស់ៗ ទាំងលោក សឺង-ង៉ុកថាញ់ ប្រមុខចលនាខ្មែរសេរីក៏បានចូលរួបរួមនឹងអស់លោកវរជន ១៨ មីនាដែរ ព្រមទាំងបញ្ជូនកងទ័ពលើកដំបូង បីម៉ឺននាក់មកជួយស្រោចស្រង់កម្ពុជាផង ឲ្យឆ្លងផុតពីគ្រោះថ្នាក់ជាដំបូងដែរ។ ទាំងអស់គ្នាធ្វើអ្វីធ្វើជាមួយគ្នា គ្មានវង់សហានសោះឡើយ ដរាបដល់ប្រកាសប្រទេសខ្មែរជាសាធារណរដ្ឋ កាលពីថ្ងៃ ៩ តុលា ១៩៧០ ទៀតៗ ឯសត្រូវចោមវាយយើងព្រោងព្រាត ប៉ុន្តែស្មារតីយើងគ្មានញ្ញោចញ៉ែរចំពោះខ្មាំងប៉ុន្មានទេ យើងសង្ឃឹមថា អាចនឹងកំចាត់សត្រូវទៅវិញបានៗ យើងមានសាមគ្គីមុតមាំណាស់ ទាំងវរជន ទាំងប្រជាពលរដ្ឋៗ

ប៉ុន្តែជាអកុសលរបស់យើងខ្មែរ ចូលមកឆ្នាំ ១៩៧១ ខែកុម្ភៈ លោក លន់-នល់ ត្រូវមានជម្ងឺខូចដៃឆ្វេងជើងឆ្វេង ហើយត្រូវចេញទៅព្យាបាលនៅបរទេស រហូតដល់ថ្ងៃទី ១២ មេសា ទើបត្រឡប់មកវិញៗ ស្ថានការណ៍ក្នុងស្រុកដូចជាល្អក់ខ្វល់ព្រោះនៅថ្ងៃទី ២០ មេសា ១៩៧១ លោក លន់-នល់ ដាក់ពាក្យសុំលាលែងពីដំណែងនាយករដ្ឋមន្ត្រី ចំពោះលោក ចេង-ហេង ប្រមុខរដ្ឋៗ ថ្ងៃ ២១ មេសា

លោក ចេង-ហេង អនុញ្ញាតតាមពាក្យសុំរបស់លោក លន់-នល់ តែលោកសុំឲ្យលោក លន់-នល់ រៀបចំគណៈរដ្ឋមន្ត្រី។

- ថ្ងៃ ២៧ មេសា នៅវិមានរដ្ឋចំការមន លោកប្រមុខរដ្ឋ ដោយមានសភាទាំងពីរ និងរដ្ឋមន្ត្រីឃោសនាការចូលរួមផង បានជួបសន្ទនាជាមួយអង្គការសារពតិមានជាតិដើម្បីប្តូរយោបល់រឿងវិបត្តិគណៈរដ្ឋមន្ត្រី។
- ថ្ងៃ ២៨ មេសា លោក លន់-នល់ ជូនដំណឹងទៅលោក ចេង-ហេង វិញថា លោកពុំអាចរៀបចំគណៈរដ្ឋមន្ត្រីបានទេ។
- ថ្ងៃ ២៩ មេសា ដោយលោក នល់-នល់ ពុំអាចតែងតាំងគណៈរដ្ឋមន្ត្រីបាន លោកប្រមុខរដ្ឋក្រោយពីបានពិគ្រោះជាមួយប្រធានរដ្ឋសភា និងប្រធានក្រុមប្រឹក្សាសាធារណរដ្ឋ (កាលណោះហៅដូច្នោះ) ក៏បានស្នើលោក ស៊ីសុវត្ថិ សិរិមតៈ ឲ្យរៀបចំគណៈរដ្ឋមន្ត្រី។ លោក សិរិមតៈ ថា ចាំគិតមើលសិន។
- ថ្ងៃទី ៣០ មេសា លោក សិរិមតៈតបទៅលោក ចេង-ហេង វិញថា លោកស្តាយណាស់ដោយពុំអាចតែងតាំងគណៈរដ្ឋមន្ត្រីថ្មីបាន ពីព្រោះ ៖ ទី ១ លោកជារដ្ឋមន្ត្រីចាស់ចង់ឲ្យអ្នកថ្មីកាន់ការម្តង, ទី ២ ស្រុកកំពុងកើតសង្គ្រាមវល់ធ្វើសង្គ្រាម។ លោក ចេង-ហេង អស់ផ្លូវក៏ស្នើទៅលោក ជួប-ហ៊ែល អតីតប្រធានរដ្ឋសភា ឲ្យតែងតាំងគណៈរដ្ឋមន្ត្រី។
- ថ្ងៃទី ១ ឧសភា លោក ជួប-ហ៊ែល ឆ្លើយតបទៅវិញថាលោកពុំអាចជ្រើសរើសគណៈរដ្ឋមន្ត្រីបានទេ។ លោក ចេង-ហេង ក៏ចាត់ឲ្យលោក អ៊ិន-តាំ ប្រធានសភាជាតិជ្រើសតាំងគណៈរដ្ឋមន្ត្រី។
- ថ្ងៃ ៣ ឧសភា លោក អ៊ិន-តាំ បានឆ្លើយតបថាលោកពុំអាចជ្រើសតាំងគណរដ្ឋមន្ត្រីបានទេ។

ទៅឯណោះពុំអាចទៅឯណោះពុំអាច ក៏តាំងប្រជុំទាំងអស់គ្នាតែម្តង គឺលោក ចេង-ហេង, លោក លន់-នល់, លោក ស៊ីសុវត្ថិ សិរិមតៈ, លោក អ៊ិន-តាំ, លោក អ៊ុង-ស៊ឹម។ ទាំងអស់គ្នាតម្រូវឲ្យលោក លន់-នល់ ជ្រើសតាំងគណៈរដ្ឋមន្ត្រី។

ទំរាំតែនិយាយត្រូវគ្នា ព្រមធ្វើការជាមួយគ្នា យើងមានវិបត្តិគណៈរដ្ឋមន្ត្រីអស់ពេលកន្លះខែលេងទទេ។

- ថ្ងៃទី ៥ ឧសភា សមាជិកនៃគណៈរដ្ឋមន្ត្រី បានចូលទៅបង្ហាញខ្លួននៅទីស្តីការនាយករដ្ឋមន្ត្រី។ សមាជិកសំខាន់ គឺលោក លន់-នល់ ជានាយករដ្ឋមន្ត្រី, លោក សិរិមតៈ ជានាយកប្រតិភូ, លោក អ៊ិន-តាំ ជាឧបនាយករដ្ឋមន្ត្រីទី ១, លោក សុខ-ធុង ជាឧបនាយករដ្ឋមន្ត្រីទី ២, លោក ហង្ស-ធុនហាក់ ឧបនាយករដ្ឋមន្ត្រីទី ៣។

អស់លោកអ្នកនៅកត់សំគាល់ឃើញថា អស់លោកវរជនទាំងអស់នេះ នៅរួបរួមគ្នាគួរសរសើរ។

ក្នុងខែមិថុនា-កក្កដា បញ្ហាខ្វះអង្ករបានចោទឡើងគួរឲ្យព្រឹក្សាលរហូតដល់ធ្លាក់លោក យ៉េង-ថៃលី ពីដំណែងរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និង ផ្គត់ផ្គង់ការ។

ក្រឹត្យ ៤៦៨/៧១ប.វ. ចុះថ្ងៃ ២៩-៥-៧១ តាំងគណៈកម្មការចំរុះទូលំទូលាយ ទទួលបន្ទុករៀបចំសេចក្តីព្រាងដើមរដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋខ្មែរមានសមាជិក ៣ នាក់ តំណាងអង្គការរដ្ឋនិមួយៗ និងសមាគមនិមួយៗ។ រយៈពេលធ្វើរដ្ឋធម្មនុញ្ញ : ៣ ខែ។

ថ្ងៃ ១៦ មិថុនា ១៩៧១ ម៉ោង ៩ ព្រឹក លោក សិរិមតៈ បានបើកពិធី (ប្រកាសនាយកលេខ ១១១១-៧១) ឲ្យគណៈកម្មការចាប់ធ្វើការរបស់ខ្លួន។ គណៈកម្មការចំរុះមានសមាជិកទាំងអស់ ២៣១ នាក់ ដែលមានខ្ញុំ ប៉ុណ្ណចន្ទ-ម៉ុល ម្នាក់ផងតំណាងពុទ្ធិកសមាគមមជ្ឈមណ្ឌលសាធារណរដ្ឋ។ គណៈកម្មការចំរុះដោយមានលោក មាស-សាឯម ជាព្រឹទ្ធប្រធានបណ្តោះអាសន្ន បានបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានទាំងពីរនិងគណៈកម្មការតែងសេចក្តី ១៥ នាក់។ លទ្ធផលនៃការបោះឆ្នោត គឺ ប្រធាន លោក សូ-ណែម, អនុប្រធានទី១ លោក ឱុក-ក៉ាស៊ី, អនុប្រធានទី ២ លោក ទ្រិញ-វ៉ាញ។

គណៈកម្មការចំរុះនេះបានធ្វើការយ៉ាងសកម្មមក។

- ថ្ងៃ ៦ សីហា ១៩៧១ លោក សិរិមតៈ ទៅសហរដ្ឋអាមេរិក រហូតដល់ថ្ងៃ ៣០ សីហា ទើបត្រឡប់មកវិញ បានជោគជ័យត្រចះត្រចង់។
- ថ្ងៃសៅរ៍ ទី ៤ កញ្ញា លោក សិរិមតៈ បានធ្វើសន្និសីទមួយរាយការណ៍អំពីលទ្ធផលដែលលោកបានទៅទាក់ទងនឹងសហរដ្ឋអាមេរិក ហើយលោកថា ឲ្យតែយើងរួបរួមគ្នាយ៉ាងល្អតទៅទៀត គេនឹងកាន់តែជួយយើងទ្វេរឡើងទៀត។ ស្តាប់លោក សិរិមតៈ នាំឲ្យសប្បាយចិត្តណាស់។ គឺត្រូវតែសាមគ្គី ប៉ុន្តែទន្ទឹមនឹងពេលនោះ មិនដឹងហេតុដូចម្តេច ស្រាប់តែនៅរដ្ឋសភាឯណោះ តំណាងរាស្ត្រ ៣៦ នាក់ ធ្វើញត្តិសុំដកលោក យ៉ែម-សំបូរ ចេញពីតំណែងប្រធាន។
- ថ្ងៃ ១៦ ខែកញ្ញា ១៩៧១, ក្រោយពីពេលជជែកគ្នាបែកផ្សែងមក ក្នុងរឿងទម្លាក់លោក យ៉ែម-សំបូរ រដ្ឋសភាបោះឆ្នោតសម្ងាត់មាន ២៤ សម្លេងឲ្យទម្លាក់តាមញត្តិ មាន ៣១ សម្លេងឲ្យទុក។ ដូច្នេះលោក យ៉ែម-សំបូរ នៅតទៅទៀត។ ជជែកគ្នានោះនាំឲ្យមនុស្សបែកសាមគ្គីមិនតិច។ បន្ទាប់នោះ នៅស្ងៀមៗ ស្រាប់តែថ្ងៃ ២៤ កញ្ញា លោក អ៊ិន-តាំ ដែលជាឧបនាយករដ្ឋមន្ត្រីទី ១ និងជាឧត្តមសេនីយត្រីនោះ ត្រូវដកចេញពីតំណែងទាំងអស់ ប្តូរតំណែងនេះជូនទៅលោក ទឹម-ង៉ួន ត្ពយ។ ប្រជាជនខ្មែរបែបស្ងើក ដោយឆ្ងល់។ យី! អស់លោកធំៗ ម៉េចក៏ដេញគ្នាចោលធូរម៉្លេះ?
- ក្រឹត្យលេខ ៥៧០/៧១ប.វ. ចុះថ្ងៃ ៤-១០-៧១ គណៈកម្មការចម្រុះតែងរដ្ឋធម្មនុញ្ញ ត្រូវបានពន្យាពេល ២ ខែ តទៅទៀត ប៉ុន្តែមិនដឹងហេតុដូចម្តេច ស្រាប់តែមានក្រឹត្យលេខ ៦០៩/៧១ប.វ. ចុះថ្ងៃ ១៦-១០-៧១ បង្កើតសភាធម្មនុញ្ញ ដោយបញ្ចូលសភាទាំងពីរ ចាប់តាំងពីថ្ងៃ ១៨ តុលា ១៩៧១ តទៅ។
- គណៈរដ្ឋមន្ត្រីជ្រើសរើសថែមថ្មី គឺលោក ទឹម-ង៉ួន ឧបនាយករដ្ឋមន្ត្រីទី ១ ទទួលបន្ទុកទីស្តីការនាយករដ្ឋមន្ត្រី និងការសម្របសម្រួលខាងមហាផ្ទៃ សន្តិសុខជាតិ ធម្មការយុត្តិធម៌ សាធារណការ និងទេពកោសល្យជនបទ។
- លោក ធន-សុខុម ទេសរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មនិងសប្បិយកម្ម។
- លោកឧត្តមសេនិយត្រី ឋាប្បណាង៉ិន្ទ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សន្តិសុខជាតិ និងកម្មការ។

- លោក ម៉ាឡាយ-ខេម រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងផ្គត់ផ្គង់សម្ភារៈ។

ថ្ងៃទី ២០ តុលា ព្រះសង្ឃនៅភ្នំពេញបានធ្វើបាតុកម្មស្ងប់ស្ងាត់នៅមុខវត្តអារាម ទាមទារឲ្យលោក លន់-នល់ ធ្វើប្រមុខរដ្ឋ ព្រមទាំងបិទពាក្យស្លោក សុំឲ្យតម្រឹមតម្រង់នូវកិច្ចការរដ្ឋទាំងឡាយដែលល្អៀងឃ្លៀងឃ្លាត។

- ថ្ងៃទី ៨ វិច្ឆិកា ១៩៧១ លោក ចេង-ហេង បើកពិធីប្រកាសជាផ្លូវការនូវសភាធម្មនុញ្ញ។ ពេលនោះសភាធម្មនុញ្ញបោះឆ្នោតជ្រើសតាំងប្រធាននិងអនុប្រធាន បានលទ្ធផល លោក អ៊ិន-តាំ ជាប្រធាន, លោក ពិន-យ៉ឹន ជាអនុប្រធានទី ១, លោក កើត-គីហ៊ាង អនុប្រធានទី ២។

យើងឃើញថា លោក អ៊ិន-តាំ ដែលគេហូតឆាករនោះ ត្រូវមានមុខចេញមកទៀតតាមរយៈសភាធម្មនុញ្ញនេះ។

សូមជម្រាបថា ស្ថានការណ៍សឹកពេលនោះ យើងវាយទៅកាន់ខេត្តកំពង់ធំ បានទៅដល់ភ្នំសន្ទុក ស្រាប់តែថយមកវិញក្រាកៗ អស់រលីង ហើយស្ថានការណ៍ខាងលិចភ្នំពេញ (ទួលលៀប) ក៏កម្រើកយ៉ាងធ្ងន់ធ្ងរគួរព្រួយបារម្ភ តែបានធូរទៅវិញនៅចុងខែធ្នូ ១៩៧១ នោះ។

សង្ឃឹមថា ឆ្នាំ ១៩៧២ បែបបានស្រួល ប៉ុន្តែមិនដូច្នោះ បែរជាមានរឿងតៗ ទៀត :

- ថ្ងៃទី ៨ មិនា ១៩៧២ ស្រាប់តែមានញត្តិរបស់និស្សិតមហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជូនសភាធម្មនុញ្ញ សូមស្នើម៉ឺងម៉ាត់ មិនឲ្យដាក់ក្នុងកាលៈទេសៈណាដែលការបោះឆ្នោតពុំអាចប្រព្រឹត្តទៅបាននោះ បុគ្គលណាមានឈាមជ័រជាស្តេចឲ្យកាន់តំណែងធំៗរបស់សាធារណរដ្ឋខ្មែរ ដូចមានចែងខាងក្រោមនេះ

  ១- ប្រធានាធិបតី
  
  ២- អនុប្រធានាធិបតី
  
  ៣- នាយករដ្ឋមន្ត្រី ឬ រដ្ឋមន្ត្រី
  
  ៤- នាយអគ្គសេនាធិការកងយោធពលខេមរជាតិ

- ថ្ងៃ ៩ មីនា និស្សិតប្រជុំយ៉ាងធំនៅសាលសន្និសីទចតុមុខ ហៅថាសមាជយុវជន មានបិទបដាព្រោងព្រាតសុទ្ធតែពាក្យស្លោកថា : កុំករយុវជន, អធ្យាស្រ័យមនុស្សពុករលួយគឺក្បត់ជាតិ, កុំចែកអំណាចដូចចែកនំគ្នាស៊ី ។ល។

នៅទីបញ្ចប់ សមាជសម្រេចថា :

«យើងជាយុវជនលែងទុកចិត្តរដ្ឋាភិបាលលោកឧត្តមសេនិយ សិរិមតៈ ហើយ»

ស្អែកឡើងថ្ងៃ ១០ មីនា ១៩៧២ នៅកំពែងវត្តកោះ វត្តលង្កា មានបដាគាំទ្រសេចក្តីសំរេចចិត្តរបស់សមាជយុវជន។ ក្នុងល្ងាចនោះ លោក ចេង-ហេង ថ្លែងតាមវិទ្យុថា លោកអស់លទ្ធភាពនឹងបំរើប្រទេសក្នុងឋានៈជាប្រមុខរដ្ឋតទៅទៀតហើយ លោកសុំផ្ទេរឋានៈនេះទៅលោក លន់-នល់ វិញ។

មិនតែប៉ុណ្ណោះ ម៉ោង ២១ យប់ លោក លន់-នល់ ក្នុងសាររបស់លោក ដែលទទួលឋានៈប្រមុខរដ្ឋពីលោក ចេង-ហេង លោកក៏បានឲ្យសភាធម្មនុញ្ញឈប់ចប់សកម្មភាពទៅដែរ។

នៃ៎! វាទៅជាអីចឹង និស្សិតមិនទុកចិត្តលោក សិរិមត: វាទៅជាអស់មានលោក ចេង-ហេង ហើយមករលីងឯសភាធម្មនុញ្ញ! ស្មុគស្មាញសម្បើម!

- ថ្ងៃ ១២ មីនា លោកប្រមុខរដ្ឋ លន់-នល់ បានថ្លែងសារកែប្រែឋានៈប្រមុខរដ្ឋ ឲ្យទៅជាមានប្រធានាធិបតី ដោយចែងថា :

១- ប្រមុខរដ្ឋខ្មែរ
នឹងមានឈ្មោះជាប្រធានាធិបតីនៃសាធារណរដ្ឋពីត្រឹមណោះទៅ។

២- ប្រធានាធិបតីនៃសាធារណរដ្ឋខ្មែរ
ជាអគ្គមេបញ្ជាការនៃកងយោធពលខេមរ ជាតិ។

៣- ប្រធានាធិបតីនៃសាធារណរដ្ឋខ្មែរ
ទទួលខ្លួនឯងនូវមុខងារជានាយករដ្ឋមន្ត្រី។ ក្នុង កិច្ចការនេះ ប្រធានាធិបតីមានរដ្ឋមន្ត្រីទី ១ ម្នាក់ជាជំនួយ ដើម្បីសម្របសម្រួលសកម្មភាពនិងកិច្ចការនៃសមាជិកទាំងឡាយ នៃគណៈរដ្ឋមន្ត្រី។ មានទីប្រឹក្សានិង ឧបការីអមផង។ មានខុទ្ទកាល័យនីតិប្រតិបត្តិមួយ និងក្រុមប្រឹក្សាជាតិខាងសន្តិ សុខជាជំនួយផង។

លោក លន់-នល់ ធ្វើបុណ្យសម្ពោធឋានៈរបស់លោកនៅថ្ងៃទី ១៤ មីនា ១៩៧២ ដោយមានព្រះសង្ឃ ១០៨ អង្គ ឧត្តមសេនិយ វរសេនិយ និងឲ្យប្រជាពលរដ្ឋស្រីប្រុសចូលរួម។

ការនេះខ្មែរសង្ឃឹមថាបានសុខស្រួលហើយ មិនដឹងជាយ៉ាងម៉េច ស្រាប់តែមានវិបត្តិគណៈរដ្ឋមន្ត្រីទៀត វីវរវល់នឹងរកវរជនម្នាក់ឲ្យមកជ្រើសរើសគណៈរដ្ឋមន្ត្រីថ្មី។ រកឯណោះពុំបាន ឯណោះពុំកើត ក៏ទៅហៅលោក សឺង-ង៉ុកថាញ់ ពីព្រៃនគរឲ្យមករៀបចំគណៈរដ្ឋមន្ត្រី។

យើងវវល់នឹងរឿងនេះ ក៏ស្រាប់តែខ្មាំងស្រោចគ្រាប់រ៉ុក្កែតចូលក្រុងពីរាត្រីទី ២០ ទៅ ២១ មីនា យ៉ាងសម្បើម ស្លាប់អស់មនុស្ស ១១២ នាក់ គួរឲ្យឈឺចាប់ណាស់។ ខ្ទេចវិទ្យុស៊ីងមានជ័យ។

លោកប្រធានាធិបតី លន់-នល់ ថ្លែងសាររឿងនេះថាប្រាកដជាមានអ្នកក្នុងឲ្យដៃ។

ឯចំណែកលោក សឺង-ង៉ុកថាញ់ ក៏បានរៀបចំគណៈរដ្ឋមន្ត្រីតាមឧវាទរបស់លោក លន់-នល់ ទៅតាមរបៀប Régime Présidentiel ។

ស្រាប់តែថ្ងៃ ២៤ មីនា គេឃើញខិតប័ណ្ណប្រឆាំងនឹងលោកគ្រូ ខៀវ-ជុំ ដែលចេះតែចប្រប់អារ៉ាប់ទៅជំនុំជាមួយសិស្ស នាំឲ្យមានបរិយាកាសមិនល្អ។

ហើយសម្តេចព្រះសង្ឃរាជគណៈមហានិកាយក៏ត្រូវបង្ខំព្រះទ័យឲ្យថ្លែងសារមួយ បន្ទោសលោកគ្រូ ខៀវ-ជុំ ដែរ។

ថ្ងៃ ២៨ មីនា មានបដាព្រោងព្រាតនៅតាមមហាវិទ្យាល័យនានាថា:

- កុំកេណ្ឌរាស្ត្រឲ្យស្រែក ជយោ!
- កុំចោទយុវជនថាបង្កើតអានាធិបតេយ្យ !
- កុំទេចចោលឲ្យអស់កំអែលសក្តិភូមិ !
- ទៅហើយ មកវិញខ្មែ !

ហើយនៅថ្ងៃ ២៩ មីនា នៅសាកលវិទ្យាល័យភ្នំពេញ មានសមាជយុវជនមួយ ការពារលោក តា ប៉ាង-ខាត់ និង ខៀវ-ជុំ ដែលចេះតែឧស្សាហ៍មកចូលរួមប្រជុំជាមួយសិស្ស តាមសេចក្តីនិមន្តរបស់សិស្ស។

ស្ថានការណ៍វឹកវរ៉ល់របស់សិស្សនេះ បានលាតវែងអន្លាយរហូតដល់ថ្ងៃ ២៣ មេសា ១៩៧២ មហាវិទ្យាល័យច្បាប់ត្រូវអាជ្ញាធរអាវុធហត្ថព័ទ្ធជុំវិញ។ នៅក្នុងនោះ មានលោក កែវ-អន និងនិស្សិត កុយ-ប៊ុច។

ឯលោក ស៊ីង-ង៉ុកថាញ់ ប្រកាសក្នុងថ្ងៃនោះឲ្យសិស្សនៅឲ្យស្ងៀម កុំរំជើបរំជួល។

ថ្ងៃ ២៦ មេសា ស្ថានការណ៍អាប់អួបានកើតឡើង ក្រុមបាតុកររាប់ពាន់នាក់ ដែលបានទម្លាយរនាំងហាមឃាត់កាលពីព្រឹកនោះ បានស្ថិតនៅមុខមហាវិទ្យាល័យច្បាប់ មានមីក្រូស្រែកជៀមជាមឲ្យរដ្ឋាភិបាល។ ហើយម៉ោង ១៧ ក៏នាំគ្នាចោលដុំថ្មមកលើអាវុធហត្ថ អាវុធហត្ថក៏ចោលគ្រាប់បែកផ្សែងព្រមទាំងស្នូរកាំភ្លើងអស់ ៥ នាទី បាតុកររត់ជាន់គ្នា។ បាតុករស្រែកជេរពួកអាវុធហត្ថយ៉ាងខ្លាំង។ ស្អែកឡើងទៀតអធិករណ៍មានតទៅទៀត បាញ់គ្នាច្រង៉ាប់ច្រងិលនៅទីនោះ។

នេះជាលើកទី ១ ហើយ ដែលអធិករណ៍កើតឡើងរវាងសិស្ស និងអាជ្ញាធរ។

លោក ថាច់-ជា រដ្ឋមន្ត្រីក្រសួងអប់រំជាតិ សូត្រតាមវិទ្យុអំពាវនាវឲ្យសិស្សដាក់អាវុធចុះនៅម៉ោង ១៤ ថ្ងៃទី ២៧ មេសា។

ថ្ងៃ ២៨ មេសា បាតុកម្មយ៉ាងធំនៅវិមានឯករាជ្យ សិស្សពាក់កំណាត់ខ្មៅនៅអាវ និងជួតក្បាលកំណាត់ស មានទម្លាក់ជាយបីដូចកាន់ទុក្ខខ្មោចចិន-យួន តែគេកាន់ទុក្ខខ្មោចគ្នាគេដែលថាអាវុធហត្ថបាញ់សម្លាប់នោះ។ មានបដាជេររដ្ឋាភិបាលយ៉ាងសម្បើម : បាញ់យុវជនគឺជាទមិឡ ! បរាជ័យរដ្ឋាភិ-បាលផ្តាច់ការ ស៊ីង-ង៉ុកថាញ់ សម្លាប់យុវជន មានតែរដ្ឋាភិបាលខ្មែរទេ ដែលសម្លាប់យុវជន !

ហើយគេឃោសនាគគ្រឹកគគ្រេង បានប្រាក់កាសសន្ធឹក។ ពេលនោះនិស្សិត កុយ-ប៊ុច ដែលជាមេនៃរឿង បែរជាមកប្រកាសតាមវិទ្យុសុំទោសរដ្ឋាភិបាលក្តុយ។

- លោក លន់-នល់ ថ្លែងសារសុំឲ្យសិស្សដែលធ្វើបុណ្យនៅវិមានឯករាជ្យនោះ ឈប់ធ្វើបុណ្យដែលគ្មានខ្មោចនោះតទៅទៀត ដើម្បីឲ្យមានរបៀបរៀបរយក្នុងសង្គម។ លោកថាខ្មាំងកំពុងរារាំងយើងកុំឲ្យបោះឆ្នោតបាននៅថ្ងៃ ៣០ មេសា លោកសុំឲ្យសិស្សស្ងប់ចាំបោះឆ្នោតអនុមតិលើគម្រោងរដ្ឋធម្មនុញ្ញសិន។ តែសិស្សលែងស្តាប់ គេនៅតែទៅ នៅដេកជុំវិញវិមានឯករាជ្យបន្តបុណ្យដដែល។

សុំរំលឹកថា ពេលនោះចំថ្ងៃពិសាខបូជាផង បុណ្យពិសាខបូជា គេធ្វើគ្រវីសគ្រវាសឲ្យរួចតែពីដៃ ព្រោះវល់នឹងរឿងចលាចលសិស្សនៅវិមានឯករាជ្យនោះ។

ថ្ងៃ ៣០ មេសា ១៩៧៣ ជាថ្ងៃបោះឆ្នោតបញ្ចេញមតិលើគម្រោងរដ្ឋធម្មនុញ្ញថ្មី។ ទាហាននិងស៊ីវិលក៏បានទៅបោះឆ្នោត ទោះបីខ្មាំងកៀបសង្កត់និងគម្រាមកំហែងយ៉ាងណាក៏ដោយ។ រដ្ឋធម្មនុញ្ញនេះ អ្នកខ្លះថាមិនល្អ មិនកើត អ្នកខ្លះថាដូច្នេះ ខ្លះថាដូច្នោះ គឺថាយើងគ្មានឯកភាពអ្វីទេ។ ប៉ុន្តែដោយប្រទេសនិមួយៗ ត្រូវតែមានរដ្ឋធម្មនុញ្ញនោះ រដ្ឋាភិបាលត្រូវតែបង្ខំឲ្យចេញច្បាប់នោះខានពុំបាន ល្អអាក្រក់ចាំកែកុនថ្ងៃក្រោយ។

- *វដ្តធម្មនុញ្ញសាធារណរដ្ឋខ្មែរ ត្រូវលោកប្រធានាធិតី លន់-នល់ ប្រកាសឲ្យប្រើនៅថ្ងៃទី ១២ ឧសភា ១៩៧២ តមកៗ*

*ចប់រឿងនេះ កំលេចរឿងរបស់បុគ្គលិកសិក្សាធ្វើកូដកម្មចំពោះរឿងដែលរដ្ឋាភិបាលបញ្ចុះក្របខ័ណ្ឌបុគ្គលិកសិក្សា ពីប្រភេទ «ខ» មកនៅប្រភេទ «គ» វិញៗ*

- *កូដកម្មបុគ្គលិកនៅក្រសួងមហាផ្ទៃទាំងពីរប្រភេទ គឺលេខាធិការ-លេខហារី ទាមទារក្របខ័ណ្ឌឲ្យស្មើនិងក្របខ័ណ្ឌគ្រូបឋមសិក្សា និងក្របខ័ណ្ឌភ្នាក់ងារនគរបាលជាតិៗ*
- *កូដកម្មបុគ្គលិកពន្ធនាគារអនុរក្ស ចំនួនប្រហែល ២០០ នាក់ ទាំងស្រីទាំងប្រុសទាមទារក្របខ័ណ្ឌរបស់ខ្លួនឲ្យស្មើនឹងក្របខ័ណ្ឌប៉ូលីសដែរ (ក្របខ័ណ្ឌ គ)ៗ*

*រដ្ឋាភិបាលល្វីងមុខរាល់ថ្ងៃៗ ពេលនោះដូចជាគ្មានមេគ្មានកោយមិនដឹងជាស្តាប់នរណាៗ ប៉ុន្តែយ៉ាងណាក៏ដោយ ប្រទេសខ្មែរត្រូវតែបោះឆ្នោតជ្រើសរើសប្រធានាធិបតីៗ*

- *ថ្ងៃទី ២១ ឧសភា ក្រសួងមហាផ្ទៃបានប្រកាសនាមបេក្ខជនប្រធានាធិបតី គឺមាន :*

  *លោក កែវ-អន អាយុ ៤១ ឆ្នាំ*

  *លោក លន់-នល់ អាយុ ៥៩ ឆ្នាំ*

  *លោក អ៊ិន-តាំ អាយុ ៥០ ឆ្នាំ*

*លោក អ៊ិន-តាំ និង លន់-នល់ មានដៃជើងឃោសនាគគ្រឹកគគ្រេងសម្បើមណាស់ ចុងចប់លោក លន់-នល់ ក៏បានជាប់ឆ្នោតទៅៗ*

*ថ្ងៃ ២១ មិថុនា លោក លន់-នល់ ថ្លែងសារឲ្យប្រជាពលរដ្ឋរួបរួមគ្នាទាំងអស់ ដើម្បីសំរេចគោលការ គឺ :*

- *រដ្ឋាភិបាលជួយ*
- *ប្រជាពលរដ្ឋដែលមានសេរីភាព ជាអ្នកកសាងជីវភាពខ្លួនឯង*
- *អ្នកបច្ចេកទេសជួយឧបត្ថម្ភ ជួយបង្ហាត់បង្រៀននិងជួយដឹកនាំៗ*

*អង្គការរួបរួមគ្នានោះលោកឲ្យឈ្មោះថា: «អង្គការជាតិបង្រួបបង្រួមខ្មែរអ្នកជាតិនិយម» បារាំងហៅថា:* «Rassemblement National de l'Union Nationaliste.»

*ប៉ុន្តែហាក់គ្មាននរណាអើពើនឹងលោកសោះៗ*

*ប៉ុន្តែយ៉ាងណាក៏ដោយ ថ្ងៃទី ៣ និងទី ៤ កក្កដា ១៩៧២, លោក លន់-នល់ ក៏ត្រូវតែបានតែងតាំងជាប្រធានាធិបតីនៃសាធារណរដ្ឋខ្មែរយ៉ាងហ៊ឹកហ៊ាក់ដែរៗ*

*ពីនោះមកនេះ អស់លោកអ្នកអាចកត់សំគាល់បានថា វរជនយើងចាប់ផ្តើមបែកបាក់គ្នាមែនទែនហើយៗ ចូលមកក្នុងខែសីហា ១៩៧២ គណបក្សបីក្រុមក៏កើតឡើង ហើយមានកម្លាំងសម្បើមៗ គឺ គណបក្សសង្គមសាធារណរដ្ឋ ក្រោមការឧបត្ថម្ភរបស់លោក លន់-នល់, គណបក្សសាធារណរដ្ឋរបស់លោក សិរិមតៈ, គណបក្សប្រជាធិបតេយ្យ របស់លោក អ៊ិន-តាំៗ គណបក្សនិមួយៗ សុទ្ធតែមានសារពត៌មានផ្សាយរៀងៗ ខ្លួនៗ ហើយគេដឹងថា កាសែតដំណឹងពេលព្រឹក និងកាសែតខេមរាធិបតី ដែលសរសេរទ្រទ្រង់គណបក្សសាធារណរដ្ឋ និងរិះគន់រដ្ឋាភិបាលត្រង់ៗ នោះ គឺជាកាសែតបក្សពួករបស់សាធារណរដ្ឋដែរៗ ប្រជារាស្ត្រខ្មែរឡប់ស្មារតី មិនដឹងជាស្តាប់ខាងណា ជឿខាងណាទេៗ*

រឿងបោះឆ្នោតរើសតំណាងរាស្ត្រ សភាជាតិ ត្រូវប្រព្រឹត្តទៅនៅថ្ងៃទី ៣ កញ្ញា ១៩៧២; បោះឆ្នោតជ្រើសរើសព្រឹទ្ធសភាជាតិ ត្រូវប្រព្រឹត្តទៅ នៅថ្ងៃទី ១៧ កញ្ញា ១៩៧២។

ប៉ុន្តែអើយផ្តើមឡើង ស្រាប់គណបក្សសាធារណរដ្ឋរបស់លោក សិរិមតៈ បានផ្ញើលិខិតទៅជូនលោក លន់-នល់ មានចំណុច ៥ ខ សុំតវ៉ាអំពីបញ្ញត្តិបោះឆ្នោត លេខ ៨៥-៧២ បសខ ចុះថ្ងៃទី ១២-៧-៧២ ហើយក្រសួងមហាផ្ទៃបែរជាឆ្លើយជួសបានតែ ១ ខ ប៉ុណ្ណោះ គណបក្សនេះក៏សម្រេចថាៈ

១- មិនចូលរួមក្នុងការបោះឆ្នោតនោះទេ,

២- សូមដកសេចក្តីទុកចិត្តទាំងស្រុងពីរដ្ឋាភិបាលបច្ចុប្បន្ន,

៣- គណបក្សនៅតែរក្សាសិទ្ធិជាគណបក្សនយោបាយសកម្ម ។

ហើយកាសែតរបស់គណបក្សនេះ បានសរសេរយ៉ាងខ្លាំងៗសម្បើម ដូចជាសរសេរលើក្បាលកាសែតក្នុងថ្ងៃទី ១១ សីហា ១៩៧២ ថាៈ មនុស្សព្រៃធ្លាប់ប្រើច្បាប់ព្រៃ លុះដល់ចូលមកក្នុងស្រុក ក៏នៅតែប្រើច្បាប់ព្រៃដដែល, ការចេះថយដើម្បីដោះស្រាយបញ្ហាជាតិ ពុំមែនជាការកំសាកទេ គឺជាសេចក្តីក្លាហានក្នុងកិច្ចជាតិរស់ !

បន្ទាប់ពីគណបក្សសាធារណរដ្ឋដកថយមិនចូលប្រកួតបោះឆ្នោតនោះ គណបក្សប្រជាធិតេយ្យក្បាលដីរបស់លោក អ៊ិន-តាំ រួមប្រជុំល្ងាចថ្ងៃទី ៥ សីហា ក៏តាំងសម្រេចដែរថា :

១- ដកខ្លួនមិនចូលប្រឡូកក្នុងការបោះឆ្នោតទេ,

២- ថ្កោលកំហុសចំពោះការរំលោភជាអចិន្ត្រៃយ៍ ពីសំណាក់រដ្ឋាភិបាលទៅលើគោលសំខាន់ៗនៃលទ្ធិប្រជាធិបតេយ្យ និងរដ្ឋធម្មនុញ្ញ,

៣- សម្រេចមិនទទួលស្គាល់លទ្ធផលនៃការបោះឆ្នោតខាងមុខ ហើយទុកលទ្ធផលនោះថាគ្មានភាពតំណាងជាតិទាល់តែសោះ។

អស់លោកអ្នកឃើញហើយ នូវអ្នកដឹកនាំបដិវត្តន៍យើងបែកបាក់គ្នាប៉ុណ្ណា? យើងអាចនឹងរស់ទំហំនោះបានទេ?

ឯពួកគណបក្សសង្គមសាធារណរដ្ឋ ដែលបានមកលោក ហង្ស-ធុនហាក់ កាន់ងារជាអគ្គលេខាធិការនោះ ក៏ចេះតែទម្រើបៗ ទៅ មុខថ្លៃស្រែជម្រៅ (មុខក្រាស់) ដើរអង្វររាស្ត្រឲ្យយល់រឿងស្ថាប័នជាតិគ្រប់កន្លែង ព្រោះគណបក្សនេះយល់ថា ជាតិត្រូវមានអង្គការជាស្ថាប័នគ្រប់សព្វសម្រាប់និយាយការក្នុងអង្គការសហប្រជាជាតិ។

គ្រានេះ វរជនរៀមច្បងទាំងអស់ មើលមុខគ្នាលែងចំមែនទែនហើយ រីឯកូនចៅដៃជើងម្នាក់ៗនោះ ក៏កាន់ជើងចៅហ្វាយនាយ ស្រែកកោកកាកៗ ថ្កោលទោសគ្នាទៅវិញទៅមកគ្មានប្រណី។

ខ្ញុំនឹកឃើញដល់កាលឃោសនាគណបក្ស កាលពីម្ភៃប្លាយឆ្នាំកន្លងទៅហើយ សម័យនោះគេជេរគ្នាជាល្បែង ដូចជាថា កុំជឿប្រជាធិបតេយ្យពីព្រោះ «តែ-ក-វាក់» គឺទាក់កវៃ ពួកនេះសាហាវណាស់; កុំជឿសេរីភាព ពីព្រោះពួកនេះ «កាបរូត» គឺកូតរាប កររហូត; កុំទៅយកដីកំបុតក មានក្បាលឥតខ្លួនចង្រៃណាស់; កុំទៅកាន់រូបប្រាសាទដាក់អាចម៍ប្រជៀវ; កុំទៅជឿហនុមានដែលកំពុងលីផែនដីទៅលក់ ។ល។ ខ្លះប្រតិស្ឋរឿងអាសអាភាសផ្សេងៗ ដូចជាថា ហនុមានសហាយនឹងនាងគន្ធីង ។ល។ គឺគេចោទគ្នាសើចលេង គ្មានគិតដល់គោលគំនិត នៃគណបក្សសោះឡើយ។ គេគ្មានយកគោលនយោបាយដឹកនាំស្រុកទេស ដែលថាត្រូវធ្វើយ៉ាងណាៗ ទើបបានចំរើននោះមកពោលសោះឡើយ។

*ប្រជារាស្ត្រខ្មែរវិលវល់វង្វេង ល្ងង់នៅតែល្ងង់គ្មានស្គាល់មាគ៌ាច្បាស់រឿងនយោបាយស្រុក ដរាបសព្វថ្ងៃៗ សម័យនោះវាដូច្នោះ ដល់មកសម័យនេះហើយ ក៏វានៅតែដូច្នោះទៀត គួរស្តាយ !*

*ការទាស់ទែងខ្វែងគំនិតគ្នានេះ គ្មាននរណាអាចរំងាប់បានទេ។ ខ្ញុំក៏ចេះតែនឹកថា ឱ! ពេលនេះប្រសិនបើមានព្រះឥន្ទ ព្រះព្រហ្ម យមយក្សណាមកប្រោស ហ្ន៎ , ប្រហែលជាបានត្រូវរ៉ូវគ្នាខ្លះៗ ហើយអស់លោកអ្នកក៏ប្រហែលជាបានគិតដូចខ្ញុំដែរ មិនអ៊ីចឹងឬ? យើងពិបាកចិត្តដូចៗ គ្នា។ ប៉ុន្តែមានរឿងមួយដែលនាំឲ្យភ្លឺក្នុងរឿងនេះ។ ក្នុងពេលដែលខ្ញុំកំពុងនឹកផ្សងនោះ ស្រាប់តែសម្តេចព្រះសង្ឃរាជហួត-តាត លោកបានហៅខ្ញុំទៅពិគ្រោះនឹងលោក។ លោកមានព្រះបន្ទូលសួរថា ស្ថានការណ៍សព្វថ្ងៃចលាចលពេញទំហឹង ឯវរជនយើងទាស់គ្នាពេញល្បឿន តើលោក ម៉ុល ឯងយល់យ៉ាងណាដែរ? ខ្ញុំនឹកឃើញថាមានតែសម្តេចទេ ទើបពួកនោះស្តាប់ខ្លះ ទើបខ្ញុំទូលទៅព្រះអង្គថា :*

*- សូមទ្រង់មេត្តាប្រោស, ទូលបង្គំយល់ថា មានតែសម្តេចទេ ដែលប្រហែលជាពួកវរជនយើងនៅគោរពស្តាប់ខ្លះ សូមសម្តេចសរសេរលិខិតទៅស្នើពួកនោះ ឲ្យរួមគ្នាឡើងវិញទៅ ប្រហែលជាមានលទ្ធផលប្រសើរ។ លោកសួរមកខ្ញុំវិញថា : អាត្មាគិតថានឹងសរសេរទៅហើយ ប៉ុន្តែវាគ្មានអ្នកកាន់សំបុត្រនោះ យកទៅជូនអស់លោកទាំងនោះដោយផ្ទាល់ៗ ដៃ។ ខ្ញុំក៏ទូលលោកវិញប្រញាប់ថា : ទូលបង្គំធានាយកទៅជូនវរជនទាំងនោះដោយផ្ទាល់ដៃ សុំសម្តេចធ្វើសំបុត្រនោះមកចុះ។ សម្តេចព្រះសង្ឃរាជក៏ធ្វើសំបុត្រទាំងបីជាសម្ងាត់ ឲ្យខ្ញុំនាំទៅជូនលោកទាំងអស់ឲ្យរួបរួមគ្នា ខ្ញុំក៏បាននាំសំបុត្រនោះទៅជូនលោក លន់-នល់, លោក សិរិមតៈ, លោក ចេង-ហេង ដល់ទីលំនៅ។ ឯលោក អ៊ិន-តាំ សម្តេចលោកប្រើស្មៀនលោកឲ្យយកទៅជូន។ ថ្ងៃក្រោយមកក៏ឃើញលោក សិរិមតៈ, លោក ចេង-ហេង និងលោក អ៊ិន-តាំ ធ្វើលិខិតរួមគ្នាឆ្លើយថ្វាយសម្តេចវិញថា អស់លោកអរព្រះគុណសម្តេចណាស់ ហើយថាប្រុងនឹងរួបរួមគ្នាដែរ ពុំចង់បែកបាក់ទេ។*

*សម្តេចព្រះសង្ឃរាជក៏លោកមានអំណរ។ ខ្ញុំដែលជាអ្នកនាំការណ៍ក៏បានសប្បាយដែរ ប៉ុន្តែពេលដែលគណបក្សសង្គមសាធារណរដ្ឋកំពុងចាត់បេក្ខជនឃោសនាទ្រឹបៗ តែឯង មុននឹងដល់ថ្ងៃបោះឆ្នោតចំនួន ១៣ ថ្ងៃ គឺថ្ងៃ ២១ សីហា ១៩៧២ ពេលព្រឹក ស្រាប់តែ..ភ្លាំង ! គ្រាប់បែកប្លាស្ទិកមួយផ្ទុះឡើង សំដៅទៅប្រុងផ្តាច់ជីវិតលោក សឺង-ង៉ុកថាញ់ រដ្ឋមន្ត្រីទី ១ និងជារដ្ឋមន្ត្រីការបរទេសខ្មែរ!*

*បះសក់! អស់អ្នកក្រុងភ្នំពេញ និងអ្នកប្រវត្តិសាស្ត្របើកភ្នែកធំៗ ។*

*នែ! អ្នកនយោបាយខ្មែរ លេងឡើងសុទ្ធតែអីចឹង។ លោក សឺង-ង៉ុកថាញ់ ប្រាប់ពួកកាសែតថាអ្នកដែលប្រាថ្នាជីវិតលោក ជាអ្នកធ្លាប់ធ្វើទាហាន មិនមែនសត្រូវក្រៅទេ គឺសត្រូវក្នុងតែម្តង លោកថាលោកឥតខ្លាចស្លាប់ទេ ព្រោះជីវិតលោក លោកយកមកឲ្យខ្មែរប្រើហើយ បើមានគេពុំពេញចិត្តនឹងលោក គេចង់បំបាត់លោក ក៏មិនដឹងជានឹងគិតធ្វើម្តេចៗ ផ្សងៗ ទៅចុះ ស្លាប់ក៏ស្លាប់ទៅ !*

*មែន, លោក សឺង-ង៉ុកថាញ់ ជាមនុស្សនយោបាយតាំងពីឆ្នាំ ១៩៣០ ធ្លាប់ចោលស្រុក ចោលស្រែ ចោលម៉ែ ចោលឳ ធ្លាប់ជាប់គុកច្រវាក់ ធ្លាប់នៅព្រៃស៊ីអត់ស៊ីឃ្លាន, ធ្លាប់ត្រូវគេជេរតាមវិទ្យុយ៉ាងចាស់ដៃកាលពីឆ្នាំ ១៩៦៣ ថាក្បត់ជាតិ លោកទើបតែបានងើតក្បាលមកជាន់ស្រុកខ្មែរ ក្រោយព្រឹត្តិការណ៍ ១៨ មីនា ក៏ស្រាប់តែរងគ្រោះអាក្រក់ទៀត មករងថ្មបាក់ ត្រូវកូនសិស្សជេរពេញមេឃ កាលពីខែមេសា ហើយមិនទាន់បានស្ងប់ផង ក៏ស្រាប់តែមកប៉ឹះស្លាប់បែបធូរល្អយយ៉ាងនេះទៅទៀតៗ គិតទៅដូចជាអាសូរលោកដែរ។ នេះសំដីអ្នកត្រិះរិះគេពោល។*

ចំណែកខ្ញុំ ខ្ញុំភ្ញាក់ផ្អើលក់ទឹកចិត្តថា ឱ! អ្នកនយោបាយខ្មែរ! បើលេងឡើង សុទ្ធតែប្រាថ្នាបំបាត់ស្រមោលគ្នាអីចឹង តើថ្ងៃណាឡើយនឹងបានថ្កុំថ្កើង! ឱ! បើមិនបានថ្កុំថ្កើងទេក៏ហីទៅចុះ អាណិតតែកុំឲ្យរឹតតែឱនថយទៅទៀតនោះ។ ការកាប់សម្លាប់គ្នានេះ មុខគួរឲ្យស្តាយណាស់។ រាប់ឈ្មោះមើល អ្នកចេះដឹងខ្មែរយើងមានប៉ុន្មាននាក់? បើរវល់តែលបកាប់សម្លាប់គ្នាអីចឹង ចុងចប់វាទៅសល់អ្វី? មាននរណាដឹកនាំនរណា? បើយើងមិនពេញចិត្តនឹងលោក ស៊ឺង-ង៉ុកថាញ់ទេ លោក ស៊ឺង-ង៉ុកថាញ់ចេះខ្មែរដែរតើ ម៉េចមិននិយាយប្រាប់ឲ្យត្រង់ទៅ? ម្យ៉ាងទៀតលោក ស៊ឺង-ង៉ុកថាញ់នេះ គាត់មកដើម្បីបង្រ្គប់កិច្ចដែលជាត្រូវបង្កើតឲ្យមានស្ថាប័នជាតិគ្រប់សព្វទេតើ ចប់ហើយគាត់ឈប់ គាត់មានក្រាញចង់ដឹកនាំឯណា? ម៉េចក៏មិនចាំមើលគាត់សិន?

ប៉ុន្តែ! ចរិតខ្មែរយើង!!! អើធ្វើម៉េចបើវាអីចឹងពីកំណើតមកហើយនោះ!!! កែពុំបាន! ខ្ញុំមិនដឹងជាឈ្មោះណានៅក្នុងក្រុមណាទេ ដែលប្រុងសម្លាប់លោក ស៊ឺង-ង៉ុកថាញ់នោះ ប៉ុន្តែខ្ញុំជឿថា អ្នកនោះក៏គឺជាខ្មែរដែរ។

- ថ្ងៃទី ៣ កញ្ញា ១៩៧២ បោះឆ្នោតជ្រើសរើសសភាជាតិ
- ថ្ងៃទី ១៧ កញ្ញា ១៩៧២ បោះឆ្នោតជ្រើសរើសព្រឹទ្ធសភា :

ពេលទាំងនោះបានប្រព្រឹត្តិទៅដោយស្រួល ។

លុះដល់ចូលមកខែតុលា ១៩៧២ មានការកត់សំគាល់មួយទៀត គឺថ្ងៃទី ១៤ តុលា ១៩៧២ គណៈមន្ត្រីរបស់លោក ស៊ឺង-ង៉ុកថាញ់ តាំងឡើងដោយក្រឹត្យលេខ ១៨៧/៧២ PRK ថ្ងៃ២១មីនា១៩៧២ បានដាក់ពាក្យសុំលាលែង ចំពោះលោកសេនាប្រមុខ លន់-នល់ ។

លោកសេនាប្រមុខប្រធានាធិបតីបានចាត់ឲ្យលោក ហង្ស-ធុនហាក់ អគ្គលេខាធិការគណបក្សសង្គមសាធារណរដ្ឋឲ្យរៀបចំគណៈរដ្ឋមន្ត្រីថ្មី។ គណៈរដ្ឋមន្ត្រីថ្មីកើតឡើងដោយក្រឹត្យលេខ ៧៨៥/៧២ PRK ចុះថ្ងៃ ១៥ តុលា ១៩៧២ មានទេសរដ្ឋមន្ត្រី ៤ រូប, រដ្ឋមន្ត្រីថ្មី ១១ រូប និងរដ្ឋលេខាធិការ ៥ រូប ។

- ថ្ងៃ ១៧ តុលា គណៈរដ្ឋមន្ត្រីថ្មី បានបង្ហាញខ្លួនចំពោះសហសភា។

ហើយទាំងអស់គ្នា ចាប់ធ្វើការតទៅ ដោយមានសង្ឃឹមថាបានចម្រើនស្រុកទេស។

សរុបក្នុងឆ្នាំ ១៩៧២ យើងបែកបាក់គ្នាយ៉ាងខ្លាំង ហើយផ្លូវជាតិលេខ ១ ពីអ្នកលឿងទៅស្វាយរៀង យើងទៅលែងរួច ទីខេត្ត ទីក្រុងរួញចូលក្នុងបន្តិចម្តង ។

យើងចូលមកក្នុងឆ្នាំ ១៩៧៣។

យើងរាល់គ្នាជឿថា ប្រហែលជាយើងឆ្អែតឆ្អន់នឹងរឿងប្រទូសរ៉ាយ ជេរគ្នា បាតុកម្ម កូដកម្ម ស្អីទៀតហើយ។ ប៉ុន្តែចាំមើល?

ថ្ងៃទី ២៧ មករា ១៩៧៣ អាមេរិកាំងនិងយួនខាងជើងចុះហត្ថលេខាឈប់ច្បាំងនៅយួនខាងត្បូង។ លោកសេនាប្រមុខខ្មែរ បញ្ជាឲ្យទាហាននៅក្នុងបន្ទាយទុកឱកាសឲ្យយួនខាងជើងដកទ័ពទៅស្រួលៗ ចេញទៅវិញ។

យើងមានពន្លឺសង្ឃឹម! ប៉ុន្តែស្រាប់តែព្រឹបៗ ពួកព្រៃកន្ទ្រឹបទ័ពរដ្ឋាភិបាលស៊ើរគ្រប់កន្លែង ធ្វើឲ្យស្លាប់ខ្មែរក្មេងចាស់ទ្វេលើសដើម! ខាងណេះគ្រាប់បែក ខាងណោះផ្គត់ចូល ! បូកគ្នាទៅម៉ដ្ឋៗ ទាំងភូមិ ! នរណាចាញ់? នរណាឈ្នះ? ឆ្លើយថា ខ្មែរចាញ់ទាំងអស់គ្នា ! នេះរឿងច្បាំង។ ឯរឿងកិច្ចការរដ្ឋវិញ លោកកុង្ស៊ីយ៍កិច្ចការសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តម្រូវឲ្យឡើងថ្លៃប្រេងឥន្ធនៈ ក៏ដូចជាជាស់អាគមចិនតម្លើង

ថ្ងៃអីវ៉ាន់គ្រប់ជំពូកព្រឹបៗ ដូចទឹកចាល់ទំនប់ៗ បុគ្គលិកសិក្សាខ្មែរអត់ទ្រាំពុំបាន ក៏ផ្ដើមធ្វើកូដកម្ម (ថ្ងៃ ១០-២-៧៣) គគ្រឹកឡើង គ្រូបង្រៀនឈប់បង្រៀនសិស្ស ព្រោះបញ្ហាប្រកួតនឹងទំនិញឡើងថ្លៃៗ ក្នុងថ្ងៃទី ២៣ កុម្ភៈ ម៉ោង ៨ កន្លះព្រឹក នៅមហាវិទ្យាល័យគរុកោសល្យ, គណៈកម្មការចម្រុះតំណាងគ្រប់ក្របខ័ណ្ឌបុគ្គលិកសិក្សាខ្មែរដែលមានលោក សេង-ប៊ុនថន ជាប្រធាន និងមានគ្រូបង្រៀនប្រមាណ ៤០០ នាក់រួមផង បានធ្វើសន្និសីទសារពត៌មានស្ដីអំពីគោលបំណងដ៏ពិតប្រាកដ នៃកូដកម្មរបស់បុគ្គលិកសិក្សាខ្មែរៗ

លោក សេង-ប៊ុនថន បុគ្គលិកសិក្សាធ្វើកូដកម្មនេះ ដោយសារក្រពះដែលប្រទាំងប្រទើសនឹងរឿងឡើងថ្លៃទំនិញគ្រប់សារពើៗ បើរដ្ឋាភិបាលមិនដោះស្រាយទេ កូដកម្មនឹងបន្តទៅទៀត!

រឿងកូដកម្មបានលាតវែងតទៅ អ្នកខ្លះកាន់ជើងថាគ្រូធ្វើនេះត្រូវ ព្រោះថាប្រយោជន៍រួម ត្រូវតែទាមទារៗ អ្នកខ្លះថា ពួកលោកគ្រូ អ្នកគ្រូធ្វើនេះមិនសម ព្រោះបើទាមទារផង បង្រៀនសិស្សផងទៅវាម៉េច? លេងទម្លាក់ការបោល ទុកឲ្យកូនខ្មែរគ្មានវិជ្ជាព្រោះរឿងទាមទារនោះ វាមិនស្លាប់ហើយ? កូនខ្មែរកៀសពីព្រៃ, កូនអ្នកក្ររហេមរហាម កូនគេកូនឯងដែលគ្មានប្រាក់កាសនឹងជួលសាលារៀននោះ វាមិននៅតែខ្វាក់ពពើមទៅហើយ? ជាមួយគ្នានឹងកូនយើងរាល់គ្នានៅផ្ទះ, នៅ Lycée Descartes គេបង្រៀនគគ្រឹក រួចកូនចៅថៅកែចិនធំៗ អ្នកធំៗ គេមានគ្រូបង្រៀនដល់ផ្ទះ ខ្លះសុំទៅរៀនរហូតបរទេសៗ ពួកអស់នោះចេះដឹងត្រឡប់មកវិញ ចៅហ្វាយយើងទៀត ! ទៅណាវាល្បែង!

នៅថ្ងៃអាទិត្យ ទី៤ មីនា ១៩៧៣, នៅសាលមហោស្រពទន្លេបាសាក់ មានបើកសម័យប្រជុំមួយពិភាក្សាស្ដីពីបញ្ហាទំនិញឡើងថ្លៃនោះ ឆ្លើយតបនឹងកូដកម្មបុគ្គលិកសិក្សាៗ អស់លោកអ្នកធំ មានលោក លន់-ណុន, អ៊ិត-ធុយ, សាផុន-សាវ៉ាស៊ី, ថាច់-ជា, កែវ-ម៉ុងគ្រី, ឡុង-បុត្តា, ស៊ុម-ឈុំៗ និយាយទៅនិយាយមកគ្មានដំណោះស្រាយអ្វីនាំឲ្យកក់ក្ដៅសោះឡើយៗ ហើយដែលនាំឲ្យលោក លន់-ណុន ក្ដៅក្រហមមុខនោះ គឺមានគ្រូបង្រៀនម្នាក់ចោទលោកថា លោកមាន ៩២ លានដុល្លារ U.S. ផ្ញើនៅបាំងស្វីស Banque Suisse !

ហ៊ឺ ស្ដាប់ទៅឈឺក្បាល ៗ

រឿងនេះមិនទាន់ចប់ផង លេចរឿងលោកផ្កាយ១ អ៊ុង-ញ៉ច ចៅហ្វាយខេត្តកំពត ទះកំផ្លៀងលោកគ្រូ គង់-លីម, មកទៀត គ្រូៗ ក៏រំជួលឡើងទៀតៗ លោកអភិបាលក្រុងយើងយល់ថាបែបមិនស្រួល ក៏ធ្វើដីកាក្រុងថ្ងៃ ១៤ មីនា ១៩៧៣ ហាមប្រាមមិនឲ្យធ្វើបាតុកម្មផ្ដេសផ្ដាស !

ប៉ុន្តែមានប្រសិទ្ធភាពឯណា? ថ្ងៃទី ១៧ មីនា ១៩៧៣ មានមីទីងគ្រូបង្រៀនគគ្រឹកគគ្រេង នៅមហាវិទ្យាល័យគរុកោសល្យ, មានបដាជាច្រើនប្រឆាំងនឹងរដ្ឋាភិបាល ដូចជាថា : អ្នកដឹកនាំល្មោភអំណាច + ខ្វះសមត្ថភាព = កប់ខ្លួនឯង, ជាដើម ៗ

ម៉ោង ១១ ជិតឈប់ប្រជុំទៅហើយ ក៏ស្រាប់តែ ក្ឌាំង! ស្លាប់ ២ នាក់ របួសច្រើននាក់ ! ផ្ទុះគ្រាប់បែក !

– ហើយព្រឹត្តិការណ៍ធំបំផុត ស្ទើរក្រឡាប់ផែនដីក្នុងថ្ងៃដដែលនោះ គឺវេលាម៉ោង ១ កន្លះ ថ្ងៃត្រង់ ស្រាប់តែ ក្ឌាំង! ក្ឌាំង! ពីរគ្រាប់ក្បែររបងវិមានសាធារណរដ្ឋចំការមន! យន្តហោះ T 28 បើកបរដោយឈ្មោះ ស-កុត្រា ដែលថាត្រូវជាអតីតស្វាមីនាងបទុមបុប្ផា បានទំលាក់គ្រាប់បែកនេះ សំដៅលោកប្រធានាធិបតី លន់-នល់ ដែលវេលានោះក៏មានប្រជុំគណៈរដ្ឋមន្ត្រីផងៗ

ក្នុងថ្ងៃនោះមានការបទ្ទាន់ៗ ជាប់ៗ គ្នា។ បន្ទាប់ពីទំលាក់គ្រាប់បែកនេះភ្លាម លោកប្រធានាធិបតី លន់-នល់ ថ្លែងសារប្រាប់រាស្ត្រឲ្យរួបរួមគ្នា រួចលោកថ្លែងប្រកាសភាពអាសន្ន ប្រទេសជាតិស្ថិតនៅក្នុងគយន្តរាយ, លោក គាំ-រ៉េត រដ្ឋមន្ត្រីឃោសនាការ ថ្លែងអំពីវិធានការការពារ ហើយឲ្យរាស្ត្រនៅឲ្យស្ងៀមកុំភ្ញាក់ផ្អើល, លោក ថោង-លីមហួង ធ្វើសន្និសីទកាសែត, ហើយបំរាមគោចរប្រកាសពីម៉ោង ២១ ដល់ម៉ោង ៥ ភ្លឺ។

ព្រឹត្តិការណ៍ច្រើនស្អុកស្កះ រកកត់មិនទាន់។ បន្ទាប់មកមានការចាប់ពពួកស្តេចឃុំមួយកន្លែង។ បន្ទាប់មក ខ្មែរយើងក៏ហៅកប៉ាល់ហោះអាមេរិកាំង ឲ្យចូលមកជួយទម្លាក់គ្រាប់បែកនៅជុំវិញរដ្ឋធានីភ្នំពេញតែម្តង ព្រោះពេលនោះយួននិងខ្មែរខាងម្ខាងទៀតនោះ ចូលមកកាន់តែកៀកនឹងក្រុងភ្នំពេញណាស់ទៅហើយ ដូចនៅអរិយក្សត្រនេះជាដើម។

ប៉ុន្តែបែបធូរបន្តិចមកវិញ។

ថ្ងៃទី ១៧ មេសា ១៩៧៣ លោក នល់-នល់ ថ្លែងសារជំរាបរាស្ត្រអំពីចំណង់និងបំណងរបស់លោកក្នុងការបង្កើតក្រុមប្រឹក្សាជាន់ខ្ពស់ខាងនយោបាយមួយ ( Un Haut Conseil Politique ) សម្រាប់កាន់កាប់ការដឹកនាំរួមគ្នា ចំពោះបញ្ហាធំៗ របស់ជាតិ។

ស្តាប់ពាក្យនេះ សហសភាពេលប្រជុំពេញអង្គជាសមាជសភាក្នុងសម័យប្រជុំវិសាមញ្ញនៅថ្ងៃចន្ទ ទី ២៣ មេសា ១៩៧៣ សំរេចចិត្តគាំទ្រម៉ឺងម៉ាត់នូវគំនិតពង្រីកមូលដ្ឋាននយោបាយនេះ ហើយដើម្បីអនុវត្តនូវកម្មវិធីនេះ រដ្ឋាភិបាលពិសេស ត្រូវបានអនុញ្ញាតឲ្យចាត់វិធានការតាមបញ្ញត្តិក្នុងរយៈ ៣ ខែ។

ថ្ងៃ ២៤ មេសា ១៩៧៣ លោក លន់-នល់ ថ្លែងសារជំរាបខ្មែរអំពីសមាសភាពឧត្តមក្រុមប្រឹក្សានយោបាយ។

១- ផ្អាកសម័យប្រជុំនៃសភាជាតិនិងព្រឹទ្ធសភាសម្រាប់រយៈពេល ៦ ខែ។

២- បង្កើតគណៈកម្មាធិការមួយមានឈ្មោះថា ឧត្តមក្រុមប្រឹក្សានយោបាយ ដែលមានភារៈជួយលោកប្រធានាធិបតីនៃសាធារណរដ្ឋ ក្នុងកិច្ចការដឹកនាំប្រទេសជាតិ។

*　　*
*

ក្នុងរយៈពេលជិត ៦ ខែនេះ ឧត្តមក្រុមប្រឹក្សានយោបាយ អាស្រ័យដោយសម្ដេងនៃលោកប្រធានាធិបតីសាធារណរដ្ឋខ្មែរ នឹងធ្វើសេចក្តីសម្រេចផ្សេងៗ ដែលនឹងត្រូវឲ្យរដ្ឋាភិបាលពិសេសអនុវត្ត។

ការចាត់តាំងនិងការប្រព្រឹត្តទៅ នៃឧត្តមក្រុមប្រឹក្សានយោបាយ នឹងត្រូវកំណត់ដោយបញ្ញត្តិនៃលោកប្រធានាធិបតីសាធារណរដ្ឋ។

មកដល់ត្រង់នេះ យើងដូចជាបានសប្បាយ ត្បិតបានឃើញអស់លោកវរជនទាំងអស់ បានរួបរួមគ្នាឡើងវិញដូចប្រាថ្នា។

ប៉ុន្តែមកនឹកធ្លល់ត្រង់ណេះបន្តិច គឺថ្ងៃទី ២ ឧសភា ១៩៧៣ គណៈរដ្ឋមន្ត្រីលោក ហង្ស-ធុនហាក់ បានលាលែង ហើយថ្ងៃទី ១៦ ឧសភា ១៩៧៣ លោក អ៊ិន-តាំ ដែលជាសមាជិកឧត្តមក្រុមប្រឹក្សានយោបាយនោះ ស្រាប់តែសម្រុតខ្លួនចុះមករៀបចំគណៈរដ្ឋមន្ត្រីបន្តពីលោក ហង្ស-ធុនហាក់ ហើយ

*ចំពោះរឿងនេះ ខ្ញុំសូមរំលឹកឡើងវិញបន្តិចថា គណៈរដ្ឋមន្ត្រីស្រុកខ្មែរយើងដូចជាផ្លាស់ប្តូរញឹកញាប់ពេក រកតែនឹងទទួលខុសត្រូវចំពោះប្រវត្តិសាស្ត្រឲ្យបានជាក់ច្បាស់ប្រាកដប្រជាពុំទាន់ៗ គិតមើលចុះតាមដែលខ្ញុំកត់ត្រា : ពីខែកុម្ភៈ ១៩៥៨ ដល់ខែមីនា ១៩៧០ យើងមានគណៈរដ្ឋមន្ត្រី ៤៥ លើក ដែលក្នុងនេះ មានគណៈរដ្ឋមន្ត្រីគណបក្ស ២០ លើក គណៈរដ្ឋមន្ត្រីសង្គមរាស្ត្រនិយម ២៥ លើកៗ ហើយនាយករដ្ឋមន្ត្រីឃើញតែមនុស្សដដែលៗ ច្រើនលើកដូចជាញ៉ាំមញ្ញៀនតែឋានៈនេះយ៉ាងម៉េចមិនដឹង តែការ មិនឃើញចម្រើនទៅមុខសោះ ផ្លាស់ចុះផ្លាស់ឡើង មនុស្សដដែលៗ ដើរជ្រុំជើងលើដានចាស់ដដែលៗ មិនឃើញឈានទៅមុខសោះៗ តាំងពីឆ្នាំ ១៩៤៨ ដល់ឆ្នាំ ១៩៧០ មានឈ្មោះមនុស្សដែលមានវាសនាធ្វើនាយកនោះ ១៧ នាក់ ដូចជាសីហនុ ១៥ លើកម្នាក់ឯង សម្តេច ប៉ែន-នុត ៦ លើកម្នាក់ឯងៗ អ៊ុម-ឈៀងស៊ុន និង នរោត្តម-កន្តុល ៣ លើកម្នាក់ៗ ហើយកាលនីតិកាលទី ១ នៃសភាជាតិនោះ នាយករដ្ឋមន្ត្រីមានលោក ឈាន-វ៉ម, ប៉ែន-នុត, យ៉ែម-សំបូរ, អៀវ-កើសៗ នីតិកាលទី ២ មានលោក ហ៊ុយ-កន្ធុលៗ*

*ឃើញថា វរជនខ្មែរទាំងនោះ លាយចម្រុះគ្នាទាំងអ្នកល្មោភអំណាច អញ្ញនិយម កៅអីនិយម ផ្តាច់ការនិយម ព្រមទាំងអ្នកជាតិនិយមខ្លះផងៗ*

*ការផ្លាស់ប្តូរហើយវិលទៅវិលមក ធ្លាក់ទៅលើតែបុគ្គលម្នាក់ៗ និងពួកក្រុមម្នាក់ៗ នេះហើយដែលទុកដូចជាទម្លាប់ម្យ៉ាងរបស់អ្នកកាន់អំណាចស្រុកខ្មែរ ហើយដែលគេប្រកាន់ថាជាទម្លាប់ «ល្អ» របស់គេទៀតៗ*

*ហើយមកដល់ត្រង់នេះ ខ្ញុំសូមបញ្ចប់កំណត់របស់ខ្ញុំពេលនេះចុះ តែសូមឲ្យអស់លោកអ្នកអានពិចារណាឡើងវិញ តាំងពីក្រោយព្រឹត្តិការណ៍ ១៨ មីនា ១៩៧០ រហូតមកដល់នេះ តើយើងបំផ្លាញពេលឲ្យខូចទទេៗ ទៅប៉ុណ្ណា? យើងប្រឈ្លោះគ្នាប្រខាំគ្នា គ្មានមេ គ្មានកោយ អស់ពេលប៉ុន្មាន? តើយើងអាចនឹងរិះគន់ការបែកបាក់ដ៏អាស្រូវនេះបានដែរទេ?*

*សូមអស់លោកអ្នកមេត្តាគិត ហើយឆ្លើយចំពោះរឿងនេះផងចុះៗ តើ* **ចរិតខ្មែរ** *យើងអាចផ្លាស់ខ្លះបានទេ? ដើម្បីកសាងសាធារណរដ្ឋតទៅទៀតនោះ?*

*

*          *

# ឧបសម្ព័ន្ធ

## គំនិត «មានតែអញ»

មានវរជនខ្លះ ដែលធ្វើជាប្រធានអង្គប្រជុំណាមួយ សប្បាយណាស់នឹងនិយាយបែកជាអូរហូរជាស្ទឹង រហូតដល់ទៅជ្រុលរឿងខុសរបៀបវារៈទៅក៏មានៗ បញ្ចេញយោបល់មកសុទ្ធតែបញ្ជាក់ថា គិតនោះត្រឹមត្រូវហើយ យោបល់នោះល្អហើយ ឲ្យសមាជិកអង្គប្រជុំអនុម័តតាមចុះៗ កាលបើមានសមាជិកណាជំទាស់ ឬសុំជូនយោបល់ខ្លះនោះ រមែងតែងមិនសប្បាយចិត្តសោះឡើយ ព្រោះទំលាប់អាត្មាឯងនោះចេះតែមើលងាយគេ ថាគេមិនកើតទេ គេមិនដល់ខ្លួនទេ គេល្ងង់, ឯខ្លួនវិញគឺជាអ្នកចេះជ្រៅជ្រះជាបញ្ញវន្ត ជាមនុស្សកំពូល គំនិតរបស់ខ្លួនជាគំនិតពេជ្រ គំនិតរបស់អ្នកដទៃជាគំនិតកាក មិនបានការមិនត្រូវមកបញ្ចេញអ្វីទេៗ

គំនិត«អញនិយម»នេះ ជាគំនិតផ្តាសហួសហេតុ ពីព្រោះគេឯទៀតក៏ជាមនុស្សមានវិចារណ-ញ្ញាណដែរ ធ្លាប់ត្រិះរិះរកហេតុផលក្នុងរឿងណាមួយដែរ គេចេះដឹងមួយបែប យើងចេះដឹងមួយបែបត្រូវបញ្ចេញយោបល់ផង ដើម្បីរកលទ្ធផលល្អឲ្យអង្គប្រជុំ ឬសមាគមៗ ពីព្រោះតាមធម្មតា សូម្បីអ្នកសិល្បៈដូចគ្នា ក៏មិនអាចទទួលភារៈធ្វើការឲ្យបានសព្វគ្រប់តែម្នាក់ឯងបានទេ វាត្រូវតែអ្នករបាំពូកែខាងរាំ អ្នកគូរពូកែខាងគូរ អ្នកភ្លេងពូកែខាងភ្លេង មួយមុខៗ ពិសេសៗ ដោយខ្លួន វាមិនមែនអ្នករបាំចេះរាំហើយចេះគូរ ចេះលេងភ្លេងសព្វគ្រប់នោះទេ ឬក៏អ្នកភ្លេងចេះទាំងគូរទាំងរាំរែកនោះទេៗ ម្នាក់ៗ មានវិជ្ជាជីវៈពិតប្រាកដដោយៗ ខ្លួនៗ យ៉ាងណាមិញ យើងប្រធាន យើងចេះដឹងតាមសមត្ថភាពយើង ឯគេឯទៀត គេក៏មានចំណេះអ្វីផ្សេង សម្រាប់និយាយឲ្យយើងស្តាប់ដែរ គួរតែយើងឲ្យគេនិយាយផង ស្តាប់គេផង ព្រោះតាមសង្កេតមក ធម្មតាប្រធានអង្គប្រជុំច្រើនតែយល់លើការទូទៅ ឯការកំប៉ិកកំប៉ុក កំទេចកំទីរាយរងនោះ គេសមាជិកគេយល់គេដឹងៗ

នៅប្រទេសខ្មែរយើង ច្រើនតែអ្នកមានតម្រិះចេះដឹង មានសញ្ញាប័ត្រធំៗ ចេញមកពីបរទេសមកនាំឲ្យខូចរបៀបរៀបរយក្នុងសង្គមខ្មែរ ពីព្រោះតែលោកនិយាយនៅក្នុងពេលប្រជុំម្តងៗ ច្រើនតែអួតថា នៅអឺរ៉ុបឬនៅអាស៊ីទ្វីប គេច្រើនតែប្រើរបៀបដូចលោកពន្យល់ជូននេះឯង ត្រង់ពិតឬមិនពិត ស្រេចតែលោកដ៏មហិមានោះ អធិប្បាយរៀបរាប់ទៅតាមការយល់របស់បុគ្គលនោះទេ មិនមែនជាវិជ្ជាដែលបានរៀននោះយកមកពន្យល់នោះទេ គឺជាយោបល់ម្នាក់ៗ ទេតើៗ ប៉ុន្តែគ្នាដែលមានតម្រិះតិចតួចស្តួចស្តើង មិនហ៊ានជូនយោបល់ ដោយខ្លាចអ្នកមានតម្រិះនោះមើលងាយខ្លួន ! នេះហើយចរិតខ្មែរសម័យសតវត្សរ៍ទី ២០ នេះ សំគាល់មើលចុះ អ្នកដែលបានដឹកនាំមុនៗ កន្លងមកនេះ ច្រើនតែអាត្មានិយមមានតែអញទើបដឹកនាំប្រទេសជាតិទៅបាន គ្មានបណ្តុះចិត្តរួបរួមជួយពន្យល់ជូនយោបល់ ឃើញត្រូវហើយនាំគ្នាធ្វើតាមនោះទេ មានតិចណាស់ ច្រើនតែប្រជុំរួចចប់តែម្តង ត្រង់អនុវត្តទៅតាមនោះ សូន្យតែម្តងៗ នេះហើយប្រជុំច្រើនបានការតិច ប្រទេសចំរើនលូតលាស់ គេប្រជុំតិចធ្វើការបានច្រើន ទើបទៅមុខបាន ខ្ញុំសំគាល់មើលមកឃើញបែបនេះច្រើនៗ

*ហេតុនេះ យើងគួរអនុលោមស្តាប់សម្លេង ស្តាប់យោបល់របស់សមាជិកឯទៀតខ្លះផងៗ កុំអញនិយមពេកៗ*

## គំនិតលួចយកយោបល់គេ

*មានជនជាតិយើងខ្លះ ចូលចិត្តយកយោបល់អ្នកដទៃមកធ្វើជាយោបល់ឯងផ្ទាល់ ជាហេតុនាំឲ្យអ្នកបញ្ចេញយោបល់លែងចង់បញ្ចេញយោបល់ខ្លួនតទៅទៀតៗ បញ្ចេញធ្វើអ្វី បើប្រធាន បើមិត្តនោះយកយោបល់ខ្លួនទៅធ្វើជាយោបល់គេទៅហើយៗ ដូចយ៉ាងឈ្មោះ ម៉ី បានជូនយោបល់នៅពេលប្រជុំធំ ហើយអង្គប្រជុំបានយល់ស្របទាំងស្រុងៗ ដល់ពេលសម្រេច ស្រាប់តែបាត់ឈ្មោះ ម៉ី ទៅចេញឈ្មោះ សុក្រ-សៅរ៍ ឯណាឯណោះទៅវិញៗ*

*កាលពីជំនាន់ចាស់ សម្តេចសីហនុតែងសួរយោបល់នៅអង្គប្រជុំរាល់ពេល ហើយចម្រាញ់យកយោបល់ណា ៤-៥ ដែលល្អៗ មក ស្រែកថា : បើតាមយោបល់ខ្ញុំ គួរតែធ្វើយ៉ាងនេះយ៉ាងនោះៗ ត្រង់ថា បើធ្វើតាមលោកនេះ លោកនោះ ឬធ្វើតាមយោបល់លោកនេះលោកនោះ ដែលគាត់សរសេរក្នុងសៀវភៅនេះនោះ ជាហេតុនាំឲ្យម្ចាស់យោបល់នោះគ្នាពេញចិត្តផងនោះ ឥតថាទេ ថាសុទ្ធតែជាគំនិតឯង យោបល់ឯងៗ បើវល់ដូច្នេះ តើនរណានឹងជួយឲ្យយោបល់ល្អៗ ទៀត?*

*គំនិតលួចយោបល់គេនេះ ល្មមអស់លោកខ្លះផ្លាស់ចេញហើយៗ*

## គួរតែពិគ្រោះសាកសួរ

*មានវរជនខ្លះបានធ្វើធំហើយ នៅមិនទាន់ចេះរបៀបដេកដើរឈរអង្គុយ តាមបែបបទជាខ្មែរនៅឡើយទេ ច្រើនតែប្រើអាកប្បកិរិយា ឥរិយាបថគ្គងៗ មិនសមៗ ទាំងប្រពន្ធទាំងប្តី នៅបែបជាជនសាមញ្ញធម្មតាតយន្ដ័យទៅៗ*

*ដើម្បីសមរម្យនឹងឋានៈយើង ដែលជាអ្នកជួយដឹកនាំប្រទេសជាតិ គប្បីយើងពិគ្រោះសាកសួរអស់លោកចាស់ទុំ កាន់ទំនៀមទំលាប់ជាតិផ្និនផ្ទៅ ឲ្យលោកជួយណែនាំពន្យល់ផង ទើបល្អៗ ពីព្រោះយើងអ្នកធំ គឺជាតំណាងជាតិមួយផ្នែក កុំយើងច្រងេងច្រងាងគ្គងៗ នោះ គោងតែគិតមុននឹងធ្វើអ្វីៗ ថាអាត្មាអញជាតំណាងជាតិខ្មែរទាំងមូល បើអាត្មាអញធ្វើខុស គឺនាំឲ្យជាតិបរទេសមើលងាយជាតិខ្មែរទាំងមូលតែម្តងៗ ម្យ៉ាងទៀត បរទេសក៏ដូចជាពិបាកយល់សកាពទន់ភ្លន់របស់ជាតិខ្មែរខ្លាំងណាស់ៗ ធំហើយគប្បីយកចាស់ទុំជាទីប្រឹក្សាខ្លះទើបល្អៗ យើងបានធ្វើធំដោយតម្រិះវិជ្ជា ពុំមែនដោយចេះដឹងទំនៀមទំលាប់ប្រពៃណីទេ ដូច្នេះយើងកុំអួតថាយើងចេះ យើងយល់ទំនៀមទំលាប់ប្រពៃណីខ្មែរនោះៗ*

# គំនិតខ្លាចនយោបាយ

មានវរជនយើងខ្លះ ខ្លាចនយោបាយទាំងខ្លួនឯងកំពុងស្ថិតនៅក្នុងវង្វង់នយោបាយ។ រដ្ឋការបោត់ឲ្យទៅកាន់ការនយោបាយដើម្បីជួយប្រទេសជាតិខ្លួន តែបែរជាទៅនិយាយនឹងជនបរទេសនោះថា : ខ្ញុំស្អប់នយោបាយណាស់ ខ្ញុំសុំតែរស់ទេ ខ្ញុំមិនចេះធ្វើនយោបាយទេ ! ។

ស្ដាប់ចុះ ! បើមានមនុស្សរបៀបហ្នឹងច្រើននាក់ ប្រទេសជាតិមុខជានឹងពិបាកពុំខាន។ គួរឆ្ងល់ ! បើថាខ្លាចនយោបាយហើយ ម្ដេចឡើយក៏ទៅស្ម័គ្រសុំគេ ទៅនៅធ្វើការត្រង់កន្លែងដែលគេកំពុងធ្វើនយោបាយ? នេះហើយចរិតខ្មែរ! ដែលចង់តែធំ តែមិនចេះដឹងមុខងាររបស់ឯងថាត្រូវធ្វើអ្វី។ ឬមួយយល់ថាកន្លែងនោះជាកន្លែងខ្លាញ់ស្រួលអញប្រមូលដុល្លារយកមកធ្វើមានបាន? ឱ! បើគិតបែបនេះ ខ្ញុំសូមអង្វរ ! ព្រោះរបររកស៊ីសម្រាប់មានបាននោះមានគរគោក ចេញទៅរកស៊ីទៅ កុំលេងយកកន្លែងដែលគេត្រូវធ្វើនយោបាយ មកធ្វើជាកន្លែងជំនួញនោះ មិនស្រួលទេ ! ប្រយ័ត្នក្លាយទៅជាចម្ប៉ា សោត់ដូចចក កូនចៅរកស្រុកនៅនឹងគេគ្មាន។ ត្រូវតែយើងបណ្ដុះស្មារតីជាអ្នកនយោបាយគ្រប់ៗ គ្នា ឲ្យគំរូដល់កូនចៅយើងតៗ ទៅទៀត កុំឲ្យខ្លាចនយោបាយ ឲ្យស្រឡាញ់នយោបាយ ស្រឡាញ់ស្រុកទេសកសាងស្រុកទេសដោយខ្លួនឯង។ កុំបាច់ពឹងនរណាឲ្យមកដើរនយោបាយជួស កសាងស្រុកជួសនោះ ! គ្មានបរទេសណាគេមានចិត្តល្អ ចង់ជួយដើរនយោបាយជួសខ្មែរ កសាងស្រុកខ្មែរជួសខ្មែរទេ ! បើថាចង់យកផលប្រយោជន៍ពីខ្មែរនោះ វាមែន !

រឿងបរទេសនេះ ចាស់ទុំបរមបុរាណយើងបានចងជាសុភាសិតថា : កុំទុកចិត្តបរទេស កុំទុកចិត្តអភិនេស្រ្គម៍ កុំទុកចិត្តអភិប្រាយ។ ពីរឃ្លាខាងក្រោយទាក់ទងនឹងរឿងផ្សេងៗ ឯឃ្លាទី ១ ខាងដើម គឺលោកប្រដៅយើងយ៉ាងច្បាស់ថា ឲ្យយើងប្រយ័ត្នឲ្យណាស់ចំពោះជនបរទេសនេះ ពីព្រោះគ្មានបរ-ទេសណាស្មោះត្រង់នឹងយើងសោះឡើយ។ បរទេសណាដែលជួយយើង ដែលហុចភស្ដុតាងថាគេពិតជាស្មោះនោះ ក៏ព្រោះតែប្រយោជន៍គេពិតជាត្រូវបានពីយើងនេះទៅដែរ។ ឬក៏ហោចណាស់ប្រយោជន៍យើងនិងគេវាស្របគ្នា គេត្រូវតែរួមនឹងយើងទៅ។

# គំនិតសងសឹកសួរពូជ

នៅក្នុងសង្គមមនុស្សជឿនលឿន មនុស្សវិទ្យាសាស្រ្ដ គេតែងស្គាល់គន្លងយុត្តិធម៌ល្អណាស់។ នៅក្នុងសង្គមខ្មែរ យើងគ្មានការអប់រំមនុស្សឲ្យស្គាល់គន្លងយុត្តិធម៌ មនុស្សធម៌ទេ។ មនុស្សច្រើនតែធ្វើតាមតែខ្លួននឹកឃើញឬក៏ចេះតែដើរតាមគំនិតព្រៃផ្សៃសម័យបុរាណ ដែលចូលចិត្តតែសម្លាប់បំបាត់ពូជនោះតែម្ដង។ គំនិតដែលចូលចិត្តសម្លាប់បំផុតពូជនោះ ភាគច្រើន គឺជាគំនិតស្ដេចដែលជាអ្នកកាន់អំណាច។ មានរឿងសម័យបុរាណច្រើនណាស់ ដែលនិយាយពីការកាប់សម្លាប់នេះ។ ស្ដេចម្នាងកាលដែលច្បាំងឈ្នះសម្លាប់ស្ដេចម្នាងបានហើយនោះ មិននៅស្ងៀមទេ ឲ្យពេជ្ឈឃាតតាមចាប់សម្លាប់បុត្រា

បុត្រីស្តេចម្ខាងទៀតឲ្យវិនាសសូន្យទៅទៀតៗ ឯពួកស្តេចម្ខាងដែលបរាជ័យនោះ តែងតែរត់ចូលព្រៃ សន្សំកម្លាំង ឬក៏រត់ទៅហៅបរទេសឲ្យចូលមកជួយកំចាត់ស្តេចដែលឈ្នះនោះវិញ ហើយកាប់សម្លាប់បំបាត់ពូជគ្នាម្តងវិញៗ ម្ល៉ោះហើយ ការសម្លាប់បំបាត់ពូជគ្នាក៏ដូចជាទៅជាទម្លាប់ទំនៀមប្រចាំវង្សក្សត្រយ៉ាងជម្មតាៗ ដូច្នេះអ្នកណាដែលដឹងខ្លួនថាចាញ់នោះ តែងជញ្ជូនកូនចៅរត់ចូលព្រៃ ឬក៏ទៅនៅឯបរទេស ហើយបើមានឱកាសល្អ ស្តេចចាញ់នោះមិនញញើតសោះឡើយ ក្នុងការសងសឹកចំពោះស្តេចឈ្នះៗ

គំនិតនោះមានមកយូរសតវត្សរ៍ហើយ គួរតែបំបាត់ចេញ ប៉ុន្តែក្នុងសម័យសីហនុ នៅក្នុងសតវត្សរ៍ទី ២០ នេះ ក៏នៅឃើញមានដដែលៗ អ្នកកាន់អំណាចនេះ កាលបើឲ្យគេចាប់យករូបបុគ្គលណាម្នាក់ ដែលប្រឆាំងនឹងនយោបាយខ្លួនយកទៅដាក់គុកហើយ ពុំមែនចប់ត្រឹមហ្នឹងទេ ឲ្យគេជីកឫសជីកគល់ស្រាវជ្រាវរកខ្សែស្រឡាយបុគ្គលជាប់ចោទនោះតទៅទៀត ចាប់យកកូនប្រពន្ធគ្នាមកធ្វើទោសអស់មួយពូជៗ ជួនកាលកូនធ្វើខុសមិនធ្វើទោសតែកូនទេ ចាប់ដល់ទៅឪពុកគ្នា ជីដូនជីតាគ្នាថែមទៅទៀតៗ ជួនកាលគ្រាន់តែជាពួកម៉ាកភឿនភក្តិ ក៏ត្រូវតែបានទទួលទោសដែរៗ នេះហើយជារឿងគំនិតសងសឹកអស់មួយពូជៗ

គំនិតបែបនេះពុំមែនជាគំនិតកីឡាទេ ជាគំនិតកំសាកថោកទាបៗ

ចាប់ពីនេះតទៅ យើងនៅក្នុងរបបសាធារណរដ្ឋប្រកបដោយលទ្ធិប្រជាធិបតេយ្យហើយ គប្បីអ្នកកាន់អំណាចរដ្ឋមេត្តាលះបង់គំនិតអប្រិយនោះចេញទៅៗ សូមឲ្យមានសុភវិនិច្ឆ័យ សូមឲ្យមានយុត្តិធម៌ កុំយកកំហឹងគំនុំគុំគួនផ្ទាល់ខ្លួនមកបង្ករឲ្យកើតអគតិនៅក្នុងសង្គមឲ្យសោះ អ្នកកាន់អំណាចរដ្ឋមានស្មារតីស្មោះលើយុត្តិធម៌និងអហិង្សា ទើបប្រជាជនបានសុខកាយសប្បាយចិត្ត ហើយរឹតតែស្រឡាញ់ទុកចិត្តចំពោះអ្នកកាន់អំណាចនោះ ការពារអ្នកកាន់អំណាចនោះដោយភក្តីភាពគ្រប់គ្នា ជាហេតុនាំឲ្យមានសាមគ្គីឡើង ធ្វើការអ្វីក៏បានឥតទទើសទទែងរួញរាសោះឡើយៗ

## គំនិតផ្ដាញ់ផ្ដាល

នៅប្រទេសស៊ីវិល័យ គេមានចិត្តកីឡាប្រចាំខ្លួនៗ ទាស់ទែង វាយតប់គ្នា ក៏គេធ្វើដោយមានចិត្តកីឡា គេពុំមែនផ្ដាញ់គ្នាដោយអំពើព្រៃផ្សៃទេៗ ចិត្តកីឡានោះយ៉ាងម៉េច? សូមលើកឧទាហរណ៍ចំពោះតែរឿងវាយតប់គ្នាមកពោលៗ ទឹកចិត្តកីឡានោះគឺថា ម្នាក់ៗ គេមិនដែលលបកាប់ លបប្រហារចំពោះគូសត្រូវទេ គេតែងប្រកាសដោយចេញមុខ បានសេចក្តីថា គេហៅគូសត្រូវរបស់គេនោះ ឲ្យចូលមកប្រយុទ្ធដោយត្រង់ៗៗ ពេលប្រយុទ្ធនោះ ពេលគូប្រយុទ្ធរបស់គេត្រូវដួលចុះដោយចាញ់កម្លាំងរបស់គេនោះ គេតែងបង្អង់ដៃជើងសិនចាំឲ្យគូប្រយុទ្ធនោះងើបឡើងតស៊ូតទៅទៀត, ឬក៏គេតែងតែជួយលើកគូប្រយុទ្ធនោះឲ្យងើបឡើងហើយសួរថា : ម៉េចឯងអាចតស៊ូនឹងយើងតទៅទៀតបានទេ? បើគូប្រយុទ្ធនោះថាតស៊ូបាន គេប្រយុទ្ធគ្នាតទៅទៀតៗ បើគូប្រយុទ្ធនោះថាសុំឈប់ហើយ គេក៏ជួយបបោសអង្អែលនិយាយដោយពាក្យផ្អែមល្ហែមថា : អើ យើងឈប់ទាស់គ្នាត្រឹមណេះចុះ ! គេគ្មានបន្ទុះបង្អាប់ដោយពាក្យបញ្ឈឺចិត្តដូច្នេះដូច្នោះទេៗ ខ្មែរយើងវិញ តាមដែលធ្លាប់ឃើញ ធ្លាប់ដឹង ពុំដូច្នោះទេ ដាល់តប់គ្នា

*បើដាល់គូប្រយុទ្ធរបស់គេដួលហើយ ពុំនៅស្ងៀមទេ គេស្ទុះទៅទាត់ធាក់ថែមទៀត ជួនកាលទាត់ធាក់ទាល់តែអ្នកចាញ់នោះសន្លប់បាត់មាត់ឬក៏ស្លាប់ទៅផងក៏មាន។ គឺថា គេគ្មានពេលនិយាយតាមរបៀបកីឡាអ្វីទេ ដែលហៅថាឈ្នះសម្រាប់គេ គឺទាល់តែគូប្រយុទ្ធនោះដួលសន្លប់ឬក៏ស្លាប់ទៅ បើថានៅរស់ទេ គ្រាន់តែដួលគេយល់ថាពុំទាន់ឈ្នះទេ។ នេះឯងចរិតខ្មែរ។*

*តើដែលហៅថាឈ្នះនោះ វាស្ថិតនៅលើយើងទាត់ធាក់គូប្រយុទ្ធដែលពុំបានតដៃសោះឲ្យសន្លប់ ឬឲ្យស្លាប់ពិតមែនឬ? ពុំមែនដូច្នេះទាំងអស់ទេ វាស្ថិតនៅលើពាក្យសុំចុះចាញ់របស់គូប្រយុទ្ធឯណោះទេ។ ព្រោះថាជួនកាលគូប្រយុទ្ធនោះភ្ញាត់ស្មារតីតែបន្តិច យើងកាច់គេបំបាក់ទៅ ហើយអ្នកចាញ់សុំចុះចាញ់ហើយមិនត្រូវបណ្ដុះគំនុំនឹងគូសត្រូវរបស់ខ្លួននោះតទៅទៀតទេ គួរតែឈប់ត្រឹមពេលនោះ នៅថ្ងៃក្រោយគួរសមគ្នាជាធម្មតា ទើបត្រូវតាមមនុស្សធម៌។*

*យើងដែលឈ្នះគេ ដោយវាយគេថែមក្នុងពេលគេដួលហើយនេះ អាក្រក់មើលពន់ពេកណាស់ វាមិនមែនជាអ្នកមានកីឡាអ្វីបន្តិចសោះ។*

*រឿងអាក្រក់មួយទៀត ដែលមនុស្សកីឡាគេមិនប្រព្រឹត្តិសោះ គឺរឿងលបកាប់ លបចាក់គ្នា ពីខាងក្រោយខ្នង។ ទល់មុខនឹងគេពុំកើត លេងតាមផ្លូវស្ងាត់។ អំពើនេះជាអំពើថោកទាប ដែលមនុស្សសាមញ្ញគេថា ពុំមែនជា «អ្នកលេង» មែនទែនទេ គឺជាអ្នកក្លែងក្លាយ, កំសាកញីលបកាប់ពីក្រោយ, គ្មានអ្នកណាគេសរសើរ គេឲ្យតម្លៃថាក្លាហាន ថាមុះមុតទេ។*

*ខ្ញុំចូលចិត្តឲ្យអ្នកលេងទាំងអស់ ទាំងអ្នកលេងកាប់ចាក់ ទាំងអ្នកលេងនយោបាយ មេត្តាកាន់ចិត្តកីឡា, ឈ្លោះគ្នាមួយទល់មួយកុំព្រួតគ្នា, កាប់ចាក់, ប្រឆាំងចេញមុខ កុំលេងលបពីក្រោយ ធ្វើយ៉ាងនេះចាញ់ឈ្នះល្អមើល សាធារណជនឲ្យតម្លៃ ! ផ្ទុយពីនេះ លេងល្បែងកំសាក គ្មាននរណាសរសើរទេ សាធារណជនស្ដោះទឹកមាត់ដាក់ឲ្យដោយស្អប់ខ្ពើមពុំខាន !*

## គំនិតលោភពង្រេចពង្រីល

*មានអស់លោកអ្នកធំខ្លះធ្វើការនៅខេត្រក្រៅ រដ្ឋការឲ្យគេហដ្ឋានស្នាក់នៅដោយសមរម្យ ឯជុំវិញគេហដ្ឋាននោះក៏មានដំណាំដំណោចគ្រប់សព្វ មានរុក្ខផលដូង ស្វា ល្មុត ខ្នុរ ស្វាយ ចេកជាដើម មានផ្ទៃរយោងរយានសម្រាប់បេះអាស្រ័យឥតខ្វះ។ ថ្ងៃមួយលោកនោះឯង ត្រូវរដ្ឋការផ្លាស់ឲ្យទៅនៅកន្លែងថ្មី ខេត្រមួយផ្សេងទៀត លោកនោះឯងមានចិត្តលោភលន់ឥតមានខ្មាសសោះឡើយ ដឹងថាខ្លួនអស់បាននៅទីនេះហើយ តាំងឲ្យកូនប្រពន្ធបេះដំណាំដំណោចជំឡូង ដូង ស្វានោះអស់រលីងស្ទើរតែគ្មានសល់ក្ដឹប, ស៊ីផងលក់ផង ធ្វើយ៉ាងម៉េចឲ្យតែខាងអស់ កុំឲ្យអ្នកមកនៅក្រោយបានស៊ីផង។ មិនតែប៉ុណ្ណោះ ចលនវត្ថុដែលរដ្ឋការទិញទុកឲ្យប្រើប្រាស់ក្នុងគេហដ្ឋាននោះ ក៏មន្ត្រីនោះខ្ចប់វេចដឹកជញ្ជូនអស់ដែរ។ អ្នកមកនៅខ្វះអ្វីខ្វះទៅ អញមិនដឹងទេ ! អាណាប្រើផ្លាស់អញធ្វើអី? នេះគំនិតចង្រៃពង្រេចពង្រីលជាតិគួរឲ្យស្អប់ខ្ពើមបំផុត។*

*ឯអ្នកដែលមកនៅក្រោយ តាំងខ្វះនេះខ្វះនោះត្រដាបត្រដួស ទំរាំតែបានស្រួល គ្នាវេទនាមិនមែនតិច។ រឿងនេះជាចរិតម្យ៉ាងរបស់លោកធំជាតិខ្មែរ ដែលត្រូវតែនាំគ្នាជម្រុះចោលចេញទៅ គួរទុក*

ស្នាដៃខ្លះឲ្យគ្នាអ្នកក្រោយបានឃើញផង បើគ្មានស្នាដៃទុកទេក៏ហីទៅចុះ ចុះតែខ្លួនទៅវាបានហើយ កុំលេងមិនបានទុកស្នាដៃឲ្យគេ ហើយថែមទាំងប្រមូលខូចតាំងពីចេក ដំឡូង ដូង ស្វា របស់វត្តទៅទៀតនោះ មិនល្អទេ !

## គំនិតចង្រៃ

ខ្ញុំបានសង្កេតឃើញ គ្រប់កន្លែងដែលមានប្រាសាទបុរាណ, រូបគោ, រូបនាគ និងសសរថ្មខ្លះត្រូវធែបខូងៗ ខូចបាត់លំអអស់ ដោយសារជនចង្រៃចេះតែយកកាំបិតពូថៅទៅសំលៀងលើរូបថ្មទាំងនោះៗ បើរូបទាំងនោះនៅជិតមាត់ត្រពាំង ជិតផ្លូវដើរផង ក៏រឹតតែរេចរឹលខូងជ្រៅណាស់ទៅទៀត ខ្លះបាក់ដាច់បាត់ទៅតែម្ដងៗ មកពីជនគ្មានគំនិតទាំងនោះឆាយដៃពេកណាស់ យកកាំបិតពូថៅពីផ្ទះទៅព្រៃមិនសំលៀងឲ្យហើយទេ ចាំដល់ព្រៃត្រង់មានរូបថ្មនោះ តាំងយករូបថ្មនោះជាថ្មសំលៀងតែម្ដងៗ ជួនកាលនៅឯផ្ទះនោះគ្មានថ្មសំលៀងផងទេ អាងតែថ្មនៅឯព្រៃ ចាំទៅសំលៀងឯព្រៃនោះតែម្ដងៗ មកពីកំជិលធ្ងន់ពេកណាស់ ទើបបានជាមិនរវល់រកសព្វបើថ្មមួយដុំសម្រាប់សំលៀងកាំបិតនោះៗ ហើយបើលយជាយក លេងយកសសរថ្មចម្លាក់ រូបគោ និងសិលាចារឹកទៅទុកសំលៀងតែម្ដងៗ

ឯព្រះសង្ឃខ្លះដែលមានវត្តនៅជិតប្រាសាទ លោកខ្លាចបាបមែន មិនហ៊ានដើរកន្លងតួអក្សរទេ ដោយជឿថាតួអក្សរមួយតួៗ គឺសុទ្ធតែជាព្រះ ប៉ុន្តែចំពោះផ្ទាំងសិលាចារឹកវិញ លោកបែរជាយកមកដាក់នៅជើងជណ្ដើរនិមន្តឡើងចុះព្រងើយៗ

មកពីអ្វីបានជាដូច្នេះ? មកពីលោកមិនយល់តម្លៃនៃផ្ទាំងសិលាចារឹកនោះសោះ ស្មានតែជាថ្មធម្មតា រាងវារាបស្មើល្មមទ្រទ្រនាប់ជើងបាន ក៏លៃតាមហ្នឹងទៅៗ ឯពួកអ្នកសំលៀងកាំបិតពូថៅលើរូបគោ រូបនាគ ក៏ដូច្នោះដែរ គឺមកពីពួកនោះមិនយល់នូវតម្លៃវត្ថុនោះសោះតែម្ដង ហើយសមបើមានគំនិតខ្ជិលប្រអូសផង ឃើញវត្ថុនោះជាគ្រឿងសម្រាប់ស្រួលធ្វើការអីចឹងទៅ ក៏តាំងសំលៀងធ្វើព្រងើយៗ

ដូច្នេះគំនិតចង្រៃរបស់ពួកនោះ គឺបណ្ដាលមកពីមិនយល់ ហើយការមិនយល់ គឺមកពីគ្មានអ្នកពន្យល់ៗ បើមានអ្នកពន្យល់ឲ្យមនុស្សជំពូកនេះយល់រឿងតម្លៃវត្ថុទាំងនោះ ម្ល៉ោះសមពួកនោះ មិនសូវជាចង្រៃដល់ម៉្លឹងទេៗ អ្នកចេះដឹងបុរាណខ្លះៗ ច្រើនហាមថា «កុំប្រមាថម្ដាយ កុំរំលោយព្រះ»ៗ ត្រង់រឿងព្រះគាត់ចេះហាម ឯរូបថ្ម ចម្លាក់ថ្ម ដែលមានតម្លៃដូចព្រះពុទ្ធរូបផងដែរនោះ គាត់ឥតហាមទេ បណ្ដោយឲ្យអន្តរាយទៅចុះ បើត្រូវលោខ្លាច បែរជានាំគ្នាតំកើងថ្មមួយដុំពីរលើខ្នមក្រោមដើមជ្រៃដើមពោធិឯណោះទៅវិញ ដើរទៅលើកដៃសំពះម្ដង ដើរមកលើកដៃសំពះម្ដង អុជធូបថៃរក្យា នរណាប៉ះពាល់ពុំបានៗ វាទៅជាផ្ទុយអីចឹង !

ប្រសិនបើគាត់ជួយហាមទៅ កុំឲ្យមនុស្សយកផ្ទាំងសិលាចារឹកមកដើរជាន់ចុះឡើង កុំឲ្យមនុស្សផ្ដាស ទៅសំលៀងកាំបិតលើរូបគោ រូបនាគបុរាណទៅ វាមានអី? ម្ល៉េះសមមនុស្សចង្រៃវាញញើតខ្លះដែរ វាមិនឆាយដៃពេកៗ នេះអត់ហាមសោះៗ

ដូច្នេះ អំណើះតទៅខ្ញុំយល់ថា ខ្មែរយើងទាំងចាស់ទាំងក្មេង គួរចាប់ផ្ដើមពន្យល់គ្នាឲ្យយល់តម្លៃវត្ថុបុរាណឲ្យបានច្បាស់គ្រប់ៗ គ្នា ឲ្យយល់ថាវត្ថុទាំងនោះ គឺជាសាច់ជាឈាមដូនតាយើងសុទ្ធសាធ គឺជាស្រមោលព្រលឹងរបស់បុព្វបុរសខ្មែរសុទ្ធៗ ត្រូវតែយើងការពារ ត្រូវតែយើងស្រឡាញ់ កុំបណ្ដោយ

ឲ្យរេចរឹល, មិនត្រូវយើងបណ្ដោយឲ្យចោរជិតឆ្ងាយចូលមកលួចយកទៅណា ទៅណីទេ ពីព្រោះការបាត់បង់វត្ថុទាំងនោះ ទុកដូចជាបាត់បង់ឆ្អឹងឆ្អែងសាច់ឈាមដូនតាយើងដូច្នោះដែរៗ ឲ្យយើងដណ្ដឹងសួរគ្នាថា : តើយើងមិនពើតចាប់ឈឺផ្សាទេឬ បើមានគេមកប្រឡេះសាច់ប្របាច់ឆ្អឹងយើងនោះ?

យើងជាខ្មែរ ត្រូវពន្យល់កូនចៅឲ្យយល់ក្នុងន័យខាងលើនេះ ទើបកូនចៅយើងយល់ជួយថែរក្សាការពារវត្ថុបុរាណយើងតទៅបានយូរអង្វែងវែងឆ្ងាយៗ

# ចូរប្រយ័ត្នមនុស្សជំនិត

អ្នកធ្វើធំត្រូវប្រយ័ត្នខ្លួន ជាពិសេសចំពោះអ្នកណាដែលជំនិតនឹងខ្លួននោះតែម្ដង ពីព្រោះគឺជំនិតនោះហើយដែលនាំឲ្យយើងខូចឈ្មោះដោយសារៗ គឺអ្នកនៅជិតយើងនេះហើយ ដែលយកឈ្មោះយើងទៅលក់យកប្រយោជន៍ផ្ទាល់ខ្លួន ព្រោះវានៅជិតយើង គេមើលមកក៏ជឿទាំងអស់ៗ ចំពោះអ្នកដែលធ្វើឲ្យយើងខូចឈ្មោះនោះ មិនបាច់ដល់មនុស្សជំនិតផងទេ មនុស្សដែលគ្រាន់តែមកអែបឡបនឹងយើងរាល់ថ្ងៃនោះ ក៏អាចឲ្យយើងខូចឈ្មោះបានដែរ ឲ្យតែវាចង់ធ្វើៗ

ខ្ញុំនឹកឃើញរឿងមួយ កាលណោះនៅសាលាកាត់ក្ដីយើងនេះ មានស្មាក្ដីម្នាក់ប៉ិនប្រសប់វាយឫកអែបអបនឹងលោកចាងហ្វាងសាលាកាត់ក្ដីណាស់ រាល់ថ្ងៃគាត់តែងមកកាន់សាលាកាត់ក្ដីមុនលោកចាងហ្វាងជារឿយៗ ចាំទទួលដំណើរលោកចាងហ្វាង និងជួយកាន់កាតាបសំណុំរឿងរបស់លោកចាងហ្វាងចូលទៅកាន់ការិយាល័យផងៗ ធ្វើដូច្នេះ ដើម្បីឲ្យអ្នកកើតក្ដីក្ដាំងទាំងឡាយ សម្ងឹងមកយល់ច្រឡំថា គាត់ជាមនុស្សជិតស្និទ្ធនឹងលោកចាងហ្វាងណាស់ ពឹងពាក់គាត់ចុះ ក្ដីមិនចាញ់គេទេ ព្រោះគាត់ស្គាល់ចាងហ្វាងពិតប្រាកដណាស់ៗ លុះគេទៅជួបពឹងពាក់ គាត់នោះក៏តាំងសួរហេតុសព្វគ្រប់ រួចក៏តាំងអធិប្បាយច្បាប់ហូរហែវែងឆ្ងាយធ្វើឲ្យជនមានរឿងនោះស្ដាប់ភាំង រួចក៏ថាគាត់និងលោកចាងហ្វាងជាមិត្តនឹងគ្នា និយាយតែមួយម៉ាត់ស្រេចការភ្លាម សុំឲ្យតែចំណាយប៉ុណ្ណេះប៉ុណ្ណោះមកចុះៗ ជនមានរឿងជឿស្លុក មិនជឿឯណាបានបើគាត់ចេះច្បាប់សំបើមនិងស្គាល់លោកចាងហ្វាងទៀតនោះៗ គ្នាក៏តាំងសូកប៉ាន់គិតគូរតាមពាក្យពន្យល់ស្មាក្ដីកំហូចនោះទៅៗ ស្មាក្ដីកំហូចនោះមានយកទៅជូនលោកចាង-ហ្វាងឯណា លេបតែម្នាក់ឯងទៅៗ លុះគេកាត់ទៅជនដែលសូកប៉ាន់បានឈ្នះ ក៏តាំងថា ហ្ន៎! ឃើញទេគាត់និងចាងហ្វាងជួយមែន! លោបែរជាចាញ់វិញ ក៏ធ្វើជាក្ដៅបន្ទោសជនសូកប៉ាន់ថា មកពីភ្លេចពាក្យបណ្ដាំគាត់ គាត់ផ្ដាំឲ្យឆ្លើយដូច្នេះ អ្នកនោះទៅជានិយាយដូច្នោះខូចអស់ ទើបបានចាញ់គេៗ ស៊ីលុយគ្នាហើយបន្ទោសគ្នាទៀតៗ ឯលោកចាងហ្វាងគ្មានដឹងខ្លួនសោះ មិនដឹងថាអ្នកកាន់កាតាបឲ្យខ្លួននោះ កាន់ដោយចង់ឲ្យគេឃើញ ដើម្បីរកស៊ីឯណា លោកស្មានតែថាស្មាក្ដីនោះកាន់ឲ្យលោកដោយគោរពរាប់អានលោកដោយស្មោះតែប៉ុណ្ណោះៗ ទំរាំតែលោកដឹងខ្លួន ហើយបណ្ដេញស្មាក្ដីនោះឲ្យឈប់ទាក់ទង ឈ្មោះលោកក៏ល្បីសុះសាយសន្ធឹកថា ជាចាងហ្វាងអយុត្តិធម៌ ស៊ីសំណូកផ្ដេសផ្ដាសសំបើមៗ នេះគ្រាន់តែមនុស្សវាយអែបលុតក្រាបឡេមឡឺមផង វាអាចយកឈ្មោះយើងទៅជួញកើត ចំណង់បើជនជំនិតយើងទៀត វារឹតតែស្រួលយកឈ្មោះយើងទៅជួញណាស់ទៅទៀតៗ វាចង់បានលាភសក្ការៈពីអ្នកឯទៀតដែលចង់ប្រាស្រ័យនឹងយើង វាក៏តាំងថា យើងត្រូវការនេះត្រូវការនោះ ចូលចិត្តដូច្នេះដូច្នោះៗ គេដែល

*ចង់ប្រាស្រ័យនឹងយើងក៏តាំងរករបស់នោះមកឲ្យវាទៅ។ ជួនកាលវាធ្វើឲ្យគេដែលប្រុងមករកយើងនោះ ស្អប់យើង ជៀសគេចពីយើងតាមផ្លូវស្ងាត់ព្រងើយ ព្រោះតែអ្នកនោះពុំបានយកអ្វីទៅឲ្យវាតាមបំណងវា។ ទៅជាបំបែកយើងពីអ្នកដែលមកប្រាស្រ័យនឹងយើងទៅវិញគ្មុយ។ នេះជាគំនិតអាក្រក់ជួរជាតិ នៃជំនិតទុច្ចរិត។ វាគ្មានគិតពីរឿងយើងខូចឈ្មោះអ្វីទេ គិតតែផលប្រយោជន៍វា។*

*និយាយនេះ មិនសំដៅទៅលើជំនិតខ្លះដែលមានភក្តីភាពចំពោះចៅហ្វាយនាយ ហ៊ានស្លាប់រស់ជាមួយចៅហ្វាយនាយនោះទេ។ ជនជំនិតជំពូកនេះ គប្បីចៅហ្វាយនាយមើលឃើញគុណសម្បត្តិ និងជួយឧបត្ថម្ភគ្នា យកគ្នាជាសហការីជាជំនិតតទៅទៀត កុំឲ្យរង្គៀសឲ្យសោះ។*

# មេអំបៅ

*មានមនុស្សភាគខ្លះនៅក្មេងធ្លាប់ក្រលំបាកតោកយ៉ាក រៀនសូត្រខ្លះមុខខ្លះក្រោយ មានមិត្តភក្តិកំសត់ទុរគតដូចគ្នា បេះគួរសមរកគ្នា ស្រាប់តែខ្លួនមានវាសនាខ្ពស់ដោយបែជន្យ មានគេអ្នកមានទ្រព្យសម្បត្តិយកទៅជួយចិញ្ចឹមឲ្យរៀនសូត្របានធ្វើធំក្តី, ក្លាយទៅជាអ្នកធំ អ្នកមានដោយភរិយាជាអ្នកមានទ្រព្យឧបត្ថម្ភក្តី, បានឋានៈខ្ពង់ខ្ពស់ទ្រព្យសម្បត្តិសម្បូរភ្ញាម ក៏តាំងភ្លេចឈឹងនូវការកំសត់ទុរគតទាំងឡាយ។ មានខ្លះ នៅពីក្មេងមានមិត្តភក្តិធ្លាប់ក្រដូចគ្នា ខ្លួនឡើងជាអ្នកមាន អ្នកធំ មិត្តនោះគ្នាគ្មានពំនឹងពឹងពាក់ ក៏មករកខ្លួនដើម្បីឲ្យជួយដោះស្រាយជួយសង្គ្រោះគ្នាផង ក៏ស្រាប់តែខ្លួនមិនស្គាល់តែម្តង។ មានខ្លះ ម៉ែឪបងប្អូនខំនៅស្រែចំការ ខំរកស៊ីញើសតាំងទឹក យកប្រាក់មកផ្គត់ផ្គង់ឲ្យកូនឲ្យប្អូននោះរៀនសូត្រចេះដឹង។ កូនឬក៏ប្អូននោះរៀនសូត្របានចេះដឹងធ្វើការមានឋានៈខ្ពង់ខ្ពស់ ស្រាប់តែបានប្រពន្ធកូនគេអ្នកមាន ក៏ក្លាយទៅជាអ្នកធំ អ្នកមានសម័យថ្មី ភ្លេចម៉ែភ្លេចឪ ភ្លេចបង ភ្លេចប្អូនអស់រលីង។ ជួនកាលម្តាយឪពុកមករក ប្រពន្ធនោះក៏ប្រាប់ឲ្យទៅវិញ ជួនកាលប្រពន្ធនោះរៀបបាយទឹកឲ្យគាត់អាស្រ័យជាមួយឈ្នួល ដេកជាមួយឈ្នួល។ លោកធំនោះឥតចាប់អារម្មណ៍អ្វីទាំងអស់។ ជួនកាលប្រពន្ធដាក់គំរិតម្តាយឪពុកក្មេកឲ្យឈប់មករកទៀត។ លោកនោះក៏នៅស្ងៀម។ ម្តាយឪពុកនិងបងប្អូន បានតែទឹកភ្នែកឈឺចាប់ឱបនឹងទ្រូងយកទៅកាន់ផ្ទះសម្បែងឯស្រុកកំណើតវិញតែប៉ុណោះ។*

*អស់លោកធុននេះ តាមដែលខ្ញុំធ្លាប់ស្គាល់មានច្រើនដែរ ដែលខ្ញុំសូមអភ័យទោស សុំមិនបញ្ចេញឈ្មោះទេ ទុកឲ្យលោកនេះឯងសុខសប្បាយទៅចុះ ! មនុស្សបែបគ្នានេះដែរ មានខ្លះពីដើមក្រ រំហៀ មានកំណើតនៅស្រែចំការ ស្រាប់តែមកសេពគប់ត្រូវនៅក្រុងនេះឡើងជីវភាពខ្ពស់មានផ្ទះថ្មសសរឥដ្ឋ ក៏ឡើងចាងជោរក្អេងក្អាង លែងស្គាល់អ្នកស្រុកជាមួយគ្នាតែម្តង។ ខ្លះស្គាល់ដែរតែស្គាល់ក្នុងរបៀបមើលងាយគ្នាថាគ្នាជាមនុស្សស្រែ ជាមនុស្សថោកទាប ដើរជិតមិនបាននិយាយលេងយូរមិនកើត, ខ្លះទៀតដែលពីដើមពូជពង្សនៅស្រែចំការកប់កក់កប់ជ្រាំហាលថ្ងៃហាលភ្លៀង, បានមកធ្វើធំនៅក្រុង ក៏តាំងប្រមាថអ្នកស្រែចំការជេរស្តីកូនសុទ្ធតែជៀល ថាអាអ្នកស្រែ ! កុំធ្វើដូចអ្នកស្រែ ! បានសេចក្តីថាអ្នកស្រែដែលចិញ្ចឹមខ្លួននោះ ព្រមទាំងជាដើមវង្សរបស់ខ្លួននោះ អាក្រក់ណាស់ គំរក់ ! មានខ្លះទៀតធ្លាប់បួសរៀននៅវត្ត ឬក៏ធ្លាប់ផ្ញើខ្លួននឹងលោកសង្ឃ រៀនបានធ្វើការបានប្រពន្ធ ប្រពន្ធសួរថាបងឯងធ្លាប់នៅវត្តទេ? បុរសអន្ទិតយើងឆ្លើយថា ទេ ! បងមិនស្គាល់វត្តនោះមានកុដិវិហារបែបម៉េចផង*

*ទេ ! បងមិនធ្លាប់នៅទេ ! ខ្លះធ្វើជាពើសួរប្រពន្ធថាអូនឯងដែលឧស្សាហ៍ចូលវត្តដែរឬ? បងធុញណាស់ចូលវត្តម្ដងៗ មើលទៅក្មេងវត្តរាងអែនអនទ្រលទ្រលខ្ចិលទ្រមក់ បងមិនចង់ឃើញទេ ! ឆាកទៅកន្ទេងសុកម៉ុក ឆាកទៅបាយទឹកស៊ើតត្រលែត ហ៊ឺ... ឲ្យបងនៅ បងមិនចេះនៅទេ!!! នែ! ចេះហាមាត់ជៀលត្នះសំបុកដើមរបស់ខ្លួនទៅកើត ! ខ្លួនធ្លាប់ដើរទ្រាក់ៗ យូរបានស្រាក់បបរសៀង ត្រីងៀត ត្រីឆ្អើរជាមួយលោកសង្ឃ ទៅជាអីចឹងទៅកើត!*

*ខ្លះទៀតមានមិត្តភក្តិធ្លាប់កៀកដៃគ្នាទៅណាមកណាវាល់ៗ ថ្ងៃ ស្រាប់តែថ្ងៃមួយត្រូវបានឡើងធ្វើធំ ក៏គេចលែងឲ្យជួបមុខមិត្តនោះ ឬក៏បានជួបដែរតែព្រងើយទៅលែងស្គាល់គ្នាតែម្ដងៗ និយាយថាស្គាល់ទាំថោកខ្លួនព្រោះខ្លួនឥឡូវធំជុំៗ*

*មនុស្សប៉ុន្មានជំពូក ដែលខ្ញុំបានសង្កេតរៀបរាប់មកនេះ អស់លោកអ្នកចង់ឲ្យឈ្មោះថាជាអ្វីដែរ? គឺសុទ្ធតែជាមនុស្សអកតញ្ញូ រមិលគុណ មនុស្សមេអំបៅដែលភ្លេចកំណើតដើមខ្លួនជាដង្កូវៗ មនុស្សជំពូកនេះគ្មានសតិសម្បជញ្ញៈក្នុងខ្លួនបន្តិចសោះៗ គ្មានដឹងខ្លួនសោះថានៅជុំវិញខ្លួន គេខ្ពើបខ្ពៀវនិន្ទា សើចត្មះតិះដៀលខ្លួនពេញទំហឹងៗ ព្រោះមនុស្សទាំងអស់គ្នាសុទ្ធតែមានប្រវត្តិពិតៗ របស់ខ្លួន អ្នកដទៃគេតាមស្គាល់ហូរហែមក អ្នកនេះដឹងត្រង់ណោះ អ្នកនោះដឹងត្រង់ណោះ ខ្លួនមកគេចកែលុបស្នាមដានរបស់ខ្លួនតែត្រឹមពេលបច្ចុប្បន្ននេះ លុបម៉េចនឹងបានៗ ម៉្លោះហើយកេរ្តិ៍ឈ្មោះខ្លួននោះវានៅតែស្អុយរហ៊ុមអីចឹងទៅៗ*

*ហេតុហ្នឹងហើយ បានជាខ្ញុំសុំផ្ដាំប្អូនៗ យុវជនខ្មែរថា មេត្តាកុំយកតម្រាប់តាមពួកមេអំបៅ ដែលភ្លេចខ្លួនថាខ្លួនពីដើមជាដង្កូវនោះៗ*

*យ៉ាងម៉េចបានជាខ្ញុំចង់ឲ្យចៀស? អស់លោកដែលមានប្រមាត់ថ្មើមជាមេអំបៅ លោកមិនស្គាល់ម៉ែឪលោក មិត្តភក្តិលោក គ្រូបាអាចារ្យលោក វាជាសិទ្ធិរបស់លោកទេតើ? ខ្ញុំនេះមកអះអាងជ្រៀតជ្រែកអី? មានប្រយោជន៍ស្អី?*

*ខ្ញុំសូមជម្រាបថា មកពីសង្កេតឃើញថា :*

- *ពួកអស់លោកទាំងនេះ ត្រូវគេលបសើចពេបជ្រាយ ហើយជាមនុស្សខ្វះមិត្តដែលសុចរិត*
- *ពួកអស់លោកទាំងនេះ បើមានគ្រោះថ្នាក់ថ្ងោះយសសក្តិធ្លាក់ខ្លួនដូច្នេះដូច្នោះ គេវាល់គ្នាទះដៃបន្ទរថាឲ្យស្រឡះសាធុទៅចុះ*
- *ពួកអស់លោកទាំងនោះ ត្រូវម៉ែឪបងប្អូនមិត្តភក្តិប្រទេចផ្ដាសាដាក់ទំនាយ ឲ្យរលាយរលត់គ្រប់ៗ គ្នាៗ*

*ខ្ញុំសង្កេតឃើញយ៉ាងហ្នឹង, ខ្ញុំចង់ឲ្យយុវជនយើងដែលជាសសរទ្រទ្រង់ប្រទេសខ្មែរពីនេះរៀងទៅ បានទៅជាបុគ្គលល្អគ្រប់ៗ គ្នា មានគេរាប់អានស្មោះដូចៗ គ្នា គ្មានមិត្តភក្តិចាំសើចពេបជ្រាយ, គ្មានពួកម៉ាកចាំផ្ដន្ទាឲ្យលិចលង់, គ្មានម៉ែឪដាក់បណ្ដាសា ទើបខ្ញុំសុំឲ្យចៀសរបៀបជីវភាពមេអំបៅនោះៗ*

*ម្យ៉ាងវិញទៀត ជាប្រយោជន៍ដល់សង្គមប្រជាធិបតេយ្យ យើងត្រូវតែចៀសវាងរបៀបនោះ ពីព្រោះយើងត្រូវសាងសមភាព ដើរតន្ទងភាតរភាព ដើម្បីវឌ្ឍនភាពនិងសុភមង្គលសង្គមៗ ពីព្រោះតែរឿងវឌ្ឍនភាពនិងសុភមង្គលនៃសង្គមយើងនេះហើយ ទើបខ្ញុំនាំយករឿងមេអំបៅមកពោលក្នុងទីនេះៗ*

# ស្វាពាក់មួក

អ្នកជំខ្លះមានឫកពាមិនខុសពីស្វាពាក់មួកទេ។ ស្វាពាក់មួកនោះវាយ៉ាងណា? ស្វាដែលគេបំពាក់ឲ្យហើយ វាតែងភ្លេចខ្លួនថាក្បាលវាមានពាក់មួក វាភ្លេចស្មានតែក្បាលវានៅទទេ តែកាលណារមាស់ក្បាល ក៏តាំងលើកជើងអេះក្បាលភ្លាម នាំឲ្យគេមើលយល់ភ្លាមថា វាជាស្វាពិតប្រាកដ ព្រោះពាក់ដល់មួកហើយ នៅតែមិនកាន់ឫកឋានៈជាអ្នកមានមួកពាក់សោះ នៅតែកាន់ឫកជាសត្វតិរច្ឆានដដែល។

អ្នកជំយើងខ្លះ ដែលទើបនឹងបានយសសក្តិខ្ពង់ខ្ពស់ក៏ដូច្នោះដែរ ច្រើនតែភ្លេចខ្លួនថាខ្លួនជាធំ ច្រើនតែនៅឡេះឡោះប្រឡេមប្រឡឹម នាំឲ្យថោកទាបដល់ឋានៈគេឯងអស់។ អ្នកជំខ្លះ មិនចេះទាំងសុជីវធម៌ខាងផ្លូវទូតទៀតផង ច្រើនប្រព្រឹត្តជាមួយភ្ញៀវបរទេសអំពើផ្តេសផ្តាសនាំឲ្យខ្មាសគេ មិនខ្មាសតែខ្លួនឯងម្នាក់ គឺនាំឲ្យជាតិខ្មែរដែលមានខ្លួនជាដំណាងនោះ ខ្មាសគេតាមនោះដែរ ព្រោះខ្លួនជាអ្នកតំណាងខ្មែរ ធ្វើអ្វី ក៏ដូចជាខ្មែរធ្វើដូច្នោះដែរ។ ខ្ញុំឮមិត្តម្នាក់នៅបរទេសនិយាយប្រាប់ខ្ញុំថា មានអស់លោកបុគ្គលិកទូតយើងខ្លះ ត្រូវភ្ញៀវប្រទេសដែលយើងទៅនៅនោះ អញ្ជើញឲ្យទៅពិសាភោជននៅគេហដ្ឋានរបស់គេ ដោយគេមានអញ្ជើញភ្ញៀវបរទេសឯទៀត ឲ្យមករួបរួមផងដែរ។ ឯលោកបុគ្គលិកទូតយើងនោះ លោកភ្លេចខ្លួនថាលោកជាដំណាងខ្មែរ ភ្លេចថាកន្លែងនោះជាកន្លែងស្រុកគេដែលយើងត្រូវប្រយ័ត្ន ក៏តាំងពិសាសុរាយ៉ាងច្រើនទៀតផង ដោយមានសេចក្តីស្រេកឃ្លានជាខ្លាំងពីផ្ទះទៅ ព្រោះគ្រាន់តែទទួលសំបុត្រអញ្ជើញជប់លៀងភ្លាម លោកសំលៀងមាត់ជាស្រេច ចាំទៅអាស្រ័យឲ្យឆ្អែតទាល់តែឆ្អល់នៅកន្លែងគេតែម្តង លោកឥតហ៊ានទទួលទានអ្វីនៅផ្ទះទេ ខ្លាចទៅផ្ទះគេទទួលទានមិនកើត ត្បិតមិនឃ្លាន លោកទុកពោះឲ្យទទេស្អាត ចាំទៅវាត់ឲ្យណាណីនៅផ្ទះគេ។ មានអី! ឃ្លានពីផ្ទះមកស្រាប់ លោកបរិភោគអាហារនិងពិសាស្រាបានយ៉ាងច្រើនគួរសរសើរ!!! ស្រាប់តែហួសកំរិត ក៏កើកាយមកវិញ រួចក៏តាំងក្អួតចង្អោរជ្រហិតជ្រហមមួយរំពេច នាំឲ្យភ្ញៀវឯទៀតមើលមកគ្រប់គ្នាយ៉ាងភ្ញាក់ផ្អើល គេខ្ពើម គេយកដៃខ្ទប់ប្រមុះ ! មាត់របែករបោកជជែកគ្នាលាន់ឡើង ក្នុងចំណោមភ្ញៀវទាំងនោះថា : ឱ! គាត់នេះខ្មែរ ខ្មែរអីគេនេះស៊ីផឹកអីក៏អាក្រក់អាក្រីម្ល៉េះ? យើងមិនដែលឃើញមិនដែលយល់ នរណាគម្រក់ដូចខ្មែរទេ!

ពាក្យនេះពីរោះទេ? គឺជាពាក្យដែលគេមើលងាយចំពោះមកខ្មែរទាំងអស់ ដោយសារតែលោកម្ចាស់នោះឯង ធ្វើឲ្យថោកទាប។

តាមល្អ យើងដែលជាតំណាងជាតិខ្មែរគួររក្សាកិរិយាមារយាទឲ្យបានថ្លៃថ្នូរ ទុកកិត្តិយសឲ្យស្រុកទេសនិងបងប្អូនខ្មែរ។ គួរកុំចង់ឆ្ងាញ់ហួសហេតុ គួរអាស្រ័យពីផ្ទះសង្កត់ពោះខ្លះឲ្យហើយ ដល់ទៅអាស្រ័យជាមួយគេ វាប្រព្រឹត្តទៅបានស្រួល។ ហើយបើទុកជាពុំបានអ្វីដាក់ពោះសោះ ក៏គួរខំអត់ អាស្រ័យល្មមតែចប់ស្មើនឹងគេ ទុកពោះមកអាស្រ័យនៅផ្ទះយើងវិញចុះ។ កុំអាស្រ័យទាល់តែបាក់ជ្រះក្អួតចង្អោរប្រឯាប់ប្រងិលដូច្នេះ ព្រោះវាខ្មាសគេខ្លាំងណាស់ មុននឹងធ្វើអ្វីៗនិមួយៗ គួរនឹកថាអាត្មាអញ

ជាតិជាខ្មែរ គោរពប្រយ័ត្នចំពោះខ្មែរ ការពារប្រយោជន៍ខ្មែរ ទើបប្រទេសជាតិយើងចុំចើ្មើងទៅរួច ម្នាក់ៗ ជួយលើកបន្តិចបន្តួចទើបនគរចំរើនទៅរួចៗ

ខ្ញុំនាំរឿងនេះមកនិយាយ ព្រោះចង់ទាញការប្រុងប្រយ័ត្នអស់មិត្តឯទៀត ដែលទៅឈរនៅបរទេស និងអស់លោកដែលភ្ញៀវបរទេសអញ្ជើញទៅពិសាលៀងនៅផ្ទះគេឋិតនៅក្នុងប្រទេសខ្មែរផង តែប៉ុណ្ណោះ ឲ្យប្រុងស្មារតីប្រុងខ្លួនជានិច្ច កុំឲ្យធ្លោយនាំឲ្យខ្មាសគេៗ បើមិនចេះមិនយល់ច្បាប់ទម្លាប់ទេ សួរអស់លោកអ្នកឯណាដែលលោកចេះដឹងទៅ ព្រោះមិនខ្វះទេអស់លោកអ្នកដែលចេះដឹងទូវសុជីវ-ធម៌ខាងផ្លូវទូតនោះៗ

## បើមិនច្បាស់កុំអះអាង

បងប្អូនយើងខ្លះ ចូលចិត្តនិយាយការអ្វីដែលខ្លួនបានដឹងតែ ៥ ទេ តែនិយាយធ្វើចេះដឹងពិតរហូតដល់ ១០ ឬ ១៥ ឯណោះ គួរឲ្យស្ដាយណាស់ ព្រោះនាំឲ្យខុសពតិមានពិតអស់រលីងៗ

ដូចយ៉ាងបច្ចុប្បន្ននេះ ដែលស្រុកកំពុងមានចលាចលសង្គ្រាម មរណភ័យគ្រប់កន្លែង បងប្អូនយើងគ្នាត្រូវការដឹងស្ថានការណ៍ពិតប្រាកដ អ្នកខ្លះដែលមិនដឹងស្ថានការណ៍ច្បាស់ទេ តែនិយាយដូចជាច្បាស់ណាស់អីចឹងៗ ដូចកាលវាយគ្នានៅជីតដ្ឋ មានខ្លះនិយាយអះអាងថា អូ! ពួកវំដោះចូលដល់កៀនស្វាយហើយ ! ខ្ញុំបានបើករថយន្តទៅមើលដល់កន្លែង ពុំឃើញដូចជាពាក្យអស់លោកនោះនិយាយទេ ខ្ញុំត្រឡប់មកវិញ សួរអស់លោកនោះទៅ លោកនោះឆ្លើយមកខ្ញុំវិញថា: ទេ! ខ្ញុំឮគេថាច្បាស់ណាស់ ថាពួកវំដោះចូលដល់កៀនស្វាយ ឥឡូវបើពុំពិតទេ ខ្ញុំក៏មិនដឹងដែរ ! ធ្លុយអីចឹងទៅ !

នេះបើថាយើងជួយឃោសនាឲ្យសត្រូវ ក៏ថាបានដែរ ព្រោះនាំដំណឹងមិនពិតមកនិយាយ ឲ្យគ្នាភ័យនៅក្នុងក្រុងឯណោះៗ បងប្អូនយើងចូលចិត្តណាស់ រឿងឮគេថាហើយនិយាយអះអាងដូចជាច្បាស់ណាស់អីចឹងៗ យើងគួរកំចាត់ផ្ដាត់គំនិតអកុសលនេះទៅៗ អ្នកនិយាយ គប្បីទៅឃើញច្បាស់នឹងភ្នែកសឹមនិយាយៗ អ្នកស្ដាប់គប្បីត្រិះរិះពិចារណាឲ្យមែនទែនសឹមជឿៗ កុំករបន្តតាមគ្នា កុំជឿបន្តតាមគ្នាឲ្យសោះ, បើករបន្តគ្នា ជឿបន្តគ្នានេះនឹងនាំឲ្យផ្អើលដូចទន្សាយភ័យផ្លែព្នៅ រត់ពាសវាលពាសកាលពេញទាំងភូមិមិនខាន !

## គួរនិយាយតែរឿងមានប្រយោជន៍

ខ្ញុំសង្កេតឃើញអស់លោកមធ្យមៗ ខ្លះ ច្រើនជំនុំនិយាយគ្នាលេងរឿងអត់ប្រយោជន៍ៗ ដូចជាមុនដំបូងនិយាយឡើងរឿងនយោបាយស្រុកទេសមែនហើយ ប៉ុន្តែនិយាយបានតែបន្តិចក៏តាំងមានម្នាក់នាំវៃ និយាយពីរឿងស្រីញី ល្បែងបៀ បៀ៉ឯណោះភ្លាម រួចទាំងអស់គ្នាក៏តាំងទៅទាំងម៉ត់រឿងនោះដែរៗ ខ្លះមានសំដីថ្វីមាត់ពូកែនិយាយចំអេសចំអាស ដូចជាខ្លួននោះគ្មានម្ដាយជាស្រី គ្មានប្រពន្ធជាស្រី គ្មានកូនស្រីអីចឹង វាសឡើងពាក្យសុទ្ធតែអាសអាភាស ដូចពួកអ្នកប្រមឹកអាវ៉ាសែដូច្នោះដែរៗ លក្ខណៈយើងជាអ្នកធំ អ្នកចេះដឹងរលាយអស់រលីងៗ

ដូចយ៉ាងគ្រួសាររាជនិយមជំនាន់ដើម អស់លោកជំនាន់ចាស់ៗ គង់នឹងជ្រាបខ្លះមិនខាន។ បើគ្រួសារស្តេចណាកាន់លក្ខណៈត្រឹមត្រូវ លក្ខណៈថ្លៃថ្នូរ គ្រួសារស្តេចនោះមានរាស្ត្រគោរពច្រើន ចូលចិត្តច្រើន។ ផ្ទុយទៅវិញ គ្រួសារស្តេចណាមិនកាន់ទំនៀមទំលាប់ ក្រឹត្យវិន័យ ច្បាប់បរមបុរាណទេ គ្មានរាស្ត្រណាគោរពទេ។ គោរពយ៉ាងម៉េច បើពួកនោះក៏ជាពួកអាវ៉ាសែ ស្រី ស្រា បៀ ប៉ោ ព្រះអង្គម្ចាស់ក្សត្រាមានប្រពន្ធរាប់មិនអស់ អាងទ្រព្យព្រះរាជទ្រព្យចាយវាយខ្ជះខ្ជាយ ដូចគេជះក្រដាសប្រាក់តាមបង្អួចចោល, ឯព្រះអង្គម្ចាស់ក្សត្រីក៏ដែរ ប្តីច្រើនប្តូរផ្លាស់កត់ឈ្មោះមិនអស់មិនទាន់ វាទៅជាពួកមនុស្សមួយក្រុមដែលឲ្យគំរូដល់គេសុទ្ធតែអាក្រក់ទាំងអស់។

លក្ខណៈអាសអាភាសអាក្រក់អាក្រីនេះហើយ ដែលនាំឲ្យខូចទំនៀមទំលាប់ ប្រពៃណីខ្មែរអស់។

ដូច្នេះសរុបសេចក្តីទៅ គួរណាស់តែយើងអ្នកធំក៏ដោយ អ្នកមធ្យមក៏ដោយ និយាយស្តីអ្វីនិយាយពីរឿងខ្លឹមសារ ទាក់ទងជាពិសេសនឹងជាតិ ដើម្បីឲ្យមានពន្លឺក្នុងការដោះស្រាយរកវឌ្ឍនភាពឲ្យជាតិ។ បើយើងជួបជុំគ្នាហើយរវល់តែជជែកក្អាកក្អាយតែពីរឿងស្រី ស្រា អាភៀនកញ្ឆា បៀប៉ោនោះមានពេលឯណានិងពីគ្រោះរឿងស្រុក។

យើងគួរនាំគ្នាបែរមករកគំនិតល្អ។ អប់រំកូនចៅខ្មែរមិត្តភក្តិខ្មែរ, ឲ្យបានរស់ជាខ្មែរ ស្លាប់ទៅជាខ្មែរ, កើតវិញជាខ្មែរ ឲ្យខ្មែរមានជំហរនិងកម្លាំងមាំមួនតទៅអនាគត !

## គួរពត់ឈើកាលពីនៅតូច

គ្រួសារខ្មែរខ្លះ ភាគច្រើន ច្រើនតែអ្នកមានទ្រព្យសម្បត្តិ ទំយើទំរើសកូនមិនរវល់អប់រំអ្វីទាំងអស់ ខ្លះស្រឡាញ់កូនជ្រុល ព្រោះកូនមានតែមួយ ខ្លះជោរខ្លួនឯងដោយអាងទ្រព្យធន កូនទារប៉ុន្មានបានប៉ុណ្ណោះ ខំយកចិត្តវាទំរើសវាតាំងពីតូចគ្មានស្គាល់ហៅថាយ៉ាងម៉េចខ្វះខាត យ៉ាងម៉េចគ្មាន យ៉ាងម៉េចក្រ។ លុះដល់វាធំឡើងទម្លាប់របស់វាក៏ត្រូវតែបង្ខំម្តាយឪពុកឲ្យរកនេះ ឲ្យរកនោះ រកមិនចេះចប់ តាំងពីសម្លៀកបំពាក់គ្រឿងអលង្ការ រហូតដល់រថយន្តល្អៗ ជាចុងបំផុត។ ម៉ែឪខ្លះចេះតែខំទ្រោលទៅ ម៉ែឪខ្លះទ្រោលទៅពុំរួចក៏តាំងកាច់ពត់ក្មេងនោះមកវិញ។ ពេលពត់នេះហើយដែលម៉ែឪ ១០០ ភាគរយថ្ងូរហ៊ឹះគ្រវីក្បាលតតាត់ ដកដង្ហើមធំប្រាប់គេប្រាប់ឯងថា : ហ៊ឹ... អាកូនខ្ញុំ មេកូនខ្ញុំវាធ្វើឲ្យខ្ញុំលំបាកដល់ហើយ ទារនេះ ទារនោះមិនចេះអស់មិនចេះហើយ ហើយរៀនសូត្រអ្វីៗ គ្មានកើតសោះ ឃើញតែពួកម៉ាកទៅណេះទៅណោះ ព្រូចុះព្រូឡើង ! ។ ហើយគាត់ចង់ឲ្យគេជួយដោះស្រាយគាត់ផង តើធ្វើយ៉ាងណាឲ្យកូននោះបានស្តាប់គាត់ខ្លះ? ឲ្យកូននោះយល់ថា គាត់លំបាកចិត្តផង? ឲ្យកូននោះឈប់ផ្តេសផ្តាសផង? មានវិធីអ្វី?

ចំពោះវិធីនោះ មានតែផ្តើមអប់រំដោយទាញក្មេងនោះបន្តិចម្តងៗ ពន្យល់វាឲ្យឃើញហេតុអាក្រក់ដែលបណ្តាលមកពីវាផ្តេសផ្តាសនោះ ព្រមទាំងពន្យល់ឲ្យវាយល់ផលប្រយោជន៍នៃការរៀនសូត្រផង។ យូរៗ ទៅប្រហែលជាបានប្រកបខ្លះៗ នេះជាគំនិតខ្ញុំផ្ទាល់ទេ។ ប៉ុន្តែរឿងសំខាន់ដែលខ្ញុំចង់ពោលក្នុងទីនេះ គឺរឿងយើងត្រូវការពារក្មេងកុំឲ្យខូចទាន់ឯណោះទេ ពោលគឺយើងត្រូវអប់រំវាតាំងពីតូច ឲ្យវា

ដឹងល្អអាក្រក់ ថោកទាបឯណោះទេ។ ក្មេងដូចជាតួខ្លួនមនុស្សម្នាក់ដែរ យើងត្រូវការពាររោគវា ប្រសើរជាងចាំព្យាបាលរោគ។ យើងត្រូវអប់រំក្មេងឲ្យល្អ ជាជាងចាំតែតម្រែតម្រង់វា ក្នុងគ្រាដែលវាធំហើយនោះ។ រោគមកស្ថិតក្នុងខ្លួនទៅហើយ ថ្នាំខ្លះដាក់ទៅដល់ អ្នកជម្ងឺក៏រស់ឡើង ថ្នាំខ្លះដាក់មិនដល់ អ្នកជម្ងឺក៏ស្លាប់ទៅ។ ក្មេងដែលទម្លើសជ្រុលទៅហើយ ប្រឡើសបើសហួសទៅហើយ អាវ៉ាសែជ្រុលទៅហើយ ក៏ដូចមនុស្សមានជម្ងឺដាបដែរ ថ្នាំអប់រំពិបាកនឹងដាក់ព្យាបាលឲ្យជាណាស់។ ហើយដោយភាគច្រើន យុវជនដែលកែលែងឡើង គឺមកពីម្ដាយឪពុកបណ្ដែតបណ្ដោយជ្រុល ឲ្យវាអាវ៉ាសែ រាំរែក ស៊ីផឹកគប់មិត្តភក្តិសុទ្ធតែពួកពាល។ ខ្ញុំសង្កេតឃើញថា សម័យនេះក្មេងៗ ឈាមរាវ ចូលចិត្តបង្កើតគេហៅថា សៀរព្រី ( Surpris ) តាមរបៀបអឺរ៉ុប។ ខ្លះបែបចង់អាវ៉ាសែដែរ។ ម៉ែឪកូនស្រីខ្លះមុនដំបូងបែបសរសើរកូនស្រីខ្លួនថា កូនអញចេះរបៀបបរទេស, ដល់យូរៗ ទៅឃើញផលមិនស្រួល ដោយកូនស្រីនោះដូច្នេះដូច្នោះទៅ តាំងដេកឈឺចាប់ក្រឡាប់ផ្កាប់ផ្ងាររកបាញ់ចោល, រកកាត់កាល់...។ ខ្លួនឯងខ្មែរ វាមិនយល់រឿងបែបអឺរ៉ុបសោះ បណ្ដោយឲ្យកូនធ្វើតាមបែបអឺរ៉ុប។ តាមខ្ញុំដឹងយុវជនអឺរ៉ុប ការឱបគ្នារាំរែកមកពីធាតុអាកាសស្រុកគេត្រជាក់រហូតដល់ធ្លាក់ទឹកកក ត្រូវការឱបគ្នាឲ្យមានកំដៅកក់ក្ដៅក្នុងពេលរាំនោះ។ ម្យ៉ាងទៀតការរាំឱបរឹតគ្នា គឺជាការធម្មតារបស់គេទៅហើយ ស្រុកយើងអាស៊ីឯណោះជាស្រុកក្ដៅ មើលចុះរបាំប្រទេសចិនជាដើម គេរាំរែកម្ដងៗ ពុំដែលឱបរឹតគ្នាទេ ច្រើនត្រឹមតែចាប់ចុងដៃគ្នារាំ ជាការស្រេច។ ដូចរបាំរាំថូន រាំវង់ រាំក្បាច់ជាដើមមានបានប៉ះសាច់គ្នាឯណា ឃើញថាសមរម្យហើយសំរាប់ស្រុកយើងប្រទេសក្ដៅ។ ចុះបើយើងយករបាំអ្នកស្រុកត្រជាក់ មកលេងនៅស្រុកក្ដៅ ការនេះវាមានផលផ្សេង ការរាំនោះមិនមែននាំឲ្យកក់ក្ដៅទេ ផ្ទុយទៅវិញវានឹងនាំឲ្យផលអាក្រក់ទៅថ្ងៃក្រោយ។ ក្មេងណាចេះគិតក៏គិតទាន់, ក្មេងណាដែលខ្ជិលគិត ក៏បណ្ដោយខ្លួនទៅតាមសោតណាអីចឹងទៅ !

ត្រង់ហ្នឹងហើយបានជាថា យើងជាម៉ែឪខ្មែរ គួរកុំបណ្ដែតបណ្ដោយពេក ព្រោះអស់លោកអ្នកពិតជានៅចេះឈឺចាប់ កាលណាឃើញកូនយើងមិនដោយតាមទូន្មាននោះ។

ដូច្នេះទើបថា គប្បីយើងអប់រំកូនចៅយើងឲ្យយល់អាក្រក់ល្អតាំងពីវានៅតូចៗ នោះមកផងទើបបានផលល្អ។ ចំពោះរឿងអប់រំក្មេងតាំងពីនៅតូចៗ ទៀត ខ្ញុំសុំជូនរឿងផ្ទាល់ខ្លួនមួយ ខ្ញុំមានកូនចៅជាច្រើននាក់ ខ្ញុំតែងពន្យល់កូនចៅខ្ញុំឲ្យស្គាល់ចាស់ទុំ សូម្បីមនុស្សបំរើនៅក្នុងផ្ទះរបស់ខ្ញុំ ក៏ឲ្យកូនចៅខ្ញុំហៅពួកនេះដោយពាក្យរាបសារដែរ គឺឲ្យហៅបងនេះ បងនោះ មីងនេះ មីងនោះ ហាមផ្ដាច់មិនឲ្យហៅមេនេះ មេនោះ អានេះ អានោះ ង៉ែងហង អាមីង ជាច់ខាត។ ហើយបើក្មេងណាតូចជាងកូនខ្ញុំ ខ្ញុំបង្គាប់ឲ្យកូនខ្ញុំឲ្យហៅថា អូននេះ អូននោះ ជរាប។

លោកអើយ ដល់ពេលកូនចៅខ្ញុំទៅរៀនសាលា ខ្ញុំភ្ញាក់ព្រើតតែម្ដង ដោយឧស្សាហ៍ឮកូនចៅខ្ញុំចេះជេរបញ្ចោរនៅចំពោះមុខខ្ញុំតែម្ដង។ ខ្ញុំក៏បានហៅកូនធំជាងគេមកសួរថា : ឯងចេះរបៀបជេរនេះពីណាមក? កូននោះឆ្លើយថា : ខ្ញុំចេះមកពីសាលារៀន គូកនខ្ញុំវាជេរខ្ញុំ វាទាស់នឹងខ្ញុំ វាជេរម្ដាយខ្ញុំ វាហៅខ្ញុំថា អា.... ខ្ញុំក៏ចេះពីវាមក ! ជេរបញ្ចោរក៏ចេះពីវាមកដែរ !

គួរអស់លោកពិចារណាដែររឿងនេះ។ បើសង្គមយើង បើគ្រូបង្រៀនយើង បើម្ដាយឪពុកទាំងអស់គ្នា មិនជួយណែនាំពន្យល់កូនចៅ ឲ្យស្គាល់ពាក្យពីរោះពិសាតាំងពីក្មេងៗ ទៅទេ វាពិបាកកែខ្លាំងណាស់។ ពួកល្អម្នាក់ពីរ មុខជាជួលរេទៅតាមពួកអាក្រក់ច្រើនគ្នានោះពុំខាន។

## គួរស្តួនគ្រងលក្ខណៈខ្មែរខ្លះផង

សម័យនេះ អ្នករស់នៅក្នុងសង្គមយើងគប្បីត្រិះរិះពិចារណាអំពីទំនៀមទម្លាប់ខ្មែរឲ្យបានម៉ត់ចត់ទៅផង។ កន្លែងណាដែលហួសសម័យ ដែលមិនសមរម្យ មិនស្របនឹងដំណើរការប្រទេស ក៏គួរបោះបង់ចោលទៅចុះ ប៉ុន្តែកន្លែងណាដែលបង្ហាញបែបបទលក្ខណៈខ្មែរតាំងពីដូនតាមក យើងពុំគួរនឹងកាត់បំបាត់ចោលសោះឡើយ។

ខ្ញុំចង់ពោលពីរឿងសំលៀកបំពាក់។ ដូចជាបុណ្យសព ខ្ញុំធ្លាប់ឃើញខ្មែរចាស់ៗ ជំនាន់មុន បើហែសព ប្រុសៗ ស្លៀកពាក់ពណ៌ស ក្រវាត់ខ្មៅ ស្បែកជើងខ្មៅ, ស្រីៗ ពាក់អាវស សំពត់ចងក្បិនពណ៌ព្រីងទុំ ឬខ្មៅ មើលទៅបែបរម្យទមណាស់។

ដល់មកឥឡូវនេះ គេស្លៀកពាក់តាមអំពើចិត្ត ទៅបុណ្យខ្មោចដូចទៅបុណ្យកឋិន ចូលវត្តដូចជាចូលរង្គសាល ប្រឡូកប្រឡំហាក់ដូចជាប្រទេសនេះទើបតែកើតម្ល៉េះណោះ គ្មានវប្បធម៌ទំនៀមទម្លាប់អ្វីសោះ។

តាមល្អ គួរតែយើងម្នាក់ៗ នៅក្នុងសង្គមជួយស្តួនគ្រងនូវលក្ខណៈអ្វីដែលជាខ្មែរនោះ ឲ្យនៅតែជាលក្ខណៈខ្មែរតទៅផង ទើបប្រសើរ។

រឿងសំលៀកបំពាក់នេះទៀត អស់លោកកាត់គច្រើនចូលចិត្តស្លៀកពាក់ខោអាវធំ ពេលបុណ្យពេលជំនុំ ទោះបីរដូវក្តៅស្ទើរបែកក្បាលក៏ដោយ។ អាកាសធាតុក្តៅស្ទើរហុយផ្សែង យើងសុខចិត្តទ្រាំបែកញើស គ្រលំអាវធំធ្វើមុខជូរ។ សម្លៀកបំពាក់គេប្រើក្នុងប្រទេសត្រជាក់ ធាតុត្រជាក់ធ្លាក់ទឹកកក ឯងយកមកគ្រលុំឲ្យបែកញើស។ នេះជាអំពើឬបែបបទខុសទំនងដែរ។ ខ្ញុំពុំរិះគន់ទេ បើអស់លោកចូលចិត្តបំបែកញើសរបៀបនោះ តែខ្ញុំយល់ថា បើយើងស្លៀកពាក់ឲ្យស្គាល់របៀបរដូវក្តៅនោះ អស់លោកអ្នកនឹងបានស្រួលខ្លួន ហើយបានសមរម្យផង។

## អំពីរឿងទុកសក់សេះ

សព្វថ្ងៃនេះ នៅប្រទេសខ្លះនៅជុំវិញយើងនេះ មានវៀតណាម ថៃឡង់ដ៍ ហ្វីលីពីន គេកំពុងតែប្រយ័ត្នរឿងយុវជនទុកសក់សេះ ដែលគេយល់ថាធ្វើខូចទំនៀមទំលាប់ល្អរបស់ស្រុកគេ ព្រមទាំងគេមិនចង់ឲ្យស៊ីវិល័យខុសទំនងនោះ ឆ្លងមកលប់លើវប្បធម៌របស់គេផង។ កន្លែងខ្លះ គេចាត់ភ្នាក់ងារឲ្យចាំចាប់យុវជនទុកសក់វែងយកមកកាត់សក់នោះចោល។ ហើយស្រុកខ្លះ នៅចំណតយន្តហោះផ្ទាល់តែម្តង គេសុំអញ្ជើញភ្ញៀវបរទេសទុកសក់វែងឲ្យចូលទៅកាត់សក់នៅកន្លែងមួយសមរម្យ ដែលគេបំរុងទុកជាស្រេច មុននឹងឲ្យបរទេសនោះចូលទៅកាន់ក្រុងរបស់គេ។

យើងឯណោះវិញ យើងមានចាត់ការអ្វីដែរលើរឿងជនទុកសក់វែងនេះ?

ឃើញមានតែមួយពេលគត់ គឺលោកប្រធានាធិបតី លន់-នល់ ប្រកាសឲ្យយុវជនទុកសក់វែងកាត់សក់វែងរបស់ខ្លួនចោល កាលពីខែមីនា ១៩៧២, ប៉ុន្តែមានយុវជនណាស្តាប់ប្រសាសន៍លោកប្រធានាធិបតី លន់-នល់ ទេ? អត់ទេ !

សូមអភ័យទោស ក្រែងខ្ញុំយល់ច្រឡំ ខ្ញុំសង្កេតឃើញថា យុវជនសង្ហាទុកសក់សេះ (មិននិយាយពីពួកសិល្បករនិងនិស្សិតទេ) ច្រើនតែជាក្មេងពាល ក្មេងកាប់ចាក់ លួចប្លន់ ឆក់នាឡិកា ឆក់ខ្សែក តាមផ្សារតាមផ្លូវ... អ្នកក្រុងយើងមួលមាត់គ្នាហៅថាៈ ពួកអាទុកសក់វែងឬអាទុកសក់សេះៗ

យើងគួរផ្តើមពន្យល់យុវជនយើងឲ្យចៀសវាងរឿងទុកសក់វែងនេះផងហើយ ព្រោះមិនជាការល្អមើលសោះ ប្រុសច្រឡំស្រី ស្រីច្រឡំប្រុស ខុសពីបែបបទខ្មែរៗ យើងគួរមើលប្រទេសគេក្បែរខាងយើងនោះផង គេធ្វើយ៉ាងណា គេការពារយ៉ាងណាៗ

# គប្បីម៉ឺងម៉ាត់ឲ្យបានយូរអង្វែង

នៅឱកាសផ្លាស់របបគ្រប់គ្រង នៅប្រទេសណាក៏ដោយក្នុងលោកនេះ គេតែងតែផ្លាស់តាមរបៀបក្តៅទៅតាមបញ្ញត្តិឲ្យមនុស្សធ្វើតាមកុំឲ្យល្មើងបានៗ ជាពិសេស លុះត្រាតែអ្នកកាន់អំណាចនោះប្រយ័ត្នប្រយែងខាងផ្លូវច្បាប់ គោរពច្បាប់ទៅផងទើបបានចម្រើន ច្បាប់នោះឯងមានប្រសិទ្ធិភាពៗ ដូចជាគ្រួសារយើងនិមួយៗ ទាល់តែមេគ្រួសារនោះពូកែម៉ឺងម៉ាត់ ទើបគ្រួសារនោះបានត្រឹមត្រូវទៅតាមគន្លងល្អ មិនមែនរង់ចាំតែសមាជិកគ្រួសារនេះ គោរពតាមតែឪវាទខ្លួនជាមេនោះទេៗ យ៉ាងណាមិញ ប្រទេសជាតិនិមួយៗ ក៏ដូចនោះដែរ គួរណាស់តែអ្នករក្សាអំណាច ស្ថិតនៅក្នុងគន្លងច្បាប់នោះទៀងទាត់ម៉ឺងម៉ាត់ទើបប្រជាពលរដ្ឋបានសុខសាន្តទៅកើត តែកាលណាមិនគោរពច្បាប់ ធ្វើតាមតែតណ្ហារបស់ខ្លួននោះ ប្រទេសនោះទៅមុខពុំរួចទេ នៅតែវិលវល់ដូចបែបចាស់ដដែលជាដដែលៗ ម្យ៉ាងទៀត បើយើងតឹងយើងម៉ឺងម៉ាត់ពីដំបូងយ៉ាងណា យើងត្រូវតឹងត្រូវម៉ឺងម៉ាត់ឲ្យរហូតទៅ កុំតឹងម៉ឺងម៉ាត់តែមួយឆាប រួចធូរស្លុតនោះៗ

ដូចយើងបានឃើញស្រាប់ថ្ងៃទី ៩ តុលា ១៩៧០ យើងប្រកាសប្រទេសជាសាធារណរដ្ឋ គឺសន្មតថាប្តូរផ្លាស់អស់របៀបរាប់ចូលទាំងល្បែងពាលាផង, សិស្សានុសិស្សបានទាំងដុតរូបសំណាកបៀបៅ៉ នៅមុខសក្យមុនីចេតិយផង ជាសញ្ញាថាយើងត្រូវឈប់លេងបៀអាប៉ោងទៀតហើយៗ នៅពេលនោះដូចជាស្ងប់បន្តិច ប៉ុន្តែមិនយូរប៉ុន្មាន ល្បែងពាលាក៏រស់រវើកឡើងវិញ មកពីអ្វី? មកពីច្បាប់យើងបន្ធូរបន្ថយធិនថៃ រួចអ្នកខាងលើបែបខ្ជិលបន្តិចផង ក៏បណ្តោយៗ ទាល់តែអីចឹងទៅៗ ខ្មែរយើងមានចរិតតឹងរ៉ឹងម៉ឺងម៉ាត់តែមុនដំបូង យូរទៅធូរស្លុតៗ

និយាយរឿងយើងតាប់បន្ទូរនេះ ខ្ញុំនៅនឹកឃើញបន្តិចថា នៅឆ្នាំ ១៩៤០ កាលយើង, រាជការបារាំង-ខ្មែរ, បានតទល់ចម្បាំងសៀមគគ្រឹកគគ្រេង តែមិនមែនទាន់ជាសាហាវដូចសព្វថ្ងៃនេះផងទេ រាជការបារាំងបានធ្វើសំបុត្រចុះថ្ងៃទី ១៧ មិថុនា ១៩៤០ ហាមប្រាមទាំងអស់មិនឲ្យបើកវង់រាំច្រៀងស្រុកកើតសង្គ្រាមៗ កាលណោះស្ងាត់អស់ ហើយស្ងាត់រហូតរាប់ឆ្នាំៗ ឯយើងសព្វថ្ងៃនេះមិនដូច្នោះទេ

ហាមបិទតែមួយភ្លែតបើកវិញ រោងកុនក៏ដោយ រង្គសាលក៏ដោយ ដូចជាច្បាប់ស្ថិតនៅតែលើក្រដាសសោះតែម្តង ហាមអ្វីគ្មានប្រសិទ្ធិភាពដូចជំនាន់បារាំងទេ។ និយាយនេះមិនសរសើរច្បាប់បារាំងទេ តែសរសើរថាគំនិតបារាំងវាម៉ឺងម៉ាត់មែនទែន។ ព្រោះតែវាម៉ឺងម៉ាត់មែនទែនអីចឹងហើយ បានជាវាត្រួតក្បាលឯងកើត។ ខ្មែរយើងព្រោះតែធូរស្លុតស៊ិតព្រលែតអីចឹងហើយ បានជាពិបាកគេចផុតពីកញ្ជះគេទាំងវាស្រ្តទាំងនាម៉ឺននោះ។

ខ្ញុំនិយាយនេះដូចជាធ្ងល់ ប៉ុន្តែនិស្ស័យខ្ញុំ ខ្ញុំបានសច្ចាថាខ្ញុំសុំរស់នៅជាខ្មែរ ស្លាប់ទៅក៏ជាខ្មែរ ហើយរស់ក្នុងកំណើតថ្មីវិញក៏ជាខ្មែរដែរ។ ខ្ញុំមិនចង់ឲ្យជនជាតិណាកាឡៃខ្ញុំជាជាតិផ្សេងសោះឡើយ។

ម្យ៉ាងទៀត យើងចូលចិត្តតែធ្វេសចាំជិតសឹមធ្វើតែម្តង។ នឹកមើល នៅពេលកសាងអ្វីមួយនៅតាមខេត្តតាមក្រុង អស់លោកច្រើនមិនសូវប្រញាប់ធ្វើទេ លុះតែដល់ពេលជិតសម្ភោធតែម្តង ក៏តាំងប្រញាប់ធ្វើទាំងយប់ទាំងថ្ងៃ គ្រវីសគ្រវាសឲ្យតែបានហើយសម្រាប់សម្ភោធ យកគាប់មួយពេលនោះទៅ។ សួនច្បារគ្មានផ្កា កាច់ផ្កាមកដោតបញ្ឆោតទៅ, អណ្តូងគ្មានទឹកដងទឹកពីរបើឡានយកមកចាក់ឲ្យពេញទៅ សម្រាប់ «ព្រះអង្គទតសរសើរ» ពេលបើកសម្ភោធសមិទ្ធិរុក្ខផល កេណ្ឌយកចេកម្នាស់ល្អៗមកដាក់គរពោរពាសបង្ហាញ, ហើយទ្រុងមាន់មួយក៏ចេះតែដើរហើរហោះតាមព្រះអង្គស្ទើរគ្រប់ខេត្ត ករបញ្ជាក់អំពីការចំរើនខាងចិញ្ចឹមមាន់។ អាងតែ «ឪ» ខ្វាក់ គ ថ្លង់, «កូនចៅ» គិតតែពីភរវក់វី យកមេ-ដាយ។ នែ ! សម័យនោះ !

ឥឡូវនេះ សម័យនេះ ខ្ញុំសូមធ្វើសំណូមពរកុំឲ្យហែលតាមដំណើរមុននោះឲ្យសោះ។ រួមគ្នាធ្វើអ្វី ធ្វើឲ្យស្មោះម៉ឺងម៉ាត់ឲ្យរហូតកុំបន្ធូរ។

# ការសន្និះសង្ស័យ

អ្នកដឹកនាំខ្មែរ តាំងតែពីដើមមកចូលចិត្តតែសង្ស័យគ្នាទៅវិញទៅមក។ ការសង្ស័យនេះ ចេញផលជាការកាប់សម្លាប់គ្នាឥតប្រណី។

អ្នកដែលកំពុងកាន់អំណាច រមែងតែងតែមិនទុកចិត្តចំពោះអ្នកដែលធ្លាប់រួមការជាមួយ ដោយចេះតែក្រែងថា តិចលោអានេះវាដណ្តើមអំណាចអញទៅ, តិចលោអានេះវាលបសម្លាប់អញដើម្បីយកតំណែងអញទៅ ! តិចលោអីចេះ តិចលោអីចុះ ! ច្រើនប្រការ។

កាលបើនឹករអើលដូច្នោះហើយ ក៏តាំងលែងទុកចិត្ត រួចបើជួនមានអាម៉ីអាថោងចាក់រុកបន្តិចផងនោះ ក៏តាំងជឿជាក់មែនទែន ថាសហការីឬមិត្តពីដើមនោះក្បត់ខ្លួនមែនទែនតែម្តង។ ដល់មកត្រង់ណេះ ក៏តាំងរកលេសចោទប្រកាន់សហការីនោះឬមិត្តនោះ ឲ្យគ្នាទៅជាអាក្រក់ ដើម្បីយកទៅសម្លាប់ចោលទទេទៅ។

ផលវិបាកដែលកើតឡើង ដោយការចេះតែសង្ស័យគ្នានេះ ជួនកាលនាំឲ្យកើតសង្គ្រាមក្នុងស្រុកយ៉ាងធំទៅផងក៏មាន។

ខ្ញុំសុំរំលឹករឿងមួយ: ស្តេចសុគន្ធបទ (រវាងសតវត្សរ៍ទី ១៥ នៃ គ.ស.) ស្រឡាញ់គាប់ព្រះទ័យនឹងប្អូនថ្លៃឈ្មោះ កន នោះណាស់ ថែមទាំងប្រទានងារជា «ឃុនហ្លួងព្រះស្តេច» ត្រួតត្រាលើក្រសួង

*សង្ឃការីថែមទៅទៀតៗ ក្រោយមក ក៏ស្រាប់តែសង្ស័យថា យុនហ្វូងព្រះស្តេចកនប្រុងដណ្តើមអំណាចៗ លុះស្តាប់ពាក្យចាក់រុកពួកមន្ត្រីដែលស្អប់យុនហ្វូងព្រះស្តេចកននោះថែមទៀតទៅ ក៏យល់ថាយុនហ្វូងព្រះស្តេចកនប្រុងក្បត់មែនទែន ទើបឲ្យគេតាមចាប់យុនហ្វូងព្រះស្តេចកនយកមកសម្លាប់ៗ ឯយុនហ្វូងព្រះស្តេចកនដឹងខ្លួន ក៏កៀសខ្លួនទៅកេណ្ឌរាស្ត្រក្បត់មែនទែនតែម្តង បេញមុខច្បាំងនឹងស្តេចផែនដីពេញទំហឹងៗ ប្រជារាស្ត្រកើតវិនាសហិនហោចខ្លោចផ្សាអន្តរកប្ប សម្លាប់គ្នាដូចសត្វជាតុៗ យុនហ្វូងព្រះស្តេចកនធ្វើគត់ព្រះសុគន្ធបទទៅវិញ ហើយយករាជ្យមកសោយ តាំងខ្លួនជាម្ចាស់ផែនដីថ្មុយ ហើយក៏តាំងសប្បាយរាំរែកតាមគន្លងស្តេចផែនដីព្រងើយ ! ៗ នេះរាស្ត្រស្លាប់មួយលើកៗ ស្តេចកននេះកំពុងតែត្រេកត្រអាល ក៏ស្រាប់តែស្តេចអង្គចន្ទ (អង្គចន្ទទី ១) ចេញពីសៀមមកវិញ លើកទ័ពគគ្រឹកគគ្រេងមកដេញស្តេចកននោះទៅវិញៗ ការកាប់សម្លាប់គ្នាឯង វះសាច់កាច់ឆ្អឹងគ្នាឯង ក៏ផុសឡើងម្តងទៀត ប្រជារាស្ត្រវិនាសជីវិតរាប់ពុំអស់ៗ ទំរាំតែផ្តួលស្តេចកនបាន ចំណាយស៊ើរអស់ពូជខ្មែរដែលខ្លាំងពូកែៗ*

*នេះជារឿងចាស់ ដែលអ្នកប្រវត្តិសាស្ត្រគេដឹងគ្រប់ៗ គ្នា ហើយរកហេតុទៅឃើញថា គឺមកពីស្តេចអ្នកដឹកនាំចេះតែសង្ស័យអ្នកដែលធ្លាប់តែស្រឡាញ់ពីដំបូង ពោលគឺស្តេចសុគន្ធបទសង្ស័យលើយុនហ្វូងព្រះស្តេចកន រហូតដល់មានរឿងនាំឲ្យរាស្ត្រស្លាប់ពាសវាលពាសកាលៗ*

*រឿងថ្មីមួយទៀតកាលពី ២០ ឆ្នាំមុននេះ នរណាក៏ដឹងដែរថា សឺង-ង៉ុកថាញ់ រត់ចូលព្រៃទៅជាមេខ្មែរសេរី ក៏ដោយសារស្តេចសីហនុមិនទុកចិត្តគាត់ៗ រំលឹករឿងនេះឡើងវិញ អ្នកភ្នំពេញទឹកឃើញភ្លាមៗ កាលណោះលោក សឺង-ង៉ុកថាញ់ ត្រូវរដ្ឋាភិបាលបារាំងដោះលែងមកវិញៗ ថ្ងៃ៣០តុលា១៩៥១ លោក សឺង-ង៉ុកថាញ់ មកភ្នំពេញ រាស្ត្រខ្មែររាប់ម៉ឺននាក់ទទួលគាត់ៗ សីហនុក៏ស្រាប់តែក្រេងរអែងថា: អែយ៉ា, អាម្សៀនេះមានរាស្ត្ររាប់អានខ្លាំងណាស់តើ, មិនស្រួលទេ ថ្ងៃក្រោយម្សៀនេះមានប្រជាប្រិយភាពសម្បើមហើយ អញអស់មានមុខមានមាត់ហើយ ដូច្នេះ ត្រូវចាត់ការយកអានេះចេញទើបបានៗ សឺង-ង៉ុកថាញ់ មិនមែនមានត្រចៀកដូចត្រចៀកពាង មានភ្នែកដូចភ្នែកឫស្សីឯណា គាត់មានត្រចៀកនិងភ្នែកជាមនុស្សដែរ ដឹងខ្លួនក៏កៀសចូលព្រៃបាត់ៗ*

*រឿងមួយទៀត នរណាមិនដឹង ជួន-ម៉ុម ជាអ្នកចេះដឹងល្បីពីស្រុកបារាំងមកៗ គ្រាន់តែហៀបតែនឹងដាក់ជើងចុះជាន់លើដីពោធិ៍ចិនតុង ក៏ស្រាប់តែត្រូវដកជើងឡើងយន្តហោះវិញប្រញាប់ៗ ចុះឯណាបាន? បើពួកឆ្កែសីហនុនៅត្រៀមត្រៀបត្រាចាំខាំពាំយកទៅឲ្យសីហនុនោះៗ គេថា ជួន-ម៉ុម ជាមនុស្សក្រហមៗ*

*មួយទៀត, ៤-៥ ឆ្នាំមុននេះនរណាទៅភ្លេច? ហ៊ូ-យន់, ហ៊ូ-នឹម, ខៀវ-សំផន បានបាត់ខ្លួន តើដោយសារនរណា? គឺមកពីពួកនិយមស្តេច ពួកពុករលួយបរិវារស្តេចពាលសីហនុ ពួកចៃវាំង ៗលៗ រាស្ត្រខ្មែរណាម្នាក់ដែលភ្លេចពាក្យជេរប្រទេចរាល់ថ្ងៃ របស់សម្តេចសីហនុ ទៅលើពួកទាំងបីនោះ?*

*សរុបមក សឲ្យឃើញថាអ្នកដឹកនាំយើង គឺសីហនុនោះរវល់តែសង្ស័យវរជនឯទៀត រវល់តែនឹងប្រណែននឹងប្រជាប្រិយភាពគេឯទៀត រករឿងមិនឲ្យនរណាលូតលាស់ខ្ពស់ជាងខ្លួនកើត ឲ្យមានតែខ្លួនម្នាក់ជាកំពូល ជាដើម ជាមេ ជាឯកលើគេ ៗ*

*លទ្ធផលនៃទិដ្ឋិចង្រៃនោះ នាំឲ្យវរជនបញ្ញវន្តឃ្លាតឆ្ងាយពីសីហនុរហូតដល់សព្វថ្ងៃនេះ មានបក្សមានពួកស៊ីសាច់ហុតឈាមគ្នាគ្មានពិចារណា ព្រោះតែការកាន់ជើងពួកក្រហម ពួកខៀវ មិនគិតពី*

*រួមរស់ជាខ្មែរ ដោយសុខសាន្តសោះ។ ខ្ញុំនិយាយមកប៉ុណ្ណេះ តើអស់លោកសង្កេតឃើញបែបនេះទេ? សុំជួយពិចារណាផង។*

## ហេតុអ្វីបានជាយើងខ្វិនថយ

*ខ្ញុំយល់ថា ខ្មែរយើងសម័យសតវត្សរ៍ទី ១៣ កសាងនគរវត្តរួច ក៏ចាប់ចុះថយឥទ្ធិពលបន្តិចម្ដងៗ ដរាបដល់រៀវរួចរួញដល់សព្វថ្ងៃនេះ។ ហេតុម្ដេចក៏ដូច្នោះ? ដោយហេតុថា ជំនាន់នោះ គេផ្ដាច់ការពន់ពេកប្រើកម្លាំងមនុស្សដូចគោ-ក្របី ឲ្យដឹកថ្មធំៗ មានទម្ងន់ហួសកម្លាំងយកមកធ្វើប្រាសាទ ហើយបង្ខំឲ្យធ្វើគ្មានពេលសម្រាក។ ប្រាសាទទាំងឡាយនៅអង្គរពិតជាមរតកអនុស្សាវរីយ៍របស់ដូនតាយើងប្រាកដណាស់។ នៅពេលកសាងប្រាសាទទាំងឡាយនៅអង្គររួច យើងកត់សំគាល់ឃើញប្រជាពលរដ្ឋខូចទឹកចិត្តអស់ រហូតដល់សត្រូវចូលមកវាយប្រទេសជាតិ ប្រជាពលរដ្ឋពេលនោះកំពុងធុញទ្រាន់នឹងការលំបាកពន់ពេក ក៏កើតចិត្តនឿយណាយលែងមានចិត្តការពារប្រទេសជាតិទៅ។ ហើយរហូតមកចេះតែចុះថយឥទ្ធិពលជាលំដាប់ ឥតមានវរជនណាជួយបណ្ដុះទឹកចិត្តប្រជាពលរដ្ឋ ឲ្យភ្ញាក់រលឹកឡើងវិញទេ ចេះតែបណ្ដោយយូរជាយូរទៅ ប្រជារាស្ត្រក៏ទៅជាអស់សង្ឃឹមចំពោះជោគវាសនាខ្លួន នាំឲ្យខូចទឹកចិត្តរឹតតែខ្លាំងឡើង។ ណាមួយត្រូវពួកស្ដេចជិះជាន់ផង ណាមួយជីវភាពលំបាកផង ក៏ដេកផ្សងចាំតែវាសនាប៉ុណ្ណោះ។*

*នៅពេលដែលវាចូលលុកប្រទេសនេះម្ដងៗ សត្រូវតែងតែឃោសនាថា យើងមកជួយរំដោះអ្នករាល់គ្នាឲ្យរួចពីក្រញាំរបស់ពួកមនុស្សមួយចំនួនដែលកំពុងតែជិះជាន់អ្នករាល់គ្នាសព្វថ្ងៃ។ គួរកត់សំគាល់ថានៅពេលសត្រូវចូលមកវាយម្ដងៗ មិនដែលអត់មានមនុស្សក្បត់រត់ទៅចូលខាងសត្រូវនោះទេ តែងតែមានជាដរាប ជួយឃោសនាឲ្យសត្រូវទៀត ជាហេតុនាំឲ្យប្រជាពលរដ្ឋយល់ច្រឡំថា គេមកជួយរំដោះយើងឲ្យរួចពីការលំបាកគ្រប់យ៉ាងមែន តោងតែយើងជួយខាងសត្រូវទើបបានសេចក្ដីសុខ ហើយបបួលគ្នាចូលខាងសត្រូវដោយមិនដឹងខ្លួនទៅទៀត។ ពីនោះរៀងមកដល់សតវត្សរ៍ទី ១៧ យើងចាប់ចុះមែនទែន ដល់មកសតវត្សរ៍ទី ១៨ ខ្មែរក្លាយជាជាតិមួយបាក់ស្បាត អស់មានគំនិតអ្វីហៅថាតស៊ូនោះរលីង គិតតែពីទូលកញ្ជើរត់ រត់ជាទម្លាប់ជាប់មកដល់សព្វថ្ងៃនេះតែម្ដង។*

*អស់លោកជួយពិចារណាមើល រហូតដល់បច្ចុប្បន្នកាលនេះ តើយ៉ាងណា? យៀកកុងយួនខាងជើងចូលមកវាយប្រទេសខ្មែរ ដុតបំផ្លាញអស់ផ្ទះសម្បែងអ្នកស្រុក ហើយមានស្ដេចសីហនុបានជួយស្រែកពួកនោះទៀត ជាហេតុនាំឲ្យប្រជាពលរដ្ឋយើង ទៅតាមគន្លងសតវត្សរ៍មុនៗ តែម្ដង។ ខ្ញុំសុំរំលឹកដោយស្មោះត្រង់ថា ព្រោះតែគន្លងបាក់ស្បាតវង្វេងចូលនឹងសត្រូវរាល់ៗ ជំនាន់នេះហើយ ទើបនគរកម្ពុជាធិបតី នៅរួមរួញតូចប៉ុនបាតដៃសព្វថ្ងៃនេះ ហើយបើកុំតែបារាំងចូលមកធ្វើជាចៅហ្វាយទាន់ កុំអីរលាយបាត់ផងក៏មិនដឹង បានបារាំងវាចូលមក វាខាយាំងទុកត្រួតត្រាក៏បាននៅសល់ប៉ុណ្ណេះ។ នេះហើយវាសនាកម្ពុជាយើងដែលត្រូវតែមានចៅហ្វាយត្រួតត្រានោះ។*

*ចំពោះការឱនថយឫទ្ធានុភាព ខ្ញុំសូមប្រៀបធៀបទៅនឹងមហាប្រទេសខ្លះពីសម័យបុរាណ ដូចយ៉ាងមហាប្រទេសចិនប្រជាមានិត ជាមហាអំណាចនៅអាស៊ីដែរ កាលជំនាន់ស្ដេចចិនឈ្មោះ ជិន-ស៊ី*

ហួងទី Chin Shih Huongti[១] ខ្លាចពួកម៉ុងហ្គោលចូលវាយ ប្រទេសចិនស្ដេចនោះក៏ចាប់សាងកំពែងដ៏ធំ សតវត្សរ៍ទី ៣ មុនគ្រិស្ដសករាជ (Grande Muraille) ហើយវែងរហូតដល់ប្រាំពាន់គីឡូម៉ែត្រ នាំឲ្យប្រជាជនចិនលំបាកវេទនាជាអស្ចារ្យ សង្រួចកាលណា ប្រជាជនចិនហត់នឿយយ៉ាងខ្លាំង គ្មានកម្លាំងធ្វើសង្គ្រាមសោះ។ ទទួលពេលនោះពួកម៉ុងហ្គោលក៏ចូលមកវាយទៀត ហើយឃោសនាថាមកជួយប្រជាពលរដ្ឋចិនឲ្យផុតពីទាសភាព ប្រជាជនចិនក៏ជឿមួយចំនួនធំ លែងជួយកងទ័ពរដ្ឋាភិបាល នាំឲ្យកងទ័ពរដ្ឋាភិបាលទន់ខ្សោយ បណ្ដោយសត្រូវវាយធ្លាយមហាកំពែងនោះទៅ ហើយមហាប្រទេសចិនសម័យនោះ ក៏ធ្លាក់ចុះក្នុងហាយនភាពពេលនោះទៅ។

នៅអេហ្ស៊ីបក៏ដូច្នោះដែរ ហេតុតែចង់បានកេរ្តិ៍ឈ្មោះខ្ពស់ស្មើនឹងទេវតា ស្ដេចអេហ្ស៊ីបឈ្មោះរាមសេសទី ២ បានសាងមហាចេតិយ Pyramide ទុកជាកិត្តិគុណដ៏សំខាន់របស់សក្យវង្ស បន្ទាប់ពីនោះមក អេហ្ស៊ីបក៏ចុះថយបន្តិចម្ដងៗ ដរាបមក។

ការចុះថយឥទ្ធិពលទាំងយើងទាំងគេនេះ គឺបណ្ដាលមកពីការអ្នកគ្រប់គ្រងស្រវាំប្រទាញតែនឹងរឿងកិត្តិយស ចង់ប្រកួតនឹងអាទិទេពជាក់ច្បាស់ណាស់។

ឥឡូវនេះ ខ្ញុំសូមនិយាយអំពីប្រទេសដែលគេបានចម្រើនវិញម្ដង។ តើគេចាត់ការយ៉ាងដូចម្ដេចខ្លះ? ដូចយ៉ាងប្រទេសជប៉ុន កាលពីសតវត្សរ៍ទី ១៩ ស្ដេចរបស់គេឈ្មោះអធិរាជ មេអ៊ិជិ (Meiji) ព.ស. ២៤១០ គ.ស. ១៨៦៦ បានភ្ញាក់រលឹកឈ្វេងយល់ថា : ប្រទេសជប៉ុនត្រូវតែមានអ្នកចេះដឹងច្រើនតទៅអនាគតទើបបានចម្រើន ហើយគ្មាននរណាប្រមាថបាន។ គិតដូច្នោះក៏ចាត់បញ្ជូនកូនសិស្សឲ្យចេញទៅរៀននៅបរទេសជាច្រើនប្រទេស។ មិនយូរប៉ុន្មានកូនសិស្សនោះចេះដឹង នាំចំណេះចេះដឹងមកធ្វើការបម្រើប្រទេសជប៉ុនវិញ បានចម្រើនជាលំដាប់ដរាបដល់សព្វថ្ងៃ។

ឯប្រទេសថៃក៏ដូច្នោះដែរ ស្ដេចឈ្មោះព្រះបាទសម្ដេចចុឡាចមក្លៅ[២] កាលពីឆ្នាំព.ស. ២៤១១ គ.ស. ១៨៦៧ បានចាត់កូនចៅគេឲ្យទៅរៀននៅបរទេសជាច្រើនគ្នាដូចយ៉ាងលោក យួង អភ័យវង្ស, ហ្លួងប្រឌិត្ថឹម៉ុង... ជាដើម គេចេះដឹងត្រឡប់មកវិញ មានចំណេះគ្រប់វិស័យសម្រាប់ធ្វើការឲ្យប្រទេសថៃ។ ឯយើងខ្មែរឯណោះវិញ មានស្ដេចណាចាត់កូនសិស្សណា ឲ្យទៅរៀនដូចជប៉ុន ដូចសៀមទេ?

នៅសម័យ ព.ស. ២៤១១ គ.ស. ១៨៦៧ នោះ ស្ដេចខ្មែរកំពុងតែដណ្ដើមអំណាចគ្នា បងសម្លាប់ប្អូន ប្អូនសម្លាប់បង ដណ្ដើមគ្នាសោយរាជ្យសម្បត្តិ។ ប្រជាពលរដ្ឋស្លាប់គរជើងលើគ្នា។ តមកមានដែរ ក្រសួងអប់រំជាតិបញ្ជូនកូនសិស្សឲ្យទៅរៀននៅបរទេស ដោយជួយផ្ដល់អាហារូបករណ៍ដោយចំនួនតិចហើយស្ដួចស្ដើងថែមទៀត ឬក៏ប្រទេសនោះមានគេឲ្យអាហារូបករណ៍ ប៉ុន្តែម្ដងៗ ដោយបើព្រះអង្គមិនសព្វព្រះទ័យ ក៏តាំងឲ្យរដ្ឋាភិបាលផ្ដាច់អាហារូបករណ៍ពីសិស្សនោះជាប្រញាប់។ សិស្សនោះគ្នាតែលតោលវង្វេងវិលវល់ លែងចង់ទៅជាខ្មែរ ចង់តែសុំប្ដូរឈ្មោះចូលសញ្ជាតិបរទេសតែម្ដងដើម្បីរស់រានមានជីវិត។ ស្ដេចខ្មែរយើងវាអីចឹង ! គំនិតនេះ គឺគំនិតមិនចង់ឲ្យនរណាចេះជាងខ្លួនជាពួកស្ដេច ប៉ុន្តែមិនយល់ថា គំនិតខ្ទប់គ្នាឯងមិនឲ្យចេញក្រៅនេះ ជាគំនិតសម្រាប់ធ្វើខ្ញុំគេនោះទេ។ ស្ដេចនេះ

---

១- សរសេរឲ្យត្រូវគឺ Qin Shi Huangdi ជាមហារាជាធិរាជចិនទី១

២- នាមពិតប្រាកដគឺ ព្រះបាទសម្ដេចព្រះចុឡាចមក្លៅចៅយូហួ

មិនយល់ថា តែកាលណាប្រជាជនល្ងង់ហើយ ប្រទេសនឹងស្ថិតនៅជាខ្ញុំគេនោះ មិនយល់ទេ។ ស្មានតែថា អញស្តេច អញចេះ, ចេះគ្រប់សព្វឬ? បើគ្មានដៃជើងមន្ត្រីសេនាបតីជាអ្នកចេះផង មានតែពួកអបអែបបទូរលើកជើងហេកហាកមុខក្រោយ តើធ្វើឲ្យស្រុកល្អូតលាស់ទៅកើតឬ? ព្រោះហេតុដូច្នេះហើយ, ទើបបានជាសព្វថ្ងៃ ពេលមានអាសន្នកើតឡើង យើងខ្វះអ្នកចេះដឹងសំខាន់ៗ សម្រាប់ធ្វើការ យើងផ្ទុកផ្តាក់កិច្ចការតែទៅលើបុគ្គលមួយចំនួនឲ្យធ្វើការ ហើយបើពួកនោះធ្វើខុសផ្តាច់ការ អាវ៉ាសែក្បត់ជាតិ លក់ជាតិ ក៏តាមតែពួកនោះចាត់ អ្នកឯទៀត គ្មានដឹងគ្មានយល់អ្វីទាំងអស់ ព្រោះមិនដឹង មិនចេះ គ្មានសមត្ថភាពនឹងជួយតាមមើលតម្រែតម្រង់ ចេះកិច្ចការនេះផងសោះ។

ដូចមានពាក្យកាព្យបរមបុរាណតែងពោលនិយាយតៗ គ្នាមកថា ៖

“ស្តេចខ្លៅ នាម៉ឺនខ្លៅ ដូចពស់នាងត្រាវពេនមាត់ជណ្តើរ” ។

“ស្តេចប្រាជ្ញ នាម៉ឺនមហិទ្ធិយក្ស ដូចពស់ពក្លាក់ពេនមាត់ទ្វារ” ។

“ស្តេចប្រាជ្ញ នាម៉ឺនប្រាជ្ញ ដូចពស់នាគរាជពាំកែវមនោរា” ។

នេះហើយ លទ្ធផលនៃការឃាត់ហាមរបស់ពួកស្តេច ពួកល្មោភអំណាចជំនាន់មុនៗ ដែលតែងរកឱកាសជំទាស់រឿយៗ មិនឲ្យសិស្សចេញទៅក្រៅ ខ្លាចទៅជាក្រហម ទៅជាខៀវ។ នែ៎ ! គំនិតនេះគួរឲ្យខ្លាចរអាខ្លាំងណាស់ ព្រោះជាគំនិតដែលនាំឲ្យស្រុករលាយដោយមិនដឹងខ្លួន។

# គួរមានចិត្តសប្បុរស

ខ្ញុំបានសង្កេតឃើញអ្នកមានថ្នាក់សេដ្ឋីគហបតីខ្លះ ហេកហាកជួយជាតិតែបបូរមាត់ក្រៅៈ អើចាំជួយកសាងនេះ ចាំជួយកសាងនោះ, អើចាំឆ្នាំក្រោយសិន ចាំទៅ! ដេកចាំទៅ! ពួកនោះ កាលសម្តេចសីហនុនៅ សីហនុប្រកាសក្តែងៗ ខ្លាចកុម្មុយនីស្តចូលមកប្រមូលទ្រព្យសម្បត្តិទុកជារួមសម្បាច់, ក៏បាននិយាយថាៈ ហ៊ឺះ, ចាំឆ្នាំក្រោយទៅ អញសាងកូនសាលាមួយឲ្យក្មេងរៀន, ចាំដាច់ខែនេះទៅ អញចូលជាសមាជិកសង្គជាតិ, ចាំថ្ងៃស្អែកទៅអញយកអំណោយទៅឲ្យទាហាន (កាលណោះទាហាននៅឧត្តរមានជ័យនិងព្រះវិហារកំពុងក្រខ្សត់អត់ឃ្លានយ៉ាងខ្លាំង រដ្ឋាភិបាលអំពាវនាវឲ្យជនជាតិ រៃអង្គាសម្ហូបកំប៉ុងយកទៅឲ្យទាហានទាំងនោះ)។ ស្អែកជាស្អែក ថ្ងៃណោះជាថ្ងៃណោះ ខែនេះជាខែនោះ ឆ្នាំនេះជាឆ្នាំក្រោយ, មានអីអត់ទេ! អញគ្មានរវល់នឹងសេចក្តីអំពាវនាវស្អីទាំងអស់! នរណាធ្វើអីធ្វើទៅ! ដល់មកសម័យនេះទៀត ប្រជាជនខ្មែរកំពុងលិចលង់ក្នុងវេលកមហន្តរាយវិនាសទ្រព្យសម្បត្តិអស់រលីង គ្រួសារព្រាត់ប្រាស់គ្នា, កូនខ្មែរកំព្រាត្រៀបត្រា, ខ្វះជម្រក, ខ្វះអាហារ ខ្វះឱសថដេកចាំតែស្លាប់គ្រប់ទិសតំបន់... គឺថាជីវភាពប្រជាជនខ្មែរ កំពុងត្រូវចំរាញ់ទឹកភ្នែកស្រែកហៅជំនួយរល្វេងៗ... ក៏ពួកអភិជន ពួកសេដ្ឋីគហបតីទាំងនោះខ្ទប់ភ្នែក បិទត្រចៀក លែងឃើញលែងឮទាំងអស់។ នរណាស្លាប់ នរណាវេទនាអញមិនដឹងទាំងអស់។ រដ្ឋាភិបាលអំពាវនាវ... អំពាវនាវខ្យល់ទៅ! អញអ៊ីអើតែមាត់, ចាំថ្ងៃនេះថ្ងៃណោះ ខែណោះខែណោះ សុំជួយឲ្យនេះឲ្យនោះ។ ដេកចាំទៅ បើរបេះអំបិលមួយគ្រាប់!

នែ៎ អ្នកមានស្រុកខ្មែរវាមានអីចឹង វាមិនមែនដូចពួកសេដ្ឋីគហបតីអ៊ីស្រាអែល គេនៅដល់ទៅសហរដ្ឋអាមេរិកឯណោះ គេចេញលុយចេញកាក់ផ្ញើទៅរដ្ឋាភិបាលគេ ឲ្យរដ្ឋាភិបាលគេមានកម្លាំងធ្វើ

ការតស៊ូជាមួយអាប៉ង។ បើមិនបានអី ក៏អំពើសប្បុរសនោះឯង ជាការលើកទឹកចិត្តទាហានគេ លើកទឹកចិត្តអ្នកដឹកនាំរដ្ឋគេយ៉ាងជាក់ស្ដែងដែរ។ ឯសេដ្ឋីគហបតីស្រុកឯងដេកចាំមើល អ៊ីអើតែមាត់ក្រៅ។

កាលសម្ដេចសីហនុនៅ ពួកអ្នកកំណាញ់ទ្រឹស្ដីស្នូរនោះ និយាយអាងលេសថា សាងស្ពានឬសាលាធ្វើអី បើសម្ដេចឪយកទៅដាក់ឈ្មោះសម្ដេចឪទាំងអស់នោះ? បាត់ឈ្មោះឯងអស់រលីង បានប្រយោជន៍អី? លុះដល់សម័យនេះ ពួកដដែលនេះ និយាយទៀតថា ជួយធ្វើអី បើពួកនេះសុទ្ធតែពួកពុករលួយ, ខ្ជិលរវល់ជួយធ្វើអី។

នែ៎! វាទៅជាអ៊ីចឹង! ពួកទាំងនោះមានលេសរហូត។ តាមពិតបើសាងសាលា, ផ្ទះពេទ្យ, សាងទីជម្រក, បរិច្ចាគប្រាក់កាសស្រូវអង្ករឲ្យប្រជាជនដែលគ្នាមានរបត់រត់លូន មកចម្រុះក្បាលគ្នាដូចជផ្លូវនៅភ្នំពេញក្ដី នៅទីណាក្ដី... ដោយផ្ទាល់ដៃទៅ តើបាត់ឈ្មោះយើងឯណា? អំណោយមនុស្សធម៌យើងមានធ្លាក់ទៅលើដៃពួកដែលយើងថា ពុករលួយនោះឯណា? បើយើងប្រកាន់បក្សពួក យើងប្រកាន់ទៅចុះ នេះមិនមែនប្រជារាស្ត្រខ្មែរនៅកាន់បក្សពួក ដូចយើងម៉ែនោះឯណា? គឺយើងប្រគល់ឲ្យចំ- ពោះមនុស្សអត់ឃ្លានតែប៉ុណ្ណោះ មិនមែនឲ្យមនុស្សដែលយើងស្អប់នោះទេ គឺឲ្យដល់រាស្ត្រខ្មែរដែលជាពូជអំបូរយើងទេតើ។

តាមពិតទៅ គួរយើងអ្នកមានៗ, គហបតីមើមៗ មានមនសិការជាតិ មានសន្ដហធម៌ខ្លះទៅផងក្នុងវេលាដែលស្រុកយើងកំពុងលង់លិចនេះ ព្រោះយើងរាល់គ្នាសុទ្ធតែថាចង់ធ្វើតាមអ៊ីស្រាអែល ហើយសុទ្ធតែថា យើងជាពុទ្ធសាសនិកចេះធ្វើបុណ្យសុន្ទរ៍ទាននោះផង។

## គួរខ្មសប្រាប់គត់ត្រាព្រឹត្តិការណ៍ផ្សេងៗ

តាមធម្មតា ឯកសារ និងព្រឹត្តិការណ៍ទាំងឡាយនៃសាកលលោកនិងប្រទេសជាតិ រមែងមានតំកល់ទុកនៅបណ្ណាល័យជាតិ។ បណ្ណាល័យជាតិជាឃ្លាំងឯកសារដ៏ធំ។ ប៉ុន្តែចំពោះបណ្ណាល័យជាតិយើងវិញ បើមានអ្នកនិពន្ធណា ត្រូវការស្រាវជ្រាវរកឯកសារណាមួយនោះពិបាករកណាស់ ហើយជួនកាលរកពុំបានផង ជាពិសេសថ្ងៃខែនៃព្រឹត្តិការណ៍ជំនាន់មុនៗ រកគ្មានសោះតែម្ដង ពីព្រោះគ្មាននរណានឹងរវល់កត់ត្រាទុកសោះ។

ប្រការមួយទៀត មកពីអ្នកខ្លះទៅពិនិត្យឯកសារឬអានសៀវភៅមុខណាមួយ ឃើញរឿងត្រង់ដែលខ្លួនត្រូវការ ខ្ជិលចម្លង ក៏តាំងលួចហែកត្រង់វគ្គនោះមួយដុំចេញមកជាសម្បត្តិផ្ទាល់តែម្ដង។ គំនិតនេះចង្រៃធំ ព្រោះបានបំបាត់ឯកសារមួយទទេ មិនឲ្យអ្នកដទៃដឹងផង។ សូមអស់លោកដែលមានគំនិតនេះ មេត្តាអាណិតដល់អ្នកក្រោយៗ ដែលគ្នាចង់ដឹងនោះផង។ បើអស់លោកហែកយកតែម្នាក់ឯងទៅគ្នាបានអ្វីមើល? គួរគិតអាណិតចែកចំណេះចេះដឹងដល់គ្នា ទើបស្រុកយើងសម្បូរអ្នកចេះដឹង។

ម្យ៉ាងទៀត ឯកសារនៅស្រុកខ្មែរពិបាករកណាស់ ព្រោះអ្នកកាន់ការរដ្ឋចេះតែកប់បំបាត់ចោល ឬកាឡៃឲ្យទៅជាដូច្នេះដូច្នោះ យកតែល្អក្នុងជំនាន់ខ្លួនទាំងអស់។

ការកប់បំបាត់ចោល ឬក៏កាឡៃប្រវត្តិសាស្ត្រនោះ គេសង្កេតឃើញជាពិសេសពួកស្ដេចនេះតែម្ដង។ ក្នុងរជ្ជកាលមួយៗ របស់ខ្លួន ពុំដែលឃើញមាននិយាយអំពីរឿងអាក្រក់សោះ សុទ្ធតែល្អទាំង

*អស់ ហើយបើមានអាក្រក់ខ្លះនោះ គឺស្ដេចក្រោយជាអ្នកឲ្យគេសរសេរនូវរឿងស្ដេចមុនដែលស្លាប់ទៅហើយ តាមអំពើអាក្រក់ស្ដេចនោះយ៉ាងណាៗ តែបន្តិចប៉ុណ្ណោះៗ រឿងអាក្រក់គ្មានសូវនរណាកត់ត្រាទុកទេនៅក្នុងវាំង ប៉ុន្តែរឿងអាក្រក់ រឿងឃោរឃៅ រឿងអតមង្គលនៅក្នុងវាំង បែរជាត្រូវបានគេរាស្ត្រដែលដឹងនោះ នាំមកនិយាយផ្សព្វផ្សាយទៅវិញ។ យើងដែលដឹងរឿងក្នុងវាំងថា ស្ដេចអាវ៉ាសែ ផ្ដេសផ្ដាសយ៉ាងម៉េចនោះ ក៏ដោយសារតែពាក្យគេនិយាយឥតលាយលក្ខណ៍អក្សរនោះដែរ។*

*ម្យ៉ាងទៀត រំលឹកឡើងវិញ ឆ្នាំ ១៩៦៨ នេះ សម្ដេចសីហនុ ដែលខ្លាចមនោគមវិជ្ជាចិនក្រហមចូលស្រុកខ្មែរ ហើយខ្លាចត្រូវរាស្ត្រក្រហមចាប់ព្យួរកនោះ ក៏ឲ្យក្រសួងសន្តិសុខប្រយ័ត្នប្រយែង ក្នុងរឿងសៀវភៅចិនប៉េកាំងចូលស្រុក។ ក្រសួងនេះក៏ប្រកាសគម្រាមកំហែងរកឈ្មោះណាដែលមានសៀវភៅឬទស្សនាវដ្ដីចិនកុម្មុយនីស្ដយ៉ាងខ្លាំង។ អ្នកខ្លាចគុកច្រវាក់ ហើយដែលធ្លាប់មានសៀវភៅឬទស្សនាវដ្ដីចិនប៉េកាំង ពេលនោះប្រមូលដុតចោលគ្មានសល់ ខ្លះដុតរហូតដល់ទៅសៀវភៅឬទស្សនាវដ្ដីស្សេរីកូរ៉េខាងជើង យួនហាណូយទៅទៀត។*

*ឯកសារជាច្រើនដែលនិយាយពីទ្រឹស្ដីកុម្មុយនីស្ដនោះ ត្រូវរលាយអស់មួយសារក្នុងគ្រានោះ។*

*ឃើញទេ ខ្លាចកុម្មុយនីស្ដ គម្រាមរាស្ត្រឲ្យដុតឯកសាររឿងកុម្មុយនីស្ដចោល។ ដល់ទៅទីងនីងអាមេរិកាំង តាំងរករឿងដូច្នេះដូច្នោះទៀត។ ឯកសារនៅស្រុកខ្មែរជំនាន់សីហនុ ព្រឹលៗ ទាំងអស់និយាយយកតែពីល្អ អួតសរសើរតែតួសីហនុមួយ បន្លិចរឿងពិតឲ្យទៅជារឿងពុំពិតវិញ។ រឿងមានច្រើន រឿងសម្លាប់ខ្មែរក្រហមនៅខេត្តកំពង់ធំយ៉ាងវង្គាល រឿងសម្លាប់ខ្មែរក្រហមនៅសំឡូត, ភ្នំវាយចាប ខេត្តបាត់ដំបង ។ល។ និង ។ល។ តើមាននរណាហ៊ានសរសេរផ្សាយទេ?*

*ពាក្យពិតវែងស្ទេង ! ស្លាប់ ! គ្មាននរណាហ៊ានផ្សាយទេ !*

*ប៉ុន្តែការពិតវានៅតែពិត មានគេអ្នកកត់ត្រានៅតែលបកត់ត្រាបានអីចឹងទៅដែរ។ គឺអាស្រ័យដោយការលបកត់ត្រាដូច្នេះហើយ ទើបប្រវត្តិពិតពីមុន វាអាចផុសឡើងបាននៅពេលនេះ។*

*ហេតុដូច្នេះ ទើបខ្ញុំសូមបងប្អូនយុវជនទាំងអស់មេត្តាឧស្សាហ៍កត់ត្រាទៅផង នូវព្រឹត្តិការណ៍នៅស្រុកយើង ស្រណុកដល់កូនចៅយើងវាសួរ យើងមានចម្លើយច្បាស់លាស់តបទៅវិញ។*

*ម្យ៉ាងទៀតខ្ញុំសូមធ្វើសំណូមពរ ចំពោះអស់មិត្តដែលមានកំណត់ឯកសារផ្សេងៗ នោះ សូមមេត្តាកុំលាក់ទុកសម្ងំដឹងតែឯងធ្វើអ្វី បើមានប្អូនៗ យុវជនអ្នកស្រាវជ្រាវគ្នាចូលមកសួរ សូមឲ្យគ្នាដឹងផង។ យើងចែកគ្នាដឹងផ្សាយដំណឹងបានច្រើនគ្នា ស្រុកយើងសម្បូរអ្នកដឹង យើងមិនវង្វេងវិលវល់ ដូចកាលកន្លងមកហើយនោះសោះឡើយ។*

# សាមគ្គីអង្គរ

*កាលពីឆ្នាំ ១៩៦៤ ខ្ញុំព្រមទាំងគ្រួសារបានទៅលេងចំការនៅច្បារអំពៅ ដែលជាចំការរបស់ឪពុកម្ដាយខ្ញុំយូរអង្វែងហើយ។ ខ្ញុំបានសម្រាកនៅក្រោមដើមស្វាយមួយដើម ភ្នែកខ្ញុំមើលលើទៅមែកស្វាយ ឃើញសំបុកអង្ក្រងនៅចុងមែកមួយនោះ។ ពេលនោះមានខ្យល់ធ្លាក់មក មិនដឹងហេតុអ្វី ស្រាប់តែមានកូនមែកពុកមួយធ្លាក់ប្រឹបមកពីលើមកចំសំបុកអង្ក្រងនោះ ដូចគេយកឈើមកវាយទម្លុះដូច្នោះ...*

ស្រាប់តែក្រហមប្រាកចេញមកតែម្តង អង្ក្រងដ៏ល្អិតៗ នោះស្ទុះចេញពីសំបុកមកក្រៅដូចជាមានអាសន្នធំ រត់ចុះរត់ឡើងប្រសេចប្រសាចពេញស្លឹកឈើជិតៗ នោះមួយរំពេច ដូចជាដណ្តឹងសួរគ្នាប្រញាប់ប្រញាល់ អំពីរឿងហេតុដែលមានអ្វីធ្វើឲ្យរញ្ជួយសំបុកអម្បាញ់មិញៗ មិនតែប៉ុណ្ណោះ ពួកវាមួយចំនួនស្រាប់តែចុះស្រ មកដល់គល់មួយរំពេច គួទ-ងខ្វីត មាត់ហាប្រវាប ដូចជាចាំប្រុងជាស្រេច នឹងប្រហារស្អីណាដែលប៉ះពារដល់វាៗ ខ្ញុំយល់ថា អាពួកចុះមកនេះ ទំនងជាចុះមកសង្កេតការណ៍ខាងផ្ទៃក្រោមៗ អាពួកនេះឡើងទៅវិញ ជួបនឹងគ្នីគ្នានៅពាក់កណ្តាលដើមស្វាយ ក៏តាំងឈប់ជួបគ្នាបន្តិច ទំនងជានិយាយប្រាប់គ្នាថា : ខាងក្រោមគ្មានការណ៍អ្វីទេៗ

ដើម្បីចង់ដឹងចិត្តអង្ក្រងនោះម្តងទៀត ខ្ញុំយកមែកឫស្សីទៅញ៉ុលសំបុកវាបន្តិចទៀត ស្រាប់តែព្រុលឡើងទៀត ក្រហមក្អឹសចេញមកក្រៅ ខ្លះចុះមកគល់ ខ្លះឡើងទៅចុង សុទ្ធតែពីលឿន ព្រោះវាមានអាសន្នត្រូវតែប្រញាប់ កិរិយាវាងើសងើសគគាតអង់អាចដូចៗ គ្នាៗ

ឃើញអង្ក្រងមានសកម្មភាពគគាតអង់អាចព្រមៗ គ្នាដូច្នេះ ខ្ញុំនឹកបែកគំនិតមករកគិតជាតិខ្មែរនៅពេលកើតសង្គ្រាម បើបានប្រហែលដូចសត្វអង្ក្រងនេះ ប្រហែលជាខ្មាំងសត្រូវមិនហ៊ានឈ្លានពានជាតិខ្មែរយើងទេៗ ខ្ញុំបានមកភ្នំពេញវិញ ខ្ញុំនៅនឹករឿងសត្វអង្ក្រងនេះមែនទែនទៅ ក៏រត់រកលោក ញ៉ូង-សឿង ដែលជាមិត្ត ឲ្យលោកជួយតែងកាព្យស្តីអំពីសាមគ្គីអង្ក្រងនេះឡើងៗ

ខ្ញុំសូមបួងសួងសូមឲ្យបរិតជាតិខ្មែរទាំងមូល មានសាមគ្គីរួបរួមគ្នាដូចសត្វអង្ក្រង បេះរួបរួមគ្នាទាំងធំទាំងតូច បេះមូលមាត់គ្នា នាំគ្នាការពារជាតិខ្មែរឲ្យបានរុងរឿងស្ថិតស្ថេរចីរកាលតទៅ កុំបីអាក់ខានឡើយ នឹងសុំឲ្យបានជាជាតិមួយមានកិត្តិនាមក្នុងអាស៊ីអាគ្នេយ៍នេះៗ

# សាមគ្គីអង្ក្រង

អង្ក្រងចងមិត្តជាពួកក្រុម　　រួមផ្តុំសាមគ្គីទីត្រង់ណា
ធ្វើជាសំបុកទុករក្សា　　ពងពេញត្រៀបត្រាភ្ញាស់បំបែក។
កកើតជាកូនពូនជាចៅ　　បានជាញាតិផៅច្រើនអនេក
វាយគ្នាឃាមល្បាតចាត់ចែងចែក　　គ្រប់មែកសារពើឈើលំនៅ។
ប្រុងប្រៀបជើងការទាំងយប់ថ្ងៃ　　ក្រែងខ្មាំងចង្រៃចិត្តឃោរឃៅ
រំលោភរុករានពានចូលទៅ　　ជិះជាន់លំនៅរបស់វា។
កាលណាមែកឈើរង្គើភ្លាម　　វាឥតទីមទាមឥតរួញរា
កែនពលប្រញាប់ឆាប់ស្ទុះស្ទា　　ពុះពារតតាំងប្រឆាំងតប។
បញ្ចេញចង្កូមគួទ ង ស្ទើត　　ភ្នែកស្លោស្លន់ស្ទើតអើតរហប
សន្ទុះទឹកចិត្តឥតញ៉ើមញ៉ប　　ប្រុងប្របប្រយុទ្ធហុតស៊ីសាច់។
អ្នកស្រែចំការណាក៏ដឹង　　កាលខ្លួនខំប្រឹងយ៉ាងប្តូរផ្តាច់
ឡើងបេះអ្វីៗ ជាចាំបាច់　　រិះៗ ប្រកាច់ពីចុងឈើ។
អង្ក្រងព្រួតគ្នាទាំងរយពាន់　　ខាំបោសមិនទាន់ភាន់ងើងើ

អាខ្លះខាំភ្អែកជ្រែកល្វែងលើ    អាខ្លះរុករើខាងល្វែងក្រោម។
ខាំហើយនោមដាក់ចាក់ចូលភ្អែក    កនយើងប្រឹងស្រែកជិតលេចផោម
អែយហ៊ស់-អែយយ៉ូយអង្រ្គងចោម    ព័ទ្ធឡោមជុំជិតរិតខាំខ្លាំង។
បោសច្បូតសម្លាប់អស់ពួកមុន    ពួកក្រោយទ្វេគុណថែមកម្លាំង
រាប់រយពាន់ម៉ឺនចូលតតាំង    ប្រឆាំងខំខាំចាំព្រួតគ្នា។
ណាដែលងាប់មុនក៏ងាប់ទៅ    ណាដែលរស់ទៅឥតរួញរា
សង្គ្រឹតស្រុះស្រួបន្តគ្នា    ប្ដូរផ្ដាច់ពុះពារច្បាំងយកជ័យ។
នេះគឺសាមគ្គីសត្វអង្រ្គង    សាមគ្គីហ្មត់ហ្មងចងមានន័យ
ទុកជាតម្រាប់ច្បាប់ប្រពៃ    មនុស្សលោកគួរល៉ៃគេគិតចុះ។

**ញូង សឿង**

# អវសានកថា

អស់លោកអ្នកអានជាទីគោរព,

តាំងពីទំព័រទី ១ រៀងមកដល់នេះ ខ្ញុំសរសេរ ខ្ញុំពោល គឺកើតឡើងដោយសុទ្ធចិត្តរបស់ខ្ញុំ ដែលខ្ញុំចង់ឲ្យបងប្អូនយើង ជាពិសេសយុវជនយើង មានការភ្ញាក់រឭកកាន់តែខ្លាំងឡើង កាន់ដៃគ្នារឹតយ៉ាងណែនហើយចិត្តឲ្យស្មោះជួយយើតយោងប្រទេសមួយ ដែលយើងរាល់គ្នាកំពុងផ្ញើជីវិតសព្វថ្ងៃ ហើយដែលកំពុងធ្លាក់ទ្រុឌទ្រោមគួរឲ្យអនិច្ចា ឲ្យបានងើបមុខនឹងគេឡើងវិញ ក្នុងសតវត្សរ៍ក្រោយៗ ទៀត។

ចំពោះ ខេមរជនម្ចាស់ទឹកដីកម្ពុជានាអនាគតកាល, ខ្ញុំសូមបន់ស្រន់ សូមកុំឲ្យមានវាសនាអាក្រក់ជូរចត់ ល្អក់ខ្វល់ដូចជាយើងខ្ញុំបានទទួលនាសតវត្សរ៍នេះទៀតឲ្យសោះ។ សូមឲ្យបានសុខចំរើនមានវឌ្ឍនភាព សុកមង្គលជរាបលើគន្លងយុត្តិធម៌ សមភាព សេរីភាព ប្រជាធិបតេយ្យ ដ៏ពិតប្រាកដ !

ចំពោះខ្ញុំ ខ្ញុំសូមប្ដេជ្ញាដោយសច្ចវាចាម្ដងទៀត នៅទំព័រចុងក្រោយនេះថា : «ខ្ញុំសូមស្លាប់ដើម្បីខ្មែរ កើតដើម្បីខ្មែរ និងរស់ដើម្បីខ្មែរ» ។ រៀងរាល់ជាតិ ខ្ញុំសូមឲ្យបានកើតជាខ្មែរ រស់ជាខ្មែរ ស្លាប់ជាខ្មែរ កុំឲ្យឃ្លាតទៅឯណាឆ្ងាយពីទឹកដីកម្ពុជានេះឲ្យសោះ ។

ហើយខ្ញុំជឿជាក់ថា អស់លោកដែលស្នេហាជាតិសម័យបច្ចុប្បន្ន ហើយដែលកំពុងឃើញស្រុកយើងបែកបាក់គ្នា ហួរហែកគ្នាយ៉ាងផង់ផល់សព្វថ្ងៃនេះ មុខជាមានការឈឺចាប់ ហើយមុខជានឹងប្ដេជ្ញាដូចពាក្យរបស់ខ្ញុំខាងលើនេះដែរពុំខាន។

ម្យ៉ាងទៀត ខ្ញុំសូមឧទ្ទិស «ចរិតខ្មែរ» ចំពោះព្រលឹងយុទ្ធជនទាំងអស់ ដែលបានបូជាជីវិតដើម្បីខ្មែរ សាធារណរដ្ឋ តាំងពីនោះមកនេះ។ ខ្ញុំសូមគោរពព្រលឹង និងវិញ្ញាណក្ខន្ធអស់លោកទាំងនោះដោយស្មោះ។

ខ្ញុំសូមទុកស្នាដៃនេះដែលខ្ញុំសន្មតថា ជាកំណាប់អនុស្សាវរីយ៍ក្នុងមួយជីវិតរបស់ខ្ញុំ ដែលបានរស់នៅជាងកន្លះសតវត្សរ៍មកហើយ ហើយបានហក់ហែលរលកព្រឹត្តិការណ៍នយោបាយស្រុកខ្មែរស្ទើរគ្មានចន្លោះនេះ ទុកជាអនុស្សាវរីយ៍ចំពោះអស់លោកអ្នកអានជាមិត្ត និងយុវជនជាប្អូនៗ នៅសម័យនេះ និងសម័យតៗ ទៅទៀតដោយស្មោះអស់ពីដួងចិត្ត។ សូមអស់លោកអ្នកអាននិងយុវជនប្អូនៗ ទាំងអស់ទទួលនូវសេចក្ដីគោរពរាប់អានដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

ថ្ងៃទី ២០ កក្កដា ១៩៧៣

**ប៊ុណ្ណចន្ទ-ម៉ុល**

# មាតិការឿង


| មាតិកា | ទំព័រ |
|---|---|
| អារម្ភកថា | ២ |
| សេចក្តីផ្តើម | ៤ |
| ជំពូក ១ : | ៦ |
| ជំពូក ២ : | ១០ |
| ជំពូក ៣ : | ១៤ |
| ជំពូក ៤ : | ២៣ |
| ជំពូក ៥ : | ២៧ |
| ជំពូក ៦ : | ៣០ |
| ជំពូក ៧ : | ៣៣ |
| ជំពូក ៨ : | ៣៧ |
| ជំពូក ៩ : | ៤១ |
| ជំពូក ១០ : | ៤៦ |
| អនុសាសន៍ | ៥៩ |
| គំនិតមានតែអញ | ៦០ |
| គំនិតលួចយកយោបល់គេ | ៦១ |
| គួរតែពិគ្រោះសាកសួរ | ៦១ |
| គំនិតខ្វាចនយោបាយ | ៦២ |
| គំនិតសង់សឹកសួរពូជ | ៦២ |
| គំនិតផ្ទាញ់ផ្ទាល | ៦៣ |
| គំនិតលោភពង្រេចពង្រឹល. | ៦៤ |
| គំនិតចង្រៃ | ៦៥ |
| ចូរប្រយ័ត្នមនុស្សជំនិត | ៦៦ |
| មេអំពៅ. | ៦៧ |
| ស្វាពាក់ម្កុដ | ៦៩ |
| បើមិនច្បាស់កុំអះអាង | ៧០ |

គួរតែនិយាយតែរឿងមានប្រយោជន៍ . . . . . ៧០
គួរពត់ឈើកាលនៅពីតូច . . . . . . ៧១
គួរស្ងួនគ្រងលក្ខណៈខ្មែរខ្លះផង . . . . . . ៧៣
អំពីរឿងទុកសក់សេះ . . . . . . . ៧៣
គប្បីម៉ឹងម៉ាត់ឲ្យបានយូរអង្វែង . . . . . . ៧៤
ការសន្ទិះសង្ស័យ . . . . . . . . ៧៥
ហេតុអ្វីបានជាយើងចុះឱនថយ? . . . . . . ៧៧
គួរមានចិត្តសប្បុរស . . . . . . . ៧៩
គួរឧស្សាហ៍កត់ត្រាព្រឹត្តិការណ៍ផ្សេងៗ . . . . . ៨០
សាមគ្គីអង្គ្រង . . . . . . . . ៨១
អវសានកថា . . . . . . . . ៨៤

# អំណរគុណ

*អ្នកនិពន្ធសូមថ្លែងអំណរគុណជ្រាលជ្រៅចំពោះ ៖*

- *លោក ឤន់-គិមហួន ប្រធានសភាជាតិ ដែលបានផ្ដល់នូវថ្ងៃខែនៃព្រឹត្តិការណ៍ខ្លះសម័យមុន*
- *អ្នកនិពន្ធ គុយ-ឡុត ដែលបានផ្ដល់ឯកសារសម័យក្រោយមកទៀត ព្រមទាំងបានជួយបាត់បែង «**ចរិតខ្មែរ**» ដរាបមានជារូបរាងនេះ ។*

**ប៊ុណ្ណចន្ទ-ម៉ុល**

*តម្កល់ទុកតាមលេខ ៦៤៩*
*ចុះថ្ងៃទី ៥ កក្កដា ១៩៧៣*

********************

*វាយអក្សរសាឡើងវិញៈ យុន-ពីម៉ូច*
*ជួយពិនិត្យនិងកែសម្រួលៈ មាន់ព្រឹក*
*សហរដ្ឋអាមេរិក ២០០៤*